ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល

ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ

ករណីសិក្សា

វិទ្យាល័យពោធិ៍ចិន្តា ខេត្តបាត់ដំបង

ជ័យលាភីចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩

សមូហភាពដឹកនាំ សមូហភាពសម្រេច បុគ្គលទទួលខុសត្រូវ

សាលាភូមិន្ទរដ្ឋបាល

២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល

ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ

ករណីសិក្សា

វិទ្យាល័យពេជ្រចិន្តា ខេត្តបាត់ដំបង

ជ័យលាភីចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩

សមូហភាពដឹកនាំ សមូហភាពសម្រេច បុគ្គលទទួលខុសត្រូវ

សាលាភូមិន្ទរដ្ឋបាល

២០២០

បុព្វកថា

អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា តាំងពីដំណាក់កាលទី១ រហូតដល់ដំណាក់កាលទី៤នេះ ដែលត្រូវបានកំណត់ក្រោមចក្ខុវិស័យដឹកនាំផ្ទាល់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីកែទម្រង់ជារចនាសម្ព័ន្ធគន្លឹះ ចំនួនបួន ដែលរួមមានកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ដែលកម្មវិធីកែទម្រង់ទាំងបួននេះជាក្បាលម៉ាស៊ីនដឹកនាំកែលម្អអភិបាលកិច្ចសាធារណៈ សំដៅបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានកាន់តែមានប្រសិទ្ធភាព។

ការដាក់ចេញនូវគោលនយោបាយកែទម្រង់ឱ្យចំអាទិភាព គឺជាបេសកកម្មរបស់រាជរដ្ឋាភិបាលតែអ្វីដែលរឹតតែត្រូវផ្តល់ការយកចិត្តទុកដាក់នោះ គឺប្រសិទ្ធភាពជាក់ស្តែងនៃគោលនយោបាយទាំងនោះដែលត្រូវអនុវត្តដោយតួអង្គនីមួយៗ តាមមុខងារនិងភារកិច្ចរៀងៗខ្លួន រាប់ចាប់តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។ ដូចនេះ ការចុះអង្កេតដោយផ្ទាល់ការសិក្សា និងការវាយតម្លៃអំពីការផ្តល់សេវាសាធារណៈនៅក្នុងកម្រិតមូលដ្ឋាន គឺជាកញ្ចក់ឆ្លុះមួយដែលអាចឱ្យរដ្ឋបាលថ្នាក់ជាតិយល់អំពីសភាពការណ៍ពិតធៀបនឹងការដាក់ចេញគោលនយោបាយនៅថ្នាក់ជាតិ។ កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវយន្តការគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដើម្បីជាការសិក្សា ការវាយតម្លៃ និងស្វែងរកនូវធាតុចូលសំខាន់ៗក្នុងការកែលម្អអភិបាលកិច្ច ដែលនៅក្នុងនោះមានការផ្តល់ចំណាត់ថ្នាក់ជាការលើកទឹកចិត្តដល់អង្គភាពដែលមានអភិបាលកិច្ចនិងការផ្តល់សេវាសាធារណៈល្អប្រសើរជាងគេ។

ក្នុងស្មារតីខាងលើនេះ ខ្ញុំពិតជាមានក្តីរំភើបនិងសូមកោតសរសើរដោយស្មោះចំពោះគំនិតរៀបចំឱ្យមានជាឯកសារ ការគ្រប់គ្រងនិងការផ្តល់សេវារបស់វិទ្យាល័យពេជ្រចិន្តា «**សម្ពហភាពដឹកនាំ សម្ពហភាពសម្រេច បុគ្គលទទួលខុសត្រូវ**» នេះ។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងសម្រេចចេញជាសមិទ្ធផលនេះឡើង ក្រោមការដឹកនាំរបស់ឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** ទេសរដ្ឋមន្ត្រីនិងជាប្រធានគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដោយមានការចូលរួមសហការយ៉ាងសស្រាក់សស្រាំពីឯកឧត្តមបណ្ឌិត-សភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងឯកឧត្តម **ថ្ងៃ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រោមឱវាទនៃសាមីក្រសួងនីមួយៗ។

ខ្ញុំរំពឹងថាឯកសារនេះ នឹងក្លាយជាមគ្គទេសក៍អភិបាលកិច្ចសាធារណៈដ៏មានគុណ-ប្រយោជន៍មួយ សម្រាប់អង្គភាពផ្តល់សេវាសាធារណៈផ្សេងទៀត ជាពិសេសអង្គភាពផ្តល់សេវាអប់រំ អាចយកជាការដកស្រង់បទពិសោធន៍ និងជាធាតុចូលនៃការគ្រប់គ្រងអង្គភាព និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ទន្ទឹមនេះ ឯកសារនេះក៏អាចផ្តល់វិភាគទានខាងពុទ្ធិ ដល់ការយល់ដឹង ការរៀនសូត្រ និងការសិក្សាស្រាវជ្រាវរបស់និស្សិត សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ បញ្ញវន្ត និងសាធារណជនជាទូទៅផងដែរ។

ថ្ងៃ ច័ន្ទ ១៤រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២០

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

អារម្ភកថា

ការកសាងជំនឿនិងទំនុកចិត្តពីប្រជាពលរដ្ឋ គឺជាការលំបាកដែលរាជរដ្ឋាភិបាល ត្រូវបន្តយកចិត្តទុកដាក់តាមរយៈការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពជូនប្រជាពលរដ្ឋ។ ផ្តើមចេញពីចំណុចនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបំផុសឡើងវិញនូវយន្តការនៃការលើកទឹកចិត្តមន្ត្រីរាជការ និងអង្គភាពដែលមានស្នាដៃឆ្នើមក្នុងការបង្កើនផលិតភាពការងារក្នុងរដ្ឋបាលសាធារណៈ និងការលើកកម្ពស់គុណភាពសេវាសាធារណៈ ដែលកន្លងមកធ្លាប់ត្រូវបានអនុវត្តនៅអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា។ ផ្អែកលើសំណើរបស់ក្រសួងមុខងារសាធារណៈ ក្នុងនាមគណៈ-កម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំឱ្យមានយន្តការនេះឡើងវិញ ដើម្បីលើកទឹកចិត្តដល់បណ្តាអង្គភាពផ្តល់សេវាសាធារណៈ រាជរដ្ឋាភិបាលបានសម្រេចឱ្យមានការប្រកួតប្រជែងអង្គភាពផ្តល់សេវាសាធារណៈគំរូ តាមរយៈការដាក់ឱ្យអនុវត្តអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

តាមរយៈអនុក្រឹត្យនេះ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំនិងបង្កើតឡើង ដើម្បីពិនិត្យនិងវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងកម្រិតវិទ្យាល័យសម្រាប់វិស័យអប់រំ និងក្នុងកម្រិតមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ សម្រាប់វិស័យសុខាភិបាល ដោយផ្អែកលើសូចនាករលក្ខណៈវិនិច្ឆ័យគោល លក្ខណៈវិនិច្ឆ័យរង និងលក្ខណៈវិនិច្ឆ័យលម្អិត។ ការវាយតម្លៃនេះត្រូវបានអនុវត្តផ្អែកលើគោលការណ៍តម្លាភាព សុចរិតភាព និងភាពជឿទុកចិត្តបាន។ ការវាយតម្លៃក៏បានឆ្លុះបញ្ចាំងអំពីការគ្រប់គ្រងនិងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធ-ភាពនិងនវានុវត្តន៍ ក្នុងក្របខណ្ឌនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ថ្នាក់ដឹកនាំ មន្ត្រីអង្គភាព អាជ្ញាធរមូលដ្ឋាន សហគមន៍ និងអង្គការដៃគូអភិវឌ្ឍនានា ក្នុងគោលដៅកែលម្អ និងពង្រឹង

គុណភាពសេវាសាធារណៈឱ្យកាន់តែល្អប្រសើរសម្រាប់បម្រើប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។

ក្នុងឱកាសនៃពិធីប្រកាសទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានណែនាំឱ្យមានការរៀបចំជាករណីសិក្សា ចងក្រងបទពិសោធន៍នៃការអនុវត្តការងាររបស់បណ្តាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ សម្រាប់ផ្សព្វផ្សាយជូនដល់បណ្តាអង្គភាពផ្តល់សេវាសាធារណៈផ្សេងទៀតក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ដើម្បីដកស្រង់បទពិសោធន៍ និងពង្រីកនវានុវត្តន៍ក្នុងការកែលម្អគុណភាពសេវាសាធារណៈរបស់ខ្លួន។ ក្នុងន័យនេះ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ បានរៀបចំនិងកំណត់យកអង្គភាពជ័យលាភីលេខ១ ផ្តល់សេវាសាធារណៈគំរូក្នុងកម្រិតវិទ្យាល័យសម្រាប់វិស័យអប់រំ និងអង្គភាពជ័យលាភីលេខ១ ផ្តល់សេវាសាធារណៈគំរូក្នុងកម្រិតមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ សម្រាប់វិស័យសុខាភិបាល ទុកជាមេរៀនបទពិសោធន៍សម្រាប់អង្គភាពផ្តល់សេវាសាធារណៈផ្សេងទៀតក្នុងក្របខណ្ឌទូទាំងប្រទេស។

ថ្ងៃ ពុធ ៩ រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០២០

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសនិងជាប្រធាន

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ

កិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន

អារម្ភកថា

នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងរដ្ឋបាលសាធារណៈ ឱ្យកាន់តែ**ខ្លាំង ស្អាតស្អំ និងផ្តោតលើប្រជាជនជាស្នូល**។ ក្នុងន័យនេះ ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ការពង្រឹងរដ្ឋបាលសាធារណៈឱ្យកាន់តែមានតម្លាភាព ភាពឆ្លើយតប និងប្រសិទ្ធភាព និងជំនឿទុកចិត្តបាន។

ឈរលើស្មារតីនេះ ក្រសួងមុខងារសាធារណៈ ដែលមានតួនាទីគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យមុខងារសាធារណៈ និងកែលម្អអភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ បានទទួលការគាំទ្រនិងចូលរួមសហការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ក្នុងការរៀបចំនូវគោលការណ៍ នីតិវិធី និងដំណើរការនៃការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ក៏ដូចជាការចូលរួមគាំទ្រក្នុងការរៀបចំឱ្យមានការចងក្រងករណីសិក្សាសម្រាប់អង្គភាពជ័យលាភីលេខ១ នៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ ករណីសិក្សានេះ នឹងអាចយកទៅប្រើប្រាស់សម្រាប់ធ្វើជាមេរៀនពិសោធន៍ដល់បណ្តាអង្គភាពផ្សេងៗទៀត ដើម្បីពង្រឹងអភិបាលកិច្ចនិងការកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈរបស់ខ្លួនឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព។

ការកែលម្អ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋគឺជាផ្នែកដ៏សំខាន់មួយ ដែលនឹងរួមចំណែកក្នុងការសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ឱ្យទទួលបានជោគជ័យ។ ផ្អែកលើការគាំទ្រ និងការចូលរួមអនុវត្តដ៏សកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ និងតួអង្គពាក់ព័ន្ធទាំងអស់ ខ្ញុំសង្ឃឹមថា អភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈនឹងមានដំណើរការកាន់តែមានប្រសិទ្ធភាពនិងគាំទ្រដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌។

ក្នុងនាមក្រសួងមុខងារសាធារណៈ ខ្ញុំសូមបន្តគាំទ្រ និងផ្តល់កិច្ចសហការជាមួយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាលនិងក្រសួង ស្ថាប័នផ្សេងទៀត ធ្វើការផ្សព្វផ្សាយឯកសារករណីសិក្សានេះឱ្យបានទូលំទូលាយ ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តការប្រកួតប្រជែងក្នុងការផ្តល់សេវាសាធារណៈគំរូ នៅតាមអង្គភាពផ្តល់សេវាសាធារណៈផ្សេងៗទៀត។

ថ្ងៃ អង្គារ ០៩ រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០២០

រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

ព្រុំ សុខា

អារម្ភកថា

រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដោយកំណត់យកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ នៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ ដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អប់រំជាច្រើន ក្នុងគោលបំណងធ្វើឱ្យសេវាអប់រំកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពដើម្បីផលិតបាននូវធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ កម្រិតជំនាញខ្ពស់ និងមានគំនិតច្នៃប្រឌិតខ្ពស់ស្របទៅតាមការរីកចម្រើននៃបច្ចេកវិទ្យាសង្គម សេដ្ឋកិច្ច និងបង្កើនសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ច ក្នុងតំបន់ និងសកល តាមរយៈការផ្តល់សេវាអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងគុណភាព។

ឆ្លើយតបទៅនឹងបរិបទខាងលើ និងដើម្បីផ្លាស់ប្តូរពីសេដ្ឋកិច្ចកសិកម្ម ទៅសេដ្ឋកិច្ចឧស្សាហកម្ម ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យអនុវត្តនូវកម្មវិធីអប់រំមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។ តាមរយៈកម្មវិធីនេះ ក្រសួងបាននឹងកំពុងជំរុញការអនុវត្តឱ្យបានទូលំទូលាយនៅតាមថ្នាក់រៀន និងសាលារៀន ជាពិសេសនៅកម្រិតមធ្យមសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពជំនាញរបស់សិស្សក្នុងការរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្សនៅសតវត្សទី២១។

ក្នុងចំណោមកំណែទម្រង់ទាំងអស់របស់វិស័យអប់រំ ក្រសួងបានកំណត់យកកំណែទម្រង់ជាអាទិភាពសំខាន់ៗចំនួនបីរួមមាន ១)ការដាក់ឱ្យអនុវត្តនូវកម្មវិធីសិក្សាថ្មីនៅតាមសាលារៀន ២)កំណែទម្រង់នៃការបណ្តុះបណ្តាលគ្រូបង្រៀន និងពង្រឹងគុណវឌ្ឍិនៃការបណ្តុះបណ្តាលគ្រូបង្រៀន និង ៣)ការអនុវត្តការគ្រប់គ្រងនៅតាមសាលារៀន ដើម្បីធ្វើឱ្យគុណភាពនៃការផ្តល់សេវាអប់រំនៅសាលារៀន ឱ្យកាន់តែមានប្រសិទ្ធភាព និងភាពឆ្លើបតប។ ការគ្រប់គ្រងតាមសាលារៀនជាយន្តការនៃការបង្កលក្ខណៈឱ្យសាលារៀនសហគមន៍និងអ្នកពាក់ព័ន្ធនានាធ្វើការរួមគ្នាឆ្ពោះទៅសម្រេចបាននូវគុណភាពបង្រៀននិងរៀន និងប្រែក្លាយគ្រឹះស្ថានសិក្សាមានស្វ័យភាពពេញលេញក្នុងការផ្តល់សេវាអប់រំនៅកម្រិតសាលារៀន។

ក្នុងរយៈពេលកន្លងមក ក្រសួងបានអនុវត្តការវាយតម្លៃនាយក នាយិកាសាលារៀនល្អ

គ្រូបង្រៀនល្អចាប់ពីថ្នាក់ទី៤ ដល់ថ្នាក់ទី១២ គ្រូបង្រៀនល្អ ភាសាខ្មែរនិងគណិតវិទ្យាថ្នាក់ទី១ ទី២ និងទី៣ និងសាលារៀនស្អាតដែលជាការប្រឡងប្រណាំងមួយក្នុងគោលបំណងធ្វើឱ្យការដឹកនាំ ការគ្រប់គ្រង ដំណើរការបង្រៀន និងរៀន និងបរិស្ថាននៃការសិក្សានៅតាមសាលារៀនកាន់តែមានការអភិវឌ្ឍ និងគំនិតច្នៃប្រឌិត និងប្រែក្លាយគ្រឹះស្ថានសិក្សាទាំងនោះឱ្យទៅជាអង្គភាពផ្តល់សេវាអប់រំប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់។

តាងនាមឱ្យក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមគាំទ្រ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ដែលបានផ្តួចផ្តើមគំនិតបង្កើតឱ្យមានកម្មវិធីវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលដើម្បីជំរុញ និងលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃដំណើរការរបស់អង្គភាព។ ជាមួយគ្នានេះខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រុមការងារដឹកនាំ និងគ្រប់គ្រងគម្រោងករណីសិក្សាវិទ្យាល័យពេជ្រចិន្តា ដែលជាអង្គភាពផ្តល់សេវាសាធារណៈគំរូលេខ១ ក្នុងវិស័យអប់រំប្រចាំឆ្នាំសិក្សា២០១៨-២០១៩។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា សៀវភៅករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវារបស់វិទ្យាល័យពេជ្រចិន្តាក្នុងការផ្តល់សេវាសាធារណៈគំរូ និងរួមចំណែកចែករំលែកនូវវិធីសាស្ត្រគន្លឹះ យុទ្ធសាស្ត្រល្អៗ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង និងនវានុវត្តន៍ថ្មីៗដល់គ្រឹះស្ថានផ្តល់សេវាសាធារណៈ ពិសេសគ្រឹះស្ថានអប់រំសាធារណៈ ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាក្នុងអង្គភាពរបស់ខ្លួន។

ថ្ងៃចន្ទ ១៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣០ខែ វិច្ឆិកា ឆ្នាំ២០២០

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

សេចក្តីថ្លែងអំណរគុណ

សូមសម្តែងនូវកតញ្ញូតាធម៌ការគោរពដ៏ខ្ពង់ខ្ពស់ និងថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានយកចិត្តទុកដាក់ខ្ពស់គាំទ្រវិស័យអប់រំ ដោយបានចាត់ទុកកាអភិវឌ្ឍធនធានមនុស្សជាកត្តាគន្លឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបានគាំទ្រក្នុងការការរៀបចំអនុវត្តការវាយតម្លៃអង្គភាពផ្តល់សេវាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានផ្តួចផ្តើមគំនិតនិងជួយឧបត្ថម្ភគាំទ្រទាំងហិរញ្ញវត្ថុ និងមន្ត្រីជំនាញចូលរួមរៀបចំចងក្រងករណីសិក្សា។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានគណៈកម្មការជាតិវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ដែលបានដឹកនាំ និងសម្រួលការវាយតម្លៃវិទ្យាល័យជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងគាំទ្រក្នុងការរៀបចំចងក្រងសរសេរករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាអប់រំរបស់វិទ្យាល័យពេជ្រចិន្តាតាំងតែពីដើមរហូតមក។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានគាំទ្រជួយសម្របសម្រួលជ្រើសរើស និងវាយតម្លៃវិទ្យាល័យជាអង្គភាពផ្តល់សេវាសាធារណៈគំរូ និងការរៀបចំសរសេរចងក្រងករណីសិក្សា។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ដែលបានគាំទ្រ អនុញ្ញាត និងសម្របសម្រួលដល់ក្រុមការងារក្នុងរៀបចំចងក្រងតាំងពីចាប់ផ្តើមរហូតដល់សម្រេចបានផ្លែផ្កាគួរជាទីមោទកភាព។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម **យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការនៃក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល ដែលបាន

ផ្តួចផ្តើម និងដឹកនាំការងាររៀបចំការសិក្សាស្រាវជ្រាវក្រុងបទពិសោធន៍ដល់អង្គភាព ដែលទទួលបានជ័យលាភីជាអង្គភាពផ្តល់សេវាសាធារណៈគំរូ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះ ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងថ្នាក់ដឹកនាំមន្ទីរពាក់ព័ន្ធខេត្តបាត់ដំបង អភិបាលនៃគណៈអភិបាលស្រុកភ្នំព្រឹក គណៈកម្មការគ្រប់គ្រងសាលារៀនពេជ្រចិន្តា និងគណៈគ្រប់គ្រងវិទ្យាល័យពេជ្រចិន្តា លោកគ្រូ អ្នកគ្រូ ក្រុមប្រឹក្សាយុវជន សិស្សានុសិស្ស និងសហគមន៍ទាំងអស់ ដែលបានសហការ គាំទ្រ ផ្តល់ព័ត៌មាន និងបទពិសោធន៍ល្អៗដល់ក្រុមការងារក្នុងការចងក្រងករណីសិក្សារហូតទទួលបានជោគជ័យ។

ជាមួយគ្នានេះផងដែរ សូមថ្លែងអំណរគុណដល់ លោកបណ្ឌិត **សំ ចន្ធី** និងក្រុមជំនាញការបច្ចេកទេសនៃកម្មវិធីកំណែទម្រង់វិមជ្ឈការនិងរដ្ឋបាលនៃអង្គការជីអាយហ្សិត (DAR/GIZ) ក្រុមការងារទីប្រឹក្សាអង្គការ GIZ ដែលបានជួយណែនាំបច្ចេកទេសដល់ក្រុមការងាររៀបចំចងក្រងករណីសិក្សា។

មាតិកានុក្រមសង្ខេប

បុព្វកថា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ I

អារម្ភកថា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ III

អារម្ភកថា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ V

អារម្ភកថា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា.................................VII

សេចក្តីថ្លែងអំណរគុណ.. IX

បញ្ជីតារាង XIII

បញ្ជីរូបភាព XIV

បញ្ជីឧបសម្ព័ន្ធ.. XV

ជំពូកទី១. សេចក្តីផ្តើម ១

១.១. លំនាំបញ្ហានៃការសិក្សាចងក្រង.. ១

១.២. គោលបំណងនៃការរៀបចំចងក្រងករណីសិក្សា.................................. ៦

ជំពូកទី២. វិធីសាស្ត្រសិក្សាចងក្រងករណីសិក្សា...................................... ៧

២.១. វិធីសាស្ត្រនៃការសិក្សាចងក្រងករណីសិក្សា ៧

២.២. ដែនកំណត់ និងវិសាលភាពនៃការសិក្សាចងក្រង ៧

២.៣. វិធីសាស្ត្រប្រមូលទិន្នន័យ ៩

២.៤. វិធីសាស្ត្រវិភាគទិន្នន័យ..១២

២.៥. ក្រមសីលធម៌នៃការសម្ភាសន៍ និងការចងក្រងករណីសិក្សា..................១៣

ជំពូកទី៣. ស្ថានភាពទូទៅ ស្នាដៃ និងភាពជោគជ័យរបស់វិទ្យាល័យពេជ្រចិន្តា ... ១៥

៣.១. ស្ថានភាពទូទៅ និងស្នាដៃរបស់វិទ្យាល័យពេជ្រចិន្តា.......................... ១៥

៣.២. បទពិសោធន៍ជោគជ័យរបស់វិទ្យាល័យពេជ្រចិន្តា ២៥

ជំពូកទី៤. សេចក្តីសន្និដ្ឋាន...១៣៥
គន្ថនិទ្ទេស ១៣៩
ឧបសម្ព័ន្ធ... ១៤១

មាតិកានុក្រមតារាង

តារាងទី១÷ ក្រុមគោលដៅដែលបានប្រមូលព័ត៌មាន និងទិន្នន័យ........................ ៨
តារាងទី២÷ លក្ខណវិនិច្ឆ័យគោលទាំងប្រាំបី និងសំណួរគន្លឹះៗ........................ ១១
តារាងទី៣÷ ស្ទង់ដាសាលារៀនមានប្រសិទ្ធភាពវិទ្យាល័យពេជ្រចិន្តាឆ្នាំសិក្សា ២០១៨-២០១៩.. ៥៥
តារាងទី៤÷ ចំណូល (អនុវត្តជាក់ស្តែង) របស់វិទ្យាល័យពេជ្រចិន្តា..................... ៦៧
តារាងទី៥÷ តារាងមុខសញ្ញាចំណាយ (ថវិការដ្ឋ)... ៦៨

បញ្ជីរូបភាព

រូបភាពទី១÷ ការប្រជុំមាតាបិតាសិស្សដើម្បីផ្សព្វផ្សាយព័ត៌មាន ៣០
រូបភាពទី២÷ ក្តារខៀនព័ត៌មាន និងគំនូសសញ្ញាបង្ហាញផ្លូវ ៣០
រូបភាពទី៣÷ ភាពយកចិត្តទុកដាក់ចំពោះអ្នកប្រើប្រាស់សេវា........................... ៣៤
រូបភាពទី៤÷ ឯកសណ្ឋានបុគ្គលិកអប់រំ និងសិស្ស...................................... ៣៥
រូបភាពទី៥÷ រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងវិទ្យាល័យពេជ្រចិន្តា ៧៩
រូបភាពទី៦÷ គុណវុឌ្ឍិបុគ្គលិកអប់រំ.. ៩១
រូបភាពទី៧÷ គំនូសតាងរចនាសម្ព័ន្ធការអនុវត្តការងារកែលម្អបរិស្ថានវិទ្យាល័យ
ពេជ្រចិន្តា.. ៩៩
រូបភាពទី៨÷ បដា និងពាក្យស្លោកអប់រំស្ដីពីបរិស្ថាន.................................. ១០០
រូបភាពទី៩÷ ទិដ្ឋភាពបរិស្ថានរបស់វិទ្យាល័យពេជ្រចិន្តា............................... ១០១
រូបភាពទី១០÷ ការធ្វើពលកម្ម និងវេនសម្អាតរបស់សិស្ស.............................. ១០៥
រូបភាពទី១១÷ ការត្រួតពិនិត្យថ្នាក់រៀនរបស់ក្រុមប្រឹក្សាយុវជន និងកុមារ........... ១០៦
រូបភាពទី១២÷ រូបភាពបន្ទប់ទឹក ឡដុតសំរាម និងអាងស្តុកទឹក ១០៩
រូបភាពទី១៣÷ ការរៀបចំបង្កើតកីឡដ្ឋាន បង់សម្រាប់អង្គុយ និងសួនជីវៈចម្រុះ... ១១០
រូបភាពទី១៤÷ អាហារដ្ឋាន ១១២
រូបភាពទី១៥÷ ការត្រួតពិនិត្យចំណីអាហារ និងម៉ាស៊ីនចម្រោះទឹក.................. ១១៣

បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១៖ ស្តង់ដារសេវាសាធារណៈ ១៤៣
បទបញ្ជាផ្ទៃក្នុងសាលារៀន ១៤៣
ប្លង់អគារ ១៤៧
ឧបសម្ព័ន្ធ ២៖ និយាមនៃការផ្ដល់ការអប់រំវិទ្យាល័យពេជ្រចិន្តា ១៤៩
សៀវភៅការងារ គណៈកម្មការគ្រប់គ្រងវិទ្យាល័យពេជ្រចិន្តា ឆ្នាំសិក្សា ២០១៩-២០២០ .... ១៤៩
ជីវប្រវត្តិសង្ខេប និងស្នាដៃសំខាន់ៗ ១៦៥
ស្តង់ដាទាំង៩ .... ១៨៧
ឧបសម្ព័ន្ធ ៣៖ និយាមនៃការផ្ដល់ការអប់រំវិទ្យាល័យពេជ្រចិន្តា ១៩៣
របាយការណ៍ចំណូលចំណាយរបស់វិទ្យាល័យពេជ្រចិន្តា ១៩៣
ឧបសម្ព័ន្ធ ៤៖ ការគ្រប់គ្រងធនធានមនុស្សក្នុងអង្គភាព ២០៣
គណៈកម្មការគ្រប់គ្រងសាលារៀន ២០៣
គណៈគ្រប់គ្រងសាលារៀន ២០៤
គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការវិទ្យាល័យពេជ្រចិន្តា ២០៦
ក្រុមការងារសង្គ្រោះបឋម វិទ្យាល័យពេជ្រចិន្តា ២០៧
ក្រុមការងារបរិស្ថាន វិទ្យាល័យពេជ្រចិន្តា ២០៨
ក្រុមប្រឹក្សាយុវជន វិទ្យាល័យពេជ្រចិន្តា ២០៩
ឧបសម្ព័ន្ធ ៥៖ ការកែលម្អបរិស្ថានអង្គភាព ២១៩
លិខិតបង្គាប់ការស្តីពីការបែងចែកតួនាទី ភារកិច្ចក្រុមប្រឹក្សាយុវជន និងកុមារ... ២១៩
កាលវិភាគសម្អាតបន្ទប់ទឹក ២២០
កិច្ចសន្យាជួលតូប ២២១

ផែនការសកម្មភាពរបស់ក្រុមប្រឹក្សាយុវជន និងកុមារ ២២២
លិខិតបង្គាប់ការស្តីពីការបែងចែកតួនាទី ភារកិច្ចក្រុមកែលម្អបរិស្ថាន និងអនាម័យ... ២២៣
កាលវិភាគត្រួតពិនិត្យអនាម័យរបស់ក្រុមប្រឹក្សាយុវជន និងកុមារ.............. ២២៤
លិខិតស្នើសុំការត្រួតពិនិត្យចំណីអាហារ ២២៥
ឧបសម្ព័ន្ធ ៦៖ គំនិតនវានុវត្តន៍... ២២៧

ជំពូកទី១. សេចក្តីផ្តើម

១.១. លំនាំបញ្ហានៃការសិក្សាចងក្រង

សេវាសាធារណៈ គឺជាសេវាដែលរដ្ឋផ្តល់ជូនប្រជាជនតាមរយៈអង្គភាពសាធារណៈ និងគ្រឹះស្ថានសាធារណៈ សំដៅបម្រើផលប្រយោជន៍ដល់ប្រជាជនទូទៅ គ្រប់ស្រទាប់វណ្ណៈ ដោយពុំមានការរើសអើង។ ដើម្បីឱ្យដំណើរការនៃការផ្តល់សេវាសាធារណៈបានល្អ លុះត្រាតែសមាសភាពបីមានភាពស៊ីសង្វាក់គ្នា ឬមានទំនាក់ទំនងល្អនឹងគ្នា ហើយសមាសភាពទាំងនោះរួមមាន អ្នកប្រើប្រាស់សេវា អ្នកផ្តល់សេវា និងអ្នកតាក់តែងគោលនយោបាយ។ រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈយ៉ាងមោះមុតក្នុងការជំរុញការអនុវត្ត ការងារកំណែទម្រង់គ្រប់ផ្នែក គ្រប់វិស័យ ឱ្យកាន់តែមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅក្នុងគោលបំណងធ្វើឱ្យប្រទេសកម្ពុជាមានសុខដុមនីយកម្ម និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិ និងប្រជាពលរដ្ឋ។ ផ្អែកលើស្មារតីនេះ ការលើកកម្ពស់អភិបាលកិច្ចល្អក្នុងរដ្ឋបាលសាធារណៈ គឺជាកម្លាំងចលករដ៏ចាំបាច់ដែលរាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ត្រូវយកចិត្តទុកដាក់ជាអាទិភាពបំផុត។ អភិបាលកិច្ចល្អត្រូវបានរាជរដ្ឋាភិបាលកំណត់ថាជាចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណ ក្នុងការជំរុញការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់តាមវិស័យផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។

ការកសាងជំនឿ និងទំនុកចិត្តពីប្រជាពលរដ្ឋ គឺជាចំណុចអាទិភាព ដែលរាជរដ្ឋាភិបាលត្រូវបន្តយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រ តាមរយៈការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពជូនប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង។ ផ្តើមចេញពីស្មារតីនេះ ការពង្រឹងស្ថាប័នផ្តល់សេវាសាធារណៈ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង ជាកាតាលីករដ៏មានសារៈសំខាន់ និងអាទិភាពបំផុតក្នុងការកែលម្អការផ្តល់សេវា

ជំពូកទី១

សាធារណៈនៅក្នុងស្ថាប័នសាធារណៈ។

ពាក់ព័ន្ធនឹងការកែលម្អការផ្ដល់សេវាសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំមួយចំនួនដូចជា គោលនយោបាយស្ដីពីការផ្ដល់សេវាសាធារណៈ ព្រះរាជក្រឹត្យស្ដីពីគោលការណ៍រួមនៃការបង្កើត និងការដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការវាយតម្លៃសេវាសាធារណៈ និងឯកសារណែនាំស្ដីពីស្ដង់ដាសេវាសាធារណៈ អនុក្រឹត្យស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការផ្ដល់សេវាអប់រំជូនសិស្សានុសិស្ស ប្រជាពលរដ្ឋ និងសហគមន៍ បានកំណត់យកគោលនយោបាយពីរគឺ១) ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ដើម្បីសម្រេចបាននូវគោលនយោបាយអប់រំខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ជាបន្តបន្ទាប់ ក្នុងគោលបំណងធ្វើឱ្យការផ្ដល់សេវាអប់រំកាន់តែមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។ ការគ្រប់គ្រងនៅតាមសាលារៀន គឺជាកំណែទម្រង់ថ្មីមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើឱ្យគុណភាពនៃការផ្ដល់សេវាអប់រំនៅសាលារៀនឱ្យកាន់តែមានភាពឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកទទួលសេវាអប់រំ (សិស្ស ប្រជាពលរដ្ឋ និងសហគមន៍) ប្រកបដោយគណនេយ្យភាពនិងការទទួលខុសត្រូវខ្ពស់ តាមរយៈការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅក្នុងសហគមន៍ ក្នុងការចូលរួមកែលម្អនិងអភិវឌ្ឍន៍សាលារៀនសម្រាប់ផ្ដល់សេវា ជាពិសេសគឺសេវាបង្រៀននិងរៀនប្រកបដោយគុណភាព។

ដើម្បីលើកទឹកចិត្តដល់អង្គភាព ដែលបានខិតខំប្រឹងប្រែងកែលម្អសេវារបស់ខ្លួន

ឱ្យកាន់តែមានគុណភាព និងឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋ និងសហគមន៍ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុង វិស័យអប់រំ និងវិស័យសុខាភិបាល និងលិខិតបទដ្ឋានគតិយុត្តគាំទ្រជាច្រើនទៀត។ អនុក្រឹត្យ នេះមានគោលបំណងជំរុញនិងលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃដំណើរការរបស់ អង្គភាពផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ និងសុខាភិបាលឱ្យកាន់តែប្រសើរឡើង តាមរយៈការកំណត់ឱ្យមានការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈ គំរូ។ អនុក្រឹត្យនេះត្រូវបានដាក់ឱ្យអនុវត្តប្រមាណជាមួយឆ្នាំកន្លងមកហើយ។ ក្នុងការដាក់ឱ្យ អនុវត្តនៅឆ្នាំដំបូងនេះ ក្រសួងមុខងារសាធារណៈ ដោយមានកិច្ចសហការជាមួយក្រសួង អប់រំ យុវជន និងកីឡា បានសម្រេចជ្រើសរើសយកវិទ្យាល័យ ជាបេក្ខភាពអង្គភាពផ្តល់ សេវាសាធារណៈក្នុងវិស័យអប់រំ សម្រាប់ការចូលរួមប្រកួតប្រជែងជាអង្គភាពផ្តល់សេវា សាធារណៈគំរូ (អ.ផ.ស.)។ ជាក់ស្តែងនៅឆ្នាំ២០២០ ក្រសួងមុខងារសាធារណៈបានពង្រីក និងផ្តល់ឱកាសដល់អនុវិទ្យាល័យ និងសាលាបឋមសិក្សាដើម្បីចូលរួមក្នុងការប្រកួតប្រជែង ជាបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ។ ដោយឡែកចំពោះសាលា មត្តេយ្យសិក្សានឹងត្រូវបានជ្រើសរើសជាបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈគំរូ ដើម្បី ចូលរួមក្នុងការប្រកួតប្រជែងនៅតាមវេនបន្តបន្ទាប់។

តាមរយៈស្មារតីអនុក្រឹត្យ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ ជាតិ រាជធានី ខេត្ត ក្រុង ខណ្ឌ ស្រុក ត្រូវបានបង្កើតឡើង។ មុនការផ្លាស់ប្តូររដ្ឋមន្ត្រីក្រសួង មុខងារសាធារណៈក្នុងខែមីនា ឆ្នាំ២០២០ គណៈកម្មការវាយតម្លៃអង្គភាពថ្នាក់ជាតិដឹកនាំ ដោយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងមានសមាសភាពគណៈកម្មការតំណាងអន្តរក្រសួង និងតំណាងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត។ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវា សាធារណៈថ្នាក់រាជធានី ខេត្ត មានអភិបាលនៃគណៈអភិបាលរាជធានីខេត្តជាប្រធាន និងមាន សមាសភាពគណៈកម្មការមកពីមន្ទីរពាក់ព័ន្ធនានានៅក្នុងរាជធានី ខេត្ត។ រីឯគណៈកម្មការ

វាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ក្រុង ស្រុក ខណ្ឌ មានអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាប្រធាន និងមានសមាសភាពគណៈកម្មការមកពីតំណាងការិយាល័យ និងផ្នែកជំនាញពាក់ព័ន្ធនៅក្នុងក្រុង ស្រុក ខណ្ឌ។

ជាក់ស្តែង ដោយផ្អែកលើនីតិវិធី គោលការណ៍ លក្ខណវិនិច្ឆ័យ និងគោលការណ៍ដែលបានកំណត់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈនៅតាមកម្រិតថ្នាក់នីមួយៗ បានខិតខំបំពេញការងារ និងភារកិច្ចរបស់ខ្លួនបានយ៉ាងល្អ ប្រកបដោយមនសិការវិជ្ជាជីវៈ និងសុចរិតភាពក្នុងដំណើរការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ ជាលទ្ធផល គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ បានសម្រេចជ្រើសរើសអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំចំនួន១០ និងវិស័យសុខាភិបាលចំនួន៣០ ដើម្បីផ្តល់ពានរង្វាន់ វិញ្ញាបនបត្រ និងថវិកាអមពានរង្វាន់លើកទឹកចិត្ត។ ក្នុងចំណោមវិទ្យាល័យទាំង១០ ដែលបានជ្រើសរើសជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ វិទ្យាល័យពេជ្រចិន្តាទទួលបានជ័យលាភីចំណាត់ថ្នាក់លេខ១ ចំណាត់ថ្នាក់លេខ២ វិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ ចំណាត់ថ្នាក់លេខ៣ វិទ្យាល័យ ហ៊ុន សែន ប្រសូតិ ចំណាត់ថ្នាក់លេខ៤ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសពួក ចំណាត់ថ្នាក់លេខ៥ វិទ្យាល័យសម្តេច ជា ស៊ីម អង្គរជ័យ ចំណាត់ថ្នាក់លេខ៦ វិទ្យាល័យកោះស្តេច ចំណាត់ថ្នាក់លេខ៧ វិទ្យាល័យ ហ៊ុន សែន ប្រាសាទបាគង ចំណាត់ថ្នាក់លេខ៨ វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសកំពង់ឈើទាល ចំណាត់ថ្នាក់លេខ៩ វិទ្យាល័យ ហ៊ុន សែន ប៊ុនរ៉ានី វត្តភ្នំ និងចំណាត់ថ្នាក់លេខ១០ វិទ្យាល័យអង្គរកា។

ជាការតបស្នងដល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលទាំង៤០ ដែលបានខិតខំបំពេញការងារក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋបានល្អនាពេលកន្លងមក ដើម្បីឆ្លើយតបទៅនឹងសមិទ្ធផលទាំងនេះ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានប្រារព្ធពិធីប្រកាសទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ក្រោមអធិបតីភាព ឯកឧត្តម

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ នៅក្នុងពិធីប្រកាសទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានផ្តល់អនុសាសន៍ប្រាំបីចំណុច ដែលក្នុងនោះអនុសាសន៍ទីមួយ និងដំបូងបំផុត គឺស្នើឱ្យមានការរៀបចំចងក្រងបទពិសោធន៍ នៃការអនុវត្តការងាររបស់បណ្តាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូដើម្បីធ្វើជាករណីសិក្សា និងបន្តផ្សព្វផ្សាយជូនអង្គភាពវិទ្យាល័យ និងមន្ទីរពេទ្យបង្អែកផ្សេងទៀតនៅទូទាំងប្រទេសសម្រាប់ជាការដកស្រង់បទពិសោធន៍ និងពង្រីកនវានុវត្តន៍សម្រាប់ការកែលម្អគុណភាពសេវាសាធារណៈរបស់ខ្លួនជូនប្រជាពលរដ្ឋ។ លើសពីនេះការចែករំលែកបទពិសោធន៍នៃភាពជោគជ័យ រវាងអង្គភាពដែលទទួលបានស្នាដៃឆ្នើម និងអង្គភាពផ្សេងៗទៀតជាកត្តាចាំបាច់បំផុត ក្នុងការបន្តកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈ ពង្រឹងភាពជាអ្នកដឹកនាំ និងការច្នៃប្រឌិតដែលអាចនឹងជំរុញឱ្យអង្គភាពបោះជំហានទៅមុខប្រកបដោយភាពជឿទុកចិត្ត។

ផ្អែកតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** កត្តាចាំបាច់បំផុតក្នុងការផ្តល់សេវាសាធារណៈគំរូបានល្អ អង្គភាពផ្តល់សេវាទាំងអស់ត្រូវសិក្សារៀនសូត្រពីគ្នាទៅវិញទៅមកក្នុងការលើកកម្ពស់ ក៏ដូចជាកែលម្អគុណភាពនៃការផ្តល់សេវានៅតាមអង្គភាព។ ក្រសួងមុខងារសាធារណៈ ដែលមានសាលាភូមិន្ទរដ្ឋបាល ជាសេនាធិការ បានរៀបចំក្រុមការងារសម្រាប់រៀបចំចងក្រងនូវបទពិសោធន៍ និងមេរៀនល្អៗពីអង្គភាពផ្តល់សេវាសាធារណៈគំរូ ដែលទទួលបានជ័យលាភីលេខ១ នាពេលកន្លងមកទាំងក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

នៅក្នុងវិស័យអប់រំវិទ្យាល័យពេជ្រចិន្តា ជាវិទ្យាល័យជ័យលាភី នៃអង្គភាពផ្តល់សេវាសាធារណៈគំរូ ត្រូវបានជ្រើសរើសជាអង្គភាពគោលដៅសម្រាប់ការចងក្រងករណីសិក្សាស្រាវជ្រាវស្តីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈគំរូ។

ជំពូកទី១

១.២. គោលបំណងនៃការរៀបចំចងក្រងករណីសិក្សា

១. ប្រមូលចងក្រងនូវមេរៀន និងបទពិសោធន៍អនុវត្តល្អៗជាក់ស្តែងពីអង្គភាពផ្តល់សេវាសាធារណៈគំរូ ដែលទទួលបានជ័យលាភីលេខ១ក្នុងវិស័យអប់រំ (ផ្តោតលើភាពជាអ្នកដឹកនាំគ្រប់គ្រង យុទ្ធសាស្រ្ត យន្តការ និងនីតិវិធីនៃការដោះស្រាយបញ្ហាប្រឈម យន្តការ និងនីតិវិធីក្នុងការកសាងអង្គភាពឱ្យទទួលបានជ័យលាភី)

២. ចែករំលែកបទពិសោធន៍ជោគជ័យ ដល់អង្គភាពផ្តល់សេវាសាធារណៈដទៃទៀត ជាពិសេសគ្រឹះស្ថានផ្តល់សេវាអប់រំសាធារណៈ ក្នុងការរៀបចំកែលម្អការផ្តល់សេវាសាធារណៈរបស់ខ្លួនឱ្យកាន់តែមានគុណភាព និងភាពឆ្លើយតបទៅនឹងតម្រូវការ

៣. សិក្សាស្វែងយល់អំពីការចូលរួមចំណែករបស់អ្នកពាក់ព័ន្ធរួមមាន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការលើកកម្ពស់ និងគាំទ្រដល់អង្គភាពផ្តល់សេវាសាធារណៈគំរូតាមរយៈការពិនិត្យមើលសកម្មភាពគាំទ្រការអនុវត្តគោលនយោបាយបទដ្ឋានគតិយុត្ត និងធនធាននានានៅក្នុងអង្គភាពផ្តល់សេវាសាធារណៈគំរូថ្នាក់ក្រោមជាតិ។

ជំពូកទី២. វិធីសាស្ត្រសិក្សាចងក្រងករណីសិក្សា

២.១. វិធីសាស្ត្រនៃការសិក្សាចងក្រងករណីសិក្សា

ការសិក្សាតាមបែបគុណភាព ត្រូវបានយកមកប្រើនៅក្នុងការសិក្សានេះ ដើម្បីប្រមូលចងក្រងបទពិសោធន៍ និងការអនុវត្តល្អៗជាក់ស្តែងរបស់វិទ្យាល័យពេជ្រចិន្តា ដែលជាអង្គភាពផ្តល់សេវាសាធារណៈ គំរូក្នុងវិស័យអប់រំ សម្រាប់ចែករំលែកចំណេះដឹង និងបម្រើផលប្រយោជន៍ដល់ការរៀនសូត្ររបស់អង្គភាពផ្តល់សេវាសាធារណៈដទៃទៀត។ ករណីសិក្សា គឺជាប្រភេទសិក្សាស្រាវជ្រាវបែបគុណភាពដែលអ្នកស្រាវជ្រាវធ្វើការវិភាគស៊ីជម្រៅទៅលើករណីនីមួយៗដែលអាចជាកម្មវិធី ព្រឹត្តិការណ៍ សកម្មភាព ឬដំណើរការ ឬពីបុគ្គលណាម្នាក់ ឬច្រើននាក់។ វិធីសាស្ត្រនេះបានជួយដល់ការសិក្សាស្វែងយល់អំពីការអនុវត្តនៃការដឹកនាំនិងការគ្រប់គ្រង និងការសម្របសម្រួលរបស់វិទ្យាល័យពេជ្រចិន្តាលើការផ្តល់សេវាអប់រំសាធារណៈដល់សិស្ស មាតាបិតា អ្នកអាណាព្យាបាលសិស្ស និងសហគមន៍។ ករណីសិក្សានេះចងក្រងនូវយុទ្ធសាស្ត្រ និងនីតិវិធីប្រតិបត្តិល្អរបស់វិទ្យាល័យរហូតទទួលបានជ័យលាភីលេខ១ ជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំកម្រិតវិទ្យាល័យនៅទូទាំងប្រទេសកម្ពុជា។

២.២. ដែនកំណត់ និងវិសាលភាពនៃការសិក្សាចងក្រង

ការចងក្រងករណីសិក្សានេះនឹងផ្តោតទៅលើតែអង្គភាពផ្តល់សេវាសាធារណៈ (អ.ផ.ស.) ទទួលបានជ័យលាភីលេខ១ ក្នុងវិស័យអប់រំដែលទទួលស្គាល់ដោយអនុក្រឹត្យលេខ១១០ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩។ ការស្រាវជ្រាវរៀបចំចងក្រងករណីសិក្សានេះនឹងផ្តោតទៅលើលក្ខណវិនិច្ឆ័យនៅក្នុងអនុក្រឹត្យលេខ៥៤[9] និងឧបសម្ព័ន្ធ

[9] អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

នៃសេចក្តីសម្រេចលេខ៣១៣៦[២]។

សម្រាប់ឯកសារពាក់ព័ន្ធនិងការវិវត្តនៃវិទ្យាល័យពេជ្រចិន្តា ដែលក្រុមសិក្សាយកមកសិក្សា និងចងក្រងជាករណីសិក្សានឹងផ្តោតតែទៅលើការវិវត្តនៃសាលារៀនក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយប៉ុណ្ណោះគឺ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩។

ក្រុមការងារបានសម្រេចជ្រើសរើសយកវិទ្យាល័យពេជ្រចិន្តា ស្ថិតក្នុងខេត្តបាត់ដំបង សម្រាប់ការចុះប្រមូលទិន្នន័យ និងព័ត៌មានពីគ្រប់ភាគីពាក់ព័ន្ធដែលធ្វើឱ្យវិទ្យាល័យពេជ្រចិន្តាទទួលបានជ័យលាភីលេខ១ ក្នុងវិស័យអប់រំក្នុងឆ្នាំ២០១៩។ ក្រុមការងារចងក្រងករណីសិក្សាបានជ្រើសរើសកំណត់ក្រុមគោលដៅសំខាន់សម្រាប់ការចុះប្រមូលទិន្នន័យ និងព័ត៌មានចម្បងពីភាគីពាក់ព័ន្ធគោល ដែលរួមមានអ្នកផ្តល់សេវាសាធារណៈផ្ទាល់នៅក្នុងអង្គភាពផ្តល់សេវាសាធារណៈ និងអ្នកទទួលសេវាផ្សេងៗដូចមានសង្ខេបក្នុងតារាងខាងក្រោម។

តារាងទី១÷ ក្រុមគោលដៅដែលបានប្រមូលព័ត៌មាន និងទិន្នន័យ

ថ្នាក់ដឹកនាំខេត្តបាត់ដំបង (អភិបាលរងខេត្ត ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ប្រធានមន្ទីរបរិស្ថាន អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត)	០៥នាក់ (ស្រី០០នាក់)
រដ្ឋបាលថ្នាក់ស្រុក-ក្រុង (អភិបាល ឬអភិបាលរងទទួលបន្ទុក)	០២នាក់ (ស្ត្រី០១នាក់)
គណៈកម្មការគ្រប់គ្រងសាលារៀន (គណៈកម្មការទ្រទ្រង់សាលា)	១៤នាក់ (ស្ត្រី០៤នាក់)
គណៈគ្រប់គ្រងសាលារៀន (នាយក ឬនាយករង)	០៣នាក់ (ស្រី០នាក់)
ក្រុមបច្ចេកទេសគ្រប់មុខវិជ្ជា និងកម្រិតថ្នាក់	០៣នាក់ (ស្រី០១នាក់)
បុគ្គលិកបង្រៀន និងមិនបង្រៀន (គ្រូបង្រៀន និងបុគ្គលិករដ្ឋបាលសាលា)	១៥នាក់ (ស្ត្រី០៥នាក់)
សិស្សានុសិស្ស និងតំណាងក្រុមនានារបស់សិស្សានុសិស្សនៅក្នុងសាលា	១០នាក់ (ស្ត្រី០៥នាក់)
មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស	០៨នាក់ (ស្ត្រី០៣នាក់)
សហគមន៍ និងអ្នកពាក់ព័ន្ធនានា អាជ្ញាធរដែនដី និងអង្គការក្រៅរដ្ឋាភិបាលនៅមូលដ្ឋាន អាជីវករ អ្នកជំនួញ សហគមន៍...)	០៥នាក់ (ស្ត្រី០១នាក់)

[២] សេចក្តីសម្រេចលេខ ៣១៣៦ មស.សសរ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តតារាងលក្ខណនិច្ឆ័យសម្រាប់ការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

២.៣. វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវចងក្រងករណីសិក្សាវិទ្យាល័យពេជ្រចិន្តានេះ ទិន្នន័យពីរប្រភេទត្រូវបានប្រើប្រាស់សម្រាប់ចងក្រងករណីសិក្សារួមមាន÷ ទិន្នន័យដើម (Primary Data) និងទិន្នន័យមានស្រាប់ (Secondary Data)។

១. ការសិក្សា ពិនិត្យ និងវិភាគលើឯកសារដែលមានស្រាប់របស់វិទ្យាល័យពេជ្រចិន្តា (ទិន្នន័យមានស្រាប់)

- លិខិតបទដ្ឋានគតិយុត្ត ឯកសារគោលនយោបាយ និងរបាយការណ៍ផ្សេងៗនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល និងដែលពាក់ព័ន្ធនឹងដំណើរការវិវត្តក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈឱ្យបានកាន់តែល្អប្រសើរ តាមរយៈអង្គភាពផ្តល់សេវាសាធារណៈជាពិសេសក្នុងវិស័យអប់រំ។
- ច្បាប់អប់រំ ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ និងឆ្នាំ២០១៩-២០២៣ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាឆ្នាំ២០១៨-២០២៣ ឯកសារណែនាំស្តីពីការគ្រប់គ្រងនៅតាមសាលារៀន គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ។

២. សម្រាប់ការប្រមូលទិន្នន័យដើម ក្រុមការងារបានធ្វើឡើងតាមរយៈ÷

ក. ការសម្ភាសន៍÷ ក្រុមការងារបានធ្វើបទសម្ភាសន៍ផ្ទាល់ជាមួយ ១.ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន ២.គណៈគ្រប់គ្រងសាលារៀន (នាយក នាយករង) ៣.ប្រធានក្រុមបច្ចេកទេស ៤.គ្រូបង្រៀន និង៥.ប្រធានក្រុមប្រឹក្សាយុវជន។ ការធ្វើសម្ភាសន៍ស៊ីជម្រៅជាមួយជនបង្គោលសំខាន់ទាំងនេះ មានចំនួន១២នាក់ (ស្ត្រី ០៤នាក់) និងមានរយៈពេលយ៉ាងច្រើនពី ៤៥-៥០នាទី សម្រាប់បុគ្គលម្នាក់ៗ។

ខ. ការពិភាក្សាជាក្រុម÷ ក្រុមការងារបានធ្វើការពិភាក្សាជាក្រុមជាមួយ ១. អភិបាលរង

ខេត្តបាត់ដំបងទទួលបន្ទុកវិស័យអប់រំ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង ប្រធានការិយាល័យមធ្យមសិក្សា នាយកវិទ្យាល័យនេតយ៉ង់ (អតីតនាយករងវិទ្យាល័យពេជ្រចិន្តា) ប្រធានមន្ទីរបរិស្ថានខេត្តបាត់ដំបង និងអនុប្រធានមន្ទីរមុខងារសាធារណៈខេត្តបាត់ដំបង ២.គណៈកម្មការគ្រប់គ្រងសាលារៀន (ក្រុមប្រឹក្សាភិបាល) ៣.គណៈគ្រប់គ្រងសាលារៀនពេជ្រចិន្តា ៤.ក្រុមបច្ចេកទេសមុខវិជ្ជា ៥.ក្រុមគ្រូបង្រៀន ៦.តំណាងសិស្សានុសិស្ស និង ៧.មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស។ ក្រុមការងារធ្វើការពិភាក្សាក្រុមជាមួយអ្នកពាក់ព័ន្ធតាមស្ថានភាពជាក់ស្តែងទៅតាមក្រុមនីមួយៗ និងតាមការណាត់អញ្ជើញចូលរួមប្រជុំជាមុននៅតាមពេលវេលា និងទីកន្លែងដែលបានព្រមព្រៀងគ្នា។ សមាជិកក្រុមពិភាក្សានីមួយៗ មានសមាជិកពិភាក្សាចំនួនមិនលើសពី១០នាក់ ដោយមានលាយសមាសភាពយេនឌ័រស្មើគ្នា (ប្រុស-ស្រី) និងរយៈពេលពិភាក្សាមានចន្លោះពី៣០-៤៥នាទី សម្រាប់ក្រុម នីមួយៗ។

គ.ការចុះអង្កេតផ្ទាល់ដល់ទីតាំងវិទ្យាល័យពេជ្រចិន្តា÷ ក្រុមសិក្សាស្រាវជ្រាវបានចុះអង្កេតមើលដោយផ្ទាល់ និងថតរូបនៅក្នុងបរិវេណវិទ្យាល័យ។ ក្រុមការងារសិក្សាស្រាវជ្រាវបានបែងចែកជាក្រុមតូចៗចុះសិក្សាទៅតាមលក្ខណវិនិច្ឆ័យគោលដោយពិនិត្យមើលស្ថានភាពជាក់ស្តែងពីទីតាំងនីមួយៗ បរិវេណ និងហេដ្ឋារចនាសម្ព័ន្ធ និងថតរូបពីទិដ្ឋភាពជាក់ស្តែងរបស់វិទ្យាល័យ។ អ្នកថតរូបបានសុំការអនុញ្ញាតពីគណៈគ្រប់គ្រងសាលារៀន ឬម្ចាស់រូបជាមុនសិនពីព្រោះរូបថតខ្លះនឹងត្រូវបានប្រើប្រាស់ជាសាធារណៈនៅក្នុងរបាយការណ៍ករណីសិក្សា។

ព័ត៌មាន និងទិន្នន័យដែលប្រមូលបានផ្តោតជាសំខាន់ទៅលើចំណុចគន្លឹះមួយចំនួនដូចជា÷ តើវិទ្យាល័យពេជ្រចិន្តាបានធ្វើអ្វីខ្លះក្នុងការផ្តល់សេវាអប់រំដល់សិស្ស មាតាបិតាអ្នកអាណាព្យាបាលសិស្ស និងសហគមន៍ ហើយបានអនុវត្តការងារទាំងនោះយ៉ាងដូចម្តេច ឬមានយុទ្ធសាស្ត្រយ៉ាងណាខ្លះ ក្នុងការជំរុញប្រសិទ្ធភាពការផ្តល់សេវាអប់រំឱ្យកាន់តែប្រសើរឡើង? លើសពីនេះ កិច្ចពិភាក្សាជាមួយថ្នាក់ដឹកនាំខេត្តបាត់ដំបង រដ្ឋបាលស្រុកភ្នំព្រឹក

សហគមន៍ និងភាគីពាក់ព័ន្ធទាំងឡាយនេះក៏ផ្តោតលើទស្សនៈ ឬការយល់ឃើញរបស់អ្នកឆ្លើយតបទាក់ទងនឹងតម្រូវការ ការគាំទ្រ បញ្ហាប្រឈម និងកិច្ចអន្តរាគមន៍នានាដែលបានអនុវត្តកន្លងមក និងសម្រាប់ពេលអនាគត ដើម្បីធានាថាការផ្តល់សេវាអប់រំសាធារណៈនៅតែមានសារៈសំខាន់ មានភាពសកម្ម និងទទួលបានការពេញចិត្តពីអ្នកប្រើប្រាស់។ សំណួរគន្លឹះទាំងអស់ដែលនឹងផ្តោតទៅលើលក្ខណវិនិច្ឆ័យទាំងប្រាំបី ដែលត្រូវបានប្រើក្នុងការជ្រើសរើសអង្គភាពផ្តល់សេវាសាធារណៈគំរូតាមរយៈសំណួរគន្លឹះគោលៗ ដូចមានសង្ខេបខាងក្រោម÷

តារាងទី២÷ លក្ខណវិនិច្ឆ័យគោលទាំងប្រាំបី និងសំណួរគន្លឹះៗ

លក្ខណវិនិច្ឆ័យគោល	**សំណួរគន្លឹះៗ**
(១) ស្តង់ដាផ្តល់សេវាសាធារណៈ	តើវិទ្យាល័យពេជ្រចិន្តាមានស្តង់ដានៃការផ្តល់សេវាសាធារណៈអ្វីខ្លះ?
(២) ស្តង់ដាផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ	តើវិទ្យាល័យពេជ្រចិន្តាបានរៀបចំ និងអភិវឌ្ឍស្តង់ដាផ្តល់សេវាសាធារណៈរបស់អង្គភាពអ្វីខ្លះ និងយ៉ាងដូចម្តេច?
(៣) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងអង្គភាព	តើវិទ្យាល័យពេជ្រចិន្តាមានយុទ្ធសាស្ត្រ និងផែនការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអ្វីខ្លះ និងយ៉ាងដូចម្តេចទៅលើផែនការហិរញ្ញវត្ថុ ការគ្រប់គ្រងចំណូលនិងចំណាយ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ?
(៤) ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព	តើវិទ្យាល័យពេជ្រចិន្តាមានយុទ្ធសាស្ត្រអ្វីខ្លះ និងយ៉ាងដូចម្តេចក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព?
(៥) ការរៀបចំនិងការកែលម្អបរិស្ថាននៅក្នុងអង្គភាព	តើវិទ្យាល័យពេជ្រចិន្តាមានយុទ្ធសាស្ត្រអ្វីខ្លះ និងយ៉ាងដូចម្តេចក្នុងការរៀបចំ និងការកែលម្អបរិស្ថាននៅក្នុងអង្គភាព?

លក្ខណៈវិនិច្ឆ័យគោល	សំណួរគន្លឹះៗ
(៦) ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ	តើវិទ្យាល័យមានយុទ្ធសាស្ត្រអ្វីខ្លះ និងយ៉ាងដូចម្តេចក្នុងការធ្វើទំនាក់ទំនងល្អជាមួយសាធារណជន សហគមន៍ ដៃគូអភិវឌ្ឍព្រមទាំងការចូលរួមវាយតម្លៃដោយអ្នកប្រើប្រាស់សេវាសាធារណៈ?
(៧) ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ សហគមន៍ និងសាធារណជន	តើវិទ្យាល័យពេជ្រចិន្ដាមានផែនការអ្វីខ្លះ និងយ៉ាងដូចម្តេចក្នុងការដោះស្រាយបញ្ហាប្រឈម ឬបណ្តឹងតវ៉ាជាមួយប្រជាពលរដ្ឋ និងសហគមន៍?
(៨) ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ	តើវិទ្យាល័យពេជ្រចិន្ដាមានការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍អ្វីខ្លះ និងធ្វើយ៉ាងដូចម្តេចដើម្បីឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ?

២.៤. វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យទទួលបាន ត្រូវបានយកមកតម្រៀបពិពណ៌នាជាសាច់រឿងដោយផ្អែកទៅតាមសូចនាករគោលនិងលក្ខណៈវិនិច្ឆ័យលម្អិត ដោយពិពណ៌នាពីរបៀបនិងដំណើរការអនុវត្តការងាររបស់វិទ្យាល័យរហូតទទួលបានជ័យលាភីជាអង្គភាពផ្តល់សេវាសាធារណៈគំរូចំណាត់ថ្នាក់លេខ១ ក្នុងវិស័យអប់រំ(ពិពណ៌នាតាមបែបគុណភាព)។ ក្រុមការងារបានរៀបចំសរសេរសេចក្តីព្រាងករណីសិក្សា ដោយផ្អែកតាមទម្រង់ដែលបានឯកភាព និងទៅតាមទិន្នន័យ ព្រមទាំងព័ត៌មានផ្តល់ជូនដោយវិទ្យាល័យ។ សេចក្តីព្រាងករណីសិក្សានេះ ត្រូវបានយកទៅពិគ្រោះយោបល់បន្ថែមជាមួយបុគ្គលិកអប់រំទាំងអស់នៅវិទ្យាល័យពេជ្រចិន្ដា និងភាគីពាក់ព័ន្ធដែលត្រូវបានជួបសម្ភាសន៍ដើម្បីធានាថាអ្វីៗដែលបានសរសេរ និងលើកឡើងនៅក្នុងករណីសិក្សាពិតជាត្រឹមត្រូវ និងឆ្លុះបញ្ចាំងបាននូវទិដ្ឋភាពជាក់ស្តែងដែលវិទ្យាល័យពេជ្រចិន្ដាធ្លាប់បានឆ្លងកាត់ និងបានកំពុងអនុវត្តផ្ទាល់រហូតដល់បច្ចុប្បន្ន។

ម្យ៉ាងទៀត ករណីសិក្សានេះត្រូវបានយកមកធ្វើបទបង្ហាញ និងពិភាក្សាជាមួយ

ក្រុមការងារផ្ទៃក្នុង និងជាមួយក្រុមការងារដឹកនាំរួមដើម្បីប្រមូលធាតុចូល និងមតិកែលម្អនានាពីក្រុមការងារទាំងអស់។ បន្ទាប់មកក្រុមការងារដឹកនាំរួមបានពិនិត្យ និងបានដាក់ជូនឆ្លងមតិយោបល់ ជាមួយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិដើម្បីសម្រេចជាលើកចុងក្រោយមុនពេលបញ្ចប់ និងបោះពុម្ពចែកចាយជាផ្លូវការ។ ការពិនិត្យផ្តល់យោបល់ និងការកែសម្រួលត្រូវបានធ្វើឡើងជាច្រើនដងដើម្បីធានាឱ្យបាននូវសុក្រឹតភាព និងភាពគ្រប់ជ្រុងជ្រោយនៃករណីសិក្សានេះ។

២.៥. ក្រមសីលធម៌នៃការសម្ភាសន៍ និងការចងក្រងករណីសិក្សា

ដើម្បីគោរពទៅតាមក្រមសីលធម៌នៃការស្រាវជ្រាវក្នុងការរៀបចំចងក្រងករណីសិក្សា ក្រុមការងារ បានអនុវត្តដូចខាងក្រោម÷

- ក្រុមការងារបានធ្វើលិខិតស្នើសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធជាមុនក្នុងការស្នើសុំកិច្ចសហការ និងសុំការអនុញ្ញាតឱ្យអង្គភាពនិងមន្ត្រីក្រោមឱវាទនានាដែលពាក់ព័ន្ធក្នុងករណីសិក្សាក្នុងផ្តល់បទសម្ភាសន៍ ផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធនៅក្នុងកំឡុងពេលនៃការសិក្សាចងក្រងករណីសិក្សាទាំងនេះ។
- ក្រុមការងារបានប្រកាន់ខ្ជាប់នូវក្រមសីលធម៌ដោយទទួលបានការឯកភាពជាមុនពីអ្នកដែលត្រូវសម្ភាសន៍ ឬអង្គភាពមុនពេលធ្វើការសម្ភាសន៍ និងស្នើសុំឯកសារពាក់ព័ន្ធនានា។ ក្រុមការងារអាចបញ្ឈប់ ឬរំលងការសម្ភាសន៍នៅពេលដែលអ្នកផ្តល់ការសម្ភាសន៍មានសភាពអសកម្មខាងផ្នែកស្មារតី និងរាង្គកាយ ឬមិនទទួលបានការអនុញ្ញាតជាដើម។ ម៉្យាងទៀត ក្រុមការងារបានជម្រាបជូនបុគ្គលិកអប់រំនៅវិទ្យាល័យពេជ្រចិន្តា និងអ្នកដែលត្រូវសម្ភាសន៍ពីគោលការណ៍ និងក្រមសីលធម៌នេះមុនពេលចាប់ផ្តើមសម្ភាសន៍។ ក្រុមការងារបានអានគោលការណ៍ និងក្រមសីលធម៌នោះឱ្យបានឮៗ ដល់អ្នកដែលត្រូវសម្ភាសន៍ ហើយអនុញ្ញាតឱ្យគាត់សួរបញ្ជាក់ចំពោះប្រយោគណាមួយដែលគាត់មិនបានយល់ច្បាស់ ប្រសិនបើគ្មានការយល់ព្រមទេនោះ

ក្រុមការងារត្រូវប្តូរទៅរកអ្នកដែលត្រូវសម្ភាសន៍បន្ទាប់ទៀត។

- រាល់ទិន្នន័យ និងព័ត៌មានដែលទទួលបានពីក្រុមគោលដៅខាងលើ ត្រូវបានរក្សាភាពសម្ងាត់ និងឯកជនភាព លើកលែងតែមានការអនុញ្ញាតឱ្យប្រើប្រាស់។

ជំពូកទី៣. ស្ថានភាពទូទៅ ស្នាដៃ និងភាពជោគជ័យរបស់វិទ្យាល័យពេជ្រចិន្តា

៣.១. ស្ថានភាពទូទៅ និងស្នាដៃរបស់វិទ្យាល័យពេជ្រចិន្តា

៣.១.១. សាវតារនៃអង្គភាព

វិទ្យាល័យពេជ្រចិន្តាស្ថិតនៅប៉ែកខាងលិចនៃប្រទេសកម្ពុជាមានចម្ងាយប្រមាណ ១៣០គីឡូម៉ែត្រ ពីទីរួមខេត្តបាត់ដំបង។ វិទ្យាល័យបានសាងសង់លើផ្ទៃដីសរុប ២២.៥៣០ ម៉ែត្រក្រឡា ស្ថិតនៅក្នុងភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ដែលមានព្រំប្រទល់ខាងកើតជាប់នឹងស្រុកបវេល ខាងជើងជាប់នឹងស្រុកសំពៅលូន ខាងត្បូងជាប់នឹងស្រុកកំរៀង និងខាងលិចជាប់នឹងប្រទេសថៃ។

ទីតាំងវិទ្យាល័យពេជ្រចិន្តានាពេលបច្ចុប្បន្ន កាលពីដើមឡើយជាអតីតដីតំបន់ចម្ការមីន និងជាតំបន់សមរភូមិក្តៅជួរមុខនៃការជួបប្រយុទ្ធគ្នារវាងកងទ័ពរដ្ឋាភិបាលកម្ពុជានិងកងទ័ពកម្ពុជាប្រជាធិបតេយ្យ។ ក្រោយពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ និងបន្ទាប់ពីរាជរដ្ឋាភិបាលបានធ្វើសមាហរណកម្មកងកម្លាំងយោធាកម្ពុជាប្រជាធិបតេយ្យចូលជាកងទ័ពជាតិរួចមក ប្រជាពលរដ្ឋ សហគមន៍ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់នៅក្នុងស្រុកភ្នំព្រឹកបានមូលមតិគ្នាជាឯកច្ឆន្ទ ខិតខំប្រឹងប្រែងប្រែក្លាយតំបន់ដីចម្ការមីននេះឱ្យទៅជាថ្នាលបណ្តុះវិជ្ជា សម្រាប់ផ្តល់ចំណេះដឹងដល់កូនចៅរបស់ពួកគាត់ជំនាន់ក្រោយវិញ។ ជាក់ស្តែងនៅឆ្នាំ២០០៣ ប្រជាពលរដ្ឋ សហគមន៍ និងអាជ្ញាធរដែនដីបានស្នើសុំឱ្យទីតាំងនេះបង្កើតទៅជាអនុវិទ្យាល័យភ្នំព្រឹក។ រហូតមកដល់ឆ្នាំ២០០៧ ដោយសារកំណើនសិស្សកាន់តែកើនច្រើនឡើងៗជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយសិស្សានុសិស្សមានការពិបាកក្នុងការបន្តការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ដែលមានទីតាំងស្ថិតនៅឆ្ងាយ និងដើម្បីជួយសម្រួលដល់ការសិក្សារបស់សិស្ស សហគមន៍ និងអាជ្ញាធរដែនដីក៏បានស្នើសុំពង្រីកពីអនុវិទ្យាល័យភ្នំព្រឹកទៅជាវិទ្យាល័យពេជ្រចិន្តា[៣] តាមប្រកាសលេខ ២៣០៦ អយក.ប្រក

[៣] ប្រកាសស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យភ្នំ ទៅជាវិទ្យាល័យពេជ្រចិន្តា ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៦

ជំពូកទី៣

ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៦ របស់ក្រសួងអប់រំ យុវជន និងកីឡា រហូតមកដល់បច្ចុប្បន្ន។

រហូតមកដល់បច្ចុប្បន្ន ក្នុងឆ្នាំ២០១៨-២០១៩ វិទ្យាល័យពេជ្រចិន្តា មានសិស្សសរុប ចំនួន ១២៥៩នាក់ ស្រីចំនួន ៣២៣នាក់។ វិទ្យាល័យមានបុគ្គលិកអប់រំសរុប ៣៦នាក់ ស្រី ១២នាក់ ដែលក្នុងនោះមានគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិចំនួន ២០នាក់ ស្រី ០៦នាក់ និងគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិចំនួន ១៦នាក់ ស្រី ០៦នាក់។ នៅពេលបង្កើតសាលារៀន ដំបូង វិទ្យាល័យបានផ្លាស់ប្តូរទីតាំងជាបន្តបន្ទាប់ ដោយសារបញ្ហាវិទ្យាល័យនៅមិនទាន់មាន ទីតាំងរបស់ខ្លួនពិតប្រាកដ និងបានខ្ចីសាលាបឋមសិក្សាភ្នំព្រីក បន្ទាប់មកខ្ចីរោងអាររឈើ និងសាលាបឋមសិក្សាភ្នំតូចធ្វើជាទីតាំងបណ្តោះអាសន្ន។ ចាប់តាំងពីវិទ្យាល័យពេជ្រចិន្តា មានទីតាំងពិតប្រាកដរបស់ខ្លួនមក គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រង សាលារៀន និងលោកគ្រូ អ្នកគ្រូបានកៀរគរសម្ភារៈ និងថវិកាពីសហគមន៍ មាតាបិតា និង អ្នកអាណាព្យាបាលសិស្ស ដៃគូអភិវឌ្ឍវិស័យអប់រំ អាជីវករ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ឱ្យចូលរួមពង្រីកទីតាំងរបស់វិទ្យាល័យ និងបានធ្វើការសាងសង់អគារសិក្សាមួយខ្នងពីរជាន់ មាន១២បន្ទប់សម្រេចបាន៥០ ភាគរយ។ ដោយសារគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រងសាលារៀនមិនមានថវិកាក្នុងការសាងសង់បន្ត ការសាងសង់អគារសិក្សា ថ្មីនេះក៏ត្រូវបានផ្អាកជបណ្តោះអាសន្ន។ ក្រោយមក ក្នុងដំណើរទស្សនកិច្ចស្វែងយល់ និង ចុះសួរសុខទុក្ខប្រជាពលរដ្ឋនៅតាមបណ្តោយព្រំដែនរបស់សម្តេចតេជោ **ហ៊ុន សែន** សម្តេចបានអញ្ជើញចុះសួរសុខទុក្ខដោយផ្ទាល់ជាមួយលោកគ្រូ អ្នកគ្រូ សហគមន៍ មាតាបិតា និងសិស្សានុសិស្ស លោកបានសម្រេចជួយសាងសង់បង្ហើយនូវអគារសិក្សាថ្មីនេះ និងបាន បន្ថែមជួយសាងសង់ទីចាត់ការមួយខ្នងបន្ថែមទៀត។

រឿងទី១ ÷ "**សូមលោកតាជួយដល់វិទ្យាល័យចៅផង**"

"**សូមលោកតាជួយដល់វិទ្យាល័យចៅផង**" ជាសារស័ព្ទរបស់យុវតីសិស្សវិទ្យាល័យពេជ្រចិន្តា ៣រូប បានបន្លឺទៅកាន់ **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** ខណៈសិស្សានុសិស្ស មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស លោកគ្រូ អ្នកគ្រូ និងគណៈកម្មការគ្រប់គ្រងសាលារៀនវិទ្យាល័យពេជ្រចិន្តាកំពុងឈរចាំស្វាក់ក្បួនដង្ហែរសម្តេច ចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមបណ្តោយព្រំដែនខ្មែរ ថៃ ពីតំបន់ស្រុកភ្នំព្រឹកខេត្តបាត់ដំបងទៅខេត្តប៉ៃលិន នៅត្រង់ចំណុចរង្វង់មូលទីរួមស្រុកភ្នំព្រឹកដើម្បីស្នើសុំអគារសិក្សា។ "កង្វះអគារសិក្សាជាក្តីកង្វល់របស់សហគមន៍វិទ្យាល័យពេជ្រចិន្តាទាំងមូល" លោក **ភឿន ឡូត** បានបញ្ជាក់បន្ថែម។

លោកបានឱ្យដឹងបន្ថែមថា កំណើនសិស្សវិទ្យាល័យពេជ្រចិន្តាបានកើនឡើងជាលំដាប់ពីមួយឆ្នាំទៅឆ្នាំជាហេតុនាំឱ្យខ្វះអគារសិក្សា។ នៅឆ្នាំ២០០៨ អាជ្ញាធរ សហគមន៍ គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូខ្វាយខ្វល់ពីការសិក្សារបស់សិស្ស ក៏បានមូលមតិគ្នាសម្រេចប្រកួកប្រកាសផ្សព្វផ្សាយពីការខ្វះអគារសម្រាប់កូនចៅរៀនសូត្រទៅដល់សហគមន៍ទាំងមូល។ ក្រោមការផ្តួចផ្តើម និងដឹកនាំដោយផ្ទាល់របស់ ឯកឧត្តម **ជាភ្លង់ ភិរម្យ** ដែលជាអតីតមេដឹកនាំសហគមន៍សម័យសង្គ្រាមស៊ីវិលផង និងជាប្រធានក្រុមការងារស្រុកភ្នំព្រឹកបច្ចុប្បន្នបានសម្រេចចិត្តកៀរថវិកាកសាងអគារសិក្សាមួយខ្នង។ ពេលនោះ ឯកឧត្តម **ជាភ្លង់ ភិរម្យ** ជាប្រធានគណៈកម្មការសាងសង់ មានព្រះគ្រូចៅអធិការទាំង១៤វត្ត អភិបាលស្រុក មេឃុំទាំង៥ ជាសមាជិក និងមានរូបលោក(**ភឿន ឡូត**) ជាគណនេយ្យករសម្រាប់ការងារសាងសង់នេះផងដែរ។ ជាលទ្ធផល ការងារសាងសង់សម្រេចបានអគារសិក្សា ១ខ្នង មាន ១២បន្ទប់ បន្ថែមទៅលើអគារសិក្សាមានស្រាប់ចំនួន ៣ខ្នង ស្មើ ១៣បន្ទប់។ នៅដំណាក់កាលសាងសង់លើកទី១ អគារសិក្សានេះសង់បានត្រឹមប្លង់សេ ១សន្ទឹក និងបានរៀបជាឥដ្ឋក្រហមឡើងតែប៉ុណ្ណោះ មិនអាចសម្រេច

ជំពូកទី៣

បាន២ជាន់ដូចការគ្រោងទុកទេ។ ដំណើរការសាងសង់ត្រូវផ្អាកពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់រយៈពេលប្រាំឆ្នាំដោយសារកង្វះថវិកាសាងសង់បន្ថែម។ សហគមន៍ទាំងមូលក៏អស់លទ្ធភាពស្វែងរកមូលនិធិ ឬសម្បុរសជនបញ្ចប់គម្រោងសាងសង់បន្ត។

លុះមកដល់ចុងឆ្នាំ២០១៦ ឱកាសល្អបានមកដល់ គាប់ជួនទទួលបានដំណឹងថា **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** នឹងចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមបណ្តោយព្រំដែនកម្ពុជា ថៃ ផងនោះ អជ្ញាធរ សហគមន៍ គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មាតាបិតា និងអ្នកអាណាព្យាបាលសិស្សក៏បានមូលមតិថា គួរធ្វើសំណើសុំទៅ **សម្តេច** សុំឱ្យលោកជួយសាងសង់អគារសិក្សាបន្ថែម។ គិតគ្នារួចក៏បានរៀបចំគម្រោងប្រមូលគ្នា ទាំងលោកគ្រូ អ្នកគ្រូ មាតាបិតា និងអ្នកអាណាព្យាបាល សិស្សចាំទទួលជួប **សម្តេច** ត្រង់ចំណុចរង្វង់មូលទីរួមស្រុកភ្នំព្រឹក។ ថ្ងៃរង់ចាំបានមកដល់ លោក **ពាន ចាង** សមាជិកសហគមន៍បានដឹកនាំសិស្សានុសិស្ស មាតាបិតា និងអ្នកអាណាព្យាបាល និងលោកគ្រូ អ្នកគ្រូ ដោយស្លៀកពាក់ស្អាតបាតទឹកមុខស្រស់ថ្លា ក្នុងចិត្តរំពឹងមុតមាំថានឹងបានជួប **សម្តេច** និងបានមកប្រមូលផ្តុំគ្នាត្រង់ចំណុចរង្វង់មូលតាមការគ្រោងទុក។ ប៉ុន្តែ ក្តីសង្ឃឹមទន្ទឹងរង់ចាំជួប **សម្តេច** បានរលាយបាត់អស់ពីអារម្មណ៍អ្នកគ្រប់គ្នា បន្ទាប់ពីទទួលបានដំណឹងពីឯកឧត្តមអភិបាលខេត្តបាត់ដំបងប្រាប់មកថា ដោយលោកគិតពីសុវត្ថិភាពជូនចំពោះ **សម្តេច** ដូច្នេះលោកមិនអនុញ្ញាតឱ្យមានការប្រមូលផ្តុំមនុស្សច្រើននៅចំណុចត្រង់រង្វង់មូលស្រុកភ្នំព្រឹកនោះទេ។ មិនបង្អង់យូរលោក ភឿន ឡូត និងអភិបាលស្រុកលោក **សួន កឿន** ក៏បានឡើងរថយន្តទៅចាំទទួល **សម្តេច** នៅកន្លែងមួយទៀត ត្រង់ចំណុចភូមិទួលខ្ពស់ ឃុំភ្នំព្រឹក សង្ឃឹមថានឹងបានជួប **សម្តេច** នៅទីនោះ។ បន្ទាប់មក លោកនាយកវិទ្យាល័យ **ប៊ិច ឈឿត** ក៏បានទៅដល់តាម ក្រោយ។ ភ្លាមនោះ **សម្តេច** បានអញ្ជើញមកដល់ រួចចុះសំដៅទៅសាលាបឋមសិក្សា ភ្នំព្រឹក បានជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងបាន

ប្រកាសផ្តល់ជូនសមិទ្ធផលជាច្រើន។ ***រូបខ្ញុំ***(លោក ភឿន ឡូត) និង លោក **ប៉ិច ឈឿត** បានសសៀរៗទៅឈរជិត **សម្តេច** រួច លោក **ប៉ិច ឈឿត** ក៏បានមានមតិទៅកាន់ **សម្តេច** ថា“ ***សូមលោកអ៊ុំជួយសាលាវិទ្យាល័យខ្ញុំផង***” ពេលនោះ **សម្តេច** លោកមានប្រសាសន៍តបវិញភ្លាមថា “ ***ក្មួយ ពូអត់មានពេលច្រើនទេ ព្រោះពូប្រញាប់ទៅឱ្យដល់ខេត្តប៉ៃលិនទៀត***”។ ក្រោយឮប្រសាសន៍**សម្តេច**ភ្លាម រូបខ្ញុំផ្ទាល់ (ភឿន ឡូត) អស់សង្ឃឹមម្តងទៀត ហើយក៏ប្រាប់ លោក **ប៉ិច ឈឿត** ថា “ឈឿតឯងនៅនេះហើយ ខ្ញុំទៅមុន”។ និយាយចប់ ខ្ញុំក៏រត់ចេញពីទីនោះមកក្រៅទាំងទឹកភ្នែកហូរស្រោចលើផ្ទៃមុខដោយមិនដឹងខ្លួន ហើយក៏មិនខ្វល់ថា ខ្ញុំបានជិះឡានមួយណាមកជាមួយលោកអភិបាលស្រុកដែរ។ ខ្ញុំដឹងតែពីរត់សំដៅទៅឡានខ្ញុំ ដីជាង៣០០ម៉ែត្រ ចាប់ទូរសព្ទទាក់ទងទៅ លោក **ពាន ចាង** កំពុងដឹកនាំក្រុមសិស្សានុសិស្ស មាតាបិតា លោកគ្រូ អ្នកគ្រូ រង់ចាំនៅរង្វង់មូលស្រុកភ្នំព្រឹកថា “ ***សូមកុំរំសាយក្មួនសិស្សអី នៅរង់ចាំជួបសម្តេចនៅទីនោះឱ្យបាន***” ពេលនោះលោក **ពាន ចាង** ក៏យល់ព្រម។ ខ្ញុំគិតថានេះជាឱកាសចុងក្រោយដើម្បីបានជួប **សម្តេច** ហើយ ហើយគិតថាអ្វីដែលខ្ញុំកំពុងធ្វើពិតណាស់ថា មានការខុសឆ្គងដែលស្ទាក់ផ្លូវជួប **សម្តេច** តែជាប្រជាពលរដ្ឋខ្មែរម្នាក់ដែរ ដូចពលរដ្ឋខ្មែរគ្រប់រូបកន្លងមក ពិតជាទទួលបានការស្វាគមន៍ពី **សម្តេចតេជោ** ដោយពុំមានការរើសអើងទេ ដូចដែលពេល **សម្តេច** ឃើញប្រជាពលរដ្ឋចាំទទួល លោកតែងតែចុះជួប និងថតរូបសែលហ្វីជាមួយជាដើមចឹងដែរ។ គុណបុណ្យបារមីស្រុកភ្នំព្រឹកតាមថែរក្សា នៅពេល **សម្តេច** ធ្វើដំណើរមកដល់ទីប្រជុំជនស្រុកភ្នំព្រឹក ឃើញប្រជាពលរដ្ឋ សិស្សានុសិស្ស លោកក៏ចុះពីរថយន្តសួរសុខទុក្ខ ពេលនោះសិស្សស្រី៣នាក់បាន លើកដៃសំពះ រួចនិយាយទៅកាន់ **សម្តេច** ថា “ ***សូមលោកតាជួយដល់វិទ្យាល័យចៅផង សាលាចៅខ្វះអគារសិក្សា***”។ **សម្តេច** ក៏សួរទៅកាន់សិស្សទាំងបីនាក់វិញថា “ ***តើសាលាចៅនៅជិត ឬឆ្ងាយ?***” ពេលនោះក្មួយៗបាននិយាយទៅកាន់ **សម្តេច** ថា “ ***លោកតានៅជិតនេះទេ ប្រហែលជា៥០០ម៉ែត្រប៉ុណ្ណោះ***”។

បន្ទាប់មក **សម្តេច** បន្ថែមថា “***អីចឹងចៅឡើងឡានជាមួយតាមក***”។ ទាំងអស់គ្នាក្ដុកក្ដួលជាពន់ពេកពេលក្មួយៗឡើងជិះឡានជាមួយ **សម្តេច** និងទាំងអស់គ្នា រួមទាំងខ្ញុំផងទឹកភ្នែកស្រក់មិនដឹងខ្លួនម្ដងទៀតដោយសារត្រេកអរពេក ពេលបានឃើញឡានសម្ដេចបត់សំដៅទៅសាលារៀន។ ទាំងខ្ញុំ ប្រជាពលរដ្ឋ និងសិស្ស មិនខ្វល់ពីជិះឡាន ឬម៉ូតូទេ នាំគ្នារត់តាំងពីរង្វង់មូលស្រុកភ្នំព្រឹក មកសាលាតែម្ដង ដើម្បីបានជួប និងស្ដាប់ប្រសាសន៍ **សម្តេច** ផ្ទាល់។ **សម្តេច** បានសំណេះសំណាលដោយក្ដីសប្បាយរីករាយរាក់ទាក់ រួចក៏មានប្រសាសន៍ចុងក្រោយដែលអ្នកគ្រប់គ្នាចងចាំជានិច្ចថា “**ជូនតាមសំណើ**” ស្ទើរពុំទាន់ចប់ប្រសាសន៍ **សម្តេច** ផង សម្លេងហ៊ោរអបអរសាទរ ទឹកភ្នែករលីងរលោង លាយឡំស្នូរទះដៃបន្លឺរឡើងកងរំពង សម្ដែងនូវការគោរពដឹងគុណមិនអាចបំភ្លេចបាន និងការគោរពស្រឡាញ់ពេញក្រអៅបេះដូងរបស់សហគមន៍ស្រុកភ្នំព្រឹក ពិសេសសិស្សានុសិស្ស និងបុគ្គលិកអប់រំវិទ្យាល័យពេជ្រចិន្តា[៤]។

បច្ចុប្បន្នសមិទ្ធផល **សម្តេច** ផ្ដល់ជូនរួមមាន អគារសិក្សាបីជាន់ ២៨បន្ទប់ អគារសិក្សាពីរជាន់ ១២បន្ទប់ ទីចាត់ការមួយខ្នង ៣បន្ទប់ ទីធ្លាលេងកីឡា (តារាងបាល់ទះ តារាងបាល់ទាត់ និងតារាងបាល់បោះ) ខ្លោងទ្វារ និងផ្លូវចាក់បេតុងនៅក្នុងបរិវេណវិទ្យាល័យ។

បន្ទាប់មក មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង សហការជាមួយនឹងការិយាល័យអប់រំ យុវជន និងកីឡាស្រុកភ្នំព្រឹក និងគណៈគ្រប់គ្រងសាលារៀនពេជ្រចិន្តាបានទាក់ទងជាមួយអង្គការសម្រេចសុបិនកុមារកម្ពុជា បានជួយសាងសង់អគារកន្លែងស្នាក់នៅសម្រាប់សិស្សចំនួន ០២ខ្នង បន្ថែមទៀត។ ដោយសារតែវិទ្យាល័យរក្សាបាននូវទំនាក់ទំនងល្អជាមួយនឹងអង្គការសម្រេចសុបិន្តកុមារ ទើបអង្គការនេះបន្តផ្ដល់កុំព្យូទ័រជាច្រើនគ្រឿងសម្រាប់បម្រើការបង្រៀន និងរៀនដើម្បីពង្រឹងគុណភាពសិក្សានៅវិទ្យាល័យបន្ថែមទៀត។ លើសពីនេះទៅទៀត អង្គការនេះក៏បានបន្តគាំទ្រជួយដល់វិទ្យាល័យបន្ថែមទៀតតាមរយៈ

[៤] ការនិទានរឿងរបស់លោក ភឿន ឡូត ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន

ការផ្តល់អាហារូបករណ៍ដល់សិស្សដែលមានជីវភាពក្រីក្រចំនួន ១៦នាក់ ក្នុងមួយឆ្នាំ ដើម្បីបន្តការសិក្សានៅវិទ្យាល័យដែលម្នាក់ៗទទួលបានថវិកាឧបត្ថម្ភចំនួន ៦០ដុល្លារអាមេរិក។

ជាក់ស្តែងដោយសារការខិតខំប្រឹងប្រែងរបស់គណៈគ្រប់គ្រង និងគណៈកម្មការគ្រប់គ្រងសាលារៀនព្រមទាំងបុគ្គលិកអប់រំវិទ្យាល័យពេជ្រចិន្តា បានធ្វើឱ្យវិទ្យាល័យសម្រេចបាននូវសមិទ្ធផលជាច្រើន ជាបន្តបន្ទាប់រហូតដល់វិទ្យាល័យពេជ្រចិន្តាបានប្រែក្លាយទៅជាវិទ្យាល័យទទួលបានជ័យលាភីលេខ១ ជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំទូទាំងប្រទេស សម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដោយទទួលបានពានរង្វាន់ និងថវិកាអមពានរង្វាន់ចំនួន ២០០លានរៀល ក្រោមការសហការដឹកនាំវាយតម្លៃពីក្រសួងមុខងារសាធារណៈ។ ពិធីប្រគល់ពានរង្វាន់ និងថវិកាអមពានរង្វាន់ បានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធ មុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** អមដោយឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស (អតីតរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ) និងជាប្រធានគណៈកម្មការជាតិវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅព្រឹកថ្ងៃពុធ ទី០៧ ខែសីហា ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ។

៣.១.២. ចក្ខុវិស័យ បេសកកម្ម និងគោលបំណង

➢ **ចក្ខុវិស័យ**

សាលាទទួលសិស្សឱ្យចូលរៀនប្រកបដោយសមភាព សមធម៌ និងបរិយាបន្ន បណ្តុះវិន័យ គុណភាព គុណធម៌ និងការច្នៃប្រឌិត កាត់បន្ថយអត្រាបោះបង់ការសិក្សាឱ្យសល់សូន្យភាគរយក្នុងមួយឆ្នាំៗ ជាពិសេសគឺផ្តល់សេវាអប់រំមួយដែលសហគមន៍ទទួលស្គាល់។

➤ **បេសកកម្ម**

វិទ្យាល័យពេជ្រចិន្តាមានបេសកកម្មដូចខាងក្រោម÷

- កសាងធនធានមនុស្សឱ្យមានចំណេះដឹង ចំណេះធ្វើ និងមានសីលធម៌ស្របតាមគោលនយោបាយរាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា
- ពង្រឹងការផ្ដល់សេវាអប់រំឱ្យបានល្អប្រសើរឡើងថែមទៀត ជាពិសេសការចែករំលែកដល់សាលារៀនដទៃៗទៀត និងប្រែក្លាយសាលារៀនឱ្យក្លាយជាសាលារៀនរបស់សហគមន៍
- ពង្រឹងគុណវុឌ្ឍិគ្រូ ទាំងមុខវិជ្ជាជំនាញឯកទេស និងសីលធម៌វិជ្ជាជីវៈ
- កសាងយុវជនមួយដែលសង្គមជាតិត្រូវការទាំងពេលបច្ចុប្បន្ន និងពេលអនាគត
- បណ្ដុះជំនាញភាសាបរទេស និងជំនាញបច្ចេកទេស នៅពេលសិស្សឈប់រៀនអាចយកទៅប្រកបមុខរបរចិញ្ចឹមជីវិតបាន
- លើកកម្ពស់យេនឌ័រលើគ្រប់សកម្មភាព។

➤ **គោលបំណង**

- ប្រែក្លាយវិទ្យាល័យឱ្យទៅជាសាលាមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស
- អនុវត្តការរៀន និងការបង្រៀនស្របតាមបដិវត្តន៍ឧស្សាហកម្ម៤.០
- ពង្រឹងភាពជាអ្នកដឹកនាំទាំងជួរអ្នកដឹកនាំ លោកគ្រូ អ្នកគ្រូ និងក្រុមប្រឹក្សាយុវជនឱ្យកាន់តែល្អប្រសើរ និងមានយេនឌ័រ
- កសាងយុវជនឱ្យមានវិន័យ គុណភាព គុណធម៌ និងការច្នៃប្រឌិត។

៣.១.៣. រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងវិទ្យាល័យពេជ្រចិន្តា

រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងរួមមាន គណៈគ្រប់គ្រងសាលារៀនដែលដឹកនាំដោយនាយកវិទ្យាល័យមួយរូប និងនាយករងវិទ្យាល័យចំនួនពីររូប ដែលនាយករងមួយរូបដឹកនាំបច្ចេកទេស និងនាយករងមួយរូបទៀតទទួលបន្ទុកការងាររដ្ឋបាល និងហិរញ្ញវត្ថុ។ នាយករងទទួលបន្ទុកបច្ចេកទេសមានតួនាទីដឹកនាំ និងគ្រប់គ្រងការបង្រៀន និងរៀនដោយបាន

បង្កើតក្រុមបច្ចេកទេសមុខវិជ្ជាចំនួនបី ក្រុមបច្ចេកទេសវិទ្យាសាស្ត្រ ក្រុមបច្ចេកទេសវិទ្យាសាស្ត្រសង្គម និងក្រុមបច្ចេកទេសភាសា។ ទន្ទឹមនឹងនេះ វិទ្យាល័យបានបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ដែលដឹកនាំដោយប្រធានមួយរូប អនុប្រធានពីររូប និងសមាជិកមួយចំនួនតាមការចាំបាច់សម្រាប់ជួយកៀរគរសម្ភារៈ និងថវិកាក្នុងការអភិវឌ្ឍវិទ្យាល័យ។

៣.១.៤. ក្រុមគោលដៅ និងភាគីពាក់ព័ន្ធ

ក្នុងការអភិវឌ្ឍគ្រឹះស្ថាន វិទ្យាល័យមានក្រុមគោលដៅ និងដៃគូអភិវឌ្ឍសំខាន់ៗដូចខាងក្រោម÷

- សិស្សានុសិស្ស មាតាបិតា អ្នកអាណាព្យាបាល អាជីវករ និងសហគមន៍ក្នុងស្រុកភ្នំព្រឹក
- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ក្នុងស្រុកភ្នំព្រឹក និងខេត្តបាត់ដំបង
- មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង
- ការិយាល័យអប់រំ យុវជន និងកីឡាស្រុកភ្នំព្រឹក និង
- អង្គការដៃគូអភិវឌ្ឍវិស័យអប់រំនានា។

៣.១.៥. សេវាសាធារណៈសំខាន់ៗរបស់វិទ្យាល័យ

វិទ្យាល័យពេជ្រចិន្តាជាគ្រឹះស្ថានអប់រំសាធារណៈដែលផ្តល់សេវាអប់រំដល់សិស្សានុសិស្សចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២។ ក្នុងការបម្រើសេវាអប់រំសាធារណៈដល់សិស្សានុសិស្ស និងសហគមន៍វិទ្យាល័យពេជ្រចិន្តាបានផ្តល់នូវសេវាអប់រំមួយចំនួន រួមមាន÷

- សេវាបង្រៀន និងរៀន
- សេវាបណ្ណាល័យ
- សេវាអន្តេវាសិកដ្ឋានសម្រាប់សិស្សានុសិស្សដែលមកពីតំបន់ឆ្ងាយៗ និងសិស្សក្រីក្រ
- សេវាបង្រៀនបំប៉នសិស្សរៀនយឺត និងរៀនលឿន
- សេវាការបញ្ជាក់ការសិក្សា និងផ្ទេរការសិក្សាសិស្ស

• ក្លឹបសិក្សា និងសិស្សជួយសិស្ស
• សេវាជួយសិស្សក្រីក្រ និងសិស្សងាយរងគ្រោះ។

៣.១.៦. ការប្រកាសទទួលស្គាល់ជាអង្គភាពសេវាសាធារណៈគំរូ

វិទ្យាល័យពេជ្រចិន្តា ត្រូវបានរាជរដ្ឋាភិបាលវាយតម្លៃ និងប្រកាសទទួលស្គាល់ជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំប្រចាំឆ្នាំ២០១៩ តាមរយៈអនុក្រឹត្យលេខ ១១០ អនក្រ.បក ចុះថ្ងៃពុធ ៨រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩។

៣.១.៧. ពានរង្វាន់ រង្វាន់ និងជ័យលាភីដែលវិទ្យាល័យទទួលបាន

ល.រ	ឆ្នាំ	ឈ្មោះពានរង្វាន់ និងរង្វាន់ទទួលបាន	ស្ថាប័នផ្តល់ជូន
១	២០១៩	ពានរង្វាន់សាលាស្អាត ចំណាត់ថ្នាក់លេខ៣	ក្រសួងអប់រំ យុវជន និងកីឡា
២	២០១៩	ពានរង្វាន់អង្គភាពផ្តល់សេវាធារណៈគំរូក្នុងវិស័យអប់រំ	រាជរដ្ឋាភិបាលកម្ពុជា
៣	២០១៩	ពានរង្វាន់សម្តេចតេជោសែន នាយកសាលាល្អ ចំណាត់ថ្នាក់លេខ១	ក្រសួងអប់រំ យុវជន និងកីឡា
៤	២០១៩	មេដាយសំរិទ្ធិសាលាមេត្រីបរិស្ថានថ្នាក់ជាតិ	ក្រសួងបរិស្ថាន
៥	២០១៩	ប័ណ្ណសរសើរអង្គភាពល្អថ្នាក់ខេត្ត	មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង
៦	២០១៩	ប័ណ្ណសរសើរគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា (SEIP)	ក្រសួងអប់រំ យុវជន និងកីឡា
៧	២០១៩	ប័ណ្ណសរសើរសិស្សទទួលបាននិទ្ទេស A ចំនួន ០៣នាក់	ក្រសួងអប់រំ យុវជន និងកីឡា
៨	២០១៩	នាយកល្អថ្នាក់ខេត្ត	មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង
៩	២០១៨	ពានរង្វាន់សាលាស្អាត ចំណាត់ថ្នាក់លេខ៣	ក្រសួងអប់រំ យុវជន និងកីឡា

ល.រ	ឆ្នាំ	ឈ្មោះពានរង្វាន់ និងរង្វាន់ទទួលបាន	ស្ថាប័នផ្តល់ជូន
១០	២០១៨	ប័ណ្ណសរសើរសាលាស្អាតថ្នាក់ខេត្ត	មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង
១១	២០១៨	ទង់ជ័យលាភីថ្នាក់លេខ១ ផ្នែកកីឡា	មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង
១២	២០១៧	ប័ណ្ណសសើរសិស្សទទួលបាននិទ្ទេស A ចំនួន ០១នាក់	ក្រសួងអប់រំ យុវជន និងកីឡា
១៣	២០១៦	ទង់ជ័យលាភីលេខ១ ផ្នែកកីឡា	មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង
១៤	២០១៥	ការប្រកួតបាល់ទាត់យុវជន ទស្សនៈពិភពលោក ចំណាត់ថ្នាក់លេខ១	អង្គការ World Vision
១៥	២០១៥	លិខិតសរសើរសកម្មភាពក្នុងសង្គម	សាខាកាកបាទក្រហមកម្ពុជា ខេត្តបាត់ដំបង
១៦	២០១១	ទង់ជ័យលាភី ចំណាត់ថ្នាក់លេខ១	មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង
១៧	២០១០	ជ្រើសរើសជើងឯកបាល់ទាត់យុវជនប្រចាំស្រុកភ្នំព្រឹក	សាលាស្រុកភ្នំព្រឹក
១៨	២០០៦	ទង់ជ័យលាភី ចំណាត់ថ្នាក់លេខ២	មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង

៣.២. បទពិសោធន៍ជោគជ័យរបស់វិទ្យាល័យពេជ្រចិន្តា

៣.២.១. ស្តង់ដាសេវាសាធារណៈ

៣.២.១.១. គុណភាពព័ត៌មាន

ក. បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវា

ក្នុងការរក្សាទុកនូវឯកសារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់បម្រើឱ្យការផ្តល់សេវាអប់រំ និងសេវាផ្សេងៗទៀតដែលមាននៅក្នុងគ្រឹះស្ថាន វិទ្យាល័យបានរៀបចំ

បន្ទប់ចំនួនមួយដែលមានទូរដាក់ឯកសារចំនួន៤ សម្រាប់រក្សាទុកឯកសារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដោយបានរៀបចំទុកដាក់ឱ្យមានរបៀបរៀបរយ និងមានសណ្តាប់ធ្នាប់ល្អ។ ឯកសារទាំងអស់ត្រូវបានរក្សាទុកនៅក្នុងទូរដាក់ឯកសារទៅតាមប្រភេទ និងចំណាត់ថ្នាក់នៃឯកសារ ដោយបានរៀបចំឱ្យមានក្រួណ្ឌ បិទឈ្មោះសម្គាល់ប្រភេទ និងចំណាត់ថ្នាក់នៃឯកសារនីមួយៗសម្រាប់ទុកដាក់ឯកសារនានា ដែលធ្វើឱ្យអ្នកផ្តល់ និងអ្នកប្រើប្រាស់សេវាមានភាពងាយស្រួលក្នុងការស្វែងរកបានឆាប់រហ័ស ហើយអាចផ្តល់ជូនទៅអ្នកប្រើប្រាស់សេវាអាចពិនិត្យផ្ទៀងផ្ទាត់បាន និងបានធ្វើបច្ចុប្បន្នកម្មជាប្រចាំអំពីបទដ្ឋានថ្មីៗដែលវិទ្យាល័យទទួលបាន។ បុគ្គលិកអប់រំ និងសាធារណជនដែលជាអ្នកប្រើប្រាស់សេវាវិទ្យាល័យ អាចស្នើសុំពិនិត្យ និងផ្ទៀងផ្ទាត់លិខិតបទដ្ឋានទាំងនេះបាននៅរៀងរាល់ម៉ោងធ្វើការ ដោយអាចទំនាក់ទំនងជាមួយគណៈគ្រប់គ្រងសាលារៀនដោយផ្ទាល់ ឬជាមួយបុគ្គលិកអប់រំប្រចាំការដែលត្រូវបានទទួលការចាត់តាំងឱ្យបំពេញការងារនេះ។ ឯកសារបទដ្ឋានគតិយុត្តដែលបានរក្សាទុកនៅក្នុងវិទ្យាល័យរួមមាន÷ ច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា ច្បាប់អប់រំ ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា គោលនយោបាយអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងកំណែទម្រង់អាទិភាពនានារបស់ក្រសួងអប់រំយុវជន និងកីឡា អនុក្រឹត្យ ប្រកាស សេចក្តីណែនាំ សេចក្តីជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង។

ដើម្បីធ្វើឱ្យការផ្តល់សេវាអប់រំកាន់តែល្អប្រសើរឡើង វិទ្យាល័យបានរៀបចំនូវនិយាម និងបទបញ្ជាផ្ទៃក្នុងនានាសម្រាប់គ្រូបង្រៀន និងបុគ្គលិកអប់រំបំពេញការងាររដ្ឋបាល ព្រមទាំងសិស្សានុសិស្ស។ និយាមនិងបទបញ្ជាផ្ទៃក្នុងទាំងនោះត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់បន្ថែមជាច្រើនលើកច្រើនសាជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំ និងអ្នក

ពាក់ពន្ធ័ក្នុងគោលបំណងឱ្យមានការឯកភាពគ្នាជាធ្លុងមួយ ទៅលើអ្វីដែលវិទ្យាល័យត្រូវយកមកអនុវត្ត និងមិនត្រូវយកមកអនុវត្ត ដើម្បីជំរុញការប្រតិបត្តិការងាររបស់វិទ្យាល័យឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ សេចក្តីសម្រេចនានាអំពីនិយាម និងបទបញ្ជាផ្ទៃក្នុងវិទ្យាល័យត្រូវបានបិទផ្សព្វផ្សាយជាសាធារណៈនៅខាងមុខថ្នាក់រៀន ទីចាត់ការបណ្ណាល័យ អន្តេវាសិកដ្ឋាន និងក្តារខៀនបិទផ្សព្វផ្សាយព័ត៌មាននៅបរិវេណវិទ្យាល័យនៅសាលាស្រុក នៅទីប្រជុំជន ហើយត្រូវបានយកផ្សព្វផ្សាយបន្តជូនទៅដល់មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស នៅក្នុងជំនួបរវាងគណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន មាតាបិតា និងអ្នកអាណាព្យាបាលសិស្សរៀងរាល់ ៣ខែម្តង នៅកិច្ចប្រជុំផ្ទៃក្នុងរបស់វិទ្យាល័យជាមួយរដ្ឋបាលស្រុកភ្នំព្រឹក និងនៅក្នុងព្រឹត្តិការណ៍នានាដែលបានរៀបចំឡើងនៅក្នុងវិទ្យាល័យមានដូចជា ការតាំងពិពណ៌វិទ្យាសាស្ត្រ និងស្នាដៃសិស្ស និងក្នុងវេទិកាសាធារណៈផ្សេងៗដែលមានតំណាងវិទ្យាល័យចូលរួម។

ខ. ការផ្សព្វផ្សាយព័ត៌មានអំពីសេវា

វិទ្យាល័យបានផ្សព្វផ្សាយនូវព័ត៌មានអំពីសេវាទាំងអស់របស់ខ្លួនដូចជា សេវាការចុះឈ្មោះចូលរៀន ការប្រឡងឡើងថ្នាក់ ការប្រឡងឡើងវិញ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ការប្រឡងមធ្យមសិក្សាទុតិយភូមិ សេវាបញ្ជាក់លិខិតការសិក្សារបស់សិស្ស ការបញ្ជាក់លិខិតផ្ទេរការសិក្សា ពាក្យសុំច្បាប់សម្រាប់បុគ្គលិកអប់រំ និងសិស្សទៅដល់សិស្សានុសិស្ស និងអ្នកប្រើប្រាស់សេវា ព្រមទាំងបានណែនាំទៅដល់អ្នកទៅទទួលសេវាអំពីតម្រូវការឯកសារពាក់ព័ន្ធនានា ដែលវិទ្យាល័យតម្រូវឱ្យដាក់ជូនភ្ជាប់ជាមួយពាក្យស្នើសុំ និងលក្ខខណ្ឌនានាដើម្បីឱ្យអ្នកទទួលសេវា អាចទទួលបានសេវាទៅតាមតម្រូវការពីវិទ្យាល័យ។

បន្ថែមពីលើនេះ ពេលវេលាបំពេញការងារ និងមធ្យោបាយសម្រាប់ទំនាក់ទំនងរបស់វិទ្យាល័យត្រូវបានបិទផ្សាយក្នុងទម្រង់ជាក្រដាស A4 នៅទីចាត់ការវិទ្យាល័យ និងនៅតាមក្តារខៀនព័ត៌មានរបស់វិទ្យាល័យដើម្បីឱ្យបុគ្គលិកអប់រំ សិស្សានុសិស្ស និងសាធារណជនបានយល់ដឹងអំពីពេលវេលាបម្រើ សេវា និងនីតិវិធី ក៏ដូចជាយន្តការនៃការទំនាក់ទំនង

ជំពូកទី៣

ដែលអ្នកទៅទទួលសេវាអាចធ្វើបានដើម្បីសាកសួរព័ត៌មានបន្ថែម ពិគ្រោះយោបល់ ឬសុំជំនួយជាបន្ទាន់ក្នុងករណីចាំបាច់ណាមួយ។ វិទ្យាល័យបានផ្តល់នូវជម្រើសផ្សេងៗជូនអ្នកប្រើប្រាស់សេវាដូចជា អ្នកទទួលសេវាអាចជួបដោយផ្ទាល់ជាមួយបុគ្គលិកអប់រំដើម្បីទទួលយកសេវា និងផ្តល់សេវាតាមរយៈក្រុមការងារដែលត្រូវបានចាត់តាំងឱ្យបំពេញការងារតាមរយៈទូរសព្ទ សៀវភៅតាមដានការសិក្សា ឬសៀវភៅសិក្ខាគារិករបស់សិស្ស ឬតាមប្រព័ន្ធទំនាក់ទំនងសង្គមដែលវិទ្យាល័យបានរៀបចំឡើង (តេឡេក្រាមវិទ្យាល័យពេជ្រចិន្តា តេឡេក្រាមរបស់ក្រុមប្រឹក្សាយុវជន ក្រុមយុវជនស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាប្រចាំវិទ្យាល័យពេជ្រចិន្តា ហ្វេសប៊ុកវិទ្យាល័យពេជ្រចិន្តា)។ ចំណុចដ៏ល្អមួយគួរកត់សម្គាល់នោះគឺវិទ្យាល័យបានរៀបចំឱ្យមានការបិទនៅពីមុខតុសិស្សនីមួយៗនូវលេខទូរសព្ទទំនាក់ទំនងរបស់មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ដែលអាចឱ្យលោកគ្រូ អ្នកគ្រូបង្រៀនធ្វើការទំនាក់ទំនងដោយផ្ទាល់ និងបានឆាប់រហ័សទៅកាន់មាតាបិតា និងអ្នកអាណាព្យាបាលសិស្សក្នុងករណីដែលសិស្សអវត្តមានដោយគ្មានច្បាប់ មករៀនយឺតឬមានបញ្ហាណាមួយដោយចៃដន្យកើតនៅខាងក្រៅបរិវេណវិទ្យាល័យ។ វិធីសាស្ត្រនេះបានបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់របស់គណៈគ្រប់គ្រងសាលារៀន ក៏ដូចជាបុគ្គលិកអប់រំវិទ្យាល័យទៅលើសុវត្ថិភាព និងការសិក្សារបស់សិស្សក្នុងការមករៀននៅវិទ្យាល័យ។

ឥ. មធ្យោបាយផ្សព្វផ្សាយព័ត៌មានស្តីអំពីសេវា

សម្រាប់ការផ្សព្វផ្សាយនូវព័ត៌មានអំពីសេវានិងកិច្ចការរបស់វិទ្យាល័យ គណៈគ្រប់គ្រងសាលារៀនបានរៀបចំយុទ្ធសាស្ត្រសំខាន់ចំនួនពីរគឺ ការជំរុញការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិច និងការផ្សព្វផ្សាយមិនមែនអេឡិចត្រូនិច។ តាមប្រព័ន្ធអេឡិចត្រូនិច វិទ្យាល័យបានបង្កើតឱ្យមាននូវហ្វេសប៊ុកផេក និងតេឡេក្រាម។ ដោយឡែក ការផ្សព្វផ្សាយតាមប្រព័ន្ធមិនមែនអេឡិចត្រូនិចមានដូចជា ការបិទផ្សាយលើក្តារខៀនព័ត៌មានក្នុងបរិវេណវិទ្យាល័យ បដា ការផ្សព្វផ្សាយនៅនឹងកន្លែង ពេលគោរពទង់ជាតិ នៅតាមទីផ្សារ ទីប្រជុំជននានា ការបញ្ជូនលិខិតទៅមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ការជួបប្រជុំជាមួយមាតាបិតា

និងអ្នកអាណាព្យាបាលសិស្ស សហគមន៍ និងអាជ្ញាធរដែនដី វេទិកាសាធារណៈ ការចុះសួរសុខទុក្ខដោយផ្ទាល់ដល់សិស្សនិងក្រុមគ្រួសាររបស់សិស្សនៅតាមខ្នងផ្ទះ និងតាមរយៈកម្មវិធីនិងព្រឹត្តិការណ៍នានាផ្សេងទៀត។

៣.២.១.២. ភាពងាយស្រួលក្នុងការទទួលយកសេវា

វិទ្យាល័យពេជ្រចិន្ដាមានទីតាំងស្ថិតនៅភូមិភ្នំតូច ឃុំពេជ្រចិន្ដា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបងដែលមានចម្ងាយប្រមាណ ១៣០គ.ម ពីទីរួមខេត្តបាត់ដំបង និងមានចម្ងាយពីព្រំដែនថៃប្រមាណ ១២០០ម៉ែត្រ នៅលើផ្ទៃដីទំហំ ២២.២០០ ម៉ែត្រក្រឡា។ បើធ្វើដំណើរពីទីរួមខេត្តបាត់ដំបងតាមផ្លូវជាតិលេខ ៥៧បេ ឆ្ពោះទៅស្រុកភ្នំព្រឹក ស្ថិតនៅខាងស្ដាំដៃគេឃើញមានស្លាកមួយដែលសរសេរថា «វិទ្យាល័យពេជ្រចិន្ដា» ហើយបត់តាមច្រកផ្លូវបេតុង ដែលមានទទឹង ៦ម៉ែត្រ និងបណ្ដោយប្រវែង ២០០ម៉ែត្រ គេនឹងឃើញខ្លោងទ្វារធំដែលមានឆ្លាក់ឈ្មោះថា «វិទ្យាល័យពេជ្រចិន្ដា»។ ហេដ្ឋារចនាសម្ព័ន្ធទាំងក្នុង និងខាងក្រៅបរិវេណវិទ្យាល័យនេះមានលក្ខណៈល្អប្រសើរទាំងរដូវវស្សា និងរដូវប្រាំង។ នៅក្នុងវិទ្យាល័យមានអគារសិក្សា៣ខ្នងដែលក្នុងនោះ អគារសិក្សាចំនួន ១ខ្នងមានកម្ពស់ ៣ជាន់ មានបន្ទប់ចំនួន ២៤ (ជាអំណោយដ៏ថ្លៃថ្លារបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**) អគារទីចាត់ការ ១ខ្នង មាន ៣បន្ទប់ ដែលមានបន្ទប់ផ្ដល់សេវាចំនួន១ បន្ទប់សម្រាប់បុគ្គលិកអប់រំចំនួន១ និងបណ្ណាល័យចំនួន១ អន្តេវាសិកដ្ឋានមាន ៣ខ្នង ផ្ទះសំណាក់គ្រូបង្រៀនមានមួយខ្នងមាន ៣បន្ទប់ អាហារដ្ឋានមាន ១កន្លែង។ នៅក្នុងបរិវេណវិទ្យាល័យមានសួនច្បារសួនជីវៈចម្រុះចំនួន១ មានទីធ្លាសម្រាប់លេងកីឡា ដែលនៅក្នុងនោះមានតារាងបាល់បោះចំនួន១ តារាងបាល់ទាត់ចំនួន១ តារាងបាល់ទះចំនួន១ មានបន្ទប់ទឹកចំនួន ៤១បន្ទប់ មានបង់អង្គុយចំនួន ១២ឈុត មានទីលានសម្រាប់ចំណតយានជំនិះ បុគ្គលិកអប់រំ និងសិស្សដាច់ដោយឡែកពីគ្នា។ សំណង់ហេដ្ឋារចនាសម្ព័ន្ធនីមួយៗមានបំពាក់នូវស្លាកឈ្មោះសម្គាល់អង្គភាពទទួលបន្ទុកការងារដូចជា អគារ (A, B, C, ...) ទីចាត់ការ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ឬបណ្ណាល័យជាដើម។ គណៈគ្រប់គ្រងសាលារៀនបានរៀបចំឱ្យមានផ្លូវចាក់បេតុងសម្រាប់

ដើរឆ្លងកាត់ពីអគារមួយទៅអគារមួយ។ បន្ថែមពីលើនេះ នៅក្នុងវិទ្យាល័យមានរៀបចំប្លង់វិទ្យាល័យ និងស្លាកសញ្ញាចង្អុលបង្ហាញទិសដៅទៅកាន់អគារនីមួយៗ និងផ្នែកផ្សេងៗដែលត្រូវបានបិទនៅតាមបរិវេណវិទ្យាល័យ ដើម្បីបង្កលក្ខណៈងាយស្រួលដល់មាតាបិតា និងអ្នកអាណាព្យាបាល ឬសិស្សានុសិស្ស ដែលទើបបានមកចុះឈ្មោះចូលរៀនថ្មី និងសាធារណជនក្នុងការស្វែងរកទៅតាមតម្រូវការ។ ដើម្បីរក្សាសុវត្ថិភាពសិស្ស និងបុគ្គលិកអប់រំវិទ្យាល័យបានសាងសង់របងថ្មព័ទ្ធជុំវិញ និងមានពាក្យស្លោកអប់រំនានាបានបិទនៅតាមដើមឈើ អគារ និងបន្ទប់រៀននីមួយៗដើម្បីជាសារអប់រំបន្ថែម។

រូបភាពទី១÷ ការប្រជុំមាតាបិតាសិស្សដើម្បីផ្សព្វផ្សាយព័ត៌មាន

រូបភាពទី២÷ ក្តារខៀនព័ត៌មាន និងគំនូសសញ្ញាបង្ហាញផ្លូវ

៣.២.១.៣. ការយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា

ក. ការរៀបចំបដិសណ្ឋារកិច្ច

គណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំ និងសិស្សានុសិស្សទាំងអស់មានភាពរួសរាយរាក់ទាក់ មានអាកប្បកិរិយា ព្រមទាំងពាក្យសំដីសមរម្យ ដែលត្រូវបានស្តែងតាមរយៈការសំពះជម្រាបសួរ ព្រមទាំងសាកសួរ និងផ្តល់ព័ត៌មាននៅពេលមានភ្ញៀវ ឬសាធារណជនអញ្ជើញចូលមកដល់ក្នុងបរិវេណវិទ្យាល័យ។ ថ្វីបើវិទ្យាល័យពុំបានបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីស្តង់ដានៃការធ្វើបដិសណ្ឋារកិច្ចទទួលអ្នកប្រើប្រាស់សេវាក៏ដោយ ប៉ុន្តែវិទ្យាល័យបានអនុវត្តជាក់ស្តែងនូវកាយវិការ និងឃ្លាប្រយោគនៅពេលទទួលអ្នកប្រើប្រាស់សេវាដូចជា "លើកដៃសំពះ និងសូមជម្រាបសួរដោយ ទឹកមុខញញឹម" "បង លោកពូ អ្នកមីង អញ្ជើញមកវិទ្យាល័យពេជ្រចិន្តាមានការអ្វីដែរ?"។ ចំណុចមួយដែលគួរកត់ចំណាំ និងកោតសរសើរគឺវិទ្យាល័យបានបង្កើតឱ្យមានស្តង់ដាបដិសណ្ឋារកិច្ចថ្មីមួយសម្រាប់វិទ្យាល័យគឺទាំងលោកនាយក លោកនាយករង លោកគ្រូ អ្នកគ្រូបង្រៀនបានរៀបចំដាក់វេនគ្នាជាប្រចាំឈររង់ចាំទទួលសិស្សានុសិស្សនៅខាងមុខខ្លោងទ្វារវិទ្យាល័យរង់ចាំទទួលស្វាគមន៍សិស្សនៅរៀងរាល់ពេលព្រឹក ដោយកាយវិការលើកដៃសំពះទទួលស្វាគមន៍ និងសួរសុខទុក្ខសិស្សដើម្បីបង្ហាញនូវភាពយកចិត្តទុកដាក់ រាក់ទាក់ និងស្និទ្ធស្នាល ហើយទិដ្ឋភាពបែបនេះកម្រឃើញមានអនុវត្តនៅក្នុងគ្រឹះស្ថានសិក្សាអប់រំសាធារណៈជាទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ដើម្បីសម្រួលដល់ការណាត់ជួបរបស់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ មាតាបិតានិងអ្នកអាណាព្យាបាលសិស្ស សហគមន៍ និងសាធារណៈជនដែលអញ្ជើញមកពីខាងក្រៅវិទ្យាល័យបានជ្រើសរើស និងរៀបចំយកបន្ទប់របស់លោកនាយក និងនាយករងវិទ្យាល័យធ្វើជាកន្លែងសម្រាប់ផ្តល់ព័ត៌មាន និងផ្តល់ការបំភ្លឺផ្សេងៗពាក់ព័ន្ធនឹងសេវានានារបស់វិទ្យាល័យ។ ចំពោះការណាត់ជួបអ្នកទទួលសេវាអាចណាត់ជួបដោយផ្ទាល់ភ្លាមៗ ឬទៅតាមពេលវេលាណាត់ជួបសមស្របណាមួយទៅតាមក្នុងករណីនីមួយៗ។

ជំពូកទី៣

ជាក់ស្តែងក្នុងរយៈពេលកន្លងមក គណៈគ្រប់គ្រងសាលារៀនបានដើរតួនាទីជាអ្នកផ្តល់ព័ត៌មាន និងផ្តល់ការបំភ្លឺផ្សេងៗដល់អ្នកប្រើប្រាស់សេវា និងសាធារណៈជនដែលអញ្ជើញចូលមកទស្សនកិច្ចនៅក្នុងបរិវេណវិទ្យាល័យ ក្នុងករណីដែលលោកនាយក ឬលោកនាយករងអវត្តមាន បុគ្គលិកអប់រំដែលនៅប្រចាំការនៅទីនោះត្រូវបានចាត់តាំងឱ្យទទួលបំពេញការងារជំនួស។

បុគ្គលិកអប់រំ និងសិស្សទាំងអស់ស្លៀកពាក់សមរម្យ មានឯកសណ្ឋានសម្រាប់សម្គាល់អត្តសញ្ញាណវិទ្យាល័យ ដោយមានពាក់ស្លាកឈ្មោះ ឬប័ណ្ណសម្គាល់ខ្លួនជាប្រចាំនៅក្នុងពេលបំពេញការងារ និងនៅក្នុងម៉ោងបង្រៀន និងរៀននៅតាមថ្នាក់រៀនទីមួយៗ។ ដោយឡែក សម្រាប់ឯកសណ្ឋានរបស់សិស្សានុសិស្ស វិទ្យាល័យបានតម្រូវឱ្យសិស្សពាក់ស្លាកឈ្មោះដោយប្រើពណ៌ខ្សែសម្គាល់ខុសគ្នាទៅតាមកម្រិតថ្នាក់ ក្នុងនោះបានធ្វើការបែងចែកស្លាកឈ្មោះមានខ្សែពណ៌ខៀវសម្រាប់សម្គាល់សិស្សដែលកំពុងរៀននៅមធ្យមសិក្សាទុតិយភូមិ និងស្លាកឈ្មោះដែលមានខ្សែពណ៌ក្រហមសម្រាប់សម្គាល់សិស្សកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ។ ម្យ៉ាងទៀត វិទ្យាល័យបានប្រជុំសម្រេចឯកភាពគ្នាកំណត់នូវការស្លៀកពាក់ឯកសណ្ឋានប្រចាំថ្ងៃសម្រាប់បុគ្គលិកអប់រំទាំងអស់ចំនួន៧ ពណ៌ខុសៗគ្នានៅក្នុងបំពេញការងារនៅក្នុងវិទ្យាល័យ។ ឯកសណ្ឋានពណ៌លឿងសម្រាប់ថ្ងៃចន្ទ ពណ៌ស្វាយសម្រាប់ថ្ងៃអង្គារ ពណ៌ស៊ីលៀបសម្រាប់ថ្ងៃពុធ ពណ៌បៃតងចាស់សម្រាប់ថ្ងៃព្រហស្បតិ៍ ពណ៌ខៀវសម្រាប់ថ្ងៃសុក្រ ពណ៌ឈាមជ្រូកសម្រាប់ថ្ងៃសៅរ៍ និងពណ៌ស សម្រាប់ពិធីបុណ្យផ្សេងៗ។ ក្នុងការចូលរួមបង្កើតឱ្យមានស្តង់ដាឯកសណ្ឋានសិស្សប្រកបដោយសោភ័ណភាព មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ក៏ដូចជាថ្នាក់ដឹកនាំវិទ្យាល័យ និងសហគមន៍បានឯកភាពគ្នាដោយស្ម័គ្រចិត្តរៀបចំឯកសណ្ឋានសិស្សអាវពណ៌ស សំពត់បត់សម្រាប់សិស្សស្រី និងខោពណ៌ខៀវសម្រាប់សិស្សប្រុស ពាក់ស្បែកជើងបាតាពណ៌ស និងកាត់សក់ខ្លីសម្រាប់សិស្សប្រុស និងកាត់សក់ត្រឹមស្មាសម្រាប់សិស្សស្រី និងគ្មានការលាបពណ៌សក់។ នៅក្នុងថ្នាក់រៀន វិទ្យាល័យតម្រូវឱ្យសិស្សប្រើស្បែកជើងផ្ទាត់ពណ៌ស។ ចំពោះ

ឯកសណ្ឋានសម្រាប់ហាត់ និងលេងកីឡា វិទ្យាល័យបានកំណត់ប្រើឯកសណ្ឋានចំនួនពីរពណ៌ ដោយកំណត់យកឯកសណ្ឋានកីឡាពណ៌ខៀវសម្រាប់សម្គាល់សិស្សមធ្យមសិក្សាទុតិយភូមិ និងឯកសណ្ឋានកីឡាពណ៌ក្រហមសម្រាប់សម្គាល់សិស្សមធ្យមសិក្សាបឋមភូមិ ដោយមានបោះពុម្ពអក្សរឈ្មោះ «វិទ្យាល័យពេជ្រចិន្ដា» នៅលើអាវទៀតផង។

ចំពោះសិស្សដែលគ្រួសារមានជីវភាពក្រីក្រ គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន និងសហគមន៍បានរួមសហការគ្នាជួយគៀរគរថវិកា និងសម្ភារៈដើម្បីជួយឧបត្ថម្ភ ដោយក្នុងនោះផ្ដល់ជូននូវឯកសណ្ឋានសម្រាប់ការសិក្សាចំនួន ១ឈុត ក្នុងនោះមានឯកសណ្ឋានសម្រាប់ការរៀន និងឯកសណ្ឋានសម្រាប់ការហាត់ និងលេងកីឡា សម្ភារៈសម្រាប់ការសិក្សា មធ្យោបាយធ្វើដំណើរ (កង់ចំនួន១) គ្រឿងឧបភោគបរិភោគ និងអន្តេវាសិកដ្ឋានសម្រាប់ស្នាក់នៅបន្តការសិក្សាទៀតផង។

ជំពូកទី៣

រូបភាពទី៣ ÷ ភាពយកចិត្តទុកដាក់ចំពោះអ្នកប្រើប្រាស់សេវា

រូបភាពទី៤៖ ឯកសណ្ឋានបុគ្គលិកអប់រំ និងសិស្ស

ខ. យន្ដការសម្របសម្រួល

វិទ្យាល័យមានការយកចិត្តទុកដាក់ចំពោះអ្នកប្រើប្រាស់សេវាតាមរយៈការផ្ដល់ព័ត៌មាន និងសម្រួលការលំបាករបស់អ្នកប្រើប្រាស់សេវា តាមទិដ្ឋភាពជាក់ស្ដែង។ គណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រងសាលារៀន បានចាត់ចែងឱ្យមានបុគ្គលិកអប់រំ ឬក្រុមការងារមួយចំនួនសម្រាប់ជួយសម្រួលដល់ការលំបាករបស់អ្នកប្រើប្រាស់សេវា ដែលជាជនងាយរងគ្រោះ និងសម្រាប់ផ្ដល់ការប្រឹក្សាយោបល់ ការបំភ្លឺ ឬឆ្លើយតបភ្លាមៗ ទៅនឹងក្ដីកង្វល់របស់អ្នកប្រើប្រាស់សេវាទៅតាមទិដ្ឋភាពជាក់ស្ដែង។

ជនងាយរងគ្រោះមានដូចជា៖

- មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សដែលជាជនក្រីក្រ ឬមានទីលំនៅឆ្ងាយពីវិទ្យាល័យ ហើយពុំមានលទ្ធភាពបញ្ជូនកូនឱ្យមករៀនបាន។ វិទ្យាល័យបានផ្ដល់អាទិភាពឱ្យបានស្នាក់នៅក្នុងអន្ដេវាសិកដ្ឋាន ដោយគ្រាន់តែតម្រូវឱ្យបំពេញនូវព័ត៌មានមួយចំនួនដែលជាលក្ខខណ្ឌកំណត់ ដោយមានការបញ្ជាក់អះអាងពីអាជ្ញាធរមូលដ្ឋាននៃលំនៅដ្ឋានរបស់សិស្ស
- មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សដែលជាអនក្ខរជនចាស់ជរា ឬពិការ វិទ្យាល័យជួយសម្រួលក្នុងការទទួលបានព័ត៌មានរបស់គាត់ ដោយចាត់តាំងក្រុមប្រឹក្សាយុវជនរបស់វិទ្យាល័យឱ្យចុះទៅសួរសុខទុក្ខដោយផ្ទាល់ដល់ខ្នងផ្ទះរបស់គាត់ដើម្បីជូនព័ត៌មានអំពីការសិក្សារបស់កូនចៅរបស់ពួកគាត់ក្នុងករណីមានបញ្ហាមករៀនមិនទាន់ម៉ោងជាញឹកញាប់ ឬអវត្តមានជាច្រើនដង។ល។
- សិស្សដែលជួបបញ្ហាដោយសារពិការភាព ដូចជា ខ្សោយគំហើញ ពិបាកស្ដាប់និងមានពិការភាពផ្សេងទៀត គោលការណ៍របស់វិទ្យាល័យគឺតម្រូវឱ្យលោកគ្រូ អ្នកគ្រូប្រចាំថ្នាក់រៀបចំឱ្យសិស្សទាំងនោះបានអង្គុយនៅតុកៅអីជួរមុខ។

សមាសភាពនៃក្រុមការងារទាំងនោះរួមមាន៖

- គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការវិទ្យាល័យពេជ្រចិន្ដា

- ប្រធានក្រុមបច្ចេកទេសមុខវិជ្ជា
- ក្រុមការងារសង្គ្រោះបឋម
- ក្រុមការងារទទួលបន្ទុកបណ្ណាល័យ
- គ្រូមគ្គុទេសក៍ប្រឹក្សាអាជីព
- ក្រុមការងារទទួលបន្ទុកអន្តេវាសិកដ្ឋានសិស្ស
- ក្រុមការងារគ្រប់គ្រងបន្ទប់ និងការបណ្តុះបណ្តាលកុំព្យូទ័រ
- ក្រុមប្រឹក្សាយុវជន
- ក្លឹបសិក្សាតាមមុខវិជ្ជា
- ក្រុមកាយវិទ្ធិ
- ក្រុមយុវជនស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា

ទន្ទឹមនឹងនេះ វិទ្យាល័យក៏បានសាងសង់ជម្រាលនៅតាមអគារទាំងអស់របស់វិទ្យាល័យដើម្បីជួយសម្រួលដល់ការលំបាករបស់សិស្សដែលមានពិការភាពផងដែរ។

៣.២.១.៤. ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ

ក. ការផ្តល់សេវាតាមគោលការណ៍កំណត់

វិទ្យាល័យពេជ្រចិន្តាផ្តល់សេវាអប់រំដោយគ្មានការរើសអើង មានគណនេយ្យភាព និងការទទួលខុសត្រូវចំពោះការផ្តល់សេវារបស់ខ្លួនស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួនដែលបានចែងក្នុងបទដ្ឋានគតិយុត្តជាធរមាន។ សេវាដែលផ្តល់ដោយវិទ្យាល័យរួមមាន÷ ការចុះឈ្មោះចូលរៀន ការប្រឡងឡើងថ្នាក់ ការប្រឡងឡើងវិញ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ការប្រឡងមធ្យមសិក្សាទុតិយភូមិ ការធ្វើលិខិតបញ្ជាក់ការសិក្សា ការបញ្ជាក់លិខិតផ្ទេរការសិក្សារបស់សិស្ស។ ចំពោះសេវាទាំងនេះ វិទ្យាល័យមិនតម្រូវឱ្យមានការយកកម្រៃសេវានោះទេ រីឯរយៈពេលនៃការផ្តល់សេវា គឺផ្តល់បានឆាប់ និងមានការទទួលខុសត្រូវ។

ក្នុងការចុះឈ្មោះចូលរៀន វិទ្យាល័យបានបញ្ជូនបុគ្គលិកអប់រំរបស់ខ្លួនទៅជួបដោយ

ផ្ទាល់ជាមួយនាយកសាលា គ្រូបង្រៀន និងសិស្សនៅតាមសាលាបឋមសិក្សាចំណុះដើម្បីស្រង់ស្ថិតិចំនួនសិស្ស និងណែនាំសិស្សពីការផ្ទេរភូមិសិក្សាមករៀននៅវិទ្យាល័យពេជ្រចិន្ដា ព្រមទាំងបានធ្វើតេស្ដវាយតម្លៃការសិក្សាវាស់ស្ទង់សមត្ថភាពសិស្ស និងជួយបំប៉នសិស្សរៀនយឺតដែលត្រូវចូលរៀននៅវិទ្យាល័យទៀតផង។

ដើម្បីជំរុញការផ្ដល់សេវារបស់ខ្លួនឱ្យកាន់តែល្អប្រសើរ វិទ្យាល័យបានអនុវត្តការវាយតម្លៃផ្ទៃក្នុងជាទៀងទាត់(ប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ) ធ្វើឡើងដោយគណៈគ្រប់គ្រងសាលារៀន និងបុគ្គលិកអប់រំទាំងអស់ក្នុងនាមជាអ្នកផ្ដល់សេវាអប់រំ ដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងសហគមន៍។ ដើម្បីទទួលបានព័ត៌មាន ក្ដីកង្វល់ និងសំណូមពរពីអ្នកប្រើប្រាស់សេវាផ្ទាល់ វិទ្យាល័យបានបង្កលទ្ធភាពឱ្យសិស្សានុសិស្សវាយតម្លៃទៅលើការផ្ដល់សេវារបស់បុគ្គលិកអប់រំ លោកគ្រូ អ្នកគ្រូ និងចំណុចខ្វះខាតនាពេលកន្លងរបស់វិទ្យាល័យផងដែរ ដោយធ្វើឡើង តាមរយៈការសេរសេរជាលិខិតសំណូមពរដាក់នៅក្នុងប្រអប់គណនេយ្យភាព។ បន្ថែមពីលើការវាយតម្លៃនៅខាងក្នុងសាលា វិទ្យាល័យបានជំរុញឱ្យមានការវាយតម្លៃពីខាងក្រៅជាទៀងទាត់ដោយមានការចូលរួមពីមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស សហគមន៍ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវា។ ផ្អែកលើព័ត៌មាន ក្ដីកង្វល់ បញ្ហាប្រឈម និងសំណូមពរដែលទទួលបានពីការវាយតម្លៃទាំងអស់នេះ គណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រងសាលារៀនបានរៀបចំប្រជុំ និងធ្វើផែនការកែលម្អការផ្ដល់សេវារបស់ខ្លួនភ្លាម ដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយគ្រប់ភាគីពាក់ព័ន្ធ ដូចជាមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស សហគមន៍ អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍក្នុងវិស័យអប់រំជាដើម។

លទ្ធផលនៃការខិតខំប្រឹងប្រែងកែលម្អការផ្ដល់សេវាជូនសិស្សានុសិស្ស និងប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង វិទ្យាល័យពេជ្រចិន្ដាទទួលបាននូវវិញ្ញាបនបត្រ និងប័ណ្ណសរសើរជាច្រើនពីក្រសួង និងស្ថាប័ននានារួមមាន៖

- ជ័យលាភីលេខ១ នាយកសាលារៀនល្អ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា

២០១៨-២០១៩
- ជ័យលាភីលេខ៣ សាលារៀនស្អាត ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៨-២០១៩
- ជ័យលាភីលេខ៩ គ្រូបង្រៀនល្អ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៧-២០១៨
- ជ័យលាភីចំណាត់ថ្នាក់សាលារៀនមេត្រីបរិស្ថានអាស៊ាន ក្រសួងបរិស្ថាន ឆ្នាំសិក្សា ២០១៨-២០១៩
- ជ័យលាភីចំណាត់ថ្នាក់លេខ១ អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំសិក្សា២០១៨-២០១៩
- ជ័យលាភីលេខ៣ សាលារៀនស្អាត ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៧-២០១៨។

ខ. ផ្តល់សេវាមានអភិបាលកិច្ចល្អ

វិទ្យាល័យពេជ្រចិន្តាបានអនុវត្តមុខងារ និងភារកិច្ចដោយគោរពទៅតាមការកំណត់របស់រាជរដ្ឋាភិបាល និងតាមអនុក្រឹត្យ ប្រកាស សេចក្តីណែនាំ និងសេចក្តីជូនដំណឹងផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ព្រមទាំងបានបែងចែកតួនាទី ភារកិច្ច និងការទទួលខុសត្រូវទៅដល់បុគ្គលិកអប់រំទាំងអស់នៅក្នុងវិទ្យាល័យស្របតាមលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានរួមមាន÷

- អនុក្រឹត្យស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
- សេចក្តីណែនាំលេខ ២៥៦ ស្តីពីនិយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យ
- សេចក្តីណែនាំលេខ ២០ អយក សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ស្តីពី

និយាមប្រើប្រាស់បុគ្គលិកអប់រំ។ ល។

ម៉្យាងទៀត ដើម្បីធានាការប្រើប្រាស់ធនធាននិងថវិការបស់វិទ្យាល័យប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ថ្នាក់ដឹកនាំវិទ្យាល័យបានអនុវត្តនូវយន្តការ "**តម្លាភាព**" និង "**ការចំណាយបានទទួលផល**" គឺមានន័យថា គ្រប់ការចំណាយធ្វើឡើងដើម្បីអភិវឌ្ឍវិទ្យាល័យ និងចំណូលនានាដែលទទួលបានពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សហគមន៍ ឬពីប្រភពស្របច្បាប់នានា ត្រូវឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង មានការកត់ត្រាចំណាយ ចំណូលច្បាស់លាស់ទៅតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងមានការចូលរួមពិគ្រោះយោបល់ និងទទួលបានការឯកភាពពីមតិភាគច្រើននៃសមាជិកចូលរួមក្នុងអង្គប្រជុំមានជាអាទិ៍ គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំ មាតាបិតា អ្នកអាណាព្យាបាលសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋានទៀតផង។

៣.២.១.៥. យន្តការព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា

ដើម្បីទទួលបានព័ត៌មានត្រឡប់ពីអ្នកប្រើប្រាស់សេវា ក្នុងការកែលម្អគុណភាពនៃការផ្តល់សេវារបស់ខ្លួនឱ្យកាន់តែឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សានុសិស្ស មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស និងសហគមន៍ វិទ្យាល័យបានបង្កើតនូវមធ្យោបាយមួយចំនួន ដើម្បីផ្តល់លទ្ធភាពដល់អ្នកប្រើប្រាស់សេវាក្នុងការចូលរួមផ្តល់មតិយោបល់កែលម្អ បង្ហាញនូវក្តីកង្វល់ ភាពខ្វះចន្លោះ ឬបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការផ្តល់សេវារបស់ខ្លួន។

មធ្យោបាយដែលវិទ្យាល័យបានប្រើសម្រាប់ទទួលព័ត៌មានត្រឡប់ពីអ្នកប្រើប្រាស់សេវារួមមាន÷

- ប្រអប់គណនេយ្យភាព នៅក្នុងបរិវេណវិទ្យាល័យមានប្រអប់គណនេយ្យភាពចំនួនពីរ
- ការរៀបចំកម្មវិធីវេទិកាសាធារណៈ (ជំនួបរវាងប្រជាពលរដ្ឋ មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ជាមួយអាជ្ញាធរដែនដី និងតំណាងវិទ្យាល័យ)

- ទំព័រហ្វេសបុករបស់សាលារៀន «វិទ្យាល័យពេជ្រចិន្តា» និងតេឡេក្រាម «វិទ្យាល័យពេជ្រចិន្តា»
- ទីកន្លែងទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា (បន្ទប់ផ្តល់សេវា)
- កិច្ចប្រជុំជាប្រចាំជាមួយមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស (រៀងរាល់បីខែម្តង)
- កិច្ចប្រជុំជាប្រចាំជាមួយសហគមន៍ (រៀងរាល់បីខែម្តង និងតាមការចាំបាច់)
- សហគមន៍ ក្រុមប្រឹក្សាយុវជន លោកនាយក នាយករង ដែលតែងតែចុះសួរសុខទុក្ខ និងស្វែងយល់ពីស្ថានភាពរស់នៅរបស់សិស្ស ដែលអវត្តមានរយៈពេលច្រើនថ្ងៃ ឬសិស្សដែលបោះបង់ការសិក្សាដោយមូលហេតុសុខភាព និងជីវភាពខ្វះខាតឱ្យបន្តការសិក្សាជាដើម។

ទស្សនទានរបស់វិទ្យាល័យគឺការផ្តល់ឱកាស និងបង្កលក្ខណៈជូនអ្នកប្រើប្រាស់សេវាក្នុង ការផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា ដើម្បីកែលម្អចំណុចខ្វះខាតរបស់ខ្លួនក្នុងការផ្តល់សេវាអប់រំឱ្យបានកាន់តែល្អប្រសើរជាងមុន។ ដើម្បីធានានូវការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះការផ្តល់សេវារបស់ខ្លួន វិទ្យាល័យពេជ្រចិន្តាបានពិគ្រោះយោបល់ និងសហការជាមួយសហគមន៍ អាជ្ញាធរមូលដ្ឋាន និងបុគ្គលិកអប់រំទាំងអស់ក្នុងការរៀបចំយន្តការឆ្លើយតបទៅនឹងមតិយោបល់ បណ្តឹងតវ៉ា ឬបញ្ហានានាទៅតាមករណី និងទិដ្ឋភាពជាក់ស្តែងដូចជាការបើកប្រអប់គណនេយ្យភាពរៀងរាល់ត្រីមាស ដោយមានការចូលរួមពីភាគីពាក់ព័ន្ធរួមមាន គណៈគ្រប់គ្រងសាលារៀន ក្រុមការងារគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការវិទ្យាល័យ ប្រធានក្រុមបច្ចេកទេសមុខវិជ្ជានីមួយៗរបស់វិទ្យាល័យ និងក្រុមការងារទទួលបន្ទុកអន្តេវាសិកដ្ឋានសិស្ស។ល។

ជាមួយគ្នាផងដែរ វិទ្យាល័យបានរៀបចំយន្តការ មធ្យោបាយ និងវិធានការនានាបន្ទាប់ពីទទួលបានព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ាពីអ្នកប្រើប្រាស់សេវា ដើម្បីត្រៀមដោះស្រាយចំពោះបញ្ហា ក្តីកង្វល់ សំណូមពរ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាក្នុងករណីដែលការផ្តល់សេវានៅមិនបានឆ្លើយតបទៅនឹងគោលការណ៍កំណត់របស់វិទ្យាល័យ

ដែលបានផ្សព្វផ្សាយ និងគោរពតៅតាមបទដ្ឋានគតិយុត្តជាធរមានរបស់រាជរដ្ឋាភិបាល ក៏ដូចជាគោលនយោបាយ ប្រកាស និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងអាជ្ញាធរដែនដី។

រហូតមកដល់ពេលនេះ វិទ្យាល័យពុំដែលទុកចោល ឬមិនដោះស្រាយនូវបញ្ហាដែលបានលើកឡើង ឬស្នើមកឡើយ។ តាមការសង្កេតកន្លងមក ភាគច្រើននៃព័ត៌មានទាំងនោះគឺច្រើនតែជាសំណូមពរ ជាជាងបណ្តឹងតវ៉ា។ សំណូមពរទាំងនោះមានដូចជា សិស្សស្នើសុំលោកគ្រូ អ្នកគ្រូដែលបង្រៀនមុខវិជ្ជាឯកទេសជួយបង្រៀនបន្ថែមម៉ោង និងការស្នើសុំធ្វើទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេសដើម្បីផ្លាស់ប្តូរបទពិសោធន៍ល្អៗ នៃការទទួលបានជោគជ័យក្នុងការសិក្សា។ ដើម្បីឆ្លើយតបទៅនឹងសំណូមពរ និងក្តីកង្វល់ផ្សេងៗរបស់អ្នកប្រើប្រាស់សេវា វិទ្យាល័យបានរៀបចំឱ្យមានផែនការកែលម្អគុណភាពសេវានិងផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់រយៈពេលខ្លី និងមធ្យម ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដោយផ្អែកទៅលើលទ្ធផលនៃការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំជាទៀងទាត់ និងផ្អែកលើព័ត៌មានដែលទទួលបានពីសិស្សានុសិស្ស មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស សហគមន៍ និងដៃគូអភិវឌ្ឍជាដើម។

៣.២.២. ស្តង់ដានៃការផ្តល់សេវាអប់រំវិទ្យាល័យពោធិ៍ចិន្តា

ចាប់តាំងពីឆ្នាំបង្កើតរហូតមកដល់បច្ចុប្បន្ន វិទ្យាល័យបានធ្វើការកែលម្អរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រង និងស្តង់ដាផ្តល់សេវាអប់រំជាបន្តបន្ទាប់។ នៅឆ្នាំសិក្សា ២០១៧-២០១៨ វិទ្យាល័យពោធិ៍ចិន្តាបានទទួលយកបរិបទបំពេញការងារបែបថ្មីដោយអនុវត្តតាមរបៀប "ការគ្រប់គ្រងតាមសាលារៀន" គាំទ្រគោលនយោបាយវិមជ្ឈការអប់រំ រហូតបានប្រែក្លាយខ្លួនជាអង្គភាពផ្តល់សេវាសាធារណៈគំរូ។ ផ្នែកនេះនឹងបង្ហាញពីភាពលេចធ្លោមួយចំនួនអំពីការធ្វើកំណែទម្រង់រចនាសម្ព័ន្ធដឹកនាំគ្រប់គ្រង តួនាទីភារកិច្ច និងការទទួលខុសត្រូវ និងការសម្រេចបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព ដែលវិទ្យាល័យបានប្រតិបត្តិកន្លងមក។

៣.២.២.១. ការដឹកនាំ និងការគ្រប់គ្រងសាលារៀន

ក. គណៈកម្មការគ្រប់គ្រងសាលារៀន

ខែតុលា ឆ្នាំ២០១៨ គណៈកម្មការគ្រប់គ្រងសាលារៀន[៥] ហៅកាត់ថា **គ.គ.ស** ដែលមានអាណត្តិមួយឆ្នាំ បានបង្កើតឡើងជំនួសឱ្យគណៈកម្មការទ្រទ្រង់សាលារៀនចាស់ ដោយទទួលបានការគាំទ្រពីការិយាល័យអប់រំ យុវជន និងកីឡាស្រុកភ្នំព្រឹក និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង។ **គ.គ.ស** ដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងក្របខ័ណ្ឌការងារសាលារៀនមានប្រសិទ្ធភាពនៃការគ្រប់គ្រងតាមសាលារៀន ដែលតម្រូវឱ្យសាលារៀន សហគមន៍ មាតាបិតា គ្រូបង្រៀន សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធនានា អាចធ្វើការជាមួយគ្នា អាចធ្វើការសម្រេចចិត្តរួមគ្នា ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ខ្លួន។ ជាមួយគ្នានេះ **គ.គ.ស** ដើរតួជាម្ចាស់សាលារៀនផង និងតំណាងសហគមន៍ផង ដើម្បីធានាបាននូវគុណភាពនៃការរៀន និងបង្រៀននៅក្នុងសាលារៀន។ **គ.គ.ស** ជារចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងថ្មីរបស់សាលារៀនដែលបំពេញការងារកាន់តែមានប្រសិទ្ធភាព កាន់តែមានភាពបត់បែន ការទទួលខុសត្រូវខ្ពស់ និងជាភ្នាក់ងារទាក់ទាញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធស្របតាមគោលនយោបាយវិមជ្ឈការអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

គ.គ.ស បង្កើតឡើងដោយឆ្លងកាត់ដំណាក់កាលសំខាន់ៗ ដូចខាងក្រោម÷

១. ផ្សព្វផ្សាយឯកសារការងារគណៈកម្មការគ្រប់គ្រងសាលារៀនទៅសហគមន៍

២. ការដាក់បេក្ខភាព និងការអញ្ជើញចូលរួមជាបេក្ខភាពរបស់គណៈកម្មការគ្រប់គ្រងសាលារៀន

៣. ការផ្សព្វផ្សាយសាវតារ និងការប្តេជ្ញាចិត្តរបស់បេក្ខភាពគណៈកម្មការគ្រប់គ្រងសាលារៀន

៤. ការបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកមានសិទ្ធិ

[៥] គណៈកម្មការគ្រប់គ្រងសាលារៀន និងរបៀបបង្កើតគណៈកម្មការ នៅទំព័រ១៦ នៃសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន-គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា ឆ្នាំ២០១៨-នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា

ជំពូកទី៣

បោះឆ្នោត

៥. ការប្រកាសទទួលស្គាល់គណៈកម្មការគ្រប់គ្រងសាលារៀន។

នៅថ្ងៃសុក្រ ១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ គណៈកម្មការគ្រប់គ្រងសាលារៀននៃវិទ្យាល័យពេជ្រចិន្តា បានបង្កើតឡើងតាមរយៈការបោះឆ្នោតដោយផ្ទាល់ពីបុគ្គលិកអប់រំ អាជ្ញាធរដែនដី និងសហគមន៍ ដោយមានការទទួលស្គាល់ជាផ្លូវការពីការិយាល័យ អប់រំ យុវជន និងកីឡាស្រុកភ្នំព្រឹក។ គណៈកម្មការគ្រប់គ្រងសាលារៀន មានសមាសភាព ១៤រូប ស្រី ៤រូប តំណាងឱ្យសាលារៀន និងសហគមន៍ទាំងមូល (តំណាងភាពជាម្ចាស់សាលារៀន) និងបានបោះឆ្នោតជាថ្មីនៅឆ្នាំបន្ទាប់ សម្រាប់ដឹកនាំគ្រប់គ្រង និងអភិវឌ្ឍសាលារៀន ឱ្យប្រែក្លាយជាសាលារៀនឆ្នើមលេចធ្លោនៅក្នុងកម្រិតជាតិ និងកម្រិតតំបន់តាមរយៈការសម្រេចបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព។

តួនាទី ភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗរបស់គណៈកម្មការគ្រប់គ្រងសាលារៀនមាន[៦]÷

១. រៀបចំ ផ្សព្វផ្សាយ និងអនុវត្តផែនការកែលម្អសាលារៀនជាមួយអ្នកពាក់ព័ន្ធ

២. ពិនិត្យតាមដានការអនុវត្តការគ្រប់គ្រងតាមសាលារៀនតាមរយៈការប្រជុំជាប្រចាំជាមួយគណៈគ្រប់គ្រងសាលារៀនដោយត្រួតពិនិត្យមើលលើ (១)ការគ្រប់គ្រងរដ្ឋបាលសាលារៀន (២)ការគ្រប់គ្រងការបង្រៀន និងរៀន (៣)ការគ្រប់គ្រងហិរញ្ញវត្ថុ និង (៤)ការគ្រប់គ្រងបុគ្គលិកសិក្សា។

៣. វាយតម្លៃ និងផ្សព្វផ្សាយការអនុវត្ត និងភាពរីកចម្រើននៃការគ្រប់គ្រងតាមសាលារៀន ប្រចាំត្រីមាស និងប្រចាំឆ្នាំដល់សហគមន៍ និងស្ថាប័នពាក់ព័ន្ធ។

ការដឹកនាំគ្រប់គ្រងរបស់គណៈកម្មការគ្រប់គ្រងសាលារៀន វិទ្យាល័យពេជ្រចិន្តា បានផ្អែកលើពាក្យស្លោកថា “**សាលារៀនជារបស់សហគមន៍ សហគមន៍ដើម្បីសាលារៀន**”

[៦] របនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការទទួលខុសត្រូវគណៈកម្មការគ្រប់គ្រងសាលារៀន ឆ្នាំសិក្សា ២០១៨-២០១៩

ដែលបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីភាពជាម្ចាស់របស់ខ្លួន ដើម្បីទាក់ទាញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ក្នុងចំណោមសមាសភាពទាំងអស់នៃគណៈគ្រប់គ្រងសាលារៀនមានសមាជិក ៦រូប ទទួលភារកិច្ច និងការទទួលខុសត្រូវខ្ពស់បំផុតក្នុងការដឹកនាំគ្រប់គ្រងការអនុវត្តការងារប្រចាំថ្ងៃ៖

១. ប្រធាន៖ ទទួលបន្ទុកមើលការខុសត្រូវប្រតិបត្តិការរួម

២. អនុប្រធានទី១៖ ទទួលបន្ទុកការងារផែនការ និងការគ្រប់គ្រងថវិកាសាលារៀន ដើម្បីធានាបានការសម្រេចចិត្ត ការអនុវត្ត និងការតាមដានពីសំណាក់មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស មេក្រុម មេភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្ថាប័នពាក់ព័ន្ធទាំងអស់។

៣. អនុប្រធានទី២៖ ទទួលបន្ទុកការគ្រប់គ្រងមន្ត្រី និងបុគ្គលិកអប់រំសាលារៀន ដើម្បីធានាបានការបំពេញការងារសាលារៀនប្រកបដោយចំណេះដឹង និងមានមនសិការខ្ពស់ ដែលជាគំរូដ៏ថ្លៃថ្នូរសម្រាប់សិស្ស ប្រជាពលរដ្ឋ និងសង្គម។

៤. សមាជិក ១រូប៖ ទទួលបន្ទុកការងារចូលរួមរបស់សហគមន៍ និងអភិបាលកិច្ចសាលារៀនដើម្បីធានាបានការធ្វើការបំពេញឱ្យគ្នាទៅវិញទៅមកប្រកបដោយសាមគ្គីភាព និងប្រសិទ្ធភាពរវាងសាលារៀនជាមួយសហគមន៍ និងស្ថាប័នពាក់ព័ន្ធ។

៥. សមាជិក ១រូប៖ ទទួលបន្ទុកការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងការអភិវឌ្ឍរបស់សាលារៀនផ្អែកលើស្តង់ដាប្រសិទ្ធភាពសាលារៀន ដើម្បីផ្សព្វផ្សាយផលសម្រេចឱ្យបានទូលំទូលាយដល់សហគមន៍ និងស្ថាប័នក្នុងមូលដ្ឋាន និងក្រៅមូលដ្ឋាន។

៦. សមាជិក ១រូប៖ ទទួលបន្ទុកគណនេយ្យភាពសាលារៀន ដើម្បីឱ្យសិស្ស មាតាបិតា មេក្រុម មេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ និងស្ថាប័នពាក់ព័ន្ធទាំងក្នុង និងក្រៅសាលារៀនមានជំនឿ និងមានទំនុកចិត្ត ព្រមទាំងឱ្យតម្លៃខ្ពស់ដល់សាលារៀន។

ចំណែកសមាជិកដទៃទៀតមានភារកិច្ច និងការទទួលខុសត្រូវ គាំទ្រដល់សមាជិកស្នូលទាំង ៦រូប ដែលមានចែងលម្អិតនៅក្នុងសៀវភៅការងារគណៈកម្មការគ្រប់គ្រងសាលារៀនពេជ្រចិន្តា។

រឿងទី២÷ **សហគមន៍ល្អ គ្រូល្អ សិស្សល្អ សាលារៀនមានការអភិវឌ្ឍ**

"***សាលាជារបស់សហគមន៍ សហគមន៍ដើម្បីសាលារៀន***" ជាទស្សនៈវិស័យរបស់គណៈកម្មការគ្រប់គ្រងសាលារៀននៃវិទ្យាល័យពេជ្រចិន្តា ដែលមានលោក **ភឿន ឡូត**[៧] ជាប្រធាន គ.គ.ស សម្រាប់ប្រមូលគំនិត យោបល់ ធនធាន និងការចូលរួមយ៉ាងសកម្មរបស់សហគមន៍ និងអ្នកពាក់ព័ន្ធ។ រាល់សកម្មភាពចូលរួមរបស់សហគមន៍បានបង្ហាញភាពជាម្ចាស់របស់សាលារៀនដែលមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំគ្រប់គ្រង និងតម្រង់ទិសសាលារៀនឱ្យប្រតិបត្តិតាមគុណតម្លៃ និងបេសកកម្មឆ្ពោះទៅរក "***សហគមន៍ល្អ គ្រូល្អ សិស្សល្អ សាលារៀនមានការអភិវឌ្ឍ***"។ ដើម្បីសម្រេចបានតាមគោលដៅដែលចង់បាន សមាជិក គ.គ.ស គ្រប់រូបបានបន្តសកម្មភាពយ៉ាងសកម្ម ក្នុងការអភិវឌ្ឍវិទ្យាល័យពេជ្រចិន្តា ក្រោមកិច្ចសហការគ្នាយ៉ាងល្អជាមួយបុគ្គលិកសិក្សា និងអ្នកពាក់ព័ន្ធ។

ការបន្តក្តីស្រមៃជាបន្តបន្ទាប់ និងឆ្លងកាត់ឧបសគ្គរាប់មិនអស់ គិតចាប់តាំងពីលោកនៅជាគណនេយ្យកររបស់គណៈកម្មការទ្រទ្រង់សាលារៀននៃអនុវិទ្យាល័យភ្នំព្រឹកដឹកនាំដោយលោកនាយក **ឯក ប៉ន** នៅឆ្នាំ២០០៣ មកបច្ចុប្បន្ន។ លោក **ភឿន ឡូត** បានសម្លឹងឃើញវែងឆ្ងាយពីតម្លៃនៃការអប់រំនិងភាពរីកចម្រើន បានជំរុញឱ្យលោកតស៊ូបញ្ចុះបញ្ចូលមាតាបិតាសិស្ស និងសហគមន៍ទាំងមូលឱ្យមើលឃើញថាការបញ្ជូនកូនចៅទៅសាលារៀន និងចំណេះវិជ្ជាជាជម្រើសដ៏ប្រសើរបំផុតតែមួយគត់សម្រាប់ពួកគាត់។ ការមើលឃើញពន្លឺអនាគត និងឱកាសថ្មីនេះ ជំរុញឱ្យសហគមន៍ទាំងមូលបានមូលមតិគ្នា ប្រែក្លាយដីចម្ការមីនត្រង់ទីតាំងវិទ្យាល័យពេជ្រចិន្តាបច្ចុប្បន្ន ឱ្យប្រែក្លាយជាថ្នាល

[៧] ប្រវត្តិរូបសង្ខេបរបស់ លោក ភឿន ឡូត ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន ឆ្នាំសិក្សា ២០១៨-២០១៩

បណ្តុះបណ្តាលធនធានមនុស្ស។ ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀនរូបនេះ មានកិច្ចសហការល្អ និងទទួលបានការគាំទ្រខ្លាំងពីសហគមន៍ និងអ្នកពាក់ព័ន្ធដោយសារបានឈរលើស្មារតីសម្ហូហភាព គឺ "សម្ហូហភាពជាអ្នកដឹកនាំ សម្ហូហភាពជាអ្នកសម្រេចចិត្ត និងបុគ្គលជាអ្នកទទួលខុសត្រូវ" បានពង្រីក និងរក្សាទំនាក់ទំនងល្អជាមួយថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងអាជ្ញាធរដែនដីក្នុងការកៀគររកមូលនិធិ និងការឧបត្ថម្ភនានាសម្រាប់អភិវឌ្ឍន៍សាលារៀន។

លោក **ភឿន ឡូត** មិនត្រឹមទទួលជោគជ័យក្នុងគ្រួសារដែលទទួលបានងារជាប្តីល្អ ឪពុកល្អ ដែលចម្លងគ្រួសារទាំងមូលចាកផុតពីភាពក្រីក្រលំបាកប៉ុណ្ណោះទេ លោកក៏ជាអ្នកជំរុញ និងនាំមកនូវភាពជោគជ័យដល់សហគមន៍ទាំងមូលរហូតមានការទទួលស្គាល់ទូទាំងប្រទេសថា សហគមន៍ខ្លាំងនៅពេជ្រចិន្តា ដែលចេះជួយគ្នា និងសាមគ្គីគ្នាជាសម្ហូហភាព។ ដើម្បីនាំមកនូវភាពជោគជ័យសម្រាប់សាលារៀន និងសហគមន៍ទាំងមូល គណៈកម្មការគ្រប់គ្រងសាលារៀនបានជ្រើសរើសយកវិធីសាស្ត្រដឹកនាំគ្រប់គ្រងមួយចំនួនដូចខាងក្រោម÷

១. ដឹកនាំគ្រប់គ្រងផ្តោតលើគោលដៅ និងមានផែនការការងារច្បាស់លាស់ជាចម្បង
   - ផែនការកែលម្អសាលារៀន និងកែលម្អបរិស្ថាន
   - ផែនការថវិកាដំណើរការសាលារៀនជាដើម

២. ចាត់ចែងភារកិច្ច និងការទទួលខុសត្រូវសម្រាប់សមាជិក និងគណៈគ្រប់គ្រងសាលារៀន
   - ចាត់ចែងក្នុងការកៀគរធនធាន និងថវិកា
   - ចាត់ចែងការងារសាងសង់ក្នុងបរិវេណសាលារៀន
   - ចាត់ចែងការងារបរិស្ថានសាលារៀនជាដើម

៣. ដឹកនាំអនុវត្តផែនការ និងសកម្មភាពនានាក្នុងសាលារៀន

- ចុះអនុវត្តផ្ទាល់ ឬដឹកនាំគ្នាក្នុងសហគមន៍ គ្រូ សិស្ស និងអ្នកពាក់ព័ន្ធធ្វើការងារសាលារៀន ដោយផ្ទាល់

៤. ប្រជុំត្រួតពិនិត្យជាប្រចាំ ដើម្បីតាមដានមើលថា
- តើផែនការអនុវត្តបានអ្វីខ្លះ?
- តើនៅមានឧបសគ្គអ្វីខ្លះដែលមិនអាចសម្រេចបានតាមផែនការ?
- ពិនិត្យផ្ទៀងផ្ទាត់ការប្រើប្រាស់ថវិកា និងធនធាននានា
- ពិនិត្យផ្ទៀងផ្ទាត់របាយការណ៍ចំណូល ចំណាយ
- រៀបចំការងារបន្តទៀតជាដើម

៥. ផ្សព្វផ្សាយលទ្ធផលការងារតាមរយៈកិច្ចប្រជុំនានា និងការបិទផ្សាយព័ត៌មានដែលធានាបាននូវគណនេយ្យភាព តម្លាភាព និងការចូលរួមដូចជា÷
- ប្រជុំជាមួយសហគមន៍
- ប្រជុំជាមួយមាតាបិតាសិស្សរៀងរាល់ ៣ខែ ម្តង
- បិទផ្សាយលទ្ធផលសិក្សារបស់សិស្ស និងសមិទ្ធផលសាលារៀនជាប្រចាំ
- ផ្សព្វផ្សាយព័ត៌មាន និងលិខិតបទដ្ឋានគតិយុត្តនានា។

ខ. គណៈគ្រប់គ្រងសាលារៀន

វិទ្យាល័យពេជ្រចិន្តា បានបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងដឹកនាំប្រទាក់ក្រឡាគ្នាជាប្រព័ន្ធតែមួយ និងតភ្ជាប់គ្នា បំពេញឱ្យគ្នាទៅវិញទៅមករវាងគណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន[៨] និងបណ្តាញអប់រំតាមភូមិគោលដៅចំណុះ និងអ្នកពាក់ព័ន្ធនានា។ គណៈគ្រប់គ្រងសាលារៀន បានបង្កើតនិងរៀបចំជាផ្នែកៗដែលមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់សម្រាប់អនុវត្តការងារ រាយការណ៍ និងទទួលខុសត្រូវ

[៨] រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងវិទ្យាល័យពេជ្រចិន្តា ឆ្នាំសិក្សា ២០១៨-២០១៩

ផ្ទាល់នៅចំពោះមុខនាយកសាលារៀន។

រចនាសម្ព័ន្ធ និងសមាសភាពគណៈគ្រប់គ្រងសាលារៀនវិទ្យាល័យពេជ្រចិន្តា រួមមាន÷

១. ប្រធានគណៈគ្រប់គ្រងសាលារៀន ជានាយកវិទ្យាល័យពេជ្រចិន្តា ទទួលខុសត្រូវក្តាប់រួម ដែលមាននាយករងផ្នែករដ្ឋបាល ១រូប និងនាយករងផ្នែកបច្ចេកទេស ១រូប ទទួលខុសត្រូវដឹកនាំគណៈកម្មការ និងក្រុមការងារនានាអនុវត្តការងារប្រចាំថ្ងៃ

២. ផ្នែកគាំទ្រគណៈគ្រប់គ្រងសាលារៀនមាន លេខាធិការ ១រូប បេឡាធិការ ១រូប និងហេរញ្ញិក ១រូប

៣. ផ្នែកបច្ចេកទេសរបស់គណៈគ្រប់គ្រងសាលារៀន ទទួលខុសត្រូវការងាររៀន និងបង្រៀន÷

- ប្រធានក្រុមបច្ចេកទេសមុខវិជ្ជាវិទ្យាសាស្ត្រ
- ប្រធានក្រុមបច្ចេកទេសមុខវិជ្ជាវិទ្យាសាស្ត្រសង្គម
- ប្រធានក្រុមបច្ចេកទេសមុខវិជ្ជាភាសាបរទេស

៤. ផ្នែករដ្ឋបាលរបស់គណៈគ្រប់គ្រងសាលារៀន ទទួលខុសត្រូវការងាររដ្ឋបាលសាលារៀន បរិស្ថាន យុវជន និងកីឡា គណៈកម្មការ និងក្រុមការងារនានា។

គណៈគ្រប់គ្រងសាលារៀនមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗ ដូចជា÷

១. រៀបចំធ្វើផែនការកែលម្អសាលារៀន និងគ្រប់គ្រងថវិកាសាលារៀនស្របតាមការណែនាំរបស់ ក្រសួងអប់រំ យុវជន និងកីឡា និងគោលនយោបាយផ្ទៃក្នុងរបស់សាលារៀន

- សម្របសម្រួលការពិភាក្សា សម្របសម្រួលបុគ្គលិកអប់រំឱ្យធ្វើការជាមួយគ្នាក្នុងការរៀបចំសូចនាករផលសម្រេច និងក្រុមគោលដៅសម្រាប់ ៣ឆ្នាំ និងផែនការកែលម្អសាលារៀន និងថវិកាប្រចាំឆ្នាំ
- ដាក់ជូនលទ្ធផលវាយតម្លៃពីការវាយតម្លៃការអនុវត្តរបស់សាលារៀនធៀប

ជំពូកទី៣

ជាមួយនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាពដល់គណៈកម្មការគ្រប់គ្រងសាលារៀន

- គ្រប់គ្រង សម្របសម្រួលការពិភាក្សា សម្របសម្រួលបុគ្គលិកអប់រំឱ្យធ្វើការជាមួយគ្នាលើសកម្មភាពរកមូលនិធិសាលារៀន

២. ការគ្រប់គ្រងបុគ្គលិកអប់រំ

- អនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រី និងដាក់ស្នើផ្តល់រង្វាន់ដល់មន្ត្រីដែលបានបំពេញការងារល្អប្រសើរ
- ស្នើដល់គណៈកម្មការគ្រប់គ្រងសាលារៀន នូវវិធានការរដ្ឋបាលសម្រាប់មន្ត្រីមិនអនុវត្តភារកិច្ច

៣. ជំរុញ និងពង្រឹងតួនាទីសហគមន៍ និងអភិបាលកិច្ចសាលារៀន

- សម្របសម្រួលធានាដំណើរការដោយរលូននូវការអនុវត្តសកម្មភាពជាតួនាទីរបស់សហគមន៍ និងអភិបាលកិច្ចសាលារៀន
- ពិនិត្យឡើងវិញ និងដាក់ស្នើការកែសម្រួលដើម្បីធានានូវតម្លាភាពក្នុងការចូលរួមរបស់សហគមន៍

៤. រៀបចំធ្វើស្វ័យវាយតម្លៃសាលារៀន និងលទ្ធផលសិក្សាសិស្ស

- សម្របសម្រួលការពិភាក្សាជាមួយបុគ្គលិកអប់រំឱ្យធ្វើការវាយតម្លៃការអនុវត្តរបស់សាលារៀន ធៀបនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាព
- ចងក្រងទិន្នន័យ និងព័ត៌មានសម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសពីការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀនដល់គណៈកម្មការគ្រប់គ្រងសាលារៀន
- ចងក្រងទិន្នន័យ និងព័ត៌មានសម្រាប់ផលិត និងធ្វើរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំពីការសម្រេចសូចនាករ និងក្រុមគោលដៅផលសម្រេចទៅគ្រប់អ្នកពាក់ព័ន្ធ

៥. ពង្រឹងគណនេយ្យភាពសាលារៀន

- រៀបចំ និងដាក់ស្នើនូវរបាយការណ៍ទាំងឡាយដែលត្រូវផ្សព្វផ្សាយជាសាធារណៈ ដល់គណៈកម្មការគ្រប់គ្រងសាលារៀន

វិធីសាស្ត្រអនុវត្តការដឹកនាំគ្រប់គ្រងសាលារៀនរបស់គណៈគ្រប់គ្រងសាលារៀន វិទ្យាល័យពេជ្រចិន្តារួមមាន÷

១. ប្រជុំរៀបចំ ពិនិត្យ សម្រេចតាមរបៀបវារៈគ្រោងទុក

២. កំណត់បញ្ហាប្រឈម និងដោះស្រាយបញ្ហាជាអាទិភាពស្របតាមមតិភាគច្រើន

៣. កំណត់កិច្ចការ ទំហំការងារ អ្នកទទួលខុសត្រូវ និងធនធានដែលត្រូវប្រើប្រាស់

៤. ពិនិត្យ សម្របសម្រួល កែតម្រូវ និងប្រជុំពង្រឹងការងារជាក្រុមជាប្រចាំ

៥. រៀបចំចងក្រង រក្សាទុកឯកសារ និងរបាយការណ៍វឌ្ឍនភាពជាប្រចាំ និងតាម កាលកំណត់

៦. បង្កើត និងរក្សាទំនាក់ទំនងល្អជាមួយគ្រប់អ្នកពាក់ព័ន្ធ

ដើម្បីការងារសម្រេចបានកាន់តែមានប្រសិទ្ធភាពខ្ពស់ និងឆ្លើយតបទៅនឹងរចនាសម្ព័ន្ធ តួនាទីភារកិច្ចនិងការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងសាលា វិទ្យាល័យពេជ្រចិន្តាបាន បង្កើតក្រុមការងារតូចៗ សម្រាប់ទទួលខុសត្រូវអនុវត្តការងារប្រចាំថ្ងៃបន្ថែមទៀត រួមមាន÷

- គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការ
- ប្រធានក្រុមបច្ចេកទេសមុខវិជ្ជានីមួយៗ
- ក្រុមការងារសង្គ្រោះបឋម
- ក្រុមការងារបរិស្ថាន
- ក្រុមការងារទទួលបន្ទុកបណ្ណាល័យ
- គ្រូមគ្គុទេសក៍ប្រឹក្សាអាជីព
- ក្រុមការងារទទួលបន្ទុកអន្តេវាសិកដ្ឋានសិស្ស
- ក្រុមការងារគ្រប់គ្រងបន្ទប់ និងការបណ្តុះបណ្តាលកុំព្យូទ័រ

ជំពូកទី៣

- ក្រុមប្រឹក្សាយុវជន
- ក្លឹបសិក្សាតាមមុខវិជ្ជា
- ក្រុមកាយរឹទ្ធិ
- ក្រុមយុវជនស្ម័គ្រចិត្តកាកបាទក្រហម

គ. គោលនយោបាយ ការរៀបចំផែនការ សមិទ្ធផល និងស្វ័យវាយតម្លៃរបស់វិទ្យាល័យពេជ្រចិន្តា

ចក្ខុវិស័យ

សាលាទទួលសិស្សឱ្យចូលរៀនប្រកបដោយ សមភាព សមធម៌ និងបរិយាបន្ន បណ្តុះវិន័យ គុណភាព គុណធម៌ និងការច្នៃប្រឌិតកាត់បន្ថយអត្រាបោះបង់ការសិក្សាឱ្យសល់សូន្យភាគរយក្នុងមួយឆ្នាំៗ ជាពិសេស គឺផ្តល់សេវាអប់រំមួយដែលសហគមន៍ទទួលស្គាល់។

បេសកកម្ម

១. កសាងមនុស្សឱ្យមានចំណេះដឹង ចំណេះធ្វើ និងមានសីលធម៌ ស្របតាមគោលនយោបាយរាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា
២. ពង្រឹងការផ្តល់សេវាអប់រំឱ្យបានល្អប្រសើរឡើងថែមទៀត ជាពិសេស ការចែករំលែកដល់សាលាដទៃៗទៀត និងប្រែក្លាយសាលារៀនឱ្យក្លាយជាសាលារបស់សហគមន៍
៣. ពង្រឹងគុណវុឌ្ឍិគ្រូ ទាំងជំនាញ និងសីលធម៌វិជ្ជាជីវៈ
៤. កសាងយុវជនមួយដែលសង្គមជាតិត្រូវការទាំងពេលបច្ចុប្បន្ន និងពេលអនាគត
៥. បណ្តុះជំនាញភាសា និងជំនាញបច្ចេកទេស នៅពេលសិស្សឈប់រៀនអាចចិញ្ចឹមជីវិតបាន
៦. លើកកម្ពស់យេនឌ័រលើគ្រប់សកម្មភាព

គោលបំណង

១. ប្រែក្លាយសាលារៀនឱ្យទៅជាសាលាមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស
២. ការរៀន និងការបង្រៀនស្របតាមបដិវត្តន៍ឧស្សាហកម្ម ៤.០

៣. ពង្រឹងភាពជាអ្នកដឹកនាំទាំងជួរអ្នកដឹកនាំ លោកគ្រូ អ្នកគ្រូ និងក្រុមប្រឹក្សាយុវជន ឱ្យកាន់តែល្អប្រសើរ និងមានយេនឌ័រ

៤. កសាងយុវជនឱ្យមានវិន័យ គុណភាព គុណធម៌ និងការច្នៃប្រឌិត

ឃ. ការរៀបចំផែនការកែលម្អសាលារៀន

គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធ មូលមតិគ្នារៀបចំបង្កើតផែនការកែលម្អសាលារៀន សម្រាប់រយៈពេល ១ឆ្នាំ និង៣ឆ្នាំ ដែលឆ្លើយតបទៅនឹងតម្រូវការសិស្ស មាតាបិតា និងសហគមន៍។ ការរៀបចំផែនការបាន ផ្ដោតលើការធ្វើឱ្យសម្រេចបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព[៩] (ស្តង់ដាទាំង៩ របស់សាលារៀន) ដែលរួមមាន÷ ១) វត្ថុបំណង គោលនយោបាយរបស់សាលារៀន ២) ការបង្រៀន និងបំណែងចែកកម្មវិធីបង្រៀន ៣) មាតាបិតា និងអ្នកអាណាព្យាបាល សិស្ស និងសហគមន៍ជួយដល់ការរៀនសូត្រ ៤) សិស្ស និងសេវាជួយសិស្ស ៥) ការដឹកនាំ និងការគ្រប់គ្រង ៦) ធនធានមនុស្ស ៧) សម្ភារៈបង្រៀន និងរៀន ៨) ហេដ្ឋារចនាសម្ព័ន្ធ និង បរិស្ថានសាលារៀន និង ៩) ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុដែលបានកត់ត្រា ទិន្នន័យសាលារៀនជាប្រចាំ។ ផែនការកែលម្អសាលារៀនបង្កើតឡើងផ្អែកលើពិន្ទុស្វ័យ វាយតម្លៃសាលារៀន[១០] ដែលបានដាក់ពិន្ទុលើទិន្នន័យសាលារៀនប្រចាំឆ្នាំ ដែលបានកត់ត្រា នៅក្នុងស្តង់ដាសាលារៀនមានប្រសិទ្ធភាព។ ការរៀបចំផែនការកែលម្អសាលារៀនក៏ជា កិច្ចសន្យារបស់សាលារៀន ចំពោះគណៈកម្មការគ្រប់គ្រងសាលារៀន ដែលនឹងសម្រេច ឱ្យបាននូវវត្ថុបំណងគោលនយោបាយរបស់សាលារៀនរួមមាន÷ សម្រេចបានអត្រា

[៩] ឧបករណ៍វាយតម្លៃប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើផលសម្រេចសម្រាប់សាលារៀនមធ្យមសិក្សា- សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន- គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា ឆ្នាំ២០១៨ នៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា

[១០] ឧបករណ៍វាយតម្លៃការអនុវត្តសាលារៀនផ្អែកតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាព (ស្វ័យវាយតម្លៃ សាលារៀន)- សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន- គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា ឆ្នាំ២០១៨ នៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ការចូលរៀន អត្រាឡើងថ្នាក់ អត្រាត្រួតថ្នាក់ អត្រាបោះបង់ការសិក្សា អត្រារៀនចប់ភូមិសិក្សា អត្រាសិស្ស-គ្រូ អត្រាសិស្ស-ថ្នាក់រៀន អត្រាសិស្សសៀវភៅសិក្សា និងលទ្ធផលសិក្សា ជាដើម។

- កាត់បន្ថយអត្រាត្រួតថ្នាក់ បោះបង់ការសិក្សា មកត្រឹម១ភាគរយ
- បង្កើនអត្រាឡើងថ្នាក់ ឆ្លងភូមិសិក្សា និងលទ្ធផលសិក្សាល្អយ៉ាងតិច៩៥ភាគរយ
- សម្រេចឱ្យបាន១០០ភាគរយ នូវការផ្តល់ឱ្យសៀវភៅសិក្សាគោលសម្រាប់គ្រូ និងសិស្ស។

ង. សមិទ្ធកម្មធៀបនឹងផែនការដែលបានកំណត់

ជាប្រចាំ វិទ្យាល័យបានប្រជុំបូកសរុបការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ សម្រាប់ផ្ទៀងផ្ទាត់សមិទ្ធផលការងារធៀបនឹងផែនការគ្រោងទុក។ ជាលទ្ធផល គណៈគ្រប់គ្រងសាលារៀន បានរៀបចំកំណត់ហេតុប្រជុំ របាយការណ៍រីកចម្រើនប្រចាំខែ ត្រីមាស និងឆមាស និងបានរាយការណ៍ពីសមិទ្ធផលដែលវិទ្យាល័យសម្រេចបានទាំងនេះទៅការិយាល័យអប់រំ យុវជន និងកីឡា ស្រុកភ្នំព្រឹក និងអ្នកពាក់ព័ន្ធនានា។ របាយការណ៍ទាំងនោះរួមមាន របាយការណ៍វឌ្ឍនភាពនៃការគ្រប់គ្រងថវិកា និងស្ថិតិប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាស។ សាលារៀនបានប្រើឧបករណ៍វាយតម្លៃប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើផលសម្រេចសម្រាប់សាលារៀនមធ្យមសិក្សា (ស្តង់ដាទាំង៩ របស់សាលារៀន) សម្រាប់កត់ត្រា និងរាយការណ៍ស្ថិតិសាលារៀននៅដើមឆ្នាំសិក្សា បំណាច់ឆមាសទី១ និងបំណាច់ឆ្នាំសិក្សានីមួយ ជាប្រភពទិន្នន័យធ្វើស្វ័យវាយតម្លៃសាលារៀន និងការរៀបចំផែនការកែលម្អសាលារៀន។

ច. ធ្វើស្វ័យវាយតម្លៃសាលារៀនជាប្រចាំ

វិទ្យាល័យ ប្រើប្រាស់ឧបករណ៍វាយតម្លៃការអនុវត្តសាលារៀនផ្អែកតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាព (ស្វ័យវាយតម្លៃសាលារៀន) សម្រាប់ដាក់ពិន្ទុស្វ័យវាយតម្លៃលើទិន្នន័យ និងសមិទ្ធផលការងារដែលបានកត់ត្រាក្នុងឧបករណ៍វាយតម្លៃប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ ផ្អែកលើផលសម្រេចសម្រាប់សាលារៀនមធ្យមសិក្សា (ស្តង់ដាទាំង៩ របស់សាលារៀន)។ វិទ្យាល័យបានធ្វើស្វ័យវាយតម្លៃសាលារៀនពីរដងក្នុងមួយឆ្នាំ ក្នុងនោះលើកទី១ ធ្វើស្វ័យវាយតម្លៃលើសមិទ្ធផលបំណាច់ឆមាសទី១ (ព្រមទាំងកែសម្រួលផែនការសម្រាប់ឆមាសទី២) និងលើកទី២ វាយតម្លៃផលសម្រេចបំណាច់ឆ្នាំសិក្សា (រៀបចំផែនការកែលម្អសាលារៀនសម្រាប់ឆ្នាំសិក្សាថ្មី) ដែលត្រូវដាក់ពិន្ទុលើសូចនាករលម្អិតទាំង ៧០។ ការធ្វើស្វ័យវាយតម្លៃសាលារៀនបានចូលរួមពីគណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន និងតំណាងអ្នកពាក់ព័ន្ធនានា។ ពិន្ទុស្វ័យវាយតម្លៃមានបីកម្រិត÷ ពិន្ទុ១ (លទ្ធផលសម្រេចបានទាបជាងផែនការគ្រោងទុក) ពិន្ទុ២ (លទ្ធផលសម្រេចបានស្មើផែនការគ្រោងទុក) និងពិន្ទុ៣ (លទ្ធផលសម្រេចបានលើសផែនការគ្រោងទុក)។

តារាងទី៣÷ ស្តង់ដាសាលារៀនមានប្រសិទ្ធភាពវិទ្យាល័យពេជ្រចិន្តា
ឆ្នាំសិក្សា ២០១៨-២០១៩

ស្តង់ដាសាលារៀនមានប្រសិទ្ធភាព វិទ្យាល័យពេជ្រចិន្តា (ឆ្នាំសិក្សា ២០១៨-២០១៩)	**ពិន្ទុស្វ័យវាយតម្លៃ**	**ពិន្ទុត្រូវជាប់**	**ពិន្ទុខ្ពស់បំផុត**
ស្តង់ដា១÷ វត្ថុបំណងគោលនយោបាយសាលារៀន	៣៣	២៤	៣៦
ស្តង់ដា២÷ ការបង្រៀន និងរៀន	៧១	៥២	៧៨
ស្តង់ដា៣÷ មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រ	៩	៨	១២
ស្តង់ដា៤÷ សិស្ស និងសេវាជួយសិស្ស	២២	១៤	២១
ស្តង់ដា៥÷ ការដឹកនាំ និងការគ្រប់គ្រង	១៨	១៤	២១
ស្តង់ដា៦÷ ធនធានមនុស្ស	៨	៦	៩

ជំពូកទី៣

ស្តង់ដាសាលារៀនមានប្រសិទ្ធភាព វិទ្យាល័យពេជ្រចិន្តា (ឆ្នាំសិក្សា ២០១៨-២០១៩)	ពិន្ទុស្វ័យវាយតម្លៃ	ពិន្ទុត្រូវជាប់	ពិន្ទុខ្ពស់បំផុត
ស្តង់ដា៧÷ សម្ភារៈបង្រៀន និងរៀន	៦	៦	៩
ស្តង់ដា៨÷ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន	១៨	១០	១៥
ស្តង់ដា៩÷ ការគ្រោងថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុ	៩	៦	៩
ពិន្ទុសរុប	**១៩៤**	**១៤០**	**២១០**

៣.២.២.២. ការដឹកនាំការបង្រៀន និងរៀន

វិទ្យាល័យបានបង្កើតក្រុមការងារមួយចំនួនសម្រាប់ដឹកនាំគ្រប់គ្រង និងអនុវត្តការងារបង្រៀន និងរៀន មានដូចជា÷ ១) នាយករងទទួលបន្ទុកបច្ចេកទេស ទទួលខុសត្រូវរួមដឹកនាំគ្រប់គ្រងការងាររៀន និងបង្រៀននៅក្នុងវិទ្យាល័យ ២) បង្កើតក្រុមការងារបច្ចេកទេសតាមមុខវិជ្ជាសម្រាប់អនុវត្តការងារបង្រៀន និងរៀន ៣) ក្រុមគ្រូបង្រៀនទទួលបន្ទុកថ្នាក់ក្រុមគ្រូបង្រៀនកាន់មុខវិជ្ជាបង្រៀន ដឹកនាំគ្រប់គ្រង អនុវត្តក្លឹបសិក្សា និងស្វ័យសិក្សារបស់សិស្ស។ ក្រុមការងារបានជួបប្រជុំ និងរាយការណ៍សមិទ្ធផលការងារបច្ចេកទេសប្រចាំខែដើម្បីរៀបចំអនុវត្តការងារធ្វើថ្នាក់និទស្សន៍ អធិការកិច្ចផ្ទៃក្នុង និងការគ្រប់គ្រងលទ្ធផលសិក្សាសិស្ស។ ក្រុមការងារទាំងនេះមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវលម្អិតដូចខាងក្រោម÷

ក. ប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជា

- សម្របសម្រួលរៀបចំបំណែងចែកកម្មវិធីសិក្សា
- រៀបចំធ្វើផែនការសកម្មភាពបង្រៀនប្រចាំសប្តាហ៍
- ដឹកនាំ និងសម្របសម្រួលការប្រជុំបច្ចេកទេស
- ពិនិត្យ និងវាយតម្លៃកិច្ចតែងការបង្រៀនរបស់សមាជិកក្រុមបច្ចេកទេសមុននឹងដាក់ឱ្យនាយករងទទួលបន្ទុកបច្ចេកទេសចុះហត្ថលេខា
- នាយករងទទួលបន្ទុកបច្ចេកទេស ចុះធ្វើអធិការកិច្ចផ្ទៃក្នុងតាមផែនការ

សកម្មភាព

- បែងចែកភារកិច្ចគ្រូបង្រៀនតាមមុខវិជ្ជានីមួយៗ
- ធ្វើកិច្ចព្រមព្រៀង និងទទួលខុសត្រូវរបស់គ្រូបង្រៀន
- ត្រួតពិនិត្យ និងវាយតម្លៃលើកផែនការបង្រៀនជារៀងរាល់ខែ
- មានផែនការច្បាស់លាស់លើការប្រជុំបច្ចេកទេស និងធ្វើថ្នាក់និទស្សន៍
- ចូលរួមតាមដាន និងវាយតម្លៃការងាររបស់សមាជិកក្រុមបច្ចេកទេស
- រៀបចំវាយតម្លៃការសិក្សា និងផ្សព្វផ្សាយលទ្ធផលសិក្សាសិស្ស

ខ. គ្រូទទួលបន្ទុកថ្នាក់ និងគ្រូមុខវិជ្ជានីមួយៗ

- ប្រើប្រាស់កម្មវិធីសិក្សាតាមមុខវិជ្ជានីមួយៗ
- បង្រៀនដោយមានកិច្ចតែងការគ្រប់មេរៀន
- បង្រៀនដោយយកចិត្តទុកដាក់ គ្មានការបង្ខិតបង្ខំសិស្សឱ្យរៀនគួរ
- ផ្តល់ព័ត៌មានត្រឡប់ជូនមាតាបិតា និងអ្នកអាណាព្យាបាលសិស្សភ្លាមៗ ករណីសិស្សមិនចូលរៀន
- ចូលរួមបង្កើតតេស្តស្តង់ដាសម្រាប់ការប្រឡង និងចូលរួមជាអនុរក្សប្រឡង
- កែកិច្ចការសិស្សដោយសុក្រឹត យុត្តិធម៌
- បូកពិន្ទុសិស្ស សរសេរសៀវភៅតាមដានការសិក្សាសិស្ស
- អញ្ជើញមាតាបិតាមកចូលរួមប្រជុំរាល់បីខែម្តង ដើម្បីជម្រាបជូនគាត់ពីអត្តចរិតកូនគាត់
- លទ្ធផលសិក្សា និងចំនួនអវត្តមាន ជាដើម
- ចុះទៅដល់ផ្ទះសិស្សករណីសិស្សឈប់គ្មានដំណឹង ឬទាក់ទងមិនបាន
- ចូលរួមប្រជុំបច្ចេកទេសតាមផែនការកំណត់
- ស្នើសុំក្រុមបច្ចេកទេសចុះអធិការកិច្ចការបង្រៀន និងរៀនក្នុងថ្នាក់រៀន

គ. ការងារជួយសិស្សតាមរយៈការវាយតម្លៃលទ្ធផលការសិក្សារបស់សិស្សជាប្រចាំ (ការធ្វើតេស្តស្តង់ដាកម្រិតសាលារៀន)

វិទ្យាល័យ បានរៀបចំជួយសិស្សទាំងសិស្សរៀនយឺត និងសិស្សពូកែនៅក្នុងសាលារៀនតាមរយៈការរៀបចំថ្នាក់បំប៉ន និងធ្វើតេស្តវាយតម្លៃការសិក្សាជាប្រចាំ។ ដំណើរការនៃការប្រឡងតេស្តសមត្ថភាពសិស្ស ស្តង់ដាកម្រិតវិទ្យាល័យប្រព្រឹត្តទៅជារៀងរាល់សប្តាហ៍ទី២នៃខែនីមួយៗ ដែលមានរយៈពេល ២ថ្ងៃ។ គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូ អ្នកគ្រូបានចូលរួមប្រជុំបែងចែកភារកិច្ចនៅក្នុងដំណើរការប្រឡង។ គ្រូកាន់មុខវិជ្ជានីមួយៗពិភាក្សាគ្នាដើម្បីបង្កើតវិញ្ញាសារួមសម្រាប់ការប្រឡងតាមគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់ទាំងអស់ចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី១២។ វិញ្ញាសាប្រឡងបែងចែកជាបីប្រភេទគឺ វិញ្ញាសាបោះពុម្ពជាក្រដាស វិញ្ញាសាសរសេរលើក្តារខៀន និងវិញ្ញាសាសរសេរតាមអានសម្រាប់សិស្សថ្នាក់ទី៧ ទី៨ និងទី៩។

មុនថ្ងៃប្រឡង វិទ្យាល័យ បានបិទឈ្មោះសិស្សតាមលំដាប់នៃអក្សរនៅក្តារខៀនព័ត៌មានសាលារៀន។ ឆ្លើយតបនឹងកង្វះបុគ្គលិកជួយដំណើរការប្រឡង ខ្វះអនុរក្សជាដើម វិទ្យាល័យបានរៀបចំសិស្សមួយបន្ទប់ចំនួន ៥០នាក់ ដោយបញ្ចូលសិស្សថ្នាក់ទី៧ និងសិស្សថ្នាក់ទី១០អោយប្រឡងជាមួយគ្នា ដែលថ្នាក់ទី៧ សិស្ស ២៥នាក់ និងថ្នាក់ទី១០ សិស្ស ២៥នាក់។ តុមួយសិស្សអង្គុយពីរនាក់ សិស្សថ្នាក់ទី៧មួយនាក់ និងថ្នាក់ទី១០មួយនាក់ឆ្លាស់គ្នាពេញបន្ទប់តាមប្លង់តុដែលសាលាបានរៀបចំ។ ក្នុងមួយបន្ទប់មានអនុរក្សមួយនាក់សម្រាប់មើលការខុសត្រូវដំណើរការប្រឡង។ សម្រាប់កម្រិតថ្នាក់ផ្សេងៗទៀតគឺធ្វើដូចគ្នានឹងថ្នាក់ទី៧ និងថ្នាក់ទី១០។

បន្ទាប់ពីការប្រឡងបញ្ចប់ លោកគ្រូអ្នកគ្រូបានញែកសន្លឹកកិច្ចការសិស្សដើម្បីធ្វើការកែ។ ក្នុងការកែ សាលាមិនបានកាត់ក្បាលសន្លឹកកិច្ចការរបស់សិស្សទេ ព្រោះលោកគ្រូអ្នកគ្រូមានការទទួលខុសត្រូវខ្ពស់ មានមនសិការ និងមានតម្លាភាពក្នុងការកែសន្លឹកកិច្ចការរបស់សិស្ស។ គ្រូតាមមុខវិជ្ជានីមួយៗ ត្រូវប្រគល់សន្លឹកកិច្ចការដែលកែរួចមកសាលា

ឱ្យបានមុនសប្តាហ៍ទី៣ ដើម្បីប្តូកស្រង់និងបញ្ចូលក្នុងកម្មវិធីគ្រប់គ្រងពិន្ទុសិស្សតាមការណែនាំរបស់ក្រុមការងារគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សារបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ។

ពិន្ទុដែលបានប្តូកស្រង់រួចបានបញ្ចូលក្នុងបញ្ជីឈ្មោះសិស្ស និងបានបិទឱ្យសិស្សមើលនៅតាមថ្នាក់រៀននីមួយៗជាមុន ដើម្បីបើកឱ្យមានការតវ៉ាពិន្ទុក្នុងករណីរកឃើញមានភាពមិនប្រក្រតីនៃពិន្ទុដែលបណ្តាលមកពីការបញ្ចូលពិន្ទុសិស្សម្នាក់ៗ។ នៅពេលដែលពិនិត្យពិន្ទុត្រឹមត្រូវអស់ហើយ សាលារៀនបិទផ្សាយពិន្ទុសិស្សតាមក្តារព័ត៌មានក្នុងសាលារៀន និងនៅតាមសហគមន៍ ដែលបិទផ្សាយតាមក្តារខៀនព័ត៌មាននៅផ្សារជាដើម ដើម្បីឱ្យមាតាបិតា និងអ្នកអាណាព្យាបាលសិស្សមើលឃើញ។

វិទ្យាល័យបានយកលទ្ធផលសិក្សារបស់សិស្សប្រចាំខែ មកសិក្សាវិភាគសម្រាប់រៀបចំថ្នាក់បំប៉ន និងដំណើរការក្លឹបសិក្សាដើម្បីជួយសិស្សក្រុមសិស្សរៀនយឺត និងរៀនលឿនទាន់ពេលវេលា។

ឃ. បង្កើត និងជំរុញសកម្មភាពក្លឹបសិក្សា

ដើម្បីជួយសិស្សរៀនយឺតលើមុខវិជ្ជានានា ដូចជាមុខវិជ្ជាវិទ្យាសាស្ត្រឱ្យទទួលបានលទ្ធផលល្អនៅពេលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ជាពិសេសសិស្សថ្នាក់ទី១២ គ្រូកាន់មុខវិជ្ជានីមួយៗបានជំរុញឱ្យសិស្សានុសិស្ស បង្កើតក្លឹបសិក្សាតាមមុខវិជ្ជារៀងៗខ្លួន។ ក្លឹបសិក្សា ដំណើរការដូចខាងក្រោម៖

១. ក្រោយពីការវាស់ស្ទង់សមត្ថភាពរបស់សិស្សតាមរយៈការការបង្រៀនលើមុខវិជ្ជា និងតេស្តវង្វាយតម្លៃប្រចាំខែយ៉ាងសុក្រឹតនិងត្រឹមត្រូវរួចមក ធ្វើឱ្យគ្រូកាន់មុខវិជ្ជាដឹងយ៉ាងច្បាស់ពីចំណេះដឹងរបស់សិស្សលើមុខវិជ្ជាខ្លួនបង្រៀន។ គ្រូបានជ្រើសរើសសិស្សពូកែចំនួនបីនាក់ដែលម្នាក់ដើរតួជាប្រធានក្លឹប ពីរនាក់ទៀតជាអនុប្រធានក្លឹបសម្រាប់ដឹកនាំ និងសម្របសម្រួលដំណើរការក្លឹបសិក្សា។

២. គ្រូបង្កើតរចនាសម្ព័ន្ធក្លឹប ធ្វើបញ្ជីឈ្មោះសមាជិកក្លឹប និងធ្វើបញ្ជីចុះវត្តមានសិស្ស

៣. គ្រូកំណត់កាលបរិច្ឆេទបង្រៀនដែលជ្រើសយកថ្ងៃណាដែលសិស្សទំនេរ ហើយកំណត់ចំនួនម៉ោងជាក់ស្តែងដែលត្រូវរៀននៅក្នុងមេរៀន ឬប្រធានបទនីមួយៗ

៤. មុនពេលដំណើរការបង្រៀន ដំបូងគ្រូបានឱ្យប្រធានក្លឹប រំឭកខ្លឹមសារគោលរបស់មេរៀន ឬរូបមន្តពាក់ព័ន្ធនឹងមេរៀនដែលត្រូវរៀនជាមុនសិន ហើយដែលមានគ្រូចាំជួយនិងសម្របសម្រួលដំណើរការរៀន

៥. មុនពេលបង្រៀន គ្រូដាក់កិច្ចការឱ្យក្លឹបសិក្សាទាំងមូលត្រូវរៀន ប្រធានក្លឹប និងអនុប្រធានធ្វើកិច្ចការជាមុន ហើយគ្រូជួយកែតម្រូវ មុននឹងឱ្យពួកគេបង្រៀនសមាជិកក្លឹប

៦. ខ្លឹមសារបង្រៀនសម្រាប់ក្លឹបចាប់ផ្តើមពីកិច្ចការងាយស្រួលទៅកិច្ចការលំបាក ដើម្បីជៀសវាងសិស្សពូកែធុញទ្រាន់

៧. ពេលបកស្រាយ ឬដោះស្រាយលំហាត់រួច សមាជិកក្លឹបម្នាក់ទៀតជាអ្នករំឭកមេរៀនដល់មិត្តភក្តិទាំងអស់ជាប្រចាំ

៨. ក្លឹបសិក្សាត្រូវការគ្រូកាន់មុខវិជ្ជាមានការតាំងចិត្ត មានឆន្ទៈនឹងធ្វើ និងមានការអំណត់ព្យាយាមខ្ពស់ ដើម្បីលើកទឹកចិត្ត និងជំរុញការខិតខំប្រឹងប្រែងក្នុងការសិក្សារបស់សិស្ស។

ង. បណ្តុះស្មារតីគ្រូ និងសិស្សឱ្យចេះសិក្សាពេញមួយជីវិតតាមរយៈការអនុវត្តគម្រោងស្រាវជ្រាវមេរៀនមុខវិជ្ជា សីលធម៌-ពលរដ្ឋវិជ្ជា

កាន់សៀវភៅ ១ក្បាល បង្កើតសៀវភៅ ១ក្បាល ជាបេសកកម្មមួយសម្រាប់សិស្សានុសិស្សកំពុងសិក្សាមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា នៅថ្នាក់ទី១០ ទី១១ និងទី១២ នៃវិទ្យាល័យពេជ្រចិន្តាត្រូវអនុវត្តក្នុងឆ្នាំសិក្សានីមួយៗ។ ការបង្រៀនតាមបែបអនុវត្តគម្រោងសិក្សាបានឆ្លើយតបទៅនឹងកម្មវិធីសិក្សា និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងចក្ខុវិស័យ បេសកកម្ម គោលបំណង និងសេចក្តីត្រូវការរបស់សិស្សានុសិស្សក្នុងការពង្រឹងនិងបង្កើនគុណភាពបង្រៀន និងរៀន និងការរីកចម្រើន ឆ្លើយតបតម្រូវការ និងនវានុវត្តន៍

នៃសម័យបច្ចេកវិទ្យា (៤.០)។ ក្រុមបច្ចេកទេសមុខវិជ្ជាវិទ្យាសាស្ត្រសង្គម វិទ្យាល័យបាន រៀបចំ និងដឹកនាំក្រុមគ្រូបង្រៀនកាន់មុខវិជ្ជានីមួយៗ ពិភាក្សារិះរកវិធីសាស្ត្រ បទពិសោធន៍ និងការរួមបញ្ចូលបច្ចេកវិទ្យាថ្មីៗ ដើម្បីចែករំលែកគ្នាទៅវិញទៅមកនូវការអនុវត្តល្អនៃ ការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលប្រកបដោយប្រសិទ្ធភាពខ្ពស់។

មុខវិជ្ជា សីលធម៌-ពលរដ្ឋវិជ្ជា បានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងគុណភាព សិក្សាមុខវិជ្ជាវិទ្យាសាស្ត្រសង្គម តាមរយៈការដឹកនាំ បង្ហាត់បង្រៀនសិស្សឱ្យចេះត្រិះរិះ ពិចារណាស៊ីជម្រៅបន្ថែមទៀតទៅលើមេរៀននីមួយៗដែលបានរៀននៅក្នុងសាលារៀន ដោយនាំសិស្សរៀនធ្វើកិច្ចការគម្រោងស្រាវជ្រាវ (Project Work)។ ការអនុវត្តកិច្ចការ ស្រាវជ្រាវគម្រោងមិនត្រឹមតែឆ្លើយតបតម្រូវការ ដឹកនាំគ្រប់គ្រងការងារបង្រៀន និងរៀន របៀបថ្មីរបស់សិស្សឱ្យចេះគិតកាន់តែទូលំទូលាយ និងស៊ីជម្រៅដែលក្រសួងចង់បាន ប៉ុណ្ណោះទេ វិធីសាស្ត្រនេះក៏បាននាំសិស្សានុសិស្សនៅវិទ្យាល័យពេជ្រចិន្តា ឱ្យចេះរៀនពី របៀបរៀនថ្មីដែលបង្កើនកម្រិតយល់ដឹងកាន់តែទូលំទូលាយបន្ថែមទៀតលើមេរៀនដែល បានរៀនរួចនៅក្នុងសាលា តាមកិច្ចការស្រាវជ្រាវបែបវិទ្យាសាស្ត្រ។ ការធ្វើគម្រោង ស្រាវជ្រាវនាំសិស្សឱ្យចេះកំណត់បញ្ហាតាមរយៈការបង្កើតសំណួរគោល ការជ្រើសរើសវិធី ប្រមូលព័ត៌មាន វិភាគព័ត៌មាន ទិន្នន័យ សរសេរបកស្រាយ និងប្រើលទ្ធផលស្រាវជ្រាវ។ ការបង្ហាញលទ្ធផលស្រាវជ្រាវទៅអ្នកពាក់ព័ន្ធបណ្តុះបាននូវភាពក្លាហាន របៀបធ្វើការ ជាក្រុម និងវិធីប្រាស្រ័យទាក់ទងថ្មីៗដល់សិស្សានុសិស្ស។

មុខវិជ្ជា***សីលធម៌-ពលរដ្ឋវិជ្ជា*** វិទ្យាល័យ បានណែនាំឱ្យអនុវត្តកិច្ចការស្រាជ្រាវជា ៣ដំណាក់កាលសំខាន់ៗ÷

ទី១÷ ការដឹកនាំការស្រាវជ្រាវ និងត្រួតពិនិត្យកិច្ចការស្រាវជ្រាវរបស់សិស្ស

- នៅដើមឆ្នាំសិក្សា គ្រូផ្តល់ការណែនាំអំពីរបៀបធ្វើគម្រោងស្រាវជ្រាវដែលមាន ជាទម្រង់ និងគំរូជាឧទាហរណ៍ដល់សិស្សកំពុងសិក្សានៅថ្នាក់ទី១០ ទី១១ និង ទី១២

- សិស្សតាមកម្រិតថ្នាក់ជ្រើសរើសប្រធានបទស្រាវជ្រាវ វិធីប្រមូល ដំណើរការស្រាវជ្រាវ និងសរសេររបាយការណ៍ស្រាវជ្រាវតាមការណែនាំរបស់គ្រូ
- គ្រូដឹកនាំការស្រាវជ្រាវ ត្រួតពិនិត្យ ប្រឹក្សាយោបល់ សម្របសម្រួល និងផ្តល់យោបល់ជាប្រចាំ
- សិស្សត្រូវរៀបចំរបាយការណ៍ស្រាវជ្រាវជាសៀវភៅ សម្រាប់បង្ហាញជាសាធារណៈ និងតម្កល់ប្រើប្រាស់នៅក្នុងបណ្ណាល័យសាលារៀន។

ទី២÷ *វង្វាយតម្លៃរបាយការណ៍ស្រាវជ្រាវសិស្ស*

- ចុងឆមាសទី១ អំឡុងខែមីនា វិទ្យាល័យរៀបចំពិធីតាំងពិព័រណ៍ស្នាដៃ និងពិព័រណ៍ការងារ ដែលសិស្សានុសិស្សគ្រប់កម្រិតថ្នាក់ចូលរួមធ្វើបទបង្ហាញការពាររបាយការណ៍ស្រាវជ្រាវរបស់ខ្លួននៅមុខសាធារណៈជន
- បង្កើតគណៈកម្មការវាយតម្លៃរបាយការណ៍ស្រាវជ្រាវសិស្សានុសិស្សដែលមានសមាសភាពចូលរួមពីគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមដែលមានតួនាទីជាប្រធាន អនុប្រធាន និងគ្រូបង្រៀនមុខវិជ្ជាឯកទេសជាសមាជិក។

ទី៣÷ *របាយការណ៍សាវជ្រាវរបស់សិស្សសម្រេចទទួលស្គាល់ជាផ្លូវការ*

- របាយការណ៍ត្រូវបានត្រួតពិនិត្យដោយគណៈកម្មការវាយតម្លៃរបាយការណ៍ស្រាវជ្រាវសិស្សានុសិស្ស
- បានបោះត្រា បានឃើញ និងឯកភាពពីនាយក ឬនាយករងទទួលបន្ទុកបច្ចេកទេស ហើយអនុញ្ញាតឱ្យប្រើប្រាស់របាយការណ៍ស្រាវជ្រាវជាផ្លូវការសម្រាប់÷
  - តម្កល់ទុកក្នុងបណ្ណាល័យ
  - ផ្សព្វផ្សាយបន្តដើម្បីជាគំរូដល់ប្អូនៗជំនាន់ក្រោយ
  - បង្ហាញស្នាដៃសិស្សដល់ក្រុមប្រតិភូទស្សនកិច្ចសិក្សាវិទ្យាល័យពេជ្រចិន្តា
  - ផ្តល់គំរូអនុវត្តន៍កិច្ចការស្រាវជ្រាវ និងការចែករំលែកបទពិសោធន៍ស្រាវជ្រាវទៅកាន់យុវជនដទៃ។

ច. វិធីសាស្ត្រសំខាន់ៗមួយចំនួនដែលបានអនុវត្តសម្រាប់ពង្រឹងគុណភាពបង្រៀន និងរៀនរបស់គ្រូនិងសិស្ស

១. ប្រជុំបច្ចេកទេសតាមកាលវិភាគ និងមានរបៀបវារៈច្បាស់លាស់

២. ធ្វើទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស

៣. រៀបចំថ្នាក់និទស្សន៍តាមផែនការគ្រោងទុក

៤. ជំរុញការងារគម្រោង សកម្មភាពក្លឹបសិក្សា និងការរៀនខ្លួនឯង

៥. ការទទួលគណៈប្រតិភូដែលបានមកទស្សនកិច្ចសិក្សាសាលា និងទទួលយកយោបល់កែតម្រូវ

៦. រៀបចំពិពណ៌ស្នាដៃសិស្ស មាន÷

- ការធ្វើម្ហូប
- ស្នាដៃស្រាវជ្រាវរបស់សិស្សតាមកម្រិតថ្នាក់ និងមុខវិជ្ជា
- វត្ថុសិល្បៈ និងការច្នៃប្រឌិត

៣.២.២.៣. គណនេយ្យភាពសាលារៀន

ដើម្បីធានា និងពង្រឹងគណនេយ្យភាពសាលារៀន វិទ្យាល័យពេជ្រចិន្តា បានអនុវត្តដូចតទៅ÷

- រៀបចំប្រព័ន្ធកត់ត្រា និងរក្សាទុកព័ត៌មាននិងទិន្នន័យសាលារៀន
- មានប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងប្រព័ន្ធរាយការណ៍ច្បាស់លាស់រួមមាន ការបង្រៀន និងរៀន មានបញ្ជីអវត្តមានគ្រូ សិស្ស លិខិតសុំអនុញ្ញាតច្បាប់របស់គ្រូនិងសិស្ស ប្រមូលកិច្ចតែងការបង្រៀនរៀងរាល់ខែ ពីលោកគ្រូ អ្នកគ្រូ
- មានទិន្នន័យអំពីស្ថិតិ សិស្ស គ្រូ ចំណូល ចំណាយ ផែនការ និងរបាយការណ៍ប្រចាំតាមកាលវិភាគដែលបានកំណត់
- មានបញ្ជីគ្រប់គ្រងវត្តមានបុគ្គលិកច្បាស់លាស់
- បិទផ្សាយលទ្ធផលសិក្សារបស់សិស្សដោយតម្លាភាពជាប្រចាំ

- បានបង្កើតគណៈកម្មការវាយតម្លៃលើការបង្រៀនដែលមាននាយក ជាប្រធាន នាយករងជាអនុប្រធាន និងប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជាជាសមាជិក
- ប្រជុំផ្សព្វផ្សាយកិច្ចបញ្ជីកាគណនេយ្យ ហិរញ្ញវត្ថុ បញ្ជីសារពើភ័ណ្ឌ និងស្ថិតិបុគ្គលិកជាប្រចាំ
- ឆ្លើយតប និងផ្តល់ព័ត៌មានត្រឡប់ទាន់ពេលវេលា និងមានតម្លាភាពតាមការស្នើសុំ

៣.២.២.៤. ហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពធានាដល់ការបង្រៀន និងរៀនប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន

ដើម្បីធានា និងពង្រឹងការបង្រៀន និងរៀនប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន វិទ្យាល័យពេជ្រចិន្តាបានរៀបចំនូវ÷

- ប្រព័ន្ធកាម៉េរាសុវត្ថិភាព
- បន្ទប់បង្រៀនកុំព្យូទ័រ
- បន្ទប់បង្រៀនភាសាបរទេស
- បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ
- បណ្ណាល័យ
- បន្ទប់រៀនមាន LCD projectors
- បន្ទប់រៀនមានភ្លើងបំភ្លឺ និងកង្ហារ
- បន្ទប់សម្រាប់គ្រូបង្រៀនធ្វើការប្រជុំ និងស្រាវជ្រាវ
- អន្តេវាសិកដ្ឋានសម្រាប់សិស្សប្រុស សិស្សស្រី និងគ្រូ
- កន្លែងលាងដៃ
- ប្រព័ន្ធបង្ហូរទឹកស្អុយ និងឡដុតសំរាម
- ភ្លើងបំភ្លឺ ផ្លូវ និងទីធ្លាសាលារៀន
- ប្រព័ន្ធទឹកចម្រោះក្នុងសាលារៀន

- អគារមានភាពងាយស្រួលដល់ជនពិការ
- ស្ទូនជីវៈចម្រុះ ដើម្បីឱ្យពួកគាត់ផ្សារភ្ជាប់ទៅនឹងជីវិតរស់នៅ
- ជួយដល់សិស្សដែលមានពិការភាព និងសិស្សក្រីក្រ (វិទ្យាល័យបានផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រចំនួន ៣៥នាក់ ថ្នាក់ទី១០ ទី១១ និងទី១២ ក្នុងឆ្នាំសិក្សា២០១៨-២០១៩ តាមរយៈអង្គការសម្រេចសុបិនកុមារ និងការផ្ដល់អាហារូបករណ៍សិស្សក្រីក្ររបស់រាជរដ្ឋាភិបាលចំនួន ៩០នាក់
- វិទ្យាល័យមានវគ្គតម្រង់ទិសដល់សិស្សានុសិស្សក្រោយពីពួកគាត់បញ្ចប់ថ្នាក់ទី១២។

៣.២.៣. ការគ្រប់គ្រងហិរញ្ញវត្ថុ

ការគ្រប់គ្រងហិរញ្ញវត្ថុ ជាផ្នែកមួយដ៏សំខាន់ដែលជះឥទ្ធិពលដោយផ្ទាល់លើការអនុវត្តផែនការសកម្មភាពរបស់អង្គភាពនីមួយៗ។ ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ទាមទារឱ្យមានគោលការណ៍ ឬបទដ្ឋានកំណត់ជាក់លាក់។ ការគ្រប់គ្រងហិរញ្ញវត្ថុ (សាធារណៈ) គឺអនុលោមទៅតាមគោលការណ៍ស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលរួមមានដំណាក់កាលនៃការរៀបចំគម្រោងថវិកា ដំណាក់កាលនៃការអនុវត្តថវិកា និងដំណាក់កាលនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ស្របទៅនឹងបទដ្ឋានគតិយុត្តនានាជាធរមាន។

៣.២.៣.១. ការរៀបចំគម្រោងថវិកា

ការគ្រោងថវិការបស់វិទ្យាល័យ អនុលោមទៅតាមគោលការណ៍ស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ព្រមទាំងស្មារតីនៃលិខិតលេខ ៨០១៥ សហវ.អថ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ ដើម្បីសម្រួលដល់ការរៀបចំគម្រោងថវិកា ក៏ដូចជាធានាបាននូវភាពត្រឹមត្រូវនៃការគ្រោងថវិកា នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំប្រព័ន្ធគ្រោង (Ms. Excel) ដែលមានរូបមន្តកំណត់រួចជាស្រេច ដើម្បីឱ្យសាលារៀនសាធារណៈនីមួយៗបំពេញ។

គណៈគ្រប់គ្រងសាលារៀន គឺជាអ្នកទទួលខុសត្រូវក្នុង ការរៀបចំគ្រោងកញ្ចប់ថវិកាដំណើរការសាលារៀន មុននឹងដាក់ឆ្លងទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត តាមរយៈការិយាល័យអប់រំ យុវជន និងកីឡាស្រុក។ ផ្អែកតាមនិយាមដែលបានកំណត់ ថវិការដ្ឋប្រចាំឆ្នាំទទួលបានសរុបតាមរូបមន្ត÷ ថវិកាថេរ (ចំនួន ៦៧០០ពាន់រៀល/ ឆ្នាំ) បូកជាមួយនឹងថវិកាអថេរ (៣៨ពាន់រៀលគុណចំនួនសិស្ស) សម្រាប់ជាមូលដ្ឋានគ្រោងថវិកាប្រចាំឆ្នាំ។

ក្រៅពីថវិកាដំណើរការសាលារៀនដែលផ្ដល់ហិរញ្ញប្បទានដោយរាជរដ្ឋាភិបាល វិទ្យាល័យក៏ទទួលបានផងដែរនូវហិរញ្ញប្បទានពីដៃគូអភិវឌ្ឍមួយចំនួន ជាពិសេសពី SIDA (ទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិប្រទេសស៊ុយអ៊ែត)។ ផ្អែកតាមនិយាមដែលបានកំណត់ ថវិកាប្រចាំឆ្នាំត្រូវបានគ្រោងតាមរូបមន្ត÷ ៦៥០០រៀលគុណចំនួនសិស្ស។ គួរកត់សម្គាល់ថាថវិកា SIDA នឹងបញ្ចប់ត្រឹមឆ្នាំ២០២២។

៣.២.៣.២. ការអនុវត្តថវិកា

ក. ចំណូល និងចំណាយ

➢ **ចំណូល**

វិទ្យាល័យមានប្រភពចំណូលចំនួន៤ រួមមាន÷ ថវិការដ្ឋ ថវិកាដៃគូ ថវិកាសហគមន៍ និងថវិកាដែលបានមកពីប្រភពផ្សេងៗ។ ក្នុងឆ្នាំសិក្សា ២០១៩-២០២០ នេះ វិទ្យាល័យពេជ្រចិន្តាមានសិស្សសរុបចំនួន ១ ០១២ នាក់។ ផ្អែកតាមរូបមន្តដែលបានបង្ហាញខាងលើ វិទ្យាល័យទទួលបានថវិការដ្ឋចំនួន ៤១ ១០៨ពាន់រៀល។ ដោយឡែក ថវិកាដៃគូសរុបដែលទទួលបានមានចំនួន ១៨៥,៧៨ពាន់រៀល (ថវិកាពី SIDA យូនីសេហ្វ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី)។

ក្រៅពីប្រភពចំណូលទាំងពីរនេះ វិទ្យាល័យក៏ទទួលបានការគាំទ្រពីសហគមន៍នៅមូលដ្ឋានផ្ទាល់ផងដែរ។ ជាក់ស្ដែង សម្រាប់ឆ្នាំសិក្សា ២០១៨-២០១៩ សហគមន៍បានចូលរួមអភិវឌ្ឍសាលារៀនតាមរយៈការផ្ដល់ជាសម្ភារៈរៀន និងបង្រៀន រួមនឹងការកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា (Grant in kind) ដែលមានទឹកប្រាក់ចំនួន ៣៦៤,៤០

ពាន់រៀល។ សូមបញ្ជាក់ថា ថវិកាគាំទ្រពីសហគមន៍ទទួលបានគឺប្រែប្រួល។ ដូចនេះ ដើម្បីដឹងពីតួលេខជាក់លាក់ យើងត្រូវរង់ចាំរហូតដល់ដំណាច់ឆ្នាំសិក្សានីមួយៗ។ តារាងទី២ ខាងក្រោម បានបង្ហាញថាថវិកាសហគមន៍ ពិតជាប្រភពហិរញ្ញវត្ថុដ៏សំខាន់របស់វិទ្យាល័យ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍បំផុតនោះ គឺនិន្នាការនិងកំណើនដ៏លឿននៃថវិកាសហគមន៍។ បើពិនិត្យមើលទិន្នន័យពីរឆ្នាំចុងក្រោយ (ឆ្នាំ២០១៨ និងឆ្នាំ២០១៩) ថវិកាសហគមន៍ច្រើនជាងថវិការដ្ឋ។ បើទោះបីជាត្រូវបានបូកបញ្ចូលជាចំណូលរួមរបស់វិទ្យាល័យក៏ដោយ ថវិកានេះត្រូវបានគ្រប់គ្រងដោយផ្ទាល់ពីសហគមន៍។

ក្រៅពីថវិកាទាំងនេះ វិទ្យាល័យមានប្រភពចំណូលផ្សេងៗ (ដូចជាភាស៊ីផ្ញើកង់ ម៉ូតូ និងតូបលក់និចំណីជាដើម)។ អ្វីដែលគួរឱ្យកត់សម្គាល់គឺក្នុងឆ្នាំ ២០១៩ ថវិកាពីប្រភពផ្សេងៗ បានកើនឡើងដល់ចំនួន ២០៣,៥ លានរៀល។ ការកើនឡើងនេះដោយសារវិទ្យាល័យទទួលបានជ័យលាភីចំណាត់ថ្នាក់លេខ១ ជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ ដែលទទួលបានប្រាក់រង្វាន់ជាថវិកាចំនួន ២០០លានរៀល។

តារាងទី៤÷ ចំណូល (អនុវត្តជាក់ស្តែង) របស់វិទ្យាល័យពេជ្រចិន្តា

ឯកតា÷ពាន់រៀល

ឆ្នាំសិក្សា	២០១៤-១៥	២០១៥-១៦	២០១៦-១៧	២០១៧-១៨	២០១៨-១៩
ថវិការដ្ឋ	១៤.៣៤៣,៨	១៨.៦៥៧,១	២៥.៦៦៨,០	២៣.៨២៧,០	៣១.៦០៦,០
ថវិកាដៃគូ	៦.៦០០,០	៧.៨៧៧,៥	៨.៣៣៤,៥	១១.៩០០,០	១២.២១៩,០
សហគមន៍	៨.៧០០,០	១២.៥០០,០	១៥.៨៥០,០	២៥.៤៧០,០	៣៦.៤៤០,០
ផ្សេងៗ	១.២០០,០	១.៧០០,០	២.៣០០,០	២.៧០០,០	២០៣.៥០០,០
សរុប	**៣០.៨៤៣,៨**	**៤០.៧៣៤,៦**	**៥២.១៥២,៥**	**៦៣.៨៩៧,០**	**២៨៣.៧៦៥,០**

ប្រភព÷ វិទ្យាល័យពេជ្រចិន្តា (ឆ្នាំ២០២០)

ជំពូកទី៣

➤ ចំណាយ

វិទ្យាល័យបានប្រើប្រាស់ថវិការដ្ឋសម្រាប់មុខសញ្ញាចំណាយចំនួនពីរ៖ គាំទ្រកិច្ចដំណើរការរដ្ឋបាល និងកែលម្អគុណភាពអប់រំ ដូចមានលម្អិតក្នុងតារាងទី៤។ ដោយឡែកថវិកាពីដៃគូត្រូវបានប្រើប្រាស់សម្រាប់កែលម្អគុណភាពអប់រំប៉ុណ្ណោះ។

តារាងទី៥៖ តារាងមុខសញ្ញាចំណាយ (ថវិការដ្ឋ)

ឯកតា៖ពាន់រៀល

ឆ្នាំសិក្សា	២០១៤-១៥	២០១៥-១៦	២០១៦-១៧	២០១៧-១៨	២០១៨-១៩
សរុបរួម	១៤.៣៤៣,៨	១៨.៦៥៧,១	២៥.៦៦៨,០	២៣.៨២៧,០	៣១.៦០៦,០
គាំទ្រ កិច្ចដំណើរការ រដ្ឋបាល	៩.៦៥០,៩	១០.២៩៦,៨	១៥.២០៨,០	១៤.៥៧៥,០	១៨.៤៩៨,០
កិច្ចដំណើរការ រដ្ឋបាល	៨.៧៥៧,១	៨.២៩៣,៥	១២.១៥៨,០	១០.៤៥០,០	១៥.៦២០,០
ការថែទាំនិង ជួសជុល	៨៩៣,៨	២.០០៣,៣	៣.០៥០,០	៤.១២៥,០	២.៨៧៨,០
កែលម្អ គុណភាពអប់រំ	៤.៦៩២,៩	៨.៣៦០,៣	១០.៤៦០,០	៩.២៥២,០	១៣.១០៨,០
ការចូលរៀន ដោយសមធម៌ និងបង្ការសិស្ស	៤៣៥,៥	១.៣១៧,១	១.៦២០,០	១.០០០,០	២.៥២០,០
សម្ភារៈរៀន និងបង្រៀន	១.៣៦៣,៩	១.៥៤៧,០	៣.៦០០,០	៤.៨២៧,០	៥.៣៦០,០
ការកែលម្អ បរិស្ថាន និង ទីធ្លាកម្សាន្ត	២.៨៩៥,៨	២.៤១៤,៨	១.០០០,០	២.៤០០,០	៤.១៧៨,០

ឆ្នាំសិក្សា	២០១៤-១៥	២០១៥-១៦	២០១៦-១៧	២០១៧-១៨	២០១៨-១៩
អប់រំបំណិនជីវិត កីឡា ការងារ យុវជន និងកុមារ	៣៩៧,៨	៣.០៨១,៤	៤.២៤០,០	១.០២៥,០	១.០២៥

ប្រភព៖ វិទ្យាល័យពេជ្រចិន្តា (ឆ្នាំ២០២០)

ខ. ការផ្ទេរសាច់ប្រាក់ចូលគណនីសាលារៀន

ថវិកាដំណើរការសាលារៀនរបស់វិទ្យាល័យត្រូវបានផ្ទេរជូនពីរដងក្នុងមួយឆ្នាំ គឺ លើកទី១ នៅខែកុម្ភៈ និងលើកទី២ នៅខែមិថុនានៃឆ្នាំនីមួយៗ ដោយផ្ទេរចូលគណនីរបស់សាលារៀនតាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។ ជានីតិវិធីហិរញ្ញវត្ថុ តាមរយៈការបូកសរុបពីការិយាល័យអប់រំ យុវជន និងកីឡាស្រុក មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ត្រូវធ្វើការស្នើសុំគោលការណ៍ចំណាយថវិកាដំណើរការសាលារៀន ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបន្ទាប់មកទៅរតនាគារខេត្ត ដើម្បីផ្ទេរថវិកាចូលក្នុងគណនីសាលារៀននីមួយៗ។

លំហូរថវិការដ្ឋ



បន្ទាប់ពីថវិកាត្រូវបានផ្ទេរចូលគណនីរបស់វិទ្យាល័យ ហេរញ្ញិករបស់វិទ្យាល័យត្រូវទៅធនាគារ ដើម្បីយកប័ណ្ណប្រកាសឥណទាន រួចសរសេរបិទផ្សាយចំនួនថវិកាដែលទទួលបានលើក្ដារខៀន ដើម្បីឱ្យមានតម្លាភាពលើការប្រើប្រាស់ថវិកា។

គ. ការប្រើប្រាស់ថវិកាដំណើរការសាលារៀន (ថវិការដ្ឋ)

ការដកសាច់ប្រាក់ពីធនាគារត្រូវធ្វើឡើងតាមមូលប្បទានបត្រ ដែលតម្រូវឱ្យមានស្នាមមេដៃចំនួនពីរ (នាយកវិទ្យាល័យ និងហេរញ្ញិក) ហើយម្នាក់ក្នុងចំណោមអ្នកទាំងពីរត្រូវជាអ្នកកាន់មូលប្បទានបត្រទៅដកសាច់ប្រាក់។ បន្ទាប់ពីទទួលបានសាច់ប្រាក់ ដើម្បីឱ្យការប្រើប្រាស់ថវិកាបានចំគោលដៅនិងស្របតាមតម្រូវការជាក់ស្តែង គណៈគ្រប់គ្រងសាលានឹងរៀបចំកិច្ចប្រជុំជាមួយនឹងប្រធានក្រុមបច្ចេកទេសទាំងអស់រួមទាំងលោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធ។ លោកគ្រូ អ្នកគ្រូ ដែលមានតម្រូវការសម្ភារៈបង្រៀន អាចបំពេញទម្រង់ពាក្យស្នើសុំបើកសាច់ប្រាក់មកនាយកសាលា។ ពេលទទួលបានការឯកភាពពីនាយកសាលា លោកគ្រូ អ្នកគ្រូ នឹងទទួលបានសាច់ប្រាក់ពីហេរញ្ញិកដើម្បីយកទៅទិញសម្ភារៈបង្រៀនដោយខ្លួនឯង ហើយត្រូវប្រគល់វិក្កយបត្រទិញមកវិញ។ ចំណែកខ្ទង់ផ្សេងៗទៀត នាយកបែងចែកទៅតាមមុខសញ្ញាចំណាយ តាមផែនការដែលបានគ្រោង។

ឃ. ការទូទាត់ និងរបាយការណ៍

សាលារៀនត្រូវមានផែនការ ការកត់ត្រាប្រតិបត្តិការចំណូល ចំណាយ (កិច្ចបញ្ជិកាគណនេយ្យ) ចូលក្នុងប្រព័ន្ធរៀបចំដោយនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា រួមនឹងរបាយការណ៍ចំណាយ (Statement of expenditures) ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្ត តាមរយៈការិយាល័យអប់រំ យុវជន និងកីឡាស្រុក។ រាល់សក្ខីបត្រចំណាយត្រូវបានរក្សាទុកនៅសាលារៀន សម្រាប់ជាកម្មវត្ថុនៃ ការធ្វើសវនកម្ម និងអធិការកិច្ចនៅពេលក្រោយ។

ង. បញ្ហាប្រឈម និងដំណោះស្រាយ

ជាទូទៅការអនុវត្តសកម្មភាពការងារនៅក្នុងខែមករា តែងជួបការលំបាកខ្លះៗ ដោយសារថវិកាដំណើរការសាលារៀនជុំទី១ ពុំទាន់ត្រូវបានផ្ទេរចូលក្នុងគណនីធនាគាររបស់សាលារៀននៅឡើយ។

ជាដំណោះស្រាយ វិទ្យាល័យប្រើប្រាស់វិធីសាស្ត្រខ្ចីថវិកាសហគមន៍ ឬជំពាក់ក្រុមហ៊ុន

ផ្គត់ផ្គង់សិនសម្រាប់ចំណាយដែលចាំបាច់ក្នុងខែមករា។ បំណុលនេះត្រូវបានទូទាត់សង ពេលដែលសាលារៀនទទួលបានថវិកា។

ម្យ៉ាងទៀតក្នុងការអនុវត្តសកម្មភាពការងារខ្លះ សាលាបានចាយលើសពីថវិកាដែលមានក្នុងផែនការ (ឆមាសទី១)។ ការណ៍នេះ អាចប៉ះពាល់ដល់ផែនការដែលត្រូវអនុវត្តសម្រាប់ឆមាសទី២។ ជាដំណោះស្រាយ វិទ្យាល័យខិតខំប្រឹងប្រែងស្វែងរកប្រភពធនធានផ្សេងៗដើម្បីមកបំពេញ ដូចជា តាមរយៈការអំពាវនាវទៅសហគមន៍ ឬតាមរយៈបុណ្យផ្កាសាមគ្គីជាដើម។ ការខិតខំអនុវត្តបែបនេះ គឺដើម្បីធានាថាផែនការដែលត្រូវអនុវត្តនៅឆមាសទី២ នៅតែអាចបន្តអនុវត្តបានតាមផែនការដែលបានកំណត់។

៣.២.៣.៣. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

ក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃនៃការអនុវត្តថវិកា វិទ្យាល័យតែងរៀបចំកិច្ចប្រជុំរៀងរាល់ត្រីមាស ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដើម្បីពិនិត្យលើការអនុវត្តថវិកា ធៀបទៅនឹងផែនការដែលបានដាក់ចេញ។ ក្រៅពីនេះ សាលារៀនក៏ធ្លាប់រងសវនកម្មពីក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាស្ថាប័នសវនកម្មផ្សេងៗទៀតផងដែរ។

វិទ្យាល័យពេជ្រចិន្តា មានលក្ខណៈដែលគួរឱ្យកត់សម្គាល់មួយចំនួន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាលារៀនរួមមាន÷

- **ភាពអ្នកដឹកនាំ÷** នាយកវិទ្យាល័យ និងគណៈគ្រប់គ្រងសាលារៀនមានភាពដឹកនាំប្រកបដោយគំនិតផ្តួចផ្តើម និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការដឹកនាំ និងអភិវឌ្ឍសាលារៀន។ ដើម្បីបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងការគ្រប់គ្រងថវិកាសាលាតែងមានកិច្ចប្រជុំជាទៀងទាត់ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធចាប់តាំងពីដំណាក់កាលរៀបចំគម្រោងថវិកា ដំណាក់កាលអនុវត្តថវិកា រហូតដល់ដំណាក់កាលនៃការត្រួតពិនិត្យ តាមដាន និងវាយតម្លៃថវិកា។ ក្រៅពីយន្តការ ដែលក្រសួងបានកំណត់ ថ្នាក់ដឹកនាំវិទ្យាល័យបានបង្កើតយន្តការផ្ទៃក្នុងថែមទៀត (គណៈកម្មការប្រើប្រាស់ថវិកានិងគណៈកម្មការគ្រប់គ្រងសម្ភារៈប្រើប្រាស់) ដើម្បី

ជំពូកទី៣

ឱ្យការប្រើប្រាស់ថវិកាកាន់តែមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

- **សហគមន៍**÷ សហគមន៍ចូលរួមនៅគ្រប់សកម្មភាពនៃការអភិវឌ្ឍវិទ្យាល័យ ជាពិសេសគឺការចូលរួមឧបត្ថម្ភគាំទ្រថវិកា និងសម្ភារៈក្នុងការអភិវឌ្ឍវិទ្យាល័យ។
- **មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស**÷ បានផ្តល់កិច្ចសហការ និងការគាំទ្រចូលរួមតាមគ្រប់រូបភាពដល់វិទ្យាល័យ។
- **អាជ្ញាធរ**÷ ការសម្របសម្រួល និងការគាំទ្រពីអាជ្ញាធរក៏ជាកត្តាដ៏សំខាន់មួយទៀតដែលបានចូលរួមដល់ការអភិវឌ្ឍសាលារៀន។ អាជ្ញាធរមូលដ្ឋាន (ខេត្ត មន្ទីរ ស្រុក ការិយាល័យ ភូមិ ឃុំ មេក្រុម) តែងតែផ្តល់ការសហការ និងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសាលារៀនមានដូចជា÷ការកៀរគរថវិកា និងសម្ភារៈក្នុងការអភិវឌ្ឍវិទ្យាល័យ ជួយឧបត្ថម្ភដល់សិស្សក្រីក្រ ការកៀរគរ និងផ្សព្វផ្សាយសិស្សឱ្យមកចុះឈ្មោះចូលរៀន ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការសិក្សា និងអាហារូបករណ៍ជាដើម។

៣.២.៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព

ស្ថានភាពទូទៅនៃការគ្រប់គ្រងបុគ្គលិក÷ ក្នុងឆ្នាំសិក្សា២០១៨-២០១៩ វិទ្យាល័យពេជ្រចិន្តាមានបុគ្គលិកអប់រំសរុបចំនួន ៣៨នាក់ ស្រី ១២នាក់ ដែលនៅក្នុងនោះមានគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិចំនួន ២០នាក់ ស្រី ០៥នាក់ គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិចំនួន ១៨នាក់ ស្រី ០៦នាក់។ សាលារៀនមានសិស្សសរុបចំនួន ១.២៥៩នាក់ ស្រី ៣២៣នាក់។ ដោយសារកំណើនសិស្សពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងឆ្នាំសិក្សា២០១៨-២០១៩ វិទ្យាល័យខ្វះបុគ្គលិកអប់រំរហូតដល់ ១៦នាក់ ដែលជាគ្រូបង្រៀនលើមុខវិជ្ជាឯកទេសមួយចំនួននៅថ្នាក់មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ កត្តានេះបានធ្វើឱ្យគណៈគ្រប់គ្រងសាលារៀនពេជ្រចិន្តា តម្រូវឱ្យបុគ្គលិកអប់រំទាំងអស់ត្រូវបង្រៀនច្រើនមុខវិជ្ជា និងបុគ្គលិកអប់រំមួយចំនួនទៀតត្រូវបំពេញការងារជាគណៈគ្រប់គ្រងសាលារៀនផង និងគ្រូបង្រៀនផង បុគ្គលិកមួយចំនួនទៀតជា បណ្ណារក្សផង និងជាគ្រូបង្រៀនផង និងបុគ្គលិកមួយចំនួន

ទៀតត្រូវបំពេញការងារជាអ្នករដ្ឋបាលផង និងជាគ្រូបង្រៀនផង។ បន្ថែមពីនេះ គ្រូបង្រៀនមួយចំនួនបានស្ម័គ្រចិត្តបំពេញការងារ ឬបង្រៀនបន្ថែមម៉ោងលើសពីនិយាមម៉ោងកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា ហើយគ្រូបង្រៀនមួយចំនួនទៀតត្រូវបង្រៀនខុសទៅនឹងមុខវិជ្ជាឯកទេសដើមរបស់ខ្លួន។

ទោះបីជាវិទ្យាល័យស្ថិតនៅក្នុងស្ថានភាពខ្វះបុគ្គលិកអប់រំក៏ដោយ ក៏គណៈគ្រប់គ្រងបានរៀបចំគ្រប់គ្រង និងចាត់ចែងបុគ្គលិកអប់រំរបស់ខ្លួនឱ្យបំពេញការងារ ជាពិសេសគឺការបង្រៀននិងរៀននៅក្នុងវិទ្យាល័យប្រកបដោយស័ក្តិសិទ្ធភាព។ វិទ្យាល័យពេជ្រចិន្តាបានផ្តល់សេវាអប់រំដល់សិស្សានុសិស្ស និងសហគមន៍ប្រកបដោយ បរិយាបន្ន សមធម៌ និងគុណភាព ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈលទ្ធផលនៃការសិក្សារបស់សិស្ស។ ឆ្នាំសិក្សា ២០១៨-២០១៩ អត្រាប្រឡងជាប់មធ្យមសិក្សាបឋមភូមិខ្ពស់ចំនួន ៩៦,៤៧% មធ្យមសិក្សាទុតិយភូមិខ្ពស់ចំនួន ៩៤,២៥% ដែលនៅក្នុងមានសិស្សទទួលបាននិទ្ទេស A ចំនួន ០៣នាក់ និងអត្រាបោះបង់ការសិក្សារបស់សិស្សទាបចំនួន ៣,៥% និងត្រូវបានគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំវាយតម្លៃជាប់ជ័យលាភីលេខ១ ជាវិទ្យាល័យផ្តល់សេវាអប់រំគំរូក្នុងវិស័យអប់រំ និងទទួលជ័យលាភីផ្សេងៗទៀតជាច្រើនផ្សេងទៀតពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងបរិស្ថាន។

បុគ្គលិកអប់រំដែលកំពុងបម្រើការនៅវិទ្យាល័យពេជ្រចិន្តាភាគច្រើន គឺជាអ្នកមកពីចម្ងាយ។ ក៏ប៉ុន្តែ ទាំងគណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន ក៏ដូចជាបុគ្គលិកអប់រំបង្រៀន និងមិនបង្រៀន បានខិតខំបន្តការសិក្សា និងសិក្សារៀនសូត្រជាប្រចាំ ដើម្បីអភិវឌ្ឍន៍វិជ្ជាជីវៈរបស់ខ្លួនតាមរយៈការបន្តការសិក្សា នៅតាមសាកលវិទ្យាល័យ ចូលរួមវគ្គបណ្តុះបណ្តាល និងធ្វើទស្សនកិច្ចសិក្សា ក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្សនៅវិទ្យាល័យពេជ្រចិន្តាឱ្យឆ្លើយតបនឹងការអប់រំសតវត្សទី២១ រហូតដល់វិទ្យាល័យមានបុគ្គលិកអប់រំដែលមានគុណវុឌ្ឍិអប់រំខ្ពស់ និងបំពេញការងារប្រកបដោយភាពច្នៃប្រឌិត និងគុណភាពការងារខ្ពស់។ ក្នុងចំណោមបុគ្គលិកទាំងអស់ចំនួន ៣៨នាក់

ជំពូកទី៣

បុគ្គលិកដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ០៥នាក់ សញ្ញាបត្របរិញ្ញាបត្រមានចំនួន ២៨នាក់ កំពុងបន្តការសិក្សាយកបរិញ្ញាបត្រមានចំនួន ០២នាក់ និងបុគ្គលិកអប់រំមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានចំនួនតែ ០៣នាក់ប៉ុណ្ណោះ។

៣.២.៤.១. ការគ្រប់គ្រងធនធានមនុស្ស

ក. ការធ្វើផែនការធនធានមនុស្ស

➤ ការវិភាគពីតម្រូវការ

នៅដើមឆ្នាំសិក្សា បន្ទាប់ពីបានទទួលពាក្យស្នើសុំចូលរៀនពីសិស្សរួច គណៈគ្រប់គ្រងសាលារៀន ជាពិសេសលោកនាយករងទទួលបន្ទុកបច្ចេកទេស បានរៀបចំធ្វើបំណែងចែកថ្នាក់រៀននៅតាមកម្រិតថ្នាក់នីមួយៗដោយគិតទៅតាមនិយាមសមាមាត្រចំនួនសិស្ស និងចំនួនគ្រូដែលមាននៅក្នុងសាលារៀនដោយអនុលោមទៅតាមសេចក្តីណែនាំលេខ២៥៦[១១] និងអនុក្រឹត្យលេខ១០[១២]។ បន្ទាប់ពីរៀបចំបែងចែកចំនួនថ្នាក់រៀនរួច នាយករងទទួលបន្ទុកបច្ចេកទេសតាមរយៈលោកនាយកវិទ្យាល័យបានរៀបចំធ្វើរបាយការណ៍ជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តពីតម្រូវការគ្រូបង្រៀន ដែលលើស និងខ្វះនៅតាមមុខវិជ្ជាឯកទេសនីមួយៗ និងតាមកម្រិតថ្នាក់ (មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ) ដោយមានការចុះហត្ថលេខាឯកភាព និងយល់ព្រមពីនាយកវិទ្យាល័យ។

លក្ខណៈដែលគួរឱ្យកត់សម្គាល់សម្រាប់ការចាត់ចែងគ្រូបង្រៀនឱ្យបង្រៀន តាមមុខវិជ្ជាឯកទេសនីមួយៗ ការបង្រៀនម៉ោងបន្ថែម និងការបង្រៀនតាមថ្នាក់នីមួយៗគឺទាំងនាយកវិទ្យាល័យ និងនាយករងទទួលបន្ទុកបច្ចេកទេសមិនបានធ្វើការចាត់ចែង ឬចាត់តាំងដោយខ្លួនឯងផ្ទាល់នោះទេ គឺបានប្រគល់សិទ្ធិអំណាចនៃការចាត់ចែងនេះទៅឱ្យប្រធាន

[១១] សេចក្តីណែនាំលេខ ២៥៦ ស្តីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យរបស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២។

[១២] អនុក្រឹត្យលេខ ១០ អនក្រ.បក ស្តីពីការកម្រិតរបបម៉ោងកំណត់ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧។

ក្រុមបច្ចេកទេសដើម្បីរៀបចំចាត់ចែងគ្រូបង្រៀនដែលស្ថិតនៅក្នុងក្រុមបច្ចេកទេសរបស់ខ្លួនផងដែរ។ ការជ្រើសរើសគ្រូបង្រៀនម៉ោងបន្ថែមទៅលើមុខវិជ្ជាឯកទេសដែលខុសពីមុខវិជ្ជាឯកទេសដើម ក៏ត្រូវបានរៀបចំ និងចាត់ចែងដោយប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជានីមួយៗ។

ក្នុងការរៀបចំការវិភាគពីតម្រូវការបុគ្គលិកនៅក្នុងវិទ្យាល័យគណៈគ្រប់គ្រងសាលារៀនជាពិសេសលោកនាយកមិនដែលបានធ្វើការអនុម័តដោយឯកឯង តែក្នុងចំណោមគណៈគ្រប់គ្រងសាលារៀននោះទេ ពោលគឺគណៈគ្រប់គ្រងសាលារៀន តែងតែអនុវត្តទៅតាមស្មារតីសម្រេចចិត្តរួមនៃអង្គប្រជុំ មុននឹងធ្វើរបាយការណ៍ផ្ញើជូនទៅការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តពីតម្រូវការរបស់បុគ្គលិកអប់រំ។

➤ ការពិភាក្សាលើសេចក្ដីព្រាងនៃផែនការ

ដោយសារតែវិទ្យាល័យពេជ្រចិន្តានៅខ្វះបុគ្គលិកអប់រំ សម្រាប់ការរៀបចំកាលវិភាគបង្រៀន និងចំនួនម៉ោងបង្រៀនសម្រាប់លោកគ្រូ អ្នកគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀនមានបញ្ហាប្រឈមជាច្រើនរួមមាន៖ ១) សាលាតម្រូវឱ្យគ្រូបង្រៀនមួយចំនួនបង្រៀនម៉ោងបន្ថែមលើសពីម៉ោង ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ២) គណៈគ្រប់គ្រងសាលាត្រូវជ្រើសរើសគ្រូបង្រៀនមួយចំនួនទៀតឱ្យបង្រៀនម៉ោងបន្ថែមទៅលើមុខវិជ្ជាឯកទេស ដែលមិនមែនជាមុខវិជ្ជាឯកទេសដើមរបស់ខ្លួន ៣) គ្រូបង្រៀនដែលបង្រៀនម៉ោងបន្ថែមនឹងត្រូវទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលទៅតាមចំនួនម៉ោងដែលគាត់បង្រៀន និងគុណវុឌ្ឍិគ្រូ ដោយយោងទៅលើអនុក្រឹត្យលេខ១០[១៣] (គ្រូមធ្យមសិក្សាទុតិយភូមិទទួលការឧបត្ថម្ភចំនួន ១០.៤០០ រៀលក្នុង១ម៉ោងសិក្សា និងគ្រូមធ្យមសិក្សាបឋមភូមិទទួលបានការឧបត្ថម្ភចំនួន ៥.៥០០រៀលក្នុង១ម៉ោងសិក្សា) ដែលនឹងអាច

[១៣] អនុក្រឹត្យលេខ ១០ អនក្រ.បក ស្ដីពីការកម្រិតរបបម៉ោងកំណត់ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧

ធ្វើឱ្យមានទំនាស់ផលប្រយោជន៍កើតឡើងនៅក្នុងចំណោមគណៈគ្រប់គ្រងសាលារៀន និងបុគ្គលិកអប់រំនៅក្នុងវិទ្យាល័យ។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ គណៈគ្រប់គ្រងសាលារៀនពេជ្រចិន្តា បានប្រជុំពិភាក្សាគ្នាធ្វើសេចក្ដីព្រាងផែនការធនធានមនុស្សក្នុងចំណោមបុគ្គលិកអប់រំទាំងអស់ប្រកបដោយតម្លាភាព និងគោរពស្មារតីសម្រេចចិត្តរួមនៅក្នុងវិទ្យាល័យក្នុងការជ្រើសរើសគ្រូបង្រៀនឱ្យបង្រៀននៅមុខវិជ្ជាណាមួយ។

យន្តការនៃការជ្រើសរើសគ្រូបង្រៀនសម្រាប់បង្រៀនម៉ោងបន្ថែមមុខវិជ្ជាណាមួយ គណៈគ្រប់គ្រងសាលារៀនក៏មិនដែលធ្វើការចាត់តាំង និងជ្រើសរើសដោយខ្លួនឯងនោះទេ ពោលគឺធ្វើឡើងទៅតាមឋានានុក្រមការងារ និងបានប្រគល់សិទ្ធិក្នុងការជ្រើសរើសទៅឱ្យប្រធានក្រុមបច្ចេកទេសនៃមុខវិជ្ជានីមួយៗជាអ្នកជ្រើសរើស និងចាត់ចែងមុននឹងស្នើមកគណៈគ្រប់គ្រងសាលា ដើម្បីប្រជុំសម្រេចជាចុងក្រោយជាមួយគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនទាំងអស់។ ចំណែកឯប្រធានក្រុមបច្ចេកទេសបានអនុវត្តការជ្រើសរើសគ្រូបង្រៀនម៉ោងបន្ថែម ដោយយោងទៅលើលទ្ធផលនៃការសិក្សារបស់សិស្សកាលពីឆ្នាំកន្លងមក ពោលគឺពួកគាត់មិនបានជ្រើសរើសគ្រូបង្រៀនបន្ថែមម៉ោងដោយគ្មានគោល-ការណ៍ ឬតាមការចូលចិត្ត និងប្រកាន់បក្សពួករបស់ខ្លួនឡើយ។ សម្រាប់គ្រូបង្រៀនម៉ោងបន្ថែមខុសទៅនឹងមុខវិជ្ជាដើមរបស់ខ្លួន គោលការណ៍នៃការជ្រើសរើសយោងទៅតាមការស្ម័គ្រចិត្តរបស់លោកគ្រូ អ្នកគ្រូ លទ្ធផលនៃការសិក្សារបស់សិស្សកាលពីឆ្នាំកន្លងមក និងគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គមអាចជ្រើសរើសបង្រៀនបានតែមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ហើយគ្រូបង្រៀនវិទ្យាសាស្ត្រអាចជ្រើសរើសបង្រៀនបានតែមុខវិជ្ជាវិទ្យាសាស្ត្រពិតប៉ុណ្ណោះ។ បន្ទាប់ពីប្រធានក្រុមបច្ចេកទេសបានជ្រើសរើសរួចត្រូវដាក់ស្នើមកគណៈគ្រប់គ្រងសាលា។ បន្ទាប់មក គណៈគ្រប់គ្រងសាលារៀននិងលោកគ្រូ អ្នកគ្រូបានប្រជុំសម្រេចការរៀបចំកាលវិភាគបង្រៀនសម្រាប់ឆ្នាំសិក្សានីមួយៗ។ បន្ថែមពីនេះ ដើម្បីធ្វើឱ្យគុណភាពនៃការបង្រៀន និងរៀននៅវិទ្យាល័យនៅតែរក្សាបានល្អប្រសើរ បើទោះបីជាបុគ្គលិកអប់រំខ្វះក៏ដោយ បន្ទាប់ពីរៀបចំកាលវិភាគរួចមក គណៈគ្រប់គ្រងសាលាបាន

បញ្ចូលបញ្ហាខ្វះបុគ្គលិកនេះទៅក្នុងផែនការនៃការអភិវឌ្ឍសាលារៀនដោយផ្ដោតលើការជួយពង្រឹងបំប៉នសមត្ថភាពបន្ថែម និងផែនការបណ្ដុះបណ្ដាលដល់គ្រូបង្រៀនដែលត្រូវបង្រៀនម៉ោងបន្ថែមទៅលើមុខវិជ្ជាឯកទេស ដែលមិនមែនជាមុខវិជ្ជាឯកទេសដើមរបស់ខ្លួន។ ការអនុវត្តយន្តការបែបនេះបានធ្វើឱ្យបុគ្គលិកអប់រំនៅវិទ្យាល័យពេជ្រចិន្តាមានសាមគ្គីភាពផ្ទៃក្នុងល្អ មិនមានទំនាស់ផលប្រយោជន៍ ចេះជួយគ្នាទៅវិញទៅមកដោយមិនប្រកាន់បក្សពួក ជាពិសេសគឺការចែករំលែកចំណេះដឹងមុខវិជ្ជានៃការបង្រៀនរវាងគ្រូ និងគ្រូដែលជាកត្តានាំឱ្យការបង្រៀន និងរៀននៅវិទ្យាល័យនៅតែរក្សាបាននូវគុណភាពនិងប្រសិទ្ធភាព ទោះបីខ្វះគ្រូបង្រៀននៅតាមមុខវិជ្ជាឯកទេសនីមួយៗ។

ខ. ការគ្រប់គ្រងគុណផល

➢ ការរៀបចំរចនាសម្ព័ន្ធដឹកនាំរបស់អង្គភាព

ការរៀបចំរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រង ត្រូវបានអនុវត្តទៅតាមអនុក្រឹត្យលេខ ១១៤[១៤] និងសេចក្ដីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

រចនាសម្ព័ន្ធដឹកនាំរួមមាន គណៈគ្រប់គ្រងសាលារៀនដែលដឹកនាំដោយនាយកសាលាមួយរូប និងនាយករងពីររូបដែលនៅក្នុងនោះនាយកសាលាមានតួនាទីជាអ្នកទទួលបន្ទុកក្ដាប់ការងាររួម នាយករងមួយរូបទទួលបន្ទុកបច្ចេកទេស និងនាយករងមួយរូបទៀតទទួលបន្ទុករដ្ឋបាល និងយុវជន។ ជាមួយគ្នានេះ នាយករងទទួលបន្ទុកផ្នែករដ្ឋបាល និងយុវជនមានតួនាទីដឹកនាំ និងគ្រប់គ្រងការងាររដ្ឋបាលសាលារៀនរួមមានលេខា បេឡាហេរញ្ញិក និងបណ្ណារក្ស។ ចំណែកឯនាយករងទទួលបន្ទុកបច្ចេកទេសមានតួនាទីដឹកនាំនិងគ្រប់គ្រងក្រុមបច្ចេកទេសចំនួនបីក្រុមរួមមាន÷ ១)ក្រុមបច្ចេកទេសមុខវិជ្ជាវិទ្យាសាស្ត្រពិត ២)ក្រុមបច្ចេកទេសភាសា និង៣)ក្រុមបច្ចេកទេសមុខវិជ្ជាវិទ្យាសាស្ត្រសង្គម។

លើសពីនេះ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារ ក៏ដូចជាដើម្បីធ្វើឱ្យវិទ្យាល័យ

[១៤] អនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥

មានការអភិវឌ្ឍនៅគ្រប់ផ្នែកទាំងអស់ វិទ្យាល័យក៏នៅមានការរៀបចំរចនាសម្ព័ន្ធដឹកនាំ គណៈកម្មការ និងក្រុមការងារផ្ទៃក្នុងមួយចំនួនទៀត ដែលជាការជួយគាំទ្រដល់សកម្មភាពនានារបស់វិទ្យាល័យផងដែរ។ គណៈកម្មការ និងក្រុមការងារផ្ទៃក្នុងទាំងនេះរួមមាន÷

- គណៈកម្មការគ្រប់គ្រងសាលារៀន
- គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការវិទ្យាល័យ
- ក្រុមការងារសង្គ្រោះបឋម
- ក្រុមការងារបរិស្ថាន
- ក្រុមការងារទទួលបន្ទុកបណ្ណាល័យ
- ក្រុមការងារទទួលបន្ទុកអន្តេវាសិកដ្ឋានសិស្ស
- ក្រុមការងារគ្រប់គ្រងបន្ទប់ និង ការបណ្តុះបណ្តាលកុំព្យូទ័រ
- ក្រុមប្រឹក្សាយុវជន
- ក្លឹបសិក្សាតាមមុខវិជ្ជា
- ក្រុមកាយវិទ្ធិ
- ក្រុមកាកបាទក្រហម

គណៈកម្មការ និងក្រុមផ្ទៃក្នុងនីមួយៗក៏មានរៀបចំរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រង ដែលក្នុងនោះដឹកនាំដោយប្រធានមួយរូប និងសមាជិកក្រុមមួយចំនួនទៅតាមការចាំបាច់។ ក្នុងការរៀបចំគណៈកម្មការនិងក្រុមផ្ទៃក្នុងទាំងនេះ មួយចំនួនរៀបចំឡើងដោយយោងទៅតាមគោលការណ៍ និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងមួយចំនួនទៀតត្រូវបានបង្កើតឡើយដោយអនុលោមទៅតាមតម្រូវការជាក់ស្តែងរបស់វិទ្យាល័យ។ សមាសភាពនៃគណៈកម្មការ និងក្រុមទាំងនេះក៏មានសមាសភាពចូលរួមពីសហគមន៍ អាជ្ញាធរដែនដី និងសិស្សនៅក្នុងវិទ្យាល័យផងដែរ។

រូបភាពទី៥៖ រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងវិទ្យាល័យពេជ្រចិន្តា



➢ ការកំណត់ការពិពណ៌នាមុខតំណែង និងការបែងចែកការងារ

វិទ្យាល័យពេជ្រចិន្តាមិនត្រឹមតែមានរចនាសម្ព័ន្ធនៃការដឹកនាំ និងគ្រប់គ្រងសាលារៀនច្បាស់លាស់ ប៉ុណ្ណោះទេ តែវិទ្យាល័យបានអនុវត្តការងារដោយគោរពតាមរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងរបស់ខ្លួនដែលបានបង្កើតឡើងយ៉ាងខ្ជាប់ខ្ជួន។ ដើម្បីជួយសម្រួលដល់ការចាត់ចែងការងារ និងជៀសវាងនូវកង្វះចន្លោះការងារ និងការជាន់ភារកិច្ចគ្នា ទាំងបុគ្គលិកអប់រំ តំណាងសហគមន៍ និងអាជ្ញាធរដែនដី ដែលត្រូវបានជ្រើសរើសឱ្យទៅកាន់មុខតំណែងណាមួយនៅក្នុងគណៈកម្មការ និងក្រុមដែលត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការអភិវឌ្ឍសុទ្ធតែមានការពិពណ៌នាពីតួនាទី និងភារកិច្ចរបស់ខ្លួនដែលត្រូវអនុវត្តដោយរាប់ចាប់តាំងពីតួនាទី និងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងសាលារៀន នាយក នាយករងទទួលបន្ទុកបច្ចេកទេស នាយករងទទួលបន្ទុករដ្ឋបាល និងយុវជន លេខា ប្រធានក្រុមបច្ចេកទេស គ្រូទទួលបន្ទុកថ្នាក់ ក្រុមប្រឹក្សាយុវជន ក្រុមកាយរឹទ្ធិ ក្រុមកាកបាទក្រហម និងក្រុមបរិស្ថានជាដើម។ ការពិពណ៌មុខតំណែងត្រូវបានរៀបចំ និងបោះត្រាទទួលស្គាល់ពីតួនាទី និងភារកិច្ចដោយនាយកសាលា និងបានបិទផ្សាយនៅតាមកន្លែងដែលខ្លួនត្រូវបំពេញការងាររៀងៗខ្លួន។ បន្ថែមពីលើការពិពណ៌នាពីមុខតំណែង គណៈគ្រប់គ្រងសាលារៀន ជាពិសេសលោកនាយកវិទ្យាល័យបានធ្វើវិមជ្ឈការអំណាច និងសិទ្ធិក្នុងការដឹកនាំគ្រប់គ្រង និងចាត់ចែងការអនុវត្តការងារទៅតាមឋានានុក្រមការងារ ព្រមទាំងបានផ្តល់សិទ្ធិ និងអំណាចនៃការសម្រេចចិត្តទៅឱ្យគណៈកម្មការ ក្រុម និងបុគ្គលិកអប់រំ ដែលទទួលបាន មុខតំណែង តួនាទី និងភារកិច្ចនោះក្នុងការចាត់ចែងការងារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនដោយផ្ទាល់ ពោលគឺគណៈគ្រប់គ្រងសាលារៀន ក៏ដូចជានាយកវិទ្យាល័យ មានតួនាទីជាអ្នកចាំជួយសម្របសម្រួល ដោះស្រាយបញ្ហាប្រឈមនៅពេលពួកគាត់ស្នើសុំតែប៉ុណ្ណោះ។ បន្ថែមពីលើនេះ គ្រប់គណៈកម្មការ ក្រុម និងបុគ្គលិកអប់រំដែលទទួលបានតួនាទី និងភារកិច្ចទាំងនោះមានការដឹកនាំ និងគ្រប់គ្រងកិច្ចការរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់។

បុគ្គលិកអប់រំនៅវិទ្យាល័យពេជ្រចិន្តា ទាំងបុគ្គលិកបង្រៀន និងមិនបង្រៀន ត្រូវបានរៀបចំជ្រើសរើស និងធ្វើបំណែងចែកការងារដោយគោរពទៅតាមគោលការណ៍ និងលក្ខខណ្ឌសំខាន់ៗរបស់វិទ្យាល័យចំនួន៣ រួមមាន៖ ១) មានជំនាញឯកទេសច្បាស់លាស់ ២) មានឧបនិស្ស័យនឹងការងារ និង ៣) គោលការណ៍ស្ម័គ្រចិត្ត។ គ្រប់គ្រូបង្រៀនទាំងអស់ ត្រូវបានជ្រើសរើសឱ្យបង្រៀនដោយផ្អែកទៅតាមមុខវិជ្ជាជំនាញឯកទេសរបស់ខ្លួនជាមុនសិន មុននឹងជ្រើសរើសគាត់ឱ្យទៅបង្រៀនលើមុខវិជ្ជាដែលមិនមែនជាមុខវិជ្ជាឯកទេសរបស់ខ្លួន។ សម្រាប់ការជ្រើសរើសគ្រូបង្រៀនឱ្យទៅបង្រៀនលើមុខវិជ្ជាណាមួយដែលមិនមែនជាមុខវិជ្ជាឯកទេសដើមរបស់ខ្លួន ឬឱ្យទៅកាន់តំណែងការងារណាមួយនៅក្នុងរដ្ឋបាលសាលារៀន គណៈកម្មការ ឬក្រុមការងារ គណៈគ្រប់គ្រងសាលារៀនបានធ្វើការជ្រើសរើសតាមរយៈគោលការណ៍ស្ម័គ្រចិត្ត និងទៅតាមឧបនិស្ស័យរបស់បុគ្គលិកអប់រំនោះ។ ជាឧទាហរណ៍ លោកគ្រូដែលកាន់ការងារជាបណ្ណារក្សរបស់វិទ្យាល័យ គាត់ត្រូវបានគណៈគ្រប់គ្រងសាលារៀនជ្រើសរើសឱ្យកាន់តួនាទីជាអ្នកគ្រប់គ្រងបណ្ណាល័យទៅតាមគោលការណ៍ស្ម័គ្រចិត្ត និងឧបនិស្ស័យ។ ដោយសារវិទ្យាល័យខ្វះបុគ្គលិកអប់រំសម្រាប់កាន់ការងារជាបណ្ណារក្ស លោកគ្រូបង្រៀនភាសាខ្មែរម្នាក់ គាត់ស្រលាញ់ការងារជាបណ្ណារក្ស បានស្ម័គ្រចិត្តបំពេញការងារជាបណ្ណារក្សផង និងជាគ្រូបង្រៀនភាសាខ្មែរផង។ ការស្រលាញ់ការងារបណ្ណាល័យរបស់លោកគ្រូ បានធ្វើឱ្យគាត់ខំបំពេញការងារជាបណ្ណារក្សរបស់វិទ្យាល័យ និងបណ្ណាល័យមានដំណើរការយ៉ាងល្អ និងជាទៀងទាត់ដោយចាប់បើកដំណើរការពីម៉ោងប្រាំពីរព្រឹក រហូតម៉ោងប្រាំរសៀលពីថ្ងៃចន្ទដល់ថ្ងៃសៅរ៍។

យន្តការនៃការដឹកនាំ និងគ្រប់គ្រងអង្គភាពរបស់វិទ្យាល័យ គឺអនុវត្តតាមគោលការណ៍ «**សមូហភាពជាអ្នកដឹកនាំ សមូហភាពជាអ្នកសម្រេចចិត្ត បុគ្គលជាអ្នកទទួលខុសត្រូវ**»។ នៅវិទ្យាល័យពេជ្រចិន្តា រាល់ការសម្រេចចិត្តក្នុងការអនុវត្តកិច្ចការអ្វីមួយនៅក្នុងសាលារៀន គឺគោរពទៅតាមស្មារតីសម្រេចរបស់អង្គប្រជុំ ពោលគឺគណៈគ្រប់គ្រងសាលាមិនអាចធ្វើការសម្រេចចិត្តធ្វើអ្វីមួយដោយឯកឯងបាននោះទេ ហើយប្រសិនបើការសម្រេចចិត្តធ្វើការងារ

ជំពូកទី៣

អ្វីមួយនៅក្នុងវិទ្យាល័យដោយមិនមានការឯកភាពគ្នាទាំងស្រុងនៅក្នុងអង្គប្រជុំ កិច្ចការនោះត្រូវបានសម្រេចតាមរយៈការបោះឆ្នោតដោយគោរពទៅតាមមតិភាគច្រើនរបស់អង្គប្រជុំ។ ការអនុវត្តរបៀបនេះបានធ្វើឱ្យបុគ្គលិកអប់រំម្នាក់ៗបានបំពេញការងារដោយមានការទទួលខុសត្រូវខ្ពស់ប្រកបដោយគុណភាព និងមានសាមគ្គីភាពផ្ទៃក្នុងល្អ។

➤ **ការគ្រប់គ្រងវត្តមានបានទៀងទាត់**

វិទ្យាល័យបានគ្រប់គ្រងវត្តមានបុគ្គលិកអប់រំ ក៏ដូចជាសិស្សបានជាទៀងទាត់តាមរយៈការរៀបចំបញ្ជីវត្តមាន លេខទូរសព្ទទំនាក់ទំនង និងការរៀបចំក្រុមទំនាក់ទំនងតាមបណ្ដាញសង្គម (តេឡេក្រាម និងទំព័រហ្វេសប៊ុករបស់វិទ្យាល័យ)។ សម្រាប់បុគ្គលិកអប់រំការគ្រប់គ្រងវត្តមានបានអនុវត្តដោយតម្រូវឱ្យបុគ្គលិកអប់រំម្នាក់ៗ ចុះហត្ថលេខានៅក្នុងបញ្ជីវត្តមានជាទៀងទាត់នៅមុនម៉ោងពេលចូលធ្វើការងារ និងនៅមុនពេលចេញពីកន្លែងធ្វើការងារ។ នៅពេលព្រឹក សាលារៀនអនុវត្តម៉ោងចូលរៀននៅម៉ោងប្រាំពីរព្រឹក ចេញនៅម៉ោងដប់មួយព្រឹក និងនៅពេលរសៀល ចូលរៀននៅម៉ោងមួយរសៀល និងចេញនៅម៉ោងប្រាំរសៀល។ នៅពេលដែលគ្រូបង្រៀនជាប់ភារកិច្ចរវល់ និងមានទុក្ខធុរៈមិនអាចមកបំពេញការងារបានត្រូវសរសេរពាក្យស្នើសុំច្បាប់ឈប់សម្រាកការងារ និងក្នុងករណីបន្ទាន់ត្រូវសុំច្បាប់តាមរយៈទូរសព្ទមកសុំគណៈគ្រប់គ្រងសាលារៀនជាមុន បន្ទាប់មកទើបធ្វើយុត្តិកម្មជាក្រោយ។ សម្រាប់ការគ្រប់គ្រងវត្តមាននៅតាមថ្នាក់រៀន ក្នុងករណីដែលគ្រូបង្រៀនណាម្នាក់អវត្តមានមិនបានមកបង្រៀននៅក្នុងម៉ោងបង្រៀនរបស់ខ្លួនដោយមិនដឹងមូលហេតុ ប្រធានថ្នាក់ត្រូវរាយការណ៍ជូនគណៈគ្រប់គ្រងសាលា ហើយគណៈគ្រប់គ្រងសាលារៀននឹងធ្វើទំនាក់ទំនងតាមលេខទូរសព្ទទៅគ្រូបង្រៀនភ្លាម។

ចំពោះសិស្សានុសិស្សវិញ ក្រៅពីរៀបចំសៀវភៅចុះសម្រង់អវត្តមានសិស្ស នៅតាមថ្នាក់រៀននីមួយៗ វិទ្យាល័យបានរៀបចំបិទស្លាកសញ្ញាសម្គាល់ឈ្មោះសិស្ស និងលេខទូរសព្ទមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សនៅតាមប្លង់តុនីមួយៗដែលសិស្សអង្គុយ។ ការធ្វើរបៀបនេះធ្វើឱ្យវិទ្យាល័យគ្រប់គ្រងអវត្តមានរបស់សិស្សប្រកបដោយប្រសិទ្ធភាពខ្ពស់

ជាពិសេសគឺសិស្សានុសិស្សដែលមានបំណងចង់គេចវេសពីសាលារៀននៅក្នុងម៉ោងបង្រៀនណាមួយ ដើម្បីទៅដើរលេងនៅខាងក្រៅដោយមាតាបិតា ឬអាណាព្យាបាលមិនបានដឹង។ នៅដើមម៉ោងសិក្សានីមួយៗ មុនពេលចាប់ផ្តើមបង្រៀន ប្រសិនបើគ្រូបង្រៀនពិនិត្យអវត្តមានសិស្ស ហើយរកឃើញថាសិស្សណាម្នាក់អវត្តមាន ដោយមិនមានការសុំច្បាប់អនុញ្ញាត និងមិនដឹងមូលហេតុច្បាស់លាស់ តាមរយៈទូរសព្ទដែលមានបិទនៅតាមប្លង់តុរបស់សិស្ស គ្រូបង្រៀននឹងទូរសព្ទទៅរកមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សនោះភ្លាម ដើម្បីជម្រាបសួរគាត់ពីមូលហេតុអវត្តមានការសិក្សារបស់កូនគាត់។

យន្តការនៃការផ្តល់ព័ត៌មានត្រឡប់ជូនមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សតាមរយៈទូរសព្ទនៅក្នុងកំឡុងពេលបង្រៀន និងរៀននេះ គឺគណៈគ្រប់គ្រងសាលារៀនបានរៀបចំប្រជុំ និងសម្រេចអនុវត្តដោយបានផ្តល់ថ្លៃកាតទូរសព្ទជូនទៅលោកគ្រូ អ្នកគ្រូ ដែលបានទូរសព្ទផ្តល់ព័ត៌មានត្រឡប់ទៅឱ្យមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សតាមរយៈថវិកាឧបត្ថម្ភរបស់មាតាបិតាសិស្ស និងសហគមន៍។ ប៉ុន្តែនៅក្នុងការអនុវត្តការងារជាក់ស្តែងនាពេលកន្លងមក បុគ្គលិកអប់រំស្ទើរតែទាំងអស់នៅក្នុងវិទ្យាល័យបានស្ម័គ្រចិត្តចំណាយថវិកាផ្ទាល់ខ្លួនក្នុងការទូរសព្ទទៅមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស ដោយមិនបានទាមទារការឧបត្ថម្ភថវិកាពីសាលារៀនឡើយ។

- **ប្រព័ន្ធវាយការណ៍ពីគុណផលនៃការងារ**

ប្រព័ន្ធវាយការណ៍ពីគុណផលនៃការងារជាផ្នែកមួយនៃការដឹកនាំ និងការគ្រប់គ្រងដោយផ្អែកទៅលើលទ្ធផលការងារ ដែលរួមមានការងាររៀបចំផែនការយុទ្ធសាស្ត្រ ផែនការការអនុវត្តការងាររបស់ស្ថាប័ន ការតាមដានត្រួតពិនិត្យ ការរាយការណ៍ និងការវាយតម្លៃគុណផលការងារមន្ត្រី ការអភិវឌ្ឍមន្ត្រី និងការផ្តល់រង្វាន់លាភការដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការងាររបស់សាលារៀន។ ក្នុងន័យនេះ វិទ្យាល័យ បានរៀបចំប្រព័ន្ធរាយការណ៍ពីគុណផលការងារតាមរយៈយន្តការជាច្រើន ក្នុងការវាយតម្លៃពីគុណផលការងាររបស់បុគ្គលិកអប់រំ ក៏ដូចជាការអនុវត្តការងារនៅតាមផ្នែកនីមួយៗ។ ប្រព័ន្ធនៃ

ជំពូកទី៣

ការរាយការណ៍ពីគុណផលការងារមានច្រើនរូបភាពយោងទៅតាមក្រុម និងគណៈកម្មការនីមួយៗដែលបានរៀបចំនៅក្នុងវិទ្យាល័យ។ តាមរយៈវិមជ្ឈការនៃអំណាច និងការសម្រេចរបស់គណៈគ្រប់គ្រងសាលារៀន គ្រប់គណៈកម្មការគ្រប់គ្រងសាលារៀន និងក្រុមការងារនៅក្នុងវិទ្យាល័យបានរៀបចំផែនការសកម្មភាព ផែនការយុទ្ធសាស្ត្រ និងយន្តការពិនិត្យតាមដាន និងវាយតម្លៃ ការអនុវត្តការងាររបស់ខ្លួនរៀងខ្លួន។ ជាក់ស្តែង គណៈកម្មការគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រង បរិស្ថាន និងអនាម័យ និងក្រុមប្រឹក្សាយុវជនជាដើម បានរៀបចំប្រព័ន្ធរាយការណ៍ពីគុណផលនៃការងារតាមរយៈយន្តការតាមដាន និងវាយតម្លៃនៃការអនុវត្តការងាររបស់ខ្លួនជាប្រចាំ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ជាមួយគ្នានេះ នៅក្នុងរចនាសម្ព័ន្ធនៃការដឹកនាំ និងគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលារៀនក៏រៀបចំយន្តការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងាររបស់បុគ្គលិកអប់រំរបស់ខ្លួនផងដែរ។ ទន្ទឹមនេះ វិទ្យាល័យបានរៀបចំកិច្ចប្រជុំជាច្រើនរួមមាន÷ កិច្ចប្រជុំក្រុមបច្ចេកទេសមុខវិជ្ជា កិច្ចប្រជុំរវាង គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងបុគ្គលិកអប់រំក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍវិទ្យាល័យ ការរៀបចំបែងចែកកាលវិភាគបង្រៀន កិច្ចប្រជុំរវាងគណៈគ្រប់គ្រងសាលានរៀនជាមួយមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស កិច្ចប្រជុំរវាងគណៈគ្រប់គ្រងសាលារៀនជាមួយគណៈកម្មការ និងក្រុមផ្សេងៗនៅក្នុងវិទ្យាល័យ។ រាល់កិច្ចប្រជុំទាំងនេះ គឺគណៈគ្រប់គ្រងវិទ្យាល័យតែងទទួលបាននូវមតិចូលរួមវាយតម្លៃកែលម្អពីការផ្តល់សេវាអប់រំ ក៏ដូចជាការអនុវត្តការងារនាពេលកន្លងមករបស់បុគ្គលិកអប់រំ ជាពិសេសគឺការបង្រៀននិងរៀនដោយផ្តោតលើរបៀបវារៈសំខាន់ចំនួនបី គឺៈ ១)រាយការណ៍លទ្ធផលសម្រេច ២)បញ្ហាប្រឈម និង ៣)ទិសដៅបន្ត។ តាមរយៈយន្តការនេះ គណៈគ្រប់គ្រងសាលារៀនបានរៀបចំដោះស្រាយបញ្ហាទាំងឡាយ និងរៀបចំកែលម្អនូវចំណុចខ្វះខាតនៃការអនុវត្តការងាររបស់ខ្លួនបានភ្លាមៗ។ លក្ខណៈដែលគួរឱ្យកត់សម្គាល់មួយក្នុងការវាយតម្លៃពីគុណផលការងារ គឺរាល់បញ្ហាទាំងឡាយដែលកើតឡើង បើសិនជាអាចដោះស្រាយបានភ្លាម គណៈគ្រប់គ្រងសាលារៀននឹងរៀបចំ

ប្រជុំដោះស្រាយភ្លាមដោយមិនរង់ចាំយូរឡើយ លើកលែងតែកិច្ចការណាដែលត្រូវការសម្រេចពីថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាស្រុក ឬមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។

➤ **ការធ្វើអធិការកិច្ចថ្នាក់រៀន**

ការចុះធ្វើអធិការកិច្ចអប់រំ គឺជាផ្នែកមួយនៃការវាយតម្លៃគុណផលការងាររបស់មន្ត្រីអប់រំ ជាពិសេសគឺគ្រូបង្រៀន។ ជារៀងរាល់ឆ្នាំនាយករងទទួលបន្ទុកបច្ចេកទេស និងប្រធានក្រុមបច្ចេកទេសមុខវិជ្ជាបានសហការគ្នារៀបចំប្រជុំធ្វើផែនការធ្វើអធិការកិច្ចគ្រូបង្រៀននៅតាមថ្នាក់រៀន និងទៅតាមមុខវិជ្ជាបង្រៀននីមួយៗ ដោយបានចុះអង្កេតមើលការបង្រៀននិងរៀនរបស់គ្រូបង្រៀន ដើម្បីពិនិត្យមើលទៅលើការរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន និងវិធីសាស្ត្រនៃការបង្រៀន និងផ្តល់យោបល់កែលម្អនូវចំណុចខ្វះខាតដល់លោកគ្រូ អ្នកគ្រូបង្រៀន ក្នុងគោលបំណងពង្រឹងគុណភាពនៃការបង្រៀនរបស់គ្រូបង្រៀនជាប្រចាំ។ ជាងនេះទៅទៀត តាមរយៈការចុះធ្វើអធិការកិច្ចអប់រំនេះ រាល់ចំណុចខ្វះខាតនៃការបង្រៀនរបស់គ្រូបង្រៀនត្រូវបានផ្តល់មតិកែលម្អដោយផ្ទាល់ទៅដល់គ្រូបង្រៀននៅក្នុងថ្នាក់ និងមួយចំនួនទៀតត្រូវបានលើកយកមកប្រជុំរកដំណោះស្រាយជារួមនៅក្នុងកិច្ចប្រជុំបច្ចេកទេស។

➤ **ការផ្តល់ការលើកទឹកចិត្តផ្អែកលើលទ្ធផលនៃការវាយតម្លៃ**

វិទ្យាល័យពេជ្រចិន្តា បានរៀបចំវាយតម្លៃផ្តល់រង្វាន់លើកទឹកចិត្តដល់បុគ្គលិកអប់រំដែលសម្រេចបានលទ្ធផលការងារល្អប្រចាំឆ្នាំ តាមរយៈការវាយតម្លៃដំឡើងកាំប្រាក់បៀវត្សដែលជាការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការវាយតម្លៃផ្តល់រង្វាន់លើកទឹកចិត្តជាពិសេសគ្រូបង្រៀនដែលមានស្នាដៃល្អនៅវិទ្យាល័យតាមរយៈការវាយតម្លៃផ្តល់លិខិតសរសើរ និងប្រាក់ឧបត្ថម្ភចំនួន ១០០.០០០ រៀល នៅចំពោះមុខថ្នាក់ដឹកនាំស្រុក អាជ្ញាធរដែនដី គណៈគ្រប់គ្រងសាលា បុគ្គលិកអប់រំ សិស្ស មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស និងសហគមន៍។ បើទោះបីជាការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនៅមានចំនួនតិចតួចក្តីក៏ប៉ុន្តែនេះជាការលើកទឹកចិត្តដល់បុគ្គលិករបស់វិទ្យាល័យ ដែលបានខិតខំប្រឹងប្រែង

ជំពូកទី៣

បំពេញការងារ។

ជារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាវិន័យរបស់វិទ្យាល័យបានដើរតួនាទីជាគណៈកម្មការវាយតម្លៃការងារបុគ្គលិកដែលបំពេញការងារសម្រាប់ការដំឡើងកាំប្រាក់ប្រាក់បៀវត្សការផ្តល់ប័ណ្ណសរសើរ និងប្រាក់ឧបត្ថម្ភ។ សមាសភាពរបស់ក្រុមប្រឹក្សាវិន័យរួមមាននាយកនាយករង និងប្រធានក្រុមបច្ចេកទេសមុខវិជ្ជា។ សម្រាប់យន្តការនៃវាយតម្លៃគឺ គណៈគ្រប់គ្រងសាលាបានរៀបចំឧបករណ៍វាយតម្លៃបុគ្គលិកអប់រំដោយខ្លួនឯង ដោយយកគំរូតាមឧបករណ៍វាយតម្លៃគ្រូបង្រៀនល្អរបស់ក្រសួង អប់រំ យុវជន និងកីឡា។

ក្នុងការវាយតម្លៃដំឡើងកាំប្រាក់បៀវត្ស គណៈគ្រប់គ្រងសាលារៀនមិនមែនធ្វើការសម្រេចដោយឯកឯងនោះទេ ពោលគឺតែងតែសុំយោបល់ពីប្រធានក្រុមបច្ចេកទេសមុខវិជ្ជាដែលគាត់ជាអ្នកគ្រប់គ្រងផ្ទាល់ទៅលើគ្រូបង្រៀនក្នុងការផ្តល់ពិន្ទុដំឡើងកាំប្រាក់បៀវត្ស។ ការវាយតម្លៃឡើងកាំបៀវត្សរបស់គ្រូបង្រៀន បើទោះបីជាមានការវាយតម្លៃផ្អែកទៅលើការបំពេញការងាររបស់គាត់នាពេលកន្លងមកក៏ពិតមែន ក៏ប៉ុន្តែគណៈគ្រប់គ្រងសាលាតែងតែអនុគ្រោះដល់បុគ្គលិកអប់រំមួយចំនួនដែលមិនសូវសកម្មការងារឱ្យគាត់មានឱកាសបានឡើងកាំប្រាក់ផងដែរ។ បើទោះបីជាពិន្ទុវាយតម្លៃឡើងកាំប្រាក់បៀវត្សរបស់គាត់ត្រូវធ្លាក់ក៏ដោយ ជួនកាលគណៈគ្រប់គ្រងសាលារៀន ក៏ដូចជាក្រុមប្រឹក្សាវិន័យ មានការអនុគ្រោះឱ្យជាប់ផងដែរតាមរយៈការអញ្ជើញបុគ្គលិកអប់រំរូបនោះមកប្រាប់ហេតុផលអំពីភាពមិនសូវសកម្ម និងចំណុចខ្វះខាតរបស់គាត់ដោយសម្ងាត់ ហើយឱ្យគាត់ខិតខំកែលម្អនូវចំណុចខ្វះខាតនេះនៅពេលក្រោយ។ វិធីសាស្ត្របែបនេះជាការលើកទឹកចិត្ត និងជំរុញគ្រូបង្រៀនដែលមិនសូវសកម្មឱ្យទៅជាសកម្ម និងពង្រឹងបាននូវសាមគ្គីភាពផ្ទៃក្នុងល្អរបស់សាលារៀន។ ការអនុវត្តបែបនេះបានធ្វើឱ្យវិទ្យាល័យទទួលបានជោគជ័យជាច្រើនក្នុងទាក់ទាញឱ្យបុគ្គលិកអប់រំ ដែលមិនសូវសកម្មការងារនៅក្នុងសាលារៀនឱ្យទៅជាសកម្មការងារ (ជាការទាញយកបេះដូងគ្រូបង្រៀនដែលមិនសូវចូលរួមក្នុងសកម្មភាពការងារនៅក្នុងសាលារៀន ឱ្យចូលរួម

ក្នុងសកម្មភាពការងារសាលារៀនយ៉ាងសកម្ម)[១៥]។

៣.២.៤.២. ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាគន្លឹះដ៏សំខាន់មួយធ្វើឱ្យអង្គភាព ឬសាលារៀនទទួលបានជោគជ័យ។ ក្នុងន័យនេះ ទាំងគណៈកម្មការគ្រប់គ្រង គណៈគ្រប់គ្រងសាលារៀនបានយកចិត្តទុកដាក់ និងផ្តល់តម្លៃទៅលើការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាពរបស់ខ្លួន។ គណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រងសាលារៀនបានរៀបចំផែនការក៏ដូចជាបង្កលក្ខណៈងាយស្រួល និងផ្តល់ឱកាសដល់បុគ្គលិកអប់រំទាំងអស់បានទទួលការបណ្តុះបណ្តាលនៅនឹងកន្លែងផង បានទស្សនកិច្ចសិក្សាផង និងបន្តការសិក្សានៅតាមវិទ្យាស្ថាន និងសាកលវិទ្យាល័យនានាផង។ ជាក់ស្តែង គណៈគ្រប់គ្រងទាំងអស់សុទ្ធតែបានបន្តការសិក្សារហូតទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ បុគ្គលិកអប់រំស្ទើរតែទាំងអស់មានសញ្ញាបត្រយ៉ាងទាបបំផុតកម្រិតបរិញ្ញាបត្រ និងមានតែគ្រូកីឡាតែពីរនាក់ប៉ុណ្ណោះនៅក្នុងសាលា ដែលមានត្រឹមសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ពិសេសជាងនេះទៅទៀត លោកប្រធានគណៈកម្មការគ្រប់គ្រងសាលា ក៏បានខិតខំចំណាយពេលវេលា និងថវិកាផ្ទាល់ទៅបន្តការសិក្សារហូតដល់ទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យនៅរាជធានីភ្នំពេញ។

មិនត្រឹមតែវិទ្យាល័យបានខិតខំអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនប៉ុណ្ណោះទេ រាល់ចំណេះដឹង ជំនាញ និងបទពិសោធន៍របស់បុគ្គលិកដែលទទួលបានពីការបណ្តុះបណ្តាលទស្សនកិច្ចសិក្សា និងបន្តការសិក្សាតិច ឬច្រើនត្រូវបានយកមកប្រើប្រាស់តាមរយៈការផ្សព្វផ្សាយ ចែករំលែក និងអនុវត្តដោយផ្ទាល់ក្នុងការអភិវឌ្ឍសាលារៀន។

កត្តាសំខាន់មួយទៀតរបស់វិទ្យាល័យដែលជាកត្តាគន្លឹះក្នុងការទាក់ទាញធនធានមនុស្ស ក៏ដូចជាអភិវឌ្ឍធនធានមនុស្សរបស់វិទ្យាល័យ គឺការចូលរួមគាំទ្រយ៉ាងសកម្មពីសំណាក់អាជ្ញាធរដែនដី សហគមន៍ និងគណៈគ្រប់គ្រងសាលារៀនក្នុងទទួលស្វាគមន៍

[១៥] តាមប្រសាសន៍របស់លោកនាយក និងនាយករងទទួលបន្ទុកបច្ចេកទេសវិទ្យាល័យពេជ្រចិន្តា

ជំពូកទី៣

ដល់គ្រប់បុគ្គលិកអប់រំ ដែលត្រូវបានក្រសួងអប់រំ យុវជន និងកីឡាចាត់តាំងឱ្យមកបម្រើការងារនៅវិទ្យាល័យពេជ្រចិន្តា។ គ្រប់បុគ្គលិកអប់រំទាំងអស់ រួមទាំងគណៈគ្រប់គ្រងសាលារៀនផង ពួកគាត់បានមកបំពេញការងារនៅវិទ្យាល័យពេជ្រចិន្តាដំបូង អាជ្ញាធរដែនដី ជាពិសេសគឺគណៈអភិបាលស្រុកភ្នំព្រឹកបានជួយឧបត្ថម្ភកន្លែងស្នាក់នៅ និងផ្តល់អាហារហូបចុកដល់ពួកគាត់ ហើយវប្បធម៌នៃការជួយទំនុកបម្រុងដល់គ្រូបង្រៀនដែលទើបតែចេញបម្រើការងារនេះមានរហូតមកដល់បច្ចុប្បន្ន។ ជាងនេះទៅទៀត នៅពេលដែលគ្រូបង្រៀននៅវិទ្យាល័យមានបំណងចង់បន្តការសិក្សា សហគមន៍តែងតែរៃអង្គាសថវិកាឧបត្ថម្ភជូនទៅដល់ពួកគាត់ដែលខិតខំទៅបន្តការសិក្សា។ វប្បធម៌ដ៏ល្អរបស់វិទ្យាល័យ និងសហគមន៍នេះ បានធ្វើឱ្យបុគ្គលិកអប់រំខិតខំបំពេញការងារ ក៏ដូចជាបង្រៀនសិស្សដែលជាកូនចៅរបស់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋនៅស្រុកភ្នំព្រឹកអស់ពីកម្លាំងកាយចិត្ត។ ជាឧទាហរណ៍ជាក់ស្តែង លោកគ្រូពលរដ្ឋវិទ្យាម្នាក់នៅវិទ្យាល័យបានមានប្រសាសន៍ថា ខ្ញុំបានខិតខំបំពេញការងារ និងបង្រៀននៅទីនេះអស់ពីកម្លាំងកាយនិងកម្លាំងចិត្តរបស់ខ្ញុំ ដោយសារខ្ញុំមិនដែលភ្លេចគុណសិស្ស សហគមន៍ គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន ដែលបានជួយទំនុកបម្រុងដល់ខ្ញុំនៅពេលដែលខ្ញុំមកបំពេញការងារនៅទីនេះដំបូង (សិស្សនាំគ្នារៃអង្គាសអង្ករមកជួយឧបត្ថម្ភគ្រូ គណៈគ្រប់គ្រងសាលារៀនបានជួយស្វែងរក និងផ្តល់កន្លែងស្នាក់នៅជូនដល់គាត់)។

ក. ការរៀបចំផែនការបណ្តុះបណ្តាល

វិទ្យាល័យបានរៀបចំផែនការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍធានមនុស្ស ហើយផែនការនៃការបណ្តុះបណ្តាលត្រូវបានបញ្ចូលនៅក្នុងផែនការអភិវឌ្ឍវិទ្យាល័យ។ គណៈគ្រប់គ្រងសាលារៀនបានខិតខំរៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្សដោយបានប្រើយន្តការសំខាន់ពីរយ៉ាងគឺ ១) ការបណ្តុះបណ្តាលនៅនឹងកន្លែង និង២) ការបណ្តុះបណ្តាលនៅខាងក្រៅអង្គភាព។ សម្រាប់ការបណ្តុះបណ្តាលនៅនឹងកន្លែង គឺសាលារៀនបានរៀបចំផែនការធ្វើការបណ្តុះបណ្តាលក្រៅផ្លូវការដែលបានធ្វើឡើងរវាងអ្នកដែលធ្លាប់មានបទពិសោធន៍

ធ្លាប់កាន់តួនាទី និងភារកិច្ចការងារនោះពីមុនបានបង្ហាត់បង្ហាញដល់អ្នកដែលទើបទទួលបានតួនាទី និងភារកិច្ចថ្មី។ ជាងនេះទៅទៀត គណៈគ្រប់គ្រងសាលារៀន បានជួយបង្ហាត់បង្រៀនដល់បុគ្គលិកអប់រំដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួនឱ្យចេះធ្វើ កិច្ចការដែលខ្លួនបំពេញការងារ ជាពិសេសភាពជាអ្នកដឹកនាំ និងគ្រប់គ្រងនៅពេលដែលពួកគាត់ទទួលបានការងារថ្មី។ ឧទាហរណ៍ លោកប្រធានក្រុមបច្ចេកទេសមុខវិជ្ជាវិទ្យាសាស្ត្រសង្គមបានបង្ហាញថា ពីមុនមកគាត់មិនសូវចេះសរសេររបាយការណ៍ និងកំណត់ហេតុប្រជុំទេ បើទោះបីគាត់ធ្លាប់បានទទួលការបណ្តុះបណ្តាលពីការរៀបចំលិខិតរដ្ឋបាលនៅវិទ្យាស្ថានជាតិអប់រំក៏ដោយ ក៏ប៉ុន្តែដោយសារការបង្ហាត់បង្រៀនរបស់គណៈគ្រប់គ្រងសាលា បានធ្វើឱ្យគាត់រៀបចំដឹកនាំ និងគ្រប់គ្រង ក្រុមបច្ចេកទេសវិទ្យាសាស្ត្រសង្គមបានល្អ ចេះធ្វើរបាយការណ៍ និងកំណត់ហេតុប្រជុំ ដោយសារគាត់បានទទួលការបង្ហាត់បង្រៀនពីនាយករងដែលជាអតីតប្រធានក្រុមបច្ចេកទេសវិទ្យាសាស្ត្រសង្គម និងនាយកសាលាដោយផ្ទាល់។ រីឯនៅក្នុងក្រុមបច្ចេកទេសនីមួយៗតែងតែមានការរៀបចំប្រជុំជាប្រចាំ និងធ្វើថ្នាក់និទស្សន៍ដើម្បីបង្រៀនដល់លោកគ្រូ អ្នកគ្រូ ដើម្បីពង្រឹងនូវចំណេះដឹង និងជំនាញវិជ្ជាជីវៈរបស់ខ្លួន។ ជាងនេះទៅទៀត គណៈគ្រប់គ្រងសាលាតែងតែផ្តល់ឱកាស និងលើកទឹកចិត្តដល់បុគ្គលិកអប់រំដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួនបានចូលរួមសិក្ខាសាលានានា និងផ្តល់ដល់អ្នកដែលមិនសូវមានជំនាញជាអាទិភាពនៃការទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាល។ ការបណ្តុះបណ្តាលដំបូងជាការអភិវឌ្ឍចំណេះដឹង សមត្ថភាព និងជំនាញរបស់បុគ្គលិកអប់រំដែលទើបចេញដំបូង ដើម្បីឱ្យការអនុវត្តការងាររបស់ខ្លួនមានប្រសិទ្ធភាព។

ខ. ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្ស គឺជាការបង្កើនសមត្ថភាពរបស់មន្ត្រី (បុគ្គលិកអប់រំ) ដោយផ្តោតទៅលើការកសាងចំណេះដឹង ជំនាញ និងលទ្ធផលនៃការបំពេញការងារតាមរយៈការផ្លាស់ប្តូរជាបន្តបន្ទាប់នូវអាកប្បកិរិយា និងឥរិយាបថនៃការបំពេញការងារដើម្បីបង្កើនគុណផលការងារនាពេលបច្ចុប្បន្ន និងត្រៀមខ្លួនឱ្យបានកាន់តែល្អប្រសើរសម្រាប់

ជំពូកទី៣

ការផ្លាស់ប្តូរនាពេលអនាគត។ នៅក្នុងន័យនេះ វិទ្យាល័យ បានចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាកត្តាគន្លឹះ ដែលធ្វើឱ្យវិទ្យាល័យទទួលបានជ័យលាភីជាបន្តបន្ទាប់ជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ ពានរង្វាន់គ្រូបង្រៀនល្អ នាយកសាលាល្អ និងពានរង្វាន់បរិស្ថានអាស៊ាន។ ទាំងគណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន ក៏ដូចជាគ្រូបង្រៀន បានខិតខំប្រឹងប្រែងបន្តការសិក្សាដោយខ្លួនឯងរហូតទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ និងបរិញ្ញាបត្រជាដើម។ ឧទាហរណ៍ជាក់ស្តែង លោកនាយកបានខិតខំបន្តការសិក្សារហូតទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ និងបានបន្តការសិក្សារហូតរៀនចប់នៅសាលាភូមិន្ទរដ្ឋបាល។

ក្រៅពីការខិតខំប្រឹងប្រែងបន្តការសិក្សាដោយខ្លួនឯង គណៈកម្មការគ្រប់គ្រង និងគណៈគ្រប់គ្រងសាលារៀនបានខិតខំទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ វិទ្យាស្ថាន សាកល-វិទ្យាល័យ និងសាលារៀនដែលមានស្នាដៃល្អទាំងក្នុង និងក្រៅប្រទេសដើម្បីផ្តល់ឱកាសដល់គ្រូបង្រៀន ក៏ដូចជាសិស្សានុសិស្សបានទៅចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាលបន្តការសិក្សា និងទស្សនកិច្ចសិក្សាក្នុងប្រទេស និងក្រៅប្រទេស (ប្រទេសថៃ)។ ការធ្វើទស្សនកិច្ចសិក្សានេះបានធ្វើឱ្យគណៈកម្មការគ្រប់គ្រង គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន ក៏ដូចជាសិស្សានុសិស្សនៅវិទ្យាល័យទទួលបាននូវចំណេះដឹង បទពិសោធន៍ និងគំនិតនវានុវត្តន៍ថ្មីៗក្នុងការអភិវឌ្ឍវិទ្យាល័យ។

រូបភាពទី៦÷ គុណវុឌ្ឍិបុគ្គលិកអប់រំ



គ. ការគាំទ្រ និងលើកទឹកចិត្តមន្ត្រីឱ្យទទួលបានការបណ្តុះបណ្តាល

ទាំងគណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងវិទ្យាល័យ និងសហគមន៍តែងតែផ្តល់ការគាំទ្រ លើកទឹកចិត្ត និងឧបត្ថម្ភជាថវិកា និងសម្ភារៈឱ្យបុគ្គលិកអប់រំនៅវិទ្យាល័យពេជ្រចិន្តាបានទទួលការបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានានៅក្នុងខេត្តបាត់ដំបង និងរាជធានីភ្នំពេញ។ ដោយសារគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រងសាលារៀនបានចាត់ទុកការបន្តការសិក្សា និងបណ្តុះបណ្តាលជាកត្តាគន្លឹះធ្វើឱ្យវិទ្យាល័យទទួលបានជោគជ័យ។ វិទ្យាល័យមានការលើកទឹកចិត្ត បង្កលក្ខណៈងាយស្រួល និងផ្តល់ឱកាសដល់បុគ្គលិកអប់រំឱ្យទទួលបានការបណ្តុះបណ្តាល និងបន្តការសិក្សាបានយ៉ាងច្រើន។ ផងដែរ នៅក្នុងវិទ្យាល័យគណៈគ្រប់គ្រងសាលារៀន តែងតែផ្តល់និងផ្គត់ផ្គង់ឯកសារទាំងឡាយ ដែលជាតម្រូវការសម្រាប់គ្រូបង្រៀនដែលបង្រៀនខុសមុខវិជ្ជាឯកទេសដើមរបស់ខ្លួនដើម្បីពង្រឹងចំណេះដឹង និងជំនាញមុខវិជ្ជាឯកទេសថ្មី ដែលគាត់ត្រូវបង្រៀន ព្រមទាំងផ្តល់ឱកាស និងអាទិភាពឱ្យពួកគាត់បានទទួលការបណ្តុះបណ្តាល និងចូលរួមសិក្ខាសាលាផ្សេងៗ ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងដៃគូអភិវឌ្ឍវិស័យអប់រំនានា។ ជាងនេះទៅទៀត គណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រង

សាលារៀន បានលើកទឹកចិត្តឧបត្ថម្ភសម្ភារៈ និងថវិកាដល់បុគ្គលិកអប់រំដែលមានបំណងចង់បន្តការសិក្សានៅតាមវិទ្យាស្ថាន និងសាកលវិទ្យាល័យនានានៅខេត្តបាត់ដំបង និងរាជធានីភ្នំពេញដោយខ្លួនឯង។ ទាំងគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រងសាលារៀនបានខិតខំធ្វើទំនាក់ទំនងជាមួយសាលារៀន វិទ្យាស្ថាន សាកលវិទ្យាល័យ និងដៃគូអភិវឌ្ឍនានាក្នុងនិងក្រៅប្រទេស (ថៃ)ដើម្បីផ្តល់ឱកាសដល់បុគ្គលិកអប់រំទទួលបានការបណ្តុះបណ្តាល ការបន្តការសិក្សា និងការធ្វើទស្សនកិច្ចសិក្សា។

កត្តាមួយដែលជាការជំរុញ និងលើកទឹកចិត្តឱ្យលោកគ្រូ អ្នកគ្រូមានទឹកចិត្តបន្តការខិតខំប្រឹងប្រែងសិក្សាបន្ត គឺពួកគាត់មើលឃើញពីភាពជាគំរូនៃលោកប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន និងលោកនាយកសាលារៀនមានទស្សនៈវិស័យវែងឆ្ងាយ ដោយពួកគាត់ទាំងពីរបានខិតខំបន្តការសិក្សារហូតទទួលបានសញ្ញាបត្រអនុបណ្ឌិត និងបានប្រឡងជាប់រៀននៅសាលាភូមិន្ទរដ្ឋបាល។ ដោយសារកត្តានេះបានធ្វើឱ្យសហការីរបស់គាត់យកជាគំរូតាម និងខិតខំបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានាទាំងនៅក្នុងខេត្តបាត់ដំបង និងរាជធានីភ្នំពេញ។

ឃ. ការប្រើប្រាស់វិធីសាស្រ្តផ្សេងៗដើម្បីផ្តល់ការបណ្តុះបណ្តាល

ដើម្បីអភិវឌ្ឍធនធានមនុស្សនៅក្នុងវិទ្យាល័យ គណៈគ្រប់គ្រងសាលារៀនបានប្រើប្រាស់វិធីសាស្រ្តមួយចំនួនក្នុងការផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិករបស់ខ្លួន។ វិធីសាស្រ្តនៃការបណ្តុះបណ្តាលទាំងនោះរួមមាន÷ ការបញ្ជូនគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្សទៅធ្វើទស្សនកិច្ចសិក្សាសាលារៀនគំរូមួយចំនួននៅក្នុងប្រទេស និងសាលារៀនមួយចំនួននៅក្នុងប្រទេសថៃ ការបញ្ជូន គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនចូលរួមសិក្ខាសាលាផ្សេងៗដែលរៀបចំដោយក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដៃគូអភិវឌ្ឍវិស័យអប់រំនានា នៅតាមវិទ្យាស្ថាននិងសាកលវិទ្យាល័យនានាក្នុងខេត្តបាត់ដំបង និងរាជធានីភ្នំពេញជាដើម។ ក្រៅពីការបញ្ជូនគណៈគ្រប់គ្រង បុគ្គលិកអប់រំ និងគ្រូបង្រៀនទៅទទួលការបណ្តុះបណ្តាលនៅខាងក្រៅ វិធីសាស្រ្តសំខាន់មួយទៀត

គឺការចែករំលែកនូវបទពិសោធន៍ និងចំណេះដឹងឱ្យគ្នាទៅវិញទៅមកនៅក្នុងចំណោមបុគ្គលិកអប់រំដែលមានចំណេះដឹងច្រើន និងមានបទពិសោធន៍ខ្ពស់ទៅដល់បុគ្គលិកអប់រំដទៃទៀតនៅក្នុងសាលា ជាពិសេសគឺការជួយបង្ហាត់បង្ហាញដល់អ្នកដែលទទួលបានការងារនិងតួនាទីថ្មីពីអ្នក ដែលធ្លាប់អនុវត្តការងារនាពេលកន្លងមក។ ឧទាហរណ៍ ប្រធានក្រុមបច្ចេកទេសមុខវិជ្ជាវិទ្យាសាស្ត្រដែលទើបបានទទួលតំណែងបន្តពីនាយករងទទួលបន្ទុកបច្ចេកទេស តែងតែទទួលបានការណែនាំពីរបៀបដឹកនាំកិច្ចប្រជុំបច្ចេកទេស របៀបសរសេរ របាយការណ៍កិច្ចប្រជុំ របៀបធ្វើអធិការកិច្ចថ្នាក់រៀន និងការបង្រៀនថ្នាក់និទស្សន៍ជាដើមពីនាយករងទទួលបន្ទុកបច្ចេកទេសជាប្រចាំ នៅពេលគាត់ទើបទទួលបានមុខតំណែងនេះដំបូង។ យន្តការនៃការបណ្តុះបណ្តាលនៅនឹងកន្លែងមួយទៀតយ៉ាងសំខាន់ផងដែរ ដើម្បីពង្រឹងគុណភាពបង្រៀន និងរៀននោះគឺការប្រជុំបច្ចេកទេស និងការបង្រៀនថ្នាក់និទស្សន៍របស់ក្រុមបច្ចេកទេសនីមួយៗ។ នៅវិទ្យាល័យពោធិ៍ជ្រចិន្តា ការប្រជុំក្រុមបច្ចេកទេសនិងការបង្រៀនថ្នាក់និទស្សន៍ត្រូវបានអនុវត្តជាប្រចាំ។ ការប្រជុំបច្ចេកទេស និងការបង្រៀនថ្នាក់និទស្សន៍បានជួយពង្រឹងនូវចំណេះដឹងលើមុខវិជ្ជាឯកទេស និងវិធីសាស្ត្របង្រៀនបានយ៉ាងច្រើនដល់គ្រូបង្រៀន ជាពិសេសគឺគ្រូបង្រៀនត្រូវបានជ្រើសរើសឱ្យបង្រៀនមុខវិជ្ជា ដែលខុសពីមុខវិជ្ជាឯកទេសដើមរបស់ខ្លួន។

ការបញ្ជូនបុគ្គលិកអប់រំ ឬគ្រូបង្រៀនឱ្យទៅចូលរួមវគ្គសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលផ្សេងៗ គណៈគ្រប់គ្រងសាលារៀនមិនមែនចេះតែបញ្ជូនបុគ្គលិកអប់រំឱ្យទៅចូលរួមសិក្ខា-សាលានោះទេ ពោលគឺ គណៈគ្រប់គ្រងសាលាបានធ្វើការពិភាក្សា សាកសួរយោបល់គ្នាជាមុនសិន មុននឹងសម្រេចបញ្ជូនបុគ្គលិកអប់រំណាម្នាក់ទៅចូលរួមសិក្ខាសាលា។ ជាក់ស្តែងនៅពេលមន្ទីរ ឬក្រសួងស្នើឱ្យសាលាបញ្ជូនគ្រូបង្រៀនមុខវិជ្ជាណាមួយទៅចូលរួមសិក្ខា-សាលាស្តីពីវិធីសាស្ត្រនៃការបង្រៀននូវវិជ្ជាឯកទេសណាមួយ គណៈគ្រប់គ្រងសាលារៀនតែងតែផ្តល់អាទិភាពដល់គ្រូបង្រៀន ដែលបានស្ម័គ្រចិត្តបង្រៀនមុខវិជ្ជា ឯកទេសថ្មី ដែលមិនមែនជាឯកទេសដើមរបស់ខ្លួនឱ្យបានចូលរួមសិក្ខាសាលានោះ ដើម្បីឱ្យគាត់ទទួលបាន

ជំពូកទី៣

ចំណេះដឹងនិងជំនាញទៅលើមុខវិជ្ជាឯកទេសដែលគាត់កំពុងបង្រៀននោះបន្ថែមទៀត និងជាការលើកទឹកចិត្តដល់ពួកគាត់ដែលបានខិតខំប្រឹងប្រែងបំពេញការងារ និងស្រាវជ្រាវឯកសារផ្សេងៗសម្រាប់មុខវិជ្ជាឯកទេសថ្មីនេះ។

ង. ការប្រើប្រាស់ធនធានមនុស្សដែលទទួលបានការបណ្តុះបណ្តាល

គ្រប់បុគ្គលិកអប់រំដែលទទួលបានការបណ្តុះបណ្តាល ជាពិសេសបុគ្គលិកអប់រំដែលបានខិតខំបន្តការសិក្សានៅតាមវិទ្យាស្ថាន និងសាកលវិទ្យាល័យនានាក្នុងខេត្តបាត់ដំបង និងរាជធានីភ្នំពេញ គណៈគ្រប់គ្រងសាលារៀនតែងតែផ្តល់ឱកាស លើកទឹកចិត្ត និងប្រើប្រាស់នូវធនធានមនុស្សទាំងនោះក្នុងការចូលរួមអភិវឌ្ឍនៅវិទ្យាល័យទៅតាមជំនាញរៀងៗរបស់ពួកគេ ដែលទទួលបានពីការបណ្តុះបណ្តាលនោះ។ តាមរយៈយន្តការនេះ បុគ្គលិកអប់រំទាំងនោះតែងតែយកចំណេះដឹង ជំនាញ បទពិសោធន៍ និងគំនិតនវានុវត្តន៍ថ្មីៗទាំងនោះមកធ្វើការកែលម្អ និងចូលរួមអភិវឌ្ឍវិទ្យាល័យ ចែករំលែកដល់បុគ្គលិកអប់រំ និងសិស្សនៅក្នុងវិទ្យាល័យ ព្រមទាំងកែលម្អ និងពង្រឹងគុណភាពការងាររបស់ខ្លួននៅក្នុងវិទ្យាល័យទៅតាមមុខជំនាញឯកទេសវិជ្ជាជីវៈនីមួយៗ។ ដោយសារកត្តានេះហើយបានធ្វើឱ្យគ្រប់សេវាអប់រំ ក៏ដូចជាកិច្ចការងារទាំងអស់នៅក្នុងវិទ្យាល័យមានដំណើរការប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ជាក់ស្តែង តាមរយៈការបញ្ជូនគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្សទៅធ្វើទស្សនកិច្ចសិក្សានៅសាលារៀនក្នុងប្រទេសថៃ ពេលត្រឡប់មកដល់វិទ្យាល័យវិញ គណៈគ្រប់គ្រងវិទ្យាល័យ គ្រូបង្រៀន និងសិស្សបានធ្វើការចែករំលែកនូវចំណេះដឹង បទពិសោធន៍ល្អៗ និងគំនិតនវានុវត្តន៍ថ្មីៗពី សាលារៀនទាំងនោះទៅដល់បុគ្គលិកអប់រំ និងសិស្សានុសិស្សដទៃទៀតនៅក្នុងវិទ្យាល័យ។ ជាមួយគ្នានេះផងដែរ គណៈគ្រប់គ្រងសាលារៀនបានផ្តល់ឱកាសដល់បុគ្គលិកអប់រំ និងសិស្សដែលបានធ្វើទស្សនកិច្ចសិក្សារៀបចំយន្តការកែលម្អនូវការងារ ក៏ដូចជាសោភ័ណភាព និងបរិស្ថានវិទ្យាល័យ។ ទស្សនកិច្ចសិក្សានេះបានធ្វើឱ្យវិទ្យាល័យមានការដឹកនាំ និងគ្រប់គ្រងបរិស្ថានបានល្អជាពិសេស គឺការគ្រប់គ្រងកាកសំណល់នៅក្នុងសាលារៀន។ ជាងនេះ

ទៅទៀត តាមរយៈការធ្វើទស្សនកិច្ចសិក្សានេះបានធ្វើឱ្យសិស្សានុសិស្ស ក៏ដូចជាលោកគ្រូ អ្នកគ្រូបានប្រតិបត្តិនូវសីលធម៌ និងសុជីវធម៌បានល្អនៅក្នុងវិទ្យាល័យ តាមរយៈការសំពះស្វាគមន៍ និងជម្រាបលាគ្នាទៅវិញទៅមករវាងគ្រូ និងសិស្សនៅពេលជួបគ្នា និងនៅពេលលាគ្នា។

ពិសេសជាងនេះទៅទៀត ដោយសារតែវិទ្យាល័យបានផ្តល់ឱកាស និងប្រើប្រាស់បុគ្គលិកអប់រំដែលទទួលបានការបណ្តុះបណ្តាល វាបានជំរុញ និងលើកទឹកចិត្តឱ្យបុគ្គលិកអប់រំដទៃទៀតនៅក្នុងវិទ្យាល័យខិតខំបន្តការសិក្សាដោយខ្លួនឯងរហូតទទួលបានបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់។ ជាក់ស្តែងគ្រូបង្រៀនបឋមភូមិ ដែលបានខិតខំបន្តការសិក្សារហូតទទួលបានបរិញ្ញាបត្រទៅលើមុខវិជ្ជាឯកទេសរបស់ខ្លួន ត្រូវបានគណៈគ្រប់គ្រងសាលារៀនលើកទឹកចិត្ត និងផ្តល់ឱកាសឱ្យគាត់បានបង្រៀននៅកម្រិតទុតិយភូមិនៅវិទ្យាល័យទៅលើមុខវិជ្ជាឯកទេសនោះ។ ពិសេសជាងនេះទៀត គ្រូបង្រៀនបឋមភូមិមួយចំនួន ដែលបានបន្តការសិក្សារហូតទទួលបានបរិញ្ញាបត្រលើឯកទេសបង្រៀនរបស់ខ្លួន បង្រៀនមុខវិជ្ជាឯកទេសនោះនៅកម្រិតទុតិយភូមិ ល្អជាងគ្រូបង្រៀនវិទ្យាល័យដែលទទួលការបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអប់រំទៅទៀត (ការបញ្ជាក់របស់លោកនាយក និងលោកនាយករងទទួលបន្ទុកបច្ចេកទេស)។ តាមរយៈការប្រើប្រាស់យុទ្ធសាស្រ្តខាងលើនេះរបស់គណៈគ្រប់គ្រងសាលារៀន បានធ្វើឱ្យគ្រូស្ទើរតែទាំងអស់ខិតខំសិក្សា បន្តការសិក្សា និងស្រាវជ្រាវដោយខ្លួនឯងរហូតដល់បុគ្គលិកអប់រំស្ទើរតែទាំងអស់នៅវិទ្យាល័យមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅស្ទើរតែទាំងអស់។

ច. មានការអនុវត្តការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា

បើទោះបីជា វិទ្យាល័យមិនទាន់បានរៀបចំ និងប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា នៅក្នុងការគ្រប់គ្រងធនធានមនុស្សរបស់ខ្លួនក៏ដោយ ក៏គ្រប់ឯកសារទាំងអស់នៃការគ្រប់គ្រងធនធានមនុស្ស ត្រូវបានរៀបចំឡើងដោយប្រើប្រាស់នូវបច្ចេកវិទ្យាព័ត៌មានវិទ្យា។ ជាងនេះទៀត បើទោះបីជាវិទ្យាល័យស្ថិតនៅឆ្ងាយពីទីរួមខេត្ត និងរាជធានីភ្នំពេញ ក៏ការប្រើប្រាស់

ជំពូកទី៣

បច្ចេកវិទ្យាព័ត៌មាន ជាពិសេសអ៊ិនធើណែតត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ក្នុងចំណោមបុគ្គលិកអប់រំរបស់វិទ្យាល័យ សម្រាប់ជាមធ្យោបាយទំនាក់ទំនងគ្នា ការស្រាវជ្រាវឯកសារបង្រៀននិងរៀន និងការងាររដ្ឋបាលរបស់សាលារៀន។ វិទ្យាល័យមានបុគ្គលិកអប់រំដែលមានជំនាញខាងបច្ចេកវិទ្យាព័ត៌មាន (បរិញ្ញាបត្រព័ត៌មានវិទ្យា) មានការរៀបចំបន្ទប់សម្រាប់បង្រៀនកុំព្យូទ័រ និងនៅតាមថ្នាក់រៀនមួយចំនួនមានបំពាក់ម៉ាស៊ីនបញ្ចាំងស្លាយសម្រាប់ការបង្រៀននិងរៀន។ តាមប្រសាសន៍របស់លោកនាយក និងនាយករងទទួលបន្ទុកបច្ចេកទេស នៅថ្ងៃអនាគតសាលារៀននឹងមានការរៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា។

៣.២.៥. ការរៀបចំ និងកែលម្អបរិស្ថានអនុភាព

៣.២.៥.១. ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ភាពស្អាត និងសុខភាព

ដើម្បីបញ្ជ្រាបការយល់ដឹងអំពីការកែលម្អបរិស្ថាន ភាពស្អាត និងសុខភាព គណៈគ្រប់គ្រង បានសិក្សាលើគោលនយោបាយក៏ដូចជាគោលការណ៍ណែនាំផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងបរិស្ថានសម្រាប់ធ្វើជាមាគ៌ាដឹកនាំកិច្ចកែលម្អបរិស្ថានភាពស្អាត និងសុខភាពមានដូចជា**គោលនយោបាយជាតិស្ដីពីសុខភាពសិក្សា គោលការណ៍ណែនាំស្ដីពីសាលាមេត្រីបរិស្ថាន គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមាស្ដីពីទឹកស្អាត និងអនាម័យតាមសាលារៀន និងសៀវភៅសិក្សាមុខវិជ្ជា ផែនដីវិទ្យានិងបរិស្ថាន និងមុខវិជ្ជាជីវវិទ្យាជាដើម**។ ផ្អែកលើឯកសារគោលមួយចំនួនខាងលើ គណៈគ្រប់គ្រងសាលារៀនបានបញ្ចូលផែនការបរិស្ថានទៅក្នុងការអភិវឌ្ឍសាលារៀនដោយផ្ដោតសំខាន់លើ **ភាពស្អាត សោភ័ណ្ឌ** ដែលចាំបាច់ត្រូវយកចិត្តទុកដាក់លើភាពស្អាតបីយ៉ាងគឺ **ភាពស្អាតរបស់បុគ្គល សាលារៀន និងចំណីអាហារ**។ ដើម្បីឱ្យផែនការនេះសម្រេចទៅបាន គណៈគ្រប់គ្រងសាលារៀនក៏បានបង្កើតយន្តការបញ្ជ្រាបការយល់ដឹងពីបរិស្ថានដោយកំណត់គោលដៅសំខាន់ៗពីរ គឺ÷

ទីមួយ គឺការបញ្ជ្រាបការយល់ដឹងដល់សិស្សានុសិស្ស ក្រៅពីការបណ្ដុះបណ្ដាលក្នុង

ថ្នាក់រៀនអំពីការគ្រប់គ្រងសំរាម គណៈគ្រប់គ្រងសាលារៀនបានធ្វើការដឹកនាំតំណាងក្រុមប្រឹក្សាយុវជននិងកុមារចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សានៅ**វិទ្យាល័យសយដាវ និង វិទ្យាល័យធុនថៈណាន** នាប្រទេសថៃក្នុងគោលបំណងសិក្សាពីបទពិសោធលើដំណើរការដឹកនាំគ្រប់គ្រង និងកែលម្អបរិស្ថាន ភាពស្អាត និងសុខភាពនៅក្នុងវិទ្យាល័យ។ ក្រោយពីត្រឡប់ពីទស្សនកិច្ចសិក្សាវិញ គណៈគ្រប់គ្រងសាលារៀនបានចាត់តាំងតំណាងសិស្សទាំងនោះ ឡើងធ្វើបទបង្ហាញចែករំលែកនូវចំណុចល្អៗដែលបានឃើញក្នុងដំណើរទស្សនកិច្ចដល់សិស្សានុសិស្សទាំងឡាយ និងបានប្ដេជ្ញាចិត្តជាមួយគ្នាចូលរួមកែលម្អបរិស្ថាន ភាពស្អាត និងសុខភាពវិទ្យាល័យឱ្យកាន់តែល្អប្រសើរឡើង។ ជាមួយគ្នានេះដែរ គណៈគ្រប់គ្រងសាលារៀនក៏បានបង្កើតយន្តការបញ្ជ្រាបការយល់ដឹងផ្សេងៗទៀត តាមរយៈការដាក់តាំងបង្ហាញពាក្យស្លោក និងបដាផ្សព្វផ្សាយដែលមានជារូបភាពនិងខ្លឹមសារអប់រំស្ដីពីបរិស្ថាន ភាពស្អាត និងសុខភាព ព្រមទាំងបានផ្ដួចផ្ដើមបង្កើតកម្មវិធីដាំកូនឈើ ដើមផ្កាបង្កើតសួនជីវៈចម្រុះក្នុងវិទ្យាល័យ និងបានចូលរួមសម្អាតបរិស្ថាន មានការចុះប្រមូលសំរាមនៅតាមទីសាធារណៈ ដើម្បីឱ្យសិស្សានុសិស្សបានចូលរួមក្នុងកិច្ចកែលម្អបរិស្ថានទាំងអស់គ្នាផងដែរ។

ទីពីរ គឺការបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់សហគមន៍ ការបញ្ជ្រាបការយល់ដឹងនេះធ្វើឡើងតាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀនដែលជាតំណាងរបស់វិទ្យាល័យ និងសហគមន៍ដែលមានតួនាទីរៀបចំបណ្ដាញអប់រំតាមភូមិ ដើម្បីធ្វើការផ្សព្វផ្សាយការយល់ដឹងនេះដល់មាតាបិតា អ្នកអាណាព្យាបាលសិស្ស និងអាជ្ញាធរមូលដ្ឋាន។ គណៈកម្មការគ្រប់គ្រងសាលារៀនជានិច្ចកាលបានចូលរួមគ្រប់សកម្មភាព ក្នុងការដឹកនាំ អភិវឌ្ឍន៍ និងកែលម្អបរិស្ថានដូចជាការធ្វើទស្សនកិច្ចសិក្សានានា ការចូលរួមប្រជុំពិភាក្សាលើកិច្ចរៀបចំផែនការអភិវឌ្ឍន៍បរិស្ថាន និងការកសាងហេដ្ឋារចនាសម្ព័ន្ធរបស់វិទ្យាល័យតាមរយៈការកៀរគរដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន។

ជំពូកទី៣

៣.២.៥.២. ការរៀបចំរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងកែលម្អបរិស្ថានអនាម័យ

ក្នុងការកែលម្អបរិស្ថាន និងសោភ័ណភាពរបស់វិទ្យាល័យ គណៈគ្រប់គ្រងសាលារៀន បានបង្កើត**គណៈកម្មការទទួលបន្ទុកផ្នែកបរិស្ថាន និងអនាម័យ** ដែលមានសមាជិកចំនួន ១១រូប ជ្រើសចេញពីក្នុងចំណោមបុគ្គលិកអប់រំទាំងអស់ និងសិស្សឆ្នើមរបស់វិទ្យាល័យ។ គណៈកម្មការនេះ ត្រូវបានបង្កើតឡើងតាមរយៈកិច្ចប្រជុំគណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំ និងតំណាងសិស្ស (ក្រុមប្រឹក្សាយុវជន និងកុមារ) ដែលត្រូវបានប្រគល់តួនាទីភារកិច្ចតាមរយៈលិខិតបង្គាប់ការរបស់នាយកសាលា។ គណៈកម្មការទទួលបន្ទុកផ្នែកបរិស្ថាន និងអនាម័យមានតួនាទី និងភារកិច្ចប្រជុំផ្តល់យោបល់លើកិច្ចការកែលម្អបរិស្ថាន និងអនាម័យ ព្រមទាំងបង្កើតយន្តការ និងកម្មវិធីគ្រប់គ្រងបរិស្ថាន និងអនាម័យវិទ្យាល័យ។ គណៈកម្មការទទួលបន្ទុកផ្នែកបរិស្ថាន និងអនាម័យមានក្រុមកែលម្អបរិស្ថានជាសេនាធិការក្នុងការអនុវត្តកិច្ចការដោយផ្ទាល់។

ក្រុមកែលម្អបរិស្ថាន÷ ក្រុមនេះបង្កើតឡើងដោយការប្រជុំចាត់តាំងរបស់គណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការទទួលបន្ទុកផ្នែកបរិស្ថាន និងអនាម័យ មានសមាជិកចំនួន០៥រូប ដែលជ្រើសចេញពីក្នុងចំណោមលោកគ្រូ អ្នកគ្រូ និងតំណាងប្រធានថ្នាក់ទាំង ២៤ថ្នាក់ និងអនុប្រធានក្រុមប្រឹក្សាយុវជនទទួលបន្ទុកផ្នែកពលកម្ម។ ក្រុមកែលម្អបរិស្ថានមានតួនាទីអនុវត្តនូវកិច្ចការនានាដែលគណៈកម្មការទទួលបន្ទុកបរិស្ថាន និងអនាម័យប្រគល់ជូន និងអនុវត្តការដាក់ពិន័យលើសិស្ស ដែលមិនបានអនុវត្ត ឬគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាល័យ។ ក្រុមកែលម្អបរិស្ថានមានក្រុមអន្តេវាសិកដ្ឋាន និងក្រុមប្រឹក្សាយុវជននិងកុមារជាសេនាធិការ។

ក្រុមអន្តេវាសិកដ្ឋាន÷ ក្រុមនេះបង្កើតឡើងតាមការប្រជុំចាត់តាំងរបស់គណៈគ្រប់គ្រងសាលារៀន ដោយជ្រើសរើសចេញពីក្នុងចំណោមលោកគ្រូ អ្នកគ្រូ និងសិស្សដែលស្នាក់នៅផ្ទាល់ក្នុងអន្តេវាសិកដ្ឋានចំនួន០៦រូប។ ក្រុមអន្តេវាសិកដ្ឋានមានភារកិច្ចជាសេនាធិការរបស់ក្រុមកែលម្អបរិស្ថាន ក្នុងការអនុវត្តការងារបរិស្ថានសាលានៅពេលដែលសិស្ស

ទាំងអស់ឈប់សម្រាក (ថ្ងៃបុណ្យនានា) ឬវិស្សមកាល។ ការគ្រប់គ្រងអន្តេវាសិកដ្ឋានចែកចេញជាពីរផ្នែកគឺ ផ្នែកបុរស និងផ្នែកស្ត្រី ដែលត្រូវធ្វើការបែងចែកក្រុមតូចៗបន្តទៀតដើម្បីអនុវត្តកិច្ចការបរិស្ថាន និងអនាម័យដូចជាស្រោចផ្កា សួនបន្លែ និងស្មៅក្នុងទីធ្លា ផងដែរ។

ក្រុមប្រឹក្សាយុវជន និងកុមារ÷ ក្រុមនេះមានតួនាទីជាសេនាធិការដល់ក្រុមកែលម្អបរិស្ថានក្នុងការជួយកែលម្អបរិស្ថាន និងអនាម័យរបស់វិទ្យាល័យ។ ក្រុមប្រឹក្សាយុវជននិងកុមារជាក្រុមបង្គោល និងជាចលករយ៉ាងសំខាន់ក្នុងការដឹកនាំយុវជនទាំងអស់ឱ្យចូលរួមយ៉ាងសកម្មក្នុងកិច្ចការបរិស្ថាន។ ការអនុវត្តលើកិច្ចការរបស់ក្រុមនេះត្រូវធ្វើឡើងនៅម៉ោងសម្រាក និងក្នុងម៉ោងពលកម្ម។ ក្រុមប្រឹក្សាយុវជន និងកុមារ មានតួនាទីនិងភារកិច្ចធ្វើការផ្សព្វផ្សាយពីគុណសម្បត្តិ និងគុណវិបត្តិនៃបរិស្ថាន ត្រួតពិនិត្យ អនាម័យថ្នាក់រៀន បរិស្ថានវិទ្យាល័យ សណ្តាប់ធ្នាប់សិស្ស ព្រមទាំងធ្វើការណែនាំដល់សិស្សតាមថ្នាក់ឱ្យអនុវត្តតាមគោលការណ៍របស់គណៈកម្មការទទួលបន្ទុកបរិស្ថាន និងអនាម័យ។

រូបភាពទី៧÷ គំនូសតាងរចនាសម្ព័ន្ធការអនុវត្តការងារកែលម្អបរិស្ថានវិទ្យាល័យពេជ្រចិន្តា



ជំពូកទី៣

រូបភាពទី៨÷ បដា និងពាក្យស្លោកអប់រំស្ដីពីបរិស្ថាន

រូបភាពទី៩÷ ទិដ្ឋភាពបរិស្ថានរបស់វិទ្យាល័យពេជ្រចិន្តា

ជំពូកទី៣

៣.២.៥.៣. ការអនុវត្តដើម្បីភាពស្អាត អនាម័យ និងភាពបៃតង

ដើម្បីឱ្យបរិវេណវិទ្យាល័យមានសោភ័ណភាពល្អ មានអនាម័យ និងមានពណ៌បៃតងជាប់ជានិច្ច និងមានភាពងាយស្រួលក្នុងការគ្រប់គ្រង គណៈកម្មការទទួលបន្ទុកបរិស្ថាន និងអនាម័យ បានបែងចែកប្លង់បរិស្ថានវិទ្យាល័យជាពីរផ្នែកសំខាន់ៗ រួមមាន÷ ផ្នែកបរិស្ថានធម្មជាតិ មានជាអាទិ៍សួនច្បារ សួនជីវៈចម្រុះ និងទឹក (ទឹកស្អាត និងប្រព័ន្ធរំដោះទឹក) និងផ្នែកសោភ័ណភាព និងអនាម័យ មានជាអាទិ៍ថ្នាក់រៀន បន្ទប់ទឹកគ្រូ-សិស្ស អាហារដ្ឋាន និងទីធ្លាសាលារៀន។

ផ្នែកបរិស្ថានធម្មជាតិ ដឹកនាំដោយប្រធានក្រុមមួយរូបជាអនុប្រធានក្រុមប្រឹក្សាយុវជន និងកុមារទទួលបន្ទុកផ្នែកពលកម្ម។ ប្រធានក្រុមនេះ មានតួនាទី និងភារកិច្ចដឹកនាំសិស្សអនុវត្តការងារបរិស្ថានធម្មជាតិរៀងរាល់ថ្ងៃព្រហស្បតិ៍ និងម៉ោងសម្រាក ឬពេលលោកគ្រូ អ្នកគ្រូនៅតាមថ្នាក់ណាមួយ អវត្តមាន។ ចំពោះផែនការអនុវត្តត្រូវធ្វើឡើងតាមការប្រជុំពិនិត្យដោយក្រុមកែលម្អបរិស្ថាន និងអនាម័យលើបញ្ហាផ្សេងៗដែលកំពុងកើតមាន ដោយមានអនុប្រធានទទួលបន្ទុកផ្នែកពលកម្មនៃក្រុមប្រឹក្សាយុវជន និងកុមារជាអ្នកត្រួតពិនិត្យការអនុវត្ត ហើយត្រូវរាយការណ៍ពីលទ្ធផលជូនដល់ប្រធានក្រុមកែលម្អបរិស្ថាន។ ចំពោះការដាក់ប្រព័ន្ធរំដោះទឹក និងការប្រើប្រាស់ទឹកស្អាតរបស់វិទ្យាល័យ ត្រូវធ្វើឡើងដោយមានមន្ត្រីជំនាញពាក់ព័ន្ធចូលរួមត្រួតពិនិត្យ និងផ្តល់យោបល់។ ជាក់ស្តែង ដូចការសាងសង់ប្រព័ន្ធរំដោះទឹកដែលជាជំនួយរបស់សហគមន៍ត្រូវធ្វើឡើងដោយមានការប្រជុំពិភាក្សា និងសុំការអនុញ្ញាតពីអាជ្ញាធរថ្នាក់ស្រុកក្នុងការរៀបចំប្រព័ន្ធរំដោះទឹកចេញពីបរិវេណវិទ្យាល័យ។

ផ្នែកសោភ័ណភាព និងអនាម័យ ផ្នែកនេះដឹកនាំអនុវត្តដោយក្រុមប្រឹក្សាយុវជន និងកុមារដោយធ្វើការបែងចែកវេនក្រុមសម្អាតតាមថ្នាក់ និងតាមវេនសម្អាតដូចតទៅ÷

ក្រុមសម្អាតបន្ទប់ទឹក យោងតាមស្ថានភាពទីតាំងអគារនិងបន្ទប់ទឹករបស់វិទ្យាល័យ ការសម្អាតបន្ទប់ទឹកត្រូវបានបែងចែកជាពីរផ្នែក ដើម្បីងាយស្រួលគ្រប់គ្រងការធ្វើអនាម័យ។

ផ្នែកទីមួយគឺបន្ទប់ទឹកនៅជាន់ផ្ទាល់ដីជាអំណោយរបស់សហគមន៍ និងផ្នែកទីពីរជាបន្ទប់ទឹកនៅតាមអគារ ៣ជាន់ ដែលជាអំណោយរបស់សហគមន៍និងជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ សម្រាប់អគារ ៣ជាន់ ដែលមានថ្នាក់រៀនចំនួន ១៧ថ្នាក់ ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១០ បែងចែកក្រុមសម្អាតជា ៦ក្រុម (សិស្សប្រុស ៣ក្រុម និងសិស្សស្រី ៣ក្រុម) ហើយការសម្អាតបន្ទប់ទឹកត្រូវបានអនុវត្តជារៀងរាល់ថ្ងៃនៃម៉ោងសិក្សា។ សម្រាប់បន្ទប់ទឹកនៅផ្ទាល់ដី ត្រូវបានសម្អាតដោយសិស្សថ្នាក់ទី១១ និងទី១២ ដែលមាន ៨ថ្នាក់ សម្រាប់អនុវត្ត។ សម្រាប់ថ្នាក់១២A ត្រូវគ្រប់គ្រងលើការដុតសំរាម។ ការរក្សាអនាម័យបន្ទប់ទឹកនេះ ត្រូវធ្វើការត្រួតពិនិត្យជារៀងរាល់ម៉ោងចេញលេងដោយអនុប្រធានផ្នែកអនាម័យរបស់ក្រុមប្រឹក្សាយុវជន និងកុមារជាអ្នកទទួលបន្ទុក និងដាក់ពិន័យលើក្រុមដែលមិនបានអនុវត្ត។

ក្រុមសម្អាតថ្នាក់រៀន៖ ក្រុមនេះដឹកនាំដោយអនុប្រធានក្រុមប្រឹក្សាយុវជន និងកុមារទទួលបន្ទុកផ្នែកបរិស្ថានជាអ្នកដឹកនាំគ្រប់គ្រង និងត្រួតពិនិត្យលើការរក្សាអនាម័យក្នុងថ្នាក់របស់សិស្សម្នាក់ៗ។ ដែនកំណត់របស់ថ្នាក់រៀនត្រូវបានកម្រិតចាប់ត្រឹមពីបរិវេណមុខថ្នាក់ (ពីកាំជណ្តើរមុខថ្នាក់រហូតដល់ក្នុងបន្ទប់) ដើម្បីងាយស្រួលត្រួតពិនិត្យលើបញ្ហាអនាម័យដូចជាសំរាម សណ្តាប់ធ្នាប់សិស្សក្នុងថ្នាក់ និងការប្រើប្រាស់ទ្រនាប់ជើងផ្លាស់ប្តូរជាដើម។ រៀងរាល់ថ្ងៃនៃម៉ោងសិក្សា ក្រុមប្រឹក្សាយុវជន និងកុមារបានកំណត់ពេលចុះត្រួតពិនិត្យក្នុងថ្នាក់រៀនចំនួនពីរដងក្នុងមួយថ្ងៃ ដើម្បីត្រួតពិនិត្យតាមតុដែលរៀបតាមប្លង់ដោយមានបិទឈ្មោះសិស្ស និងលេខទូរសព្ទមាតាបិតា ឬអ្នកអាណាព្យាបាលរបស់សិស្សម្នាក់ៗ។ ក្នុងករណីឃើញមានសំរាមនៅតុឈ្មោះសិស្សណាម្នាក់ ក្រុមប្រឹក្សាយុវជននឹងធ្វើការលើកឡើងនៅក្នុងអង្គប្រជុំរបស់ខ្លួន ដែលធ្វើឡើងរៀងរាល់មួយសប្តាហ៍ម្តង ឬពីរដងតាមការចាំបាច់ ឬមួយត្រូវរាយការណ៍ជូនប្រធានទទួលបន្ទុកផ្នែកបរិស្ថាននិងអនាម័យ ក្នុងករណីដែលសិស្សណាម្នាក់មិនអនុវត្តតាមការណែនាំ។ សូមជម្រាបថា ដើម្បីរក្សាអនាម័យក្នុងថ្នាក់រៀនសិស្សម្នាក់ៗតម្រូវឱ្យមានការប្រើប្រាស់ទ្រនាប់ជើងផ្លាស់ប្តូរដែលដាក់ឱ្យប្តូរនៅមុខថ្នាក់

នីមួយៗ និងត្រូវមានថង់ម្នាក់មួយសម្រាប់ទុកដាក់សំរាមរបស់ខ្លួនដើម្បីយកទៅចោលនៅឡដុតសំរាម ឬត្រូវយកទៅផ្ទះវិញ។ ចំពោះការហូបចុកត្រូវកាត់បន្ថយការវេចខ្ចប់អាហារមកញ៉ាំក្នុងថ្នាក់ ដោយត្រូវញ៉ាំនៅអាហារដ្ឋានឱ្យបានត្រឹមត្រូវ។

ការសម្អាតទីធ្លា ដើម្បីធ្វើឱ្យគុណភាពបរិស្ថានរបស់វិទ្យាល័យកាន់តែមានភាពល្អប្រសើរនោះ គណៈគ្រប់គ្រងសាលារៀនបានធ្វើការប្រជុំពិភាក្សាគ្នា ក្រោយពីបានធ្វើទស្សនកិច្ចសិក្សានៅប្រទេសថៃមក ដោយបានលើកឡើងពីគុណវិបត្តិនៃការដាក់ធុងសំរាមនៅតាមថ្នាក់រៀន និងនៅក្នុងបរិវេណវិទ្យាល័យដែលបណ្ដាលឱ្យមានការជះក្លិនមិនល្អ និងភាពកខ្វក់ ដោយបានដាក់ចេញនូវគោលការណ៍សម្រាប់ឱ្យសិស្សអនុវត្តគឺ «**គោលការណ៍គ្មានធុងសំរាម គឺគ្មានសំរាម និងគោលការណ៍ស្វ័យគ្រប់គ្រងសំរាម**»។ ផ្អែកលើគោលការណ៍ទាំងពីរនេះគណៈគ្រប់គ្រងសាលារៀនបានបញ្ឈប់ការប្រើប្រាស់ធុងសំរាមនៅក្នុងថ្នាក់រៀន និងបរិវេណវិទ្យាល័យ។ ដើម្បីឱ្យកិច្ចការនេះសម្រេចទៅបានល្អ គេបានបង្កើតក្រុមត្រួតពិនិត្យ និងវាយតម្លៃបរិស្ថានដោយមានក្រុមប្រឹក្សាយុវជន និងកុមារជាអ្នកទទួលខុសត្រូវលើការទុកដាក់សំរាមរបស់សិស្សម្នាក់ៗដោយមានអ្នកត្រួតពិនិត្យ និងកត់ឈ្មោះសិស្សណាដែលបានចោលសំរាមក្នុងទីធ្លា ឬស្វែងរកឈ្មោះសិស្សណាដែលបានចោលសំរាមនៅតាមបង់សម្រាប់អង្គុយ។ មិនត្រឹមតែប៉ុណ្ណោះ សិស្សគ្រប់គ្នាអាចមានសិទ្ធិរាយការណ៍ ពីការចោលសំរាមពាសវាលពាសកាលរបស់សិស្សណាម្នាក់ក្នុងទីធ្លាទៅកាន់ប្រធានផ្នែកបរិស្ថានបានផងដែរ។ ចំពោះសំរាមដែលប្រមូលបាន វិទ្យាល័យបានធ្វើការបែងចែកប្រភេទសំរាមដើម្បីកែច្នៃធ្វើជាជីកំប៉ុសសម្រាប់ប្រើប្រាស់ និងត្រូវដុតបំផ្លាញចោលក្នុងឡដុតសំរាមដោយមិនធ្វើឱ្យប៉ះពាល់ដល់សិស្សក្នុងម៉ោងសិក្សាឡើយ។

រូបភាពទី១០៖ ការធ្វើពលកម្ម និងអនាម័យរបស់សិស្ស

រូបភាពទី១១៖ ការត្រួតពិនិត្យថ្នាក់រៀនរបស់ក្រុមប្រឹក្សាយុវជន និងកុមារ

៣.២.៥.៤. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិស្ថានសាលារៀន

ដើម្បីសម្រួលដល់ការគ្រប់គ្រងលើបញ្ហាសំរាម គណៈគ្រប់គ្រងសាលារៀនបានរៀបចំកន្លែងសម្រាប់ទុកដាក់សំរាម និងផ្តួចផ្តើមកសាងឡដុតសំរាមមួយកន្លែងតាមរយៈជំនួយរបស់អង្គការទស្សនៈពិភពលោក សម្រាប់ការដុតបំផ្លាញសំរាមកាកសំណល់ផ្លាស់ស្ទិចបន្ទាប់ពីបានញែក និងបែងចែកប្រភេទសំរាមរួចហើយ។ មួយវិញទៀត ចំពោះការប្រើប្រាស់ទឹកវិញ វិទ្យាល័យបានពឹងផ្អែកលើប្រភពទឹកពីរយ៉ាងគឺ ទឹកភ្លៀង និងទឹកអណ្តូងដើម្បីឱ្យមានទឹកគ្រប់គ្រាន់ក្នុងការប្រើប្រាស់។ គណៈគ្រប់គ្រងសាលារៀនបានសាងសង់អាងស្តុកទឹកសម្រាប់ផ្ទុកទឹកទឹកភ្លៀងនារដូវវស្សា ព្រមទាំងបានជីកអណ្តូងចំនួន ៤ដោយមានបំពាក់ម៉ូទ័រសម្រាប់ទាញទឹកប្រើប្រាស់ជាទូទៅនៅក្នុងវិទ្យាល័យ និងសម្រាប់អន្តេវាសិកដ្ឋាន។ ចំពោះការប្រើប្រាស់បន្ទប់ទឹក ដើម្បីឱ្យមានភាពងាយស្រួល និងមានសុវត្ថិភាពសម្រាប់សិស្សប្រើប្រាស់ គណៈគ្រប់គ្រងបានសាងសង់បន្ទប់ទឹកចំនួន ២២បន្ទប់ និងបែងចែកសម្រាប់ប្រុសចំនួន ១១បន្ទប់ និងស្រីចំនួន ១១បន្ទប់ ប្រើដាច់ពីគ្នា។

ក្រៅពីការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រលើការគ្រប់គ្រងបរិស្ថាន គណៈគ្រប់គ្រងសាលារៀនក៏បានគិតគូរដល់ការកែលម្អសោភ័ណភាពវិទ្យាល័យដោយមានដាក់តម្កល់រូបចម្លាក់ពុទ្ធបដិមាសម្រាប់គោរពបូជា និងរៀបចំបង់អង្គុយដាក់ក្រោមម្លប់ឈើជាច្រើនកន្លែង ព្រមទាំងសាងសង់បន្ថែមនូវរោងប្របនឹងសួនច្បារសម្រាប់សិស្សអង្គុយលំហែ ឬពិភាក្សាការងារក្រុម ដែលមានសោភ័ណភាពស្រស់បំព្រងលម្អដោយផ្កា និងរុក្ខជាតិដទៃទៀត។ នៅប្របមាត់ផ្លូវក្រាលបេតុងតាមសួនច្បារក្នុងវិទ្យាល័យក៏មានការកែច្នៃអាងលាងដៃ និងដាក់សាប៊ូសម្រាប់ប្រើប្រាស់ជាសាធារណៈចំនួនប្រាំពីរកន្លែង ដោយយកទឹកប្រើប្រាស់រួចស្រោចស្រពលើសួនច្បារ។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធទាំងនេះ គណៈគ្រប់គ្រងសាលារៀនក៏បានកីឡដ្ឋានដែលមានទីលានបាល់ទាត់ បាល់ទះ បាល់បោះធំទូលាយ និងផ្នែកកីឡាអត្តពលិកដូចជា លោតកម្ពស់ រត់ចម្ងាយ និងឡើងខ្សែពួរផងដែរ។ ចំពោះចំណតយានជំនិះគេបានរៀបចំឱ្យមានសណ្តាប់ធ្នាប់ល្អដោយបង្កើតរៀបចំក្រាលបេតុងប្រក់ដំបូលស័ង្កសី

ជំពូកទី៣

ព្រមទាំងមាន ការបែងចែកទីតាំងចំណតទៅតាមប្រភេទយានជំនិះ និងបែងចែកកន្លែងចតសម្រាប់បុគ្គលិកអប់រំនិងសិស្ស។

លើសពីនេះទៀត គណៈគ្រប់គ្រងសាលារៀនក៏បានគិតគូរដល់សុខសុវត្ថិភាពសាធារណៈ ដោយបានបង្កើតប្រអប់សង្គ្រោះបឋមដែលមានថ្នាំ និងសម្ភារៈប្រើប្រាស់គ្រប់គ្រាន់សម្រាប់បង្ការក្នុងវិទ្យាល័យ និងសម្រាប់ប្រើប្រាស់ក្នុងអន្តេវាសិកដ្ឋាន។ ការងារគ្រប់គ្រងផ្នែកសង្គ្រោះបឋម ជាកិច្ចការមួយសំខាន់ ដូចនេះដើម្បីឱ្យការគ្រប់គ្រងលើបញ្ហាសុខសុវត្ថិភាព សាធារណៈនេះមានប្រសិទ្ធភាព គណៈគ្រប់គ្រងសាលារៀនបានបង្កើតក្រុមការងារសង្គ្រោះបឋមមួយឡើង ដោយមានសមាជិក ០៥រូប ជ្រើសចេញពីលោកគ្រូ អ្នកគ្រូទាំង ៣០រូប និងប្រធានក្រុមប្រឹក្សាយុវជនម្នាក់ជាសមាជិក។

រូបភាពទី១២÷ រូបភាពបន្ទប់ទឹក ឡដុតសំរាម និងអាងស្តុកទឹក

រូបភាពទី១៣៖ ការរៀបចំបង្កើតកីឡដ្ឋាន បង់សម្រាប់អង្គុយ និងសួនជីវៈចម្រុះ

៣.២.៥.៥. អនាម័យចំណីអាហារដែលលក់ដូរក្នុងបរិវេណសាលារៀន

ការលក់ចំណីអាហារ ត្រូវបានរៀបចំឱ្យមានអាហារដ្ឋានដែលមានស្តង់ដាត្រឹមត្រូវតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាល័យ ដោយសាងសង់ទីកន្លែងលក់ចំណីអាហារនៅឆ្ងាយពីថ្នាក់រៀន រៀបចំសណ្តាប់ធ្នាប់តុអាហារ រៀបចំសណ្តាប់ធ្នាប់តុអាហារ និងមានការសហការជាមួយក្រុមពេទ្យមណ្ឌលសុខភាព និងគណៈគ្រប់គ្រងសាលាក្នុងការត្រួតពិនិត្យគុណភាពរបស់អាហារតាមការស្នើសុំរបស់នាយកសាលា។ ចំពោះអាជីវករលក់ដូរក្នុងវិទ្យាល័យនេះ ចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌដែលកំណត់ដោយសាលារៀនមានដូចជា÷ ១)ត្រូវទទួលការណែនាំពីគណៈគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូ មុនពេលចាប់ផ្តើមការលក់ដូរចំណីអាហារ ២)ត្រូវចុះកិច្ចសន្យាការប្រកបអាជីវកម្មជាមួយគណៈគ្រប់គ្រងសាលារៀន ៣)ម្ចាស់អាជីវករនីមួយៗត្រូវទទួលខុសត្រូវលើសំរាមនៅទីកន្លែងរៀងៗខ្លួន ៤)មានការកម្រិតប្រភេទចំណីអាហារ និងភេសជ្ជៈដូចជាអាហារហួសកំណត់កាលបរិច្ឆេទ គ្មានប្រភពច្បាស់លាស់ ប្រភេទគ្រឿងស្រវឹង និងផលិតផលថ្នាំជក់ ភេសជ្ជៈប៉ូវកម្លាំងមានរសជាតិផ្អែមជ្រុលដូចជាកាហ្វេ ការ៉េម ទឹកស៊ើរ៉ូមគ្រប់ប្រភេទ ស្ករស្វូកូឡា ស្ករគ្រាប់ ស្ករកៅស៊ូគ្រប់ប្រភេទ ចាហួយគ្រប់ប្រភេទ នំដូណាត់ និងនំផ្អែមខ្លាំង។ ចំពោះទឹកប្រើប្រាស់សម្រាប់បរិភោគវិញ គណៈគ្រប់គ្រងសាលារៀនមានដាក់ឱ្យប្រើប្រាស់នូវឧបករណ៍ចម្រោះទឹកស្អាតពីរនៅក្នុងបរិវេណវិទ្យាល័យផងដែរ។

ជំពូកទី៣

រូបភាពទី១៤៖ អាហារដ្ឋាន

រូបភាពទី១៥៖ ការត្រួតពិនិត្យចំណីអាហារ និងម៉ាស៊ីនចម្រោះទឹក

៣.២.៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និង ដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ

ការកសាងជំនឿនិងទំនុកចិត្តពីប្រជាពលរដ្ឋ សហគមន៍ ដៃគូអភិវឌ្ឍ និងពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ជាកត្តាគន្លឹះចាំបាច់ណាស់ក្នុងការបង្កើតនិងពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ដើម្បីធានាបាននូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពដល់សិស្សានុសិស្សក៏ដូចជាសហគមន៍។ ជាមួយគ្នានេះផងដែរ វិទ្យាល័យបានផ្តល់សេវាអប់រំ**ប្រកបដោយសមធមិ បរិយាបន្ន និងគុណភាព** រហូតទទួលបានជ័យលាភីថ្នាក់ជាតិជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ ក៏ដោយសារមានការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធដូចជាសហគមន៍ជាតិ សហគមន៍អន្តរជាតិ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ មាតាបិតា និងអ្នកអាណាព្យាបាលសិស្សផងដែរ។ គណៈកម្មការគ្រប់គ្រងសាលារៀន ដែលដឹកដោយលោក **ភឿន ឡូត** បានខិតខំប្រឹងប្រែង និងរិះរកគ្រប់មធ្យោបាយដើម្បីកៀរគរអ្នកចូលរួមឧបត្ថម្ភ និងគាំទ្រដល់វិទ្យាល័យទាំងកម្លាំងកាយ ស្មារតី សម្ភារៈ និងថវិកា។

៣.២.៦.១. ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និង ដៃគូអភិវឌ្ឍ

ការផ្សារភ្ជាប់ទំនាក់ទំនងរវាងសាលារៀនទៅនឹងប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍគឺជាយន្តការនៃការពង្រឹងទំនាក់ទំនង និងជំរុញការចូលរួមដែលមិនអាចខ្វះបានក្នុងការធានាឱ្យមានវឌ្ឍនភាពប្រកបដោយនិរន្តរភាពរបស់សាលារៀន។ ក្នុងន័យនេះ គណៈកម្មការគ្រប់គ្រង គណៈគ្រប់គ្រងសាលារៀន បានប្រើប្រាស់វិធីសាស្ត្រ និងមធ្យោបាយក្នុងការពង្រឹងទំនាក់ទំនងយ៉ាងមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងការកសាងទំនុកចិត្តដល់ប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធតាមរយៈការអញ្ជើញអ្នកពាក់ព័ន្ធមកចូលរួមក្នុងការកសាងផែនការអភិវឌ្ឍន៍សាលារៀន និងការអនុវត្តប្រកប ដោយគណនេយ្យភាព និងតម្លាភាព។ កត្តាទាំងនេះបានជំរុញឱ្យមានការពេញចិត្ត ការចូលរួម

គាំទ្រទាំងស្មារតី និងការលះបង់ថវិកាក្នុងការលើកកម្ពស់សេវាអប់រំរបស់វិទ្យាល័យប្រកបដោយភាពជោគជ័យ។ កត្តាគន្លឹះជាច្រើនដែលគណៈគ្រប់គ្រងសាលារៀន ក៏ដូចជាបុគ្គលិកអប់រំបានអនុវត្តនាពេលកន្លងមក បានធ្វើឱ្យប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់សាលារៀន ក៏ដូចជាការអភិវឌ្ឍន៍សាលារៀន។ ការខិតខំប្រឹងប្រែងក្នុងការផ្តល់សេវាអប់រំជាពិសេសការបង្រៀន និងរៀនប្រកបដោយសមធម៌ បរិយាបន្ន និងគុណភាពជូនដល់អាជ្ញាធរដែនដី សហគមន៍ មាតាបិតា និងអ្នកអាណាព្យាបាល ដែលជាក់ស្តែងសិស្សានុសិស្សជាកូនជនក្រីក្រ សិស្សជាជនពិការ និងសិស្សមានទីលំនៅឆ្ងាយពីសាលាត្រូវទទួលបានការផ្តល់អាហារូបករណ៍ កន្លែងស្នាក់នៅក្នុងអន្តេវាសិកដ្ឋានរបស់សាលារៀន។ ចំពោះកូនអ្នកមានជីវភាពធូរធាដែលមិនសូវស្តាប់បង្គាប់ឪពុកម្តាយ សាលារៀនបានសហការជាមួយមាតាបិតា និងអ្នកអាណាព្យាបាលសិស្សក្នុងការផ្តល់ការអប់រំនៅសាលាឱ្យក្លាយទៅជាសិស្សមានសីលធម៌ និងសុជីវធម៌រស់នៅល្អទាំងកូនអ្នកមាន និងកូនអ្នកក្រប្រកបដោយគុណភាពដែលបានធ្វើឱ្យប្រជាពលរដ្ឋសហគមន៍មានការពេញចិត្ត និងចូលរួមគាំទ្រដោយភាពជឿជាក់។ ការលើកកម្ពស់ និងថែទាំធនធានមនុស្សគឺជាកត្តាគន្លឹះដែលគណៈគ្រប់គ្រងសាលារៀនបានយកចិត្តទុកដាក់ ដោយរក្សាបានធនធានគ្រូបង្រៀន បុគ្គលិកមានគុណវុឌ្ឍិខ្ពស់ទាំងសមត្ថភាព សីលធម៌ល្អប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់ ព្រមទាំងបង្កើតបាននូវវប្បធម៌សាមគ្គីដ៏ល្អទាំងខាងក្នុង និងខាងក្រៅដែលជាគំរូសម្រាប់សិស្សានុសិស្ស និងសហគមន៍ទាំងមូល។ វិទ្យាល័យក៏បានយកចិត្តទុកដាក់លើការគ្រប់គ្រង និងថែទាំបរិស្ថានក្នុងបរិវេណសាលារៀន បរិស្ថានធម្មជាតិ និងអនាម័យដែលធ្វើឱ្យវិទ្យាល័យមានសោភ័ណភាពល្អប្រណីតគួរជាទីមនោរម្យជាភាពទាក់ទាញដល់សិស្សានុសិស្សមានអារម្មណ៍ស្រស់ថ្លាប្រកបដោយផាសុកភាពក្នុងការសិក្សាដែលធ្វើឱ្យមាតាបិតា និងអ្នកអាណាព្យាបាល សហគមន៍ ដៃគូអភិវឌ្ឍនានាពេញចិត្តក្នុងការចូលរួមប្រកបដោយមោទកភាព។

លើការងារគ្រប់គ្រង គណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន

មានតម្លាភាព គណនេយ្យភាពក្នុងការគ្រប់គ្រងដោយបានអនុវត្តការងារប្រកបដោយស្មារតីទទួលខុសត្រូវ មនសិការវិជ្ជាជីវៈ ភាពស្មោះត្រង់ ការគិតពីប្រយោជន៍រួមជាធំ ដែលអូសទាញបាននូវចំណាប់អារម្មណ៍ពីប្រជាពលរដ្ឋក្នុងការចូលរួមដោយភាពពេញចិត្ត និងជឿជាក់ក្នុង**ស្មារតីតម្កល់ផលប្រយោជន៍សហគមន៍**ជាធំ។ ការអនុវត្តស្វ័យវាយតម្លៃលទ្ធផលបានធ្វើឡើងរៀងរាល់ ១ខែម្តង ក្នុងនោះក៏មានការចូលរួមពីសំណាក់គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងគណៈកម្មការគ្រប់គ្រងសាលារៀនដោយពិនិត្យតាមដានវាយតម្លៃលើការងារបរិស្ថាន គុណភាពអប់រំ ដែលមាននៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន។

កត្តាគន្លឹះមួយទៀតដែលធ្វើឱ្យសាលាកាន់តែកសាងបាននូវទំនាក់ទំនង និងការចូលរួមដោយពេញចិត្តពីប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ នោះគឺការកសាងផែនការអភិវឌ្ឍន៍សាលារៀន។ សាលារៀនបានអញ្ជើញគ្រប់ភាគីពាក់ព័ន្ធទាំងអស់មកចូលរួម ដើម្បីឆ្លងយោបល់ ប្រមូលព័ត៌មានគ្រប់ជ្រុងជ្រោយ ដែលជាធាតុចូលដ៏មានសារៈសំខាន់ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ប្រកបដោយប្រសិទ្ធភាពខ្ពស់។ គណៈគ្រប់គ្រងសាលារៀនយល់ឃើញថា **ការផ្តល់សិទ្ធិ និងឱកាសចូលរួម**ពីប្រជាពលរដ្ឋ សហគមន៍ ដៃគូអភិវឌ្ឍ គឺជាការផ្តល់នូវកិត្តិយស ការរួមចំណែកទទួលខុសត្រូវក្នុងភាពជាម្ចាស់ដោយឈរលើស្មារតី **រួមគ្នាគិត រួមគ្នាធ្វើ រួមគ្នាដោះស្រាយ** ដើម្បីផលប្រយោជន៍សហគមន៍ ប្រកាន់ខ្ជាប់នូវពាក្យស្លោក÷

«សាលារៀនជារបស់សហគមន៍ សហគមន៍ដើម្បីសាលារៀន»

«សហគមន៍ល្អ គ្រូល្អ សិស្សល្អ សាលាមានការអភិវឌ្ឍ»

ក. ការចូលរួមរបស់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន

ការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព(គ្មានបងតូច បងធំ) ប្រកបដោយការសហការយ៉ាងជិតស្និទ្ធពីសំណាក់អាជ្ញាធរមូលដ្ឋានជាមួយវិទ្យាល័យ បានធ្វើឱ្យសិស្សានុសិស្ស ប្រជាពលរដ្ឋជាមាតាបិតា និងអ្នកអាណាព្យាបាល សហគមន៍មានភាពកក់ក្តៅ និងជឿជាក់ចំពោះសន្តិសុខ សុវត្ថិភាពរបស់សិស្សានុសិស្ស។ ក្នុងនោះផងដែរ ជាក់ស្តែងសមត្ថកិច្ចមូលដ្ឋានបានរួមចំណែកជួយការពារសន្តិសុខ ដាក់វេនល្បាតជាប្រចាំដើម្បីរក្សា

សន្តិសុខ សណ្តាប់ធ្នាប់មូលដ្ឋាន និងបានចូលរួមអន្តរាគមន៍លើការបង្ក្រាបបទល្មើសនានា និងជួយសង្គ្រោះសិស្សានុសិស្សនិងបុគ្គលិកអប់រំដែលស្នាក់នៅក្នុងអន្តេវាសិកដ្ឋានតាមការស្នើសុំរបស់គណៈគ្រប់គ្រងសាលារៀន និងសហគមន៍ដោយស្មារតីសហការខ្ពស់មិនថាថ្ងៃឬយប់ឡើយ។ គណៈគ្រប់គ្រងវិទ្យាល័យពេជ្រចិន្តាបានចាត់ទុកថា រាល់ភាពជោគជ័យដែលសម្រេចបានពិតជាទាមទារនូវការចូលរួមគាំទ្រ សហការ និងជួយជ្រោមជ្រែងពីសហគមន៍ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងការជួយឧបត្ថម្ភទាំងស្មារតី សម្ភារៈ ថវិកា និងការរក្សាសណ្តាប់ធ្នាប់ សន្តិសុខ សុវត្ថិភាពទាំងក្នុង និងក្រៅសាលារៀន ព្រោះថាពួកគាត់ទាំងនោះមានកូនចៅរៀននៅទីនេះ។ ករណីជាក់ស្តែង វិទ្យាល័យក៏មានការយកចិត្តទុកដាក់ពី **ឯកឧត្តម ជា ភ្លងភិរម្យ** ប្រធានក្រុមការងារចុះជួយស្រុកភ្នំព្រឹក អាជ្ញាធរមូលដ្ឋាន និងសហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន បានរួមគ្នាគិតគូរធ្វើយ៉ាងណាជួយរិះរកមធ្យោបាយដើម្បីឱ្យកូនចៅនៅតំបន់នេះ បានសិក្សារៀនសូត្រដូចគេដូចឯងកុំឱ្យមានការលំបាកដូចពួកគាត់ ដែលបានឆ្លងកាត់សង្គ្រាម គ្មានសាលារៀន ឬត្រូវធ្វើដំណើរទៅរៀនឆ្ងាយពីផ្ទះ និងដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល **ប្រែក្លាយតំបន់អតីតសមរភូមិ**ឱ្យទៅជាតំបន់មានការអភិវឌ្ឍ ប្រែក្លាយចំការមីនឱ្យទៅជាថ្នាលបណ្តុះបណ្តាលធនធានមនុស្ស។ ជាមួយគ្នានេះដែរ សាលារៀនតែងតែយកចិត្តទុកដាក់ក្នុងការផ្តល់ការចូលរួមផ្ទាល់ពីអាជ្ញាធរក្នុងការជួយផ្តល់អនុសាសន៍កែលម្អ ការជួយផ្សព្វផ្សាយទៅកាន់សហគមន៍ ការចូលរួមសហការ ចុះដល់មូលដ្ឋានជាមួយគ្រូបន្ទុកថ្នាក់ គណៈកម្មការគណៈគ្រប់គ្រងសាលារៀនដើម្បីជួយពន្យល់ណែនាំសិស្សដែលបោះបង់ការសិក្សាឱ្យយល់ពីតម្លៃនៃការសិក្សានិងបានចូលរៀនវិញ។ ជាការកត់សម្គាល់ ការលះបង់កម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាបានផ្តើមចេញពីតំណាងសហគមន៍ គណៈកម្មការគ្រប់គ្រងសាលា ដែលជាចលករក្នុងការលើកកម្ពស់ស្មារតីចូលរួមប្រកបដោយទំនុកចិត្ត។ ជាក់ស្តែង ការលះបង់របស់លោកគ្រូ អ្នកគ្រូ ដែលតែងតែមកសាលាមុនម៉ោងជាប្រចាំដើម្បីចាំទទួលបដិសណ្ឋារកិច្ចសិស្សតាមវេនរៀងរាល់ពេលព្រឹក។ លើសពីនេះទៅទៀត ពួកគាត់បានចំណាយថវិកាដោយ

ជំពូកទី៣

ស្ម័គ្រចិត្តដោយមិនទទួលយកថវិកាឧបត្ថម្ភរបស់សហគមន៍ និងសិស្ស ក្នុងការទំនាក់ទំនងជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សនៅពេលដែលសិស្សអវត្តមាន និងជួយបង្រៀនបំប៉នសិស្សរៀនយឺត។ តាមរយៈធនធានគ្រូល្អ ប្រកបដោយវិន័យ និងសីលធម៌ល្អ វិធីសាស្ត្រនៃការបង្រៀនល្អ ធ្វើឱ្យសិស្សទទួលបានលទ្ធផលសិក្សាល្អ មានសីលធម៌រស់នៅល្អ មានវិន័យល្អ ចេះរស់នៅជាមួយគ្នា ចេះធ្វើការជាក្រុម មានសាមគ្គីភាពល្អ គួរឱ្យស្រឡាញ់ដែលកូនៗរបស់ពួកគាត់ទទួលបានចំណេះដឹងពិតប្រាកដ (ជាក់ស្តែង) ហួសពីការរំពឹងទុក។ កត្តាសាមគ្គីភាពនិងមានទំនាក់ទំនងល្អទាំងផ្ទៃក្នុងនិងខាងក្រៅ និងមនោសញ្ចេតនា ការគោរពរាប់អាន និងការផ្តល់ទំនុកចិត្តទៅវិញទៅមករវាងសាលា អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងសហគមន៍ទាំងនេះបានជួយអូសទាញចំណាប់អារម្មណ៍ពីសំណាក់អាជីវករអ្នកមានជីវភាពធូរធារ មានការជឿជាក់ស្ម័គ្រស្មោះ ចូលរួមជួយសាលារៀន ដោយឆន្ទៈចង់បង្កើតស្នាដៃនិងជាគំរូសម្រាប់អ្នកជំនាន់ក្រោយប្រកបដោយមោទនភាព។ ការស្តែងចេញយ៉ាងច្បាស់ពីសកម្មភាពនៃការប្រតិបត្តិរបស់គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូនិងការទទួលបានព័ត៌មានត្រឡប់តាមរយៈកូនៗរបស់ពួកគាត់ពីលទ្ធផលជាផ្លែផ្កាពីសាលាក៏ដូចជាតំណាងសហគមន៍មើលឃើញពីការខ្វះខាតនិងតម្រូវការចាំបាច់ជាក់ស្តែងរបស់សហគមន៍ និងសាលាជាអាទិភាព។ តំណាងសហគមន៍បានផ្តួចផ្តើមគំនិតជួយបំផុស និងពិភាក្សាអ្នកក្នុងភូមិ ដើម្បីប្រមូលកម្លាំងត្រៀមខ្លួនជាស្រេចក្នុងការចូលរួមជួយកសាង និងអភិវឌ្ឍសាលារៀន ដោយឈរលើទស្សនៈរួម **សហគមន៍ល្អ គ្រូល្អ សិស្សល្អ សាលារៀនមានការអភិវឌ្ឍ**។ យន្តការនៃការគាំទ្រដល់ការបំពេញបន្ថែមនូវជំនឿទុកចិត្ត ភាពកក់ក្តៅ សម្រាប់មាតាបិតា និងអ្នកអាណាព្យាបាល សហគមន៍ និងអ្នកពាក់ព័ន្ធទាំងអស់ គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀនបានអនុវត្តការប្រជុំផ្សព្វផ្សាយដល់មាតាបិតា ទទួលរាល់សំណូមពរ និងយោបល់ពីសហគមន៍ជាប្រចាំ ជាមួយនឹងដំណោះស្រាយបញ្ហាប្រឈមនានា តាមរយៈការឆ្លើយតបទាន់ពេលវេលា ការបង្កើតឱ្យមានកម្មវិធីបង្រៀនភាសាបរទេសបន្ថែម (ភាសាថៃ ព្រោះដោយសារតែ

សហគមន៍នៃតំបន់នេះមានទីតាំងនៅជាប់នឹងព្រំដែនកម្ពុជា ថៃ) ដើម្បីជួយបង្កលក្ខណៈងាយស្រួលដល់សិស្សានុសិស្សក្នុងការស្វែងរកការងារធ្វើ ដែលអាចជួយលើកកម្ពស់កម្រិតជីវភាពគ្រួសារ និងរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

តម្លាភាពនិងគណនេយ្យភាព ជាកត្តាគន្លឹះក្នុងការផ្តល់ទំនុកចិត្ត និងការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ។ ការគ្រប់គ្រងសាលារៀន បានអនុវត្តការគ្រប់គ្រងការងារប្រកបដោយស្មារតីទទួលខុសត្រូវ មនសិការវិជ្ជាជីវៈ ភាពស្មោះត្រង់ ការគិតពីប្រយោជន៍រួមជាធំ បានអូសទាញនូវចំណាប់អារម្មណ៍ពីប្រជាពលរដ្ឋ សហគមន៍ ក្នុងការចូលរួមដោយភាពពេញចិត្ត និងជឿជាក់ ក្នុងស្មារតីតម្កល់ផលប្រយោជន៍សហគមន៍ជាធំ។ ក្នុងនោះជាក់ស្តែងការអនុវត្តស្វ័យវាយតម្លៃបានធ្វើឡើងរៀងរាល់ ១ខែម្តង ដោយមានការចូលរួមពីសំណាក់គណៈគ្រប់គ្រង សាលារៀន លោកគ្រូ អ្នកគ្រូ និងគណៈកម្មការគ្រប់គ្រងសាលាដោយពិនិត្យតាមដានវាយតម្លៃលើដំណើរការការងារ ការរៀបចំផែនការដែលរាល់ការធ្វើសេចក្តីសម្រេចចិត្តនានាក្នុងការអភិវឌ្ឍសាលារៀន ធ្វើឡើងតាមរយៈការគាំទ្រដោយសម្លេងភាគច្រើនដោយឈរលើគោលការណ៍រួម «**សម្ធហភាពដឹកនាំ សម្ធហភាពសម្រេចចិត្ត បុគ្គលជាអ្នកទទួលខុសត្រូវ**»។

ខ. សាមគ្គីភាពផ្ទៃក្នុង

គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ បុគ្គលិកទាំងអស់ បានកសាងនូវវប្បធម៌គោរពស្រឡាញ់ រាប់អាន ចេះជួយគ្នាទៅវិញទៅមកដោយមិនប្រកាន់បក្សពួក ឋានៈ តួនាទីក្នុងស្មារតីសាមគ្គីភាព និងមនោសញ្ចេតនាដ៏ល្អដែលបង្កើតបាននូវភាពសុខដុមក្នុងអង្គភាពព្រមទាំងទទួលបានភាពពេញចិត្តប្រកបដោយភាពកក់ក្តៅ និងជាគំរូសម្រាប់សិស្សានុសិស្ស និងសហគមន៍ទាំងមូល។

គ. បរិស្ថានសាលារៀន

ដោយការយកចិត្តទុកដាក់ខ្ពស់លើការគ្រប់គ្រងបរិស្ថានក្នុងបរិវេណសាលារៀន

បរិស្ថានធម្មជាតិ សោភ័ណភាព និងអនាម័យប្រកបដោយគំនិតច្នៃប្រឌិត នវានុវត្តន៍បាន ធ្វើឱ្យសាលាមានអនាម័យ បរិស្ថាន និងសោភ័ណភាពល្អប្រណីតគួរជាទីមនោរម្យ ជាភាព ទាក់ទាញដល់សិស្សានុសិស្សមានអារម្មណ៍ស្រស់ថ្លា ប្រកបដោយជាសុកភាពក្នុងការសិក្សា និងបានធ្វើឱ្យមាតាបិតា និងអ្នកអាណាព្យាបាល សហគមន៍រួមទាំងដៃគូអភិវឌ្ឍនានា កោតសរសើរ និងពេញចិត្តក្នុងការចូលរួមប្រកបដោយមោទកភាព។

ឃ. គុណភាពអប់រំ (កំណែទម្រង់)

កំណែទម្រង់វិស័យអប់រំបានជំរុញការលើកកម្ពស់គុណភាពអប់រំ ជាពិសេសការលើក កម្ពស់គុណវុឌ្ឍិគ្រូ ទាំងសមត្ថភាព សីលធម៌ មនសិការវិជ្ជាជីវៈ បានធ្វើឱ្យប្រជាពលរដ្ឋ សហគមន៍ មានការពេញចិត្ត និងចូលរួមគាំទ្រដោយភាពជឿជាក់ ជាពិសេសតាមរយៈ លទ្ធផលនៃកាប្រឡងសញ្ញាបត្រទុតិយភូមិរបស់សិស្សវិទ្យាល័យពេជ្រចិន្តានាឆ្នាំសិក្សា ២០១៨-២០១៩ ដែលទទួលបានអត្រាប្រឡងជាប់របស់សិស្សថ្នាក់ទី១២ បានរហូតដល់ ៩៣,៥២% សិស្សទទួលបាននិទ្ទេស A ចំនួន ៣នាក់ និងសិស្សថ្នាក់ទី៩ បានរហូតដល់ ៩៦,៦៧% លទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងពីគុណភាពអប់រំយ៉ាងច្បាស់គួរជាទីមោទនៈ។

៣.២.៦.២. ការកៀរគរធនធាន និងសហការជាមួយដៃគូអភិវឌ្ឍ

ការកៀរគរធនធាន និងការចូលរួមសហការពីសំណាក់ដៃគូអភិវឌ្ឍ គឺជាកត្តាចម្បង ដែលមិនអាចខ្វះបានក្នុងការជួយជំរុញការអភិវឌ្ឍរបស់វិទ្យាល័យ តាំងពីដើមរហូតមក ដល់បច្ចុប្បន្ន។ វិទ្យាល័យ បានទទួលការឧបត្ថម្ភនិងគាំទ្រសម្ភារៈថវិកាយ៉ាងច្រើនពីមាតា បិតា និងអាណាព្យាបាល សិស្ស អាជីវករ សហគមន៍ និងអាជ្ញាធរដែនដី។ ជាមួយគ្នានេះ ដៃគូអភិវឌ្ឍច្រើនបានចូលរួមឧបត្ថម្ភនិងគាំទ្រសម្ភារៈ ថវិកា និងបច្ចេកទេសដល់វិទ្យាល័យ រួមមាន អង្គការសម្រេចសុបិនកុមារកម្ពុជា អង្គការទស្សនៈពិភពលោក និងអង្គការ CAPE។ ក្នុងការកៀរគរធនធាននិងទាក់ទាញការចូលរួមសហការរបស់ដៃគូអភិវឌ្ឍ សាលារៀន ពិតជាចាំបាច់ត្រូវមានវិធីសាស្ត្រប្រកបដោយភាពឈ្លាសវៃ ទេពកោសល្យ និងភាពជា អ្នកដឹកនាំរបស់អ្នកគ្រប់គ្រងអង្គភាពខ្ពស់ក្នុងការផ្តល់នូវភាពជឿទុកចិត្តដល់អ្នកចូលរួម។

អ្វីដែលជាការកត់សម្គាល់ គឺគណៈគ្រប់គ្រង ក៏ដូចជាបុគ្គលិកអប់រំបានខិតខំបំពេញការងារបានយ៉ាងល្អ និងបំពេញទៅតាមតម្រូវការរបស់ដៃគូអភិវឌ្ឍ និងសហគមន៍ ពោលគឺគាត់បានបំពេញការងារបានលឿន និងអនុវត្តទៅតាមអ្វីដែលដៃគូអភិវឌ្ឍ និងសហគមន៍ចង់បាន។ ជាមួយគ្នានេះផងដែរ គណៈគ្រប់គ្រងសាលារៀនបានប្រើប្រាស់វិធីសាស្ត្រក្នុងការកៀរគរធនធាន និងការសហការជាមួយដៃគូតាមរយៈការបង្ហាញពីផលប្រយោជន៍រួមរបស់សាលានិងសហគមន៍ប្រកបដោយតម្លាភាព និងមានគោលដៅជាក់លាក់ដោយមានការឆ្លើយតបទាន់ពេលវេលាក្នុងកិច្ចសហការជាមួយដៃគូ រួមនឹងការបង្កលក្ខណៈសម្រប-សម្រួលកិច្ចដំណើរការសម្រាប់ដៃគូអភិវឌ្ឍនានា ការយកចិត្តទុកដាក់ និងឱ្យតម្លៃលើការចូលរួមរបស់សហគមន៍។ ការធានានូវគុណភាពអប់រំបានបង្កើតជាទំនុកចិត្តដល់សហគមន៍ដោយគ្រូបានប្តេជ្ញាជាមួយសហគមន៍ ក្នុងការបង្រៀនឱ្យសិស្សប្រឡងជាប់១០០% ដើម្បីឱ្យមានការសហការល្អ វិទ្យាល័យបានផ្តល់តម្លៃជាខ្លាំងលើការចូលរួមរបស់ដៃគូដោយបដិសណ្ឋារកិច្ច និងស្វាគមន៍យ៉ាងកក់ក្តៅ ការលើកទឹកចិត្តតាមរយៈការចារឹកឈ្មោះសប្បុរសជនលើសមិទ្ធផល ផ្តល់លិខិតថ្លែងអំណរគុណ ផ្តល់មេដាយ (ថ្នាក់ក្រសួង) ការផ្តល់ការចូលរួមមតិយោបល់ក្នុងការវាយតម្លៃដំណើរការ អនុវត្តការងាររបស់សាលារៀន ការលះបង់ពេលវេលា ចំណាយថវិកាផ្ទាល់ខ្លួនរបស់គណៈគ្រប់គ្រងសាលារៀន (នាយករង) ចូលរួមជាមួយក្រុមជិះកង់ ក្រុមម៉ូតូធំ (អ្នកមានជីវភាពធូរធា) ដើម្បីអូសទាញចំណាប់អារម្មណ៍ រហូតទទួលបានការជួយផ្តល់ជាថវិកា និងគ្រឿងសំណង់មួយចំនួនដល់សាលា កសាងកន្លែងលាងដៃពីរកន្លែងក្នុងបរិវេណសាលារៀន។ ជាពិសេសជាងនេះទៅទៀត លោកគ្រូអ្នកគ្រូព្រមទាំងថ្នាក់ដឹកនាំបានចំណាយថវិកាផ្ទាល់ខ្លួនក្នុងការចូលរួមអភិវឌ្ឍកែលម្អសាលារៀនដូចជា សម្លៀកបំពាក់ ឯកសណ្ឋាន ទិញស្មៅ អំពូលសូឡា និង LCD គិតជាទឹកប្រាក់សរុប ៣៦០០ដុល្លារ។ ក្រៅពីការកៀរគរតាមរយៈការបង្កើតបរិយាកាសផ្សេងៗ គណៈគ្រប់គ្រងសាលារៀនបានផ្តួចផ្តើមធ្វើបុណ្យផ្កាប្រាក់ដែលមានសប្បុរសជនធំៗចូលរួមដូចជាលោក **ទុយ គីមហាក់** បានជួយបុកអណ្តូងដែលមានតម្លៃ ១០០០ដុល្លាអាមេរិក

ជំពូកទី៣

ម្ចាស់ហាងលក់ម៉ូតូ HONDA **ពិន ទី** បាត់ដំបងជួយស៊ីម៉ង់ ២៥តោន សហគមន៍បានជួយឧបត្ថម្ភ សម្ភារៈសិក្សា និងគ្រឿងឧបភោគបរិភោគ ដល់សិស្សក្រីក្រចំនួន ២៣នាក់ ដែលបានស្នាក់នៅអន្តេវាសិកដ្ឋានជារៀងរាល់ខែ។

ភាពជោគជ័យរបស់វិទ្យាល័យ ពិតជាត្រូវការជាចាំបាច់មិនអាចខ្វះបាននូវការចូលរួមពីភាគីពាក់ព័ន្ធជាច្រើនដូចជាសិស្សានុសិស្ស មាតាបិតា និងអ្នកអាណាព្យាបាល សហគមន៍ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជាពិសេសអាជ្ញាធរមូលដ្ឋានដែលបានរួមចំណែកក្នុងការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងផ្តល់នូវការជួយគាំទ្រ សម្របសម្រួលក្នុងកិច្ចដំណើរការនៃការអនុវត្តការងារជាប្រចាំរបស់សាលារៀន។

ការបង្កើតទំនាក់ទំនងល្អ រវាងវិទ្យាល័យជាមួយនិងអាជ្ញាធរពិតជាមានសារៈសំខាន់ដែលគណៈគ្រប់គ្រងសាលារៀនបានអនុវត្តដោយឈរលើស្មារតីសហការយ៉ាងជិតស្និទ្ធដើម្បីទាញចំណាប់អារម្មណ៍ និងការចូលរួមពីសំណាក់អាជ្ញាធរក្នុងការអភិវឌ្ឍសាលារៀន សហគមន៍ ក៏ដូចជាមូលដ្ឋានប្រកបដោយបរិយាបន្ន។ ការបង្ហាញពីតម្រូវការចាំបាច់និងជាអាទិភាពរបស់សាលារៀនទៅអាជ្ញាធរមូលដ្ឋាន ដោយចាត់ទុកអាជ្ញាធរមូលដ្ឋានជាតួអង្គគន្លឹះក្នុងការអភិវឌ្ឍសាលារៀន គោរព ផ្តល់តម្លៃ និងចាត់ទុកអាជ្ញាធរមូលដ្ឋានដូចជាឪពុកម្តាយរបស់ខ្លួនបានទាក់ទាញការចូលរួមពីសំណាក់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ប្រកបដោយភាពជាម្ចាស់ និងការយកចិត្តទុកដាក់ខ្ពស់។

៣.២.៦.៣. ការងារអភិវឌ្ឍន៍យុវជន

គណៈគ្រប់គ្រងវិទ្យាល័យ បានចាត់ទុកយុវជនជាធនធានគន្លឹះ និងមានតម្លៃបំផុតសម្រាប់ការអភិវឌ្ឍវិទ្យាល័យ និងសង្គមជាតិ។ កត្តានេះបានឆ្លុះបញ្ចាំងតាមរយៈបទពិសោធការអភិវឌ្ឍយុវជនរបស់វិទ្យាល័យដែលបានអនុវត្តកន្លងមក និងទទួលបានលទ្ធផលយ៉ាងត្រចះត្រចង់ទាំងភាពជាគំរូ ស្មារតីទទួលខុសត្រូវ សមត្ថភាពដឹកនាំ និងមនសិការចូលរួមកសាងសង្គមជាតិរបស់ក្រុមយុវជននិងកុមារ។ ក្នុងការអនុវត្តការងារអភិវឌ្ឍយុវជននេះ គណៈគ្រប់គ្រងសាលារៀនបានខិតខំប្រឹងប្រែងគាំទ្រ និងលើកទឹកចិត្តក្នុងការចងក្រង

ក្រុមយុវជន ឱ្យមានអង្គការចាត់តាំងច្បាស់លាស់មានជាអាទិ៍ **ក្រុមប្រឹក្សាយុវជន និងកុមារ** ដែលជាក្រុមបង្គោលនិងជាកម្លាំងស្នូលរបស់វិទ្យាល័យក្នុងការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន និងគាំទ្រដល់ការបង្កើត**ក្រុមកងកាយរឹទ្ធិ** ដែលជាសេនាធិការរបស់គណៈគ្រប់គ្រងសាលារៀនក្នុងការអនុវត្តការងារចុះជួយសង្គមផងដែរ។

ក. រចនាសម្ព័ន្ធក្រុមប្រឹក្សាយុវជន និងកុមារ

ក្រុមប្រឹក្សាយុវជននិងកុមារ គឺជាក្រុមបង្គោល ដែលមានតួនាទីជាសេនាធិការឱ្យគណៈគ្រប់គ្រងសាលារៀនលើកិច្ចការអនុវត្តផែនការអភិវឌ្ឍន៍មួយចំនួនរបស់វិទ្យាល័យ។ ក្រុមប្រឹក្សាយុវជន និងកុមារ មានភារកិច្ចធ្វើការផ្សព្វផ្សាយពីគុណសម្បត្តិ និងគុណវិបត្តិនៃបរិស្ថាន ត្រួតពិនិត្យអនាម័យថ្នាក់រៀន សណ្តាប់ធ្នាប់សិស្ស ធ្វើការណែនាំដល់សិស្សតាមថ្នាក់ឱ្យអនុវត្តតាមគោលការណ៍របស់គណៈកម្មការទទួលបន្ទុកបរិស្ថាន និងអនាម័យ ព្រមទាំងចុះជួយការងារសង្គមតាមការដឹកនាំរបស់គណៈគ្រប់គ្រងសាលារៀន។

ក្រុមនេះ បង្កើតឡើងតាមរយៈការប្រជុំជ្រើសរើសរបស់ប្រធាននិងអនុប្រធានថ្នាក់ទាំងអស់នៃវិទ្យាល័យ (ថ្នាក់ទី០៧-ទី១២) ដើម្បីរើសបេក្ខភាពដឹកនាំក្រុមចំនួន ១០រូប ចេញពីក្នុងចំណោមបេក្ខជនជាប្រធាន និងអនុប្រធានថ្នាក់ទី១០-ទី១២ ដែលមានអាណត្តិដឹកនាំ ១ឆ្នាំ ក្រោមការជួយសម្របសម្រួលពីលោកគ្រូ អ្នកគ្រូផងដែរ។ ក្នុងដំណើរការប្រជុំជ្រើសរើសនេះ បេក្ខជនដែលមានលក្ខណៈសម្បត្តិ និងលក្ខខណ្ឌត្រឹមត្រូវអាចស្ម័គ្រចិត្តចូលជាសមាជិកដឹកនាំក្រុមប្រឹក្សាយុវជន និងកុមារដោយយោងទៅតាមលក្ខខណ្ឌ ២យ៉ាង គឺ÷ **១) ត្រូវតែជាប្រធានឬអនុប្រធានថ្នាក់ទី១០ ដល់ទី១២ ២) ត្រូវតែជាអ្នកដែលមានឆន្ទៈលះបង់ខ្ពស់ក្នុងការជួយសាលាដោយមិនគិតពីប្រយោជន៍**។ បន្ទាប់ពីជ្រើសរើសបេក្ខភាពបានហើយ បេក្ខជនទាំង ១០រូប ត្រូវបន្តបោះឆ្នោតជ្រើសរើសប្រធាន ១រូប និងអនុប្រធាន ៤រូបទៀត ចំណែកបេក្ខជន ៥រូបនៅសល់ ត្រូវធ្វើជាសមាជិកអចិន្ត្រៃយ៍។

បន្ទាប់ពីសម្រេចបានជាលទ្ធផលនូវរចនាសម្ព័ន្ធក្រុមប្រឹក្សាយុវជន និងកុមាររួចហើយ គណៈគ្រប់គ្រងសាលារៀនត្រូវប្រគល់តួនាទីភារកិច្ចតាមរយៈលិខិតបង្គាប់ការរបស់នាយក

សាលា ដល់សមាជិកម្នាក់ៗដើម្បីអនុវត្តតាមភារកិច្ចរៀងៗខ្លួនរួមមាន÷ **ប្រធានជាអ្នកក្តាប់ការងាររួម អនុប្រធានបួនរូបជាអ្នកទទួលបន្ទុកលើកិច្ចការបរិស្ថាន អនាម័យ ពលកម្ម និងគណនេយ្យ** ចំណែក ៤រូប ទៀតជាសមាជិកអចិន្ត្រៃយ៍ មានភារកិច្ចជាជំនួយការក្នុងកិច្ចការផ្សេងៗរបស់ប្រធាន និងអនុប្រធានមានដូចជាការបើកអង្គប្រជុំក្នុងករណីប្រធាន និងអនុប្រធានអវត្តមាន ជាពិសេសពួកគាត់អាចស្នើយោបល់ ឬមានសិទ្ធិប្តឹងលើករណីដែលសិស្សណាម្នាក់មិនគោរពតាមបទបញ្ជា និងវិន័យរបស់វិទ្យាល័យបាន។

រចនាសម្ព័ន្ធក្រុមប្រឹក្សាយុវជន និងកុមារ



ខ. ដំណើរការអនុវត្តការងាររបស់ក្រុមប្រឹក្សាយុវជននិងកុមារ

កិច្ចការបរិស្ថាន÷ ជាកិច្ចការមួយដែលក្រុមប្រឹក្សាយុវជន និងកុមារ អនុវត្តតាមការដឹកនាំរបស់ក្រុមកែលម្អបរិស្ថាន និងអនាម័យ។ ជាលទ្ធផលសម្រេចបានក្នុងផ្នែកបរិស្ថានគឺការគ្រប់គ្រងសំរាមដោយមិនប្រើប្រាស់ធុងសំរាមក្នុងបរិវេណវិទ្យាល័យ ដែលជាហេតុមួយធ្វើឱ្យវិទ្យាល័យនេះ មានបរិស្ថាន និងអនាម័យល្អរហូតទទួលបានជ័យលាភីសំរឹទ្ធកម្រិតមធ្យមសិក្សាក្នុងការប្រឡងប្រណាំងសាលាមេត្រីបរិស្ថានថ្នាក់ជាតិឆ្នាំ២០១៩ របស់ក្រសួងបរិស្ថាន។ ក្នុងកិច្ចការនេះ ក្រុមប្រឹក្សាយុវជននិងកុមារបានប្រកាន់ភ្ជាប់នូវគោល-ជំហរយ៉ាងខ្ជាប់ខ្ជួនក្នុងនាមខ្លួនជាសមត្ថកិច្ចអនុវត្តលើបទបញ្ជារបស់គណៈគ្រប់គ្រង

សាលារៀនក្នុងផ្នែកបរិស្ថាន[១៦]។

កិច្ចការវិន័យ÷ ក្នុងការអនុវត្តលើការគោរពវិន័យសាលារបស់សិស្ស ក្រុមប្រឹក្សាយុវជន និងកុមារបានដើរតួនាទីជាក្រុមប្រឹក្សាវិន័យផង និងជាសមត្ថកិច្ចអនុវត្តបទបញ្ជារបស់គណៈគ្រប់គ្រងសាលារៀនផង។ ក្រៅពីការប្រកាន់ខ្ជាប់នូវភាពជាគម្រូក្នុងការគោរពបទបញ្ជា អនាម័យ និងបរិស្ថាន និងជាពិសេសគឺផ្នែកសីលធម៌មានការសំពះស្វាគមន៍ចំពោះលោកគ្រូ អ្នកគ្រូ និងសិស្សច្បងនៅក្លោងទ្វាររៀងរាល់ព្រឹក ក្នុងនាមជាក្រុមប្រឹក្សាវិន័យបានបង្កើតក្រុមភ្នាក់ងារកត់ឈ្មោះសិស្ស ដែលមកគោរពទង់ជាតិយឺតដើម្បីបញ្ជូនអ្នកទាំងនោះទៅជួបគ្រូនៅទីចាត់ការដើម្បីទទួលពិន័យ (បោសសំរាម ស្រោចស្មៅ លាងបន្ទប់ទឹក..) ព្រមទាំងពិនិត្យមើលសណ្តាប់ធ្នាប់របស់សិស្សម្នាក់ៗមានការកាត់ក្រចកខ្លី សក់ខ្លី និងមិនមានលាបពណ៌ក្រោមការដឹកនាំអនុវត្តពីសំណាក់លោកគ្រូ និងក្រុមប្រឹក្សាយុវជនរៀងរាល់១ខែម្តង ហើយត្រូវពិន័យជាសៀវភៅចំពោះសិស្សដែលពិនិត្យឃើញថាបានប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិនេះ។

កិច្ចការហិរញ្ញវត្ថុ÷ ក្នុងការងារនេះ ក្រុមប្រឹក្សាយុវជនមានភារកិច្ចធ្វើការប្រមូលថវិកាពីសិស្សក្នុង១សប្តាហ៍ ៥០០៛(ប្រាំរយរៀល) ដើម្បីប្រើប្រាស់ជាមូលនិធិសម្រាប់ទិញសម្ភារៈប្រើប្រាស់ក្នុងការងារពលកម្មនិងដើម្បីជួយឧបត្ថម្ភសិស្សក្រីក្រ និងជួយចេញថ្លៃព្យាបាលសិស្សដែលជួបគ្រោះថ្នាក់ ឬចូលរួមឧបត្ថម្ភគ្រួសារសាច់ញាតិរបស់សិស្សដែលទទួលមរណភាព។

កិច្ចការសង្គម÷ កិច្ចការសង្គម គឺជាកិច្ចការដែលទាមទារការស្ម័គ្រចិត្តចូលរួម លះបង់និងចែករំលែក។ ក្នុងនាមជាជនគម្រូ ក្រុមប្រឹក្សាយុវជនតែងដឹកនាំសិស្សស្ម័គ្រចិត្តចូលរួមរើសសំរាមនៅតាមទីសាធារណៈនៅរៀងរាល់ដើមឆ្នាំ ឬក្នុងទិវាបរិស្ថាន។ ក្រៅពីនេះ ពួកគេបានដឹកនាំក្រុមសិស្សានុសិស្សចូលរួមគោរពបដិបត្តិតាមទំនៀមព្រះពុទ្ធសាសនា មានការចូលរួមក្នុងពិធីបុណ្យផ្សេងៗ ដូចជាមាឃបូជា ពិសាខបូជាជាដើម។ ក្រុមប្រឹក្សាយុវជន ក៏

[១៦] មើលក្នុង៣.៣.៥.២. ការអនុវត្តដើម្បីភាពស្អាត អនាម័យ និងភាពបៃតង។

ដូចជាសមាជិកក្នុងថ្នាក់ទាំងអស់តែងមានសាមគ្គីភាព និងយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមកទាំងបញ្ហាការសិក្សានិងបញ្ហាផ្ទាល់ខ្លួនផងដែរ។ ក្នុងករណីដែលមានមិត្តរួមថ្នាក់បោះបង់ការសិក្សា ពួកគេតែងជួយរាយការណ៍មកប្រធានថ្នាក់ដើម្បីចុះផ្ដល់ប្រឹក្សាលើកទឹកចិត្ត និងពិភាក្សាគ្នារកមូលហេតុនៃការបោះបង់ដើម្បីរាយការណ៍បន្តជូនគណៈគ្រប់គ្រងសាលារៀនរកវិធីដោះស្រាយ។ ក្នុងការដោះស្រាយបញ្ហាបោះបង់ការសិក្សានេះ ទាំងអស់គ្នាមានលោកគ្រូអ្នកគ្រូ ក្រុមប្រឹក្សាយុវជននិងកុមារ និងប្រធានថ្នាក់បានចុះទៅផ្ទះរបស់សិស្សដែលមានបញ្ហាផ្ទាល់ដើម្បីជួបពិភាក្សាជាមួយអាណាព្យាបាល ហើយបញ្ចុះបញ្ចូលសិស្សឱ្យចូលរៀនវិញ ព្រមទាំងបានជូននូវអំណោយតិចតួចដល់ពួកគាត់ មានទឹកប្រាក់ ៤០,០០០៛(៤ម៉ឺនរៀល) សៀវភៅ១ឡូ ប៊ិច១០ដើម និងស្បែកជើង១គូរតម្លៃ ២៥០០០រៀល។

គណៈគ្រប់គ្រងសាលារៀនក៏បានផ្ដួចផ្ដើមនិងគាំទ្រដល់ការបង្កើតក្លឹបសិក្សា ក្នុងគោលបំណងជួយសិស្សដែលរៀនខ្សោយឱ្យរៀនទាន់សិស្សធម្មតា ចែករំលែកចំណេះដឹងគ្នា ស្រាវជ្រាវបន្ថែម និងជាពិសេសគឺដើម្បីឈានទៅរកការលុបបំបាត់ការរៀនត្រួតថ្នាក់របស់សិស្សនៃវិទ្យាល័យពេជ្រចិន្តាឱ្យមានប្រសិទ្ធភាព។ ដើម្បីឱ្យក្លឹបសិក្សាមានដំណើរការល្អ ក្រុមប្រឹក្សាយុវជន និងកុមារបានបញ្ចុះបញ្ចូលកៀរគរសិស្សខ្សោយឱ្យចូលរៀនក្នុងក្លឹបសិក្សា ហើយពួកគេប្រជុំគ្នាស្វែងរកចំណុចដែលធ្វើឱ្យសិស្សរៀនខ្សោយដើម្បីកែលម្អគ្នា និងវិធីសាស្ត្របង្រៀនឱ្យមានប្រសិទ្ធភាពដោយបានចាត់ឱ្យសិស្សពូកែៗចូលរួមគ្នាចែករំលែកមេរៀន និងបង្កើតកាលវិភាគដើម្បីធ្វើការបង្រៀន។ ជាលទ្ធផល ក្រុមប្រឹក្សាយុវជននិងកុមារព្រមទាំងលោកគ្រូ អ្នកគ្រូបានបញ្ចុះបញ្ចូលអូសទាញសិស្សដែលបានបោះបង់ការសិក្សាហើយឱ្យចូលរៀនវិញបានចំនួន ១២នាក់ ព្រមទាំងបានចូលរួមចំណែកកាត់បន្ថយអត្រាសិស្សបោះបង់ការសិក្សា និងលើកកម្ពស់អត្រាសិស្សប្រឡងជាប់ខ្ពស់ផងដែរ។

៣.២.៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍

៣.២.៧.១. យន្តការទទួលព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ា

យន្តការទទួលព័ត៌មានត្រឡប់និងបណ្ដឹងតវ៉ា គឺជាការកំណត់នូវធាតុចូលដែលដើរ

តួនាទីយ៉ាងសំខាន់ក្នុងការប្រមូលព័ត៌មានដើម្បីវិភាគវាយតម្លៃក្នុងគោលបំណងធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវក្នុងការដោះស្រាយបញ្ហាប្រឈមនានាប្រកបដោយប្រសិទ្ធភាពខ្ពស់។ វិទ្យាល័យបានប្រើប្រាស់វិធីសាស្ត្រ និងមធ្យោបាយដូចជា ទំនាក់ទំនងតាមរយៈទូរសព្ទមកតំណាងគណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងតំណាងសហគមន៍ គណៈកម្មការពិគ្រោះយោបល់ស្ត្រី និងកុមារ ក្រុមប្រឹក្សាអាជីព ឬតាមរយៈបណ្ដាញព័ត៌មានទំនាក់ទំនងសង្គមរបស់វិទ្យាល័យ ព្រមទាំងមានការទទួលព័ត៌មានក្រៅប្រព័ន្ធដោយផ្ទាល់ដូចជាតាមរយៈអាជីវករ សិស្សានុសិស្ស ឬទំនាក់ទំនងផ្ទាល់ខ្លួន។ ជាងនេះទៅទៀតសាលាមានវេទិកាជាមួយមាតាបិតាសិស្ស និងបើកប្រអប់គណនេយ្យភាពរៀងរាល់១ត្រីមាសម្តង ជាមួយគ្នានេះដែរគេក៏បានបង្កើតឱ្យមានជនបង្គោលតាមភូមិផងដែរ។

៣.២.៧.២. ការអនុវត្តវិធានការណ៍ឆ្លើយតបទៅនឹងបញ្ហាប្រឈមស្របតាមស្ថានភាពជាក់ស្តែង

គុណភាព នៃសេវាដែលអ្នកទទួលសេវាចង់បានគឺការឆ្លើយតបទៅនឹងបញ្ហាប្រឈមព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ាស្របតាមស្ថានភាពជាក់ស្តែងរហ័សទាន់ពេលវេលា និងមានភាពអាចជឿទុកចិត្តបាន។ អ្វីដែលមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស និងសហគមន៍ទទួលបាននូវការពេញចិត្តនោះគឺគោលការណ៍ នីតិវិធី និងវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈមរបស់វិទ្យាល័យដោយផ្អែកលើហេតុផល អំណះអំណាង។ ជាក់ស្តែងមានគ្រូជួយបំប៉នដល់សិស្សដែលរៀនយឺត គាំទ្រសម្ភារៈសិក្សា ជំរុញឱ្យមាតាបិតាជួយពិនិត្យតាមដានការប្រើប្រាស់ទូរសព្ទ កាលវិភាគសិក្សាម៉ោងរៀន និងម៉ោងរៀនបំប៉នប្រចាំសប្តាហ៍របស់កូនៗ ការធ្វើទំនាក់ទំនងតាមទូរសព្ទទៅមាតាបិតា និងអ្នកអាណាព្យាបាលសិស្សជាប្រចាំ ពន្យល់មាតាបិតា និងអ្នកអាណាព្យាបាលសិស្សឱ្យដឹងពីមុខវិជ្ជាដែលកូនរបស់គាត់រៀនខ្សោយ សៀវភៅតាមដានការសិក្សារបស់សិស្ស គ្រូទទួលបានការជួយឧបត្ថម្ភ និងលើកទឹកចិត្តពីសាលាក្នុងការជួយបង្រៀនក្រៅម៉ោងបន្ថែមចំពោះករណីសិស្សរៀនយឺត ឬរៀនមិនទាន់។ ជាក់ស្តែង ក្នុងករណីសិស្សមករៀនយឺត ឬអវត្តមានគ្មានមូលហេតុ គ្រូតាម

មុខវិជ្ជានីមួយៗទាក់ទងផ្ទាល់ទៅមាតាបិតា និងអ្នកអាណាព្យាបាលសិស្សដើម្បីឱ្យគាត់ទទួលបានព័ត៌មានទាន់ពេលវេលា និងជួយជំរុញឱ្យកូនមករៀន ក្នុងករណីសិស្សបន្លំហត្ថលេខាលើសៀវភៅតាមដានគ្រូបានទាក់ទងបញ្ជាក់បន្ថែមរៀងរាល់ការផ្ញើ។

ក. បញ្ហាប្រឈម និងដំណោះស្រាយ

កន្លងមក វិទ្យាល័យបានឆ្លងកាត់រាល់ឧបសគ្គនិងជំនះនូវរាល់ការលំបាកជាច្រើនតាមដំណាក់កាលជាបន្តបន្ទាប់ចាប់តាំងពីការចាប់ផ្តើម និងការកកើតសាលារហូតទទួលបានសមិទ្ធផលគួរជាទីមោទនៈដូចនាពេលនេះ ក្នុងនោះសាលាបានជួបនូវបញ្ហាប្រឈមចម្បងៗមួយចំនួនដូចជា ទីតាំងវិទ្យាល័យបច្ចុប្បន្នគឺជាអតីតសមរភូមិ ខ្វះអគារសិក្សា ត្រូវការបទពិសោធថ្មីសម្រាប់ការគ្រប់គ្រង កត្តាធនធានមនុស្សដែលគ្រូភាគច្រើនជាគ្រូបង្រៀនថ្មីនិងមកពីទីឆ្ងាយៗ។ ដំបូងឡើយ ប្រជាពលរដ្ឋភាគច្រើននៅតំបន់នេះជាជនចំណូលស្រុកដែលធ្វើឱ្យមានការលំបាកក្នុងការកៀរគរចូលរួមជាមួយសាលាក្នុងការបញ្ជូនកូនឱ្យចូលរៀនដោយពួកគាត់មមាញឹកក្នុងការប្រកបរបរចិញ្ចឹមជីវិត និងពុំសូវបានយកចិត្តទុកដាក់ដល់ការសិក្សារបស់កូនៗពួកគាត់ឡើយ។ បញ្ហាវិន័យសិស្សមានកម្រិតទាបបង្កការលំបាកដល់គ្រូក្នុងការបង្រៀន មិនត្រឹមតែប៉ុណ្ណោះអត្រាសិស្សបោះបង់ការសិក្សាក៏មានកម្រិតខ្ពស់ដែលមានការលំបាកក្នុងការគ្រប់គ្រង។ ការអនុវត្តវិធានវិន័យមានការប៉ះទង្គិចជាមួយមាតាបិតា និងអ្នកអាណាព្យាបាលសិស្សមួយចំនួន ដែលពុំទាន់យល់ពីផលប្រយោជន៍សម្រាប់អនាគតកូនៗពួកគាត់ ការជ្រើសរើសសិស្សឱ្យស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន ការផ្តល់អាហារូបករណ៍ដល់សិស្សក៏ធ្លាប់មានការច្រណែន ការតវ៉ាពីសំណាក់មាតាបិតាសិស្សមួយចំនួនអំពីការលក់អាហារក្នុងសាលាសុំឱ្យចេញទៅក្រៅវិញ ព្រោះមានជម្រើសតិចសម្រាប់កូនពួកគាត់ ដោយសារពួកគាត់ពុំទាន់មានទំនុកចិត្តលើការគ្រប់គ្រងរបស់សាលារៀន បញ្ហាសម្លៀកបំពាក់កីឡាដែលសាលាតម្រូវ និងលក់ជូនសិស្សានុសិស្សមានតម្លៃទាបជាងទីផ្សារ ក៏នាំឱ្យមានការតវ៉ាពីអាជីវករនៅក្នុងផ្សារ ពីតម្លៃប្រកួតប្រជែងទីផ្សារសម្រាប់ពួកគាត់ផងដែរ។ ប៉ុន្តែ រាល់បញ្ហាប្រឈមជាច្រើនទាំងនេះ ត្រូវបាន

គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន សហការជាមួយសហគមន៍ រួមគ្នារិះរកមធ្យោបាយក្នុងការដោះស្រាយជាបន្តបន្ទាប់។

ទោះបីជាសាលាបានជួបនូវបញ្ហាប្រឈមជាច្រើនក៏ដោយ ក៏គណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន បានខិតខំរិះរកវិធីដោះស្រាយ និងសហការគ្នាបានយ៉ាងល្អ តាមរយៈការបំផុសឱ្យមានការចូលរួមសហការពីភាគីពាក់ព័ន្ធ ការអនុវត្តវិធានការនានា ប្រកបដោយតម្លាភាព គណនេយ្យភាព មិនគិតពីផលប្រយោជន៍បុគ្គល។ មធ្យោបាយ និងវិធីសាស្ត្រគន្លឹះមួយចំនួនផ្សេងទៀតត្រូវបានគណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន ប្រើប្រាស់ទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាព គឺការប្រជុំឆ្លងយោបល់អភិបាលស្រុក និងសហគមន៍ រាល់ការសម្រេចចិត្តនានា ការសន្ទនាជាមួយសិស្ស មាតាបិតា និងអ្នកអាណាព្យាបាលក្នុងការបង្កើតវិទ្យាល័យ ឱ្យពួកគេមានក្តីរំពឹងទុកប្រកបដោយសុទិដ្ឋិនិយម និងភាពជឿជាក់ រួមសហការជាមួយតំណាងសហគមន៍ចុះទៅយកព័ត៌មានផ្ទាល់ ចំពោះសិស្សចង់បោះបង់ និងបានចុះជួយដល់សិស្សជួបការលំបាកជាក់ស្តែង ការផ្តួចផ្តើមគំនិតកៀរគររកថវិកាជួយសិស្សក្រីក្រ សម្របសម្រួលជាមួយអាជីវករ អប់រំ ពន្យល់ប្រជាពលរដ្ឋក្នុងសហគមន៍ឱ្យយល់ពីផលប្រយោជន៍សហគមន៍ ការបង្កើតគណៈកម្មការចុះវាយតម្លៃពីភាពក្រីក្ររបស់គ្រួសារសិស្ស ផ្តួចផ្តើមបុណ្យផ្កាប្រាក់សម្រាប់ការកសាងបំពេញបន្ថែមលើការសាងសង់នានាក្នុងបរិវេណសាលា ការពង្រឹងតួនាទីគណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងតំណាងសហគមន៍ និងការយកចិត្តទុកដាក់សហការ និងស្នើសុំការចូលរួមពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងការចុះតាមដានការងារ និងផ្តល់អនុសាសន៍ជាប្រចាំ ក្នុងស្មារតីតម្កល់ផលប្រយោជន៍សហគមន៍ជាធំ។

៣.២.៨. ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអេឡូភាពមានដំណើរ-ការកាន់តែប្រសើរ

ជាទូទៅ នវានុវត្តន៍គឺជាគំនិតច្នៃប្រឌិតមួយដែលត្រូវបានអនុវត្តដើម្បីដោះស្រាយ

បញ្ហាបន្ទាន់ចំពោះមុខ។ នវានុវត្តន៍ គឺជាសកម្មភាពនៃការបង្កើត និងអនុវត្តវិធីថ្មីៗនៃការសម្រេចបានលទ្ធផល និង/ ឬអនុវត្តការងារ។ នវានុវត្តន៍ អាចពាក់ព័ន្ធនឹងការដាក់បញ្ចូលធាតុថ្មី ការរួមបញ្ចូលគ្នាជាថ្មីនៃធាតុដែលមានស្រាប់ ឬការផ្លាស់ប្តូរណាមួយគួរឱ្យកត់សម្គាល់ ឬការផ្លាស់ប្តូររបៀបធ្វើការងារតាមបែបប្រពៃណី។ នវានុវត្តន៍ អាចសំដៅទៅលើផលិតផលថ្មី គោលនយោបាយថ្មី កម្មវិធីថ្មី វិធីសាស្ត្រថ្មី និងដំណើរការថ្មី[១៧]។

៣.២.៨.១. ការបញ្ជ្រាបអំពីប្រធានបទពាក់ព័ន្ធនឹងនវានុវត្តន៍ និងការច្នៃប្រឌិតធ្វើឱ្យអង្គភាពដំណើរការកាន់តែប្រសើរ

បើទោះបីជាវិទ្យាល័យនៅមិនទាន់បានរៀបចំការបណ្តុះបណ្តាល និងបង្កើនការយល់ដឹងអំពីនវានុវត្តន៍ និងការច្នៃប្រឌិតក្នុងអង្គភាពជាផ្លូវការក៏ដោយ ក៏វិទ្យាល័យបានបញ្ជ្រាបការយល់ដឹងពីនវានុវត្តន៍ និងគំនិតច្នៃប្រឌិតដល់បុគ្គលិកអប់រំ ក៏ដូចជាសិស្សានុសិស្សតាមរយៈការរៀបចំទស្សនកិច្ចសិក្សាទៅកាន់សាលារៀន ឬស្ថាប័នដែលមានស្នាដៃល្អៗទាំងនៅក្នុងប្រទេស និងក្រៅប្រទេស និងការធ្វើការចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ល្អៗទាំងនេះទៅដល់បុគ្គលិកអប់រំ និងសិស្សានុសិស្សដទៃទៀតនៅក្នុងវិទ្យាល័យ ការធ្វើទំនាក់ទំនងជាមួយគ្រឹះស្ថានអប់រំនានា ដើម្បីឱ្យបុគ្គលិកអប់រំបានទទួលការបណ្តុះបណ្តាល ការផ្តល់ឱកាស ការជំរុញលើកទឹកចិត្ត និងផ្តល់ការឧបត្ថម្ភដល់បុគ្គលិកអប់រំឱ្យបានបន្តការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សានានា នៅក្នុងទីរួមខេត្តបាត់ដំបង និងរាជធានីភ្នំពេញ។ តាមរយៈទស្សនកិច្ចសិក្សា ការបណ្តុះបណ្តាល និងការបន្តការសិក្សាទាំងនេះបានធ្វើឱ្យបុគ្គលិកអប់រំ និងសិស្សានុសិស្សមានគំនិតនវានុវត្តន៍ និងច្នៃប្រឌិតក្នុងការកែលម្អការបំពេញការងារ ក៏ដូចជាចូលរួមអភិវឌ្ឍវិទ្យាល័យពេជ្រចិន្តា។ ជាងនេះទៀត វិទ្យាល័យអាចចាត់ទុកថាអង្គភាពសិក្សាមួយ (Learning Organization) មានន័យថាគ្រប់បុគ្គលិកអប់រំទាំងអស់នៅក្នុងវិទ្យាល័យពេជ្រចិន្តាបានបណ្តុះវប្បធម៌សិក្សា ពោលគឺការចែករំលែកនូវចំណេះដឹង និងការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមកក្នុងចំណោម

[១៧] United Nations, 2007:7

បុគ្គលិកអប់រំនៅក្នុងវិទ្យាល័យ ការខិតខំបន្តការសិក្សាដោយខ្លួនឯង និងការបណ្ដុះបណ្ដាល និងអភិវឌ្ឍន៍សមត្ថភាពតាមរូបភាពផ្សេងៗ ដែលកម្រឃើញវិទ្យាល័យ ឬក៏សាលារៀនសាធារណៈនៅក្នុងប្រទេសរបស់យើងយកមកអនុវត្ត។ ការសិក្សារៀនសូត្រទាំងនេះបានធ្វើឱ្យបុគ្គលិកអប់រំរបស់វិទ្យាល័យ ជាពិសេសថ្នាក់ដឹកនាំគ្រប់ផ្នែកទាំងអស់នៅក្នុងវិទ្យាល័យមានគំនិតនវានុវត្តន៍ និងការច្នៃប្រឌិតខ្ពស់ក្នុងការដឹកនាំ និងគ្រប់គ្រងនៅតាមផ្នែកនីមួយៗ ដែលគណៈគ្រប់គ្រងសាលារៀនបានប្រគល់ជូន។

៣.២.៨.២. ការដឹកនាំអនុវត្ត ការជំរុញ និងការគាំទ្រការអនុវត្តគំនិតច្នៃប្រឌិត និងនវានុវត្តន៍ក្នុងអង្គភាព

គណៈគ្រប់គ្រងវិទ្យាល័យ តែងតែផ្ដល់ឱកាសដល់សិស្ស និងបុគ្គលិកអប់រំទាំងអស់ក្នុងការអនុវត្តនូវគំនិតផ្ដួចផ្ដើមដែលមានលក្ខណៈនវានុវត្តន៍ និងការច្នៃប្រឌិតក្នុងការអនុវត្តការងាររបស់ខ្លួននៅក្នុងវិទ្យាល័យ។ ការផ្ដល់ឱកាសទាំងនេះធ្វើឡើងតាមរយៈការធ្វើវិមជ្ឈការការងារ ការទទួលខុសត្រូវ និងស្វ័យភាពគ្រប់គ្រងដោយខ្លួនឯងទៅឱ្យបុគ្គលិកអប់រំ និងសិស្សានុសិស្សនៅវិទ្យាល័យ។

វិទ្យាល័យទទួលបានជោគជ័យ ការកោតសរសើរពីសិស្ស មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស និងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលតាំងពីដើមរហូតមកដល់ពេលនេះ ផ្ដើមចេញពីបុគ្គលិកអប់រំ សិស្សានុសិស្សម្នាក់ៗនៅវិទ្យាល័យបានអនុវត្តនូវវិធីសាស្ត្រដឹកនាំ និងគ្រប់គ្រង និងការអនុវត្តការងាររបស់ខ្លួនប្រកបដោយនវានុវត្តន៍ និងការច្នៃប្រឌិត និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់សិស្ស សហគមន៍ និងអាជ្ញាធរដែនដី។ លោកប្រធានគណៈកម្មការគ្រប់គ្រងសាលារៀនបានដឹកនាំ និងគ្រប់គ្រងគណៈកម្មការគ្រប់គ្រងសាលារៀន ក្នុងការចូលរួមកៀរគរសម្ភារៈ ថវិកា ដើម្បីកែលម្អសេវាអប់រំ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានរបស់វិទ្យាល័យដែលទទួលបានការកោតសរសើរពីសាធារណៈជនរហូតមកដល់ពេលនេះដោយសារគំនិតនវានុវត្តន៍ និងការច្នៃប្រឌិតរបស់គាត់ និងសមាជិកក្រុមរបស់គាត់។ យើងឃើញថាសមាសភាពនៃ

ជំពូកទី៣

គណៈកម្មការគ្រប់គ្រងសាលារៀនពេជ្រចិន្តាមានការចូលរួមមកពីគ្រប់ភាគីពាក់ព័ន្ធនៅក្នុងសហគមន៍នៃស្រុកភ្នំព្រឹករួមមាន÷ មន្ត្រីរាជការ អាជ្ញាធរដែនដី អាជីវករ អ្នកមានធនធាន និងអ្នកមានឥទ្ធិពលនៅក្នុងសហគមន៍ មិត្តព្រះធម៌ និងក្រុមជិះកង់ជាដើម។ គណៈកម្មការគ្រប់គ្រងសាលារៀនដែលសមាសភាពចូលរួមចម្រុះបែបនេះមិនមែនកើតឡើងដោយចៃដន្យនោះទេ ពោលគឺជាគំនិតយុទ្ធសាស្ត្រប្រកបដោយនវានុវត្តន៍របស់គណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រងសាលារៀន ក្នុងការទាក់ទាញគ្រប់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងសហគមន៍ឱ្យចូលរួមគាំទ្រក្នុងការអភិវឌ្ឍវិទ្យាល័យ។ ជាងនេះទៅទៀតក្នុងការកៀរគរធនធានសម្ភារៈ និងថវិកាក្នុងការជួយកសាង និងអភិវឌ្ឍន៍វិទ្យាល័យ ទាំងប្រធាន អនុប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន និងសមាជិកទាំងអស់បានរៀបចំយុទ្ធនាការក្នុងការដឹកនាំប្រមូលធនធាន ប្រកបដោយគំនិតច្នៃប្រឌិត (អាជីវករប្រមូលធនធានសម្ភារៈ និងថវិកាក្នុងចំណោមអាជីវករនៅក្នុងផ្សារដូចគ្នា ក្រុមជិះកង់ប្រមូលធនធានសម្ភារៈ និងថវិកាក្នុងចំណោមក្រុមអ្នកជិះកង់ អ្នកមានធនធាន និងក្រុមមិត្តព្រះធម៌ប្រមូលធនធានសម្ភារៈ និងថវិកាពីក្រុមរបស់ពួកគាត់)។

ជាមួយគ្នានេះផងដែរ គណៈគ្រប់គ្រងសាលារៀន ក្រុមការងារវិទ្យាល័យ បុគ្គលិកអប់រំ សិស្សានុសិស្ស បានអនុវត្តការងាររបស់ខ្លួនប្រកបដោយនវានុវត្តន៍ និងគំនិតច្នៃប្រឌិត ពោលគឺចេះយកលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង មន្ទីរ ចំណេះដឹង និងជំនាញដែលទទួលបានពីការសិក្សា និងការបណ្តុះបណ្តាលនានាយកមកអនុវត្តក្នុងការដឹកនាំគ្រប់គ្រងវិទ្យាល័យ និងការបំពេញការងារឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅក្នុងអង្គភាព និងសហគមន៍របស់ខ្លួន។ ការបង្កើតគណៈកម្មការបរិស្ថាន និងអនាម័យវិទ្យាល័យដែលមានក្រុមបរិស្ថាន ក្រុមប្រឹក្សាយុវជន និងក្រុមអន្តេវាសិកដ្ឋានជាសេនាធិការក្នុងការរៀបចំសោភ័ណភាព បរិស្ថាន និងអនាម័យ គឺគំនិតផ្តួចផ្តើមថ្មីមួយរបស់វិទ្យាល័យ ដើម្បីធ្វើឱ្យសាលារៀនមានសោភ័ណភាពល្អ បរិស្ថានស្អាត និងអនាម័យល្អរហូតដល់ទទួលពានរង្វាន់សាលាស្អាតពីក្រសួងអប់រំ យុវជន និងកីឡា និងសាលាមេត្រីបរិស្ថានអាស៊ាន

ពីក្រសួងបរិស្ថាន។

យើងឃើញមានគំនិតផ្តួចផ្តើមថ្មីៗ និងគំនិតច្នៃប្រឌិតជាច្រើនត្រូវបានយកអនុវត្តនៅក្នុងវិទ្យាល័យរួមមាន÷

- ✓ ការជំរុញលើកទឹកចិត្តការអានសៀវភៅតាមរយៈពាក្យស្លោក "កាន់សៀវភៅ ១ក្បាល បង្កើតសៀវភៅ ១ក្បាល"។ គ្រូបានដឹកនាំសិស្សរៀបចំចងក្រងសៀវភៅទៅលើប្រធាន ឬមេរៀនណាមួយ តាមរយៈការបង្កើតក្រុមសិស្សស្រាវជ្រាវ និងរៀបចំចងក្រងសៀវភៅដែលជាស្នាដៃសិស្ស សម្រាប់ការដាក់បង្ហាញនៅក្នុងបណ្ណាល័យ
- ✓ បង្កើតក្រុមការងារវិទ្យាល័យដែលមានសមាសភាពចូលរួមពីគណៈគ្រប់គ្រងសាលារៀន តំណាងសហគមន៍ គ្រូបង្រៀន ក្រុមយុវជន និងសិស្សចុះទៅតាមខ្នងផ្ទះសិស្សដែលបោះបង់ការសិក្សាដើម្បីពន្យល់ណែនាំ និងលើកទឹកចិត្តឱ្យពួកគាត់ត្រឡប់មកបន្តការសិក្សាវិញ តាមរយៈការពន្យល់ដល់សិស្ស និងមាតាបិតាសិស្សអំពីសារៈសំខាន់នៃការសិក្សាស្វែងយល់ពីស្ថានភាពជាក់ស្តែងគ្រួសារសិស្ស កៀរគរថវិកា និងសម្ភារៈជួយសិស្សដែលមានជីវភាពខ្វះខាត
- ✓ បិទស្លាកសញ្ញាសម្គាល់ឈ្មោះសិស្ស និងលេខទូរសព្ទមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សនៅតាមប្លង់តុនីមួយៗ ដែលសិស្សអង្គុយ ដើម្បីតាមដាន និងត្រួតពិនិត្យវត្តមានសិស្ស និងផ្តល់ដំណឹងជូនមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សនៅពេលសិស្សអវត្តមាន និងការគ្រប់គ្រងសម្រាមនៅតាមថតតុរបស់សិស្សម្នាក់ៗជាដើម
- ✓ អនុវត្តការគ្រប់គ្រងសំរាម និងបរិស្ថានស្អាតនៅក្នុងបរិវេណវិទ្យាល័យ និងនៅក្នុងបន្ទប់រៀន តាមគោលការណ៍ គ្មានធុងសំរាម គ្មានសំរាម ស្វ័យគ្រប់គ្រងសំរាម «សំពាធមួយ ធុងសំរាមមួយ»
- ✓ ការកៀរគរមូលនិធិសម្រាប់អភិវឌ្ឍវិទ្យាល័យតាមរយៈការចូលរួមជាមួយក្រុម

ជិះកង់ ដែលត្រូវបានបង្កើតឡើងនៅក្នុងសហគមន៍

- ✓ បង្កើតមូលនិធិសិស្សជួយសិស្សក្រីក្រនៅក្នុងវិទ្យាល័យ ដោយមានការគាំទ្រពីសហគមន៍ និងអាជ្ញាធរដែនដី និងបុគ្គលិកអប់រំ
- ✓ ធ្វើការផ្លាស់ប្តូរបទពិសោធន៍ និងកែលម្អគុណភាពបំពេញការងារ តាមរយៈការបញ្ជូនគណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំ និងសិស្ស ទៅទស្សនកិច្ចសិក្សានៅសាលារៀន និងអង្គភាពដទៃទៀត និងធ្វើការចែករំលែកនូវបទពិសោធន៍ និងចំណេះដឹង (វិទ្យាល័យសយដាវនៅក្នុងប្រទេសថៃ)
- ✓ ដោះស្រាយបញ្ហាប្រឈមខ្វះគ្រូបង្រៀន និងគ្រូបង្រៀនខុសមុខវិជ្ជាឯកទេសដើមរបស់ខ្លួនតាមរយៈការលើកទឹកចិត្តឱ្យគ្រូបង្រៀនចេះសហការជួយគ្នាទៅវិញទៅមក ធ្វើការជាក្រុមក្នុងការពង្រឹងសមត្ថភាពលើមុខវិជ្ជាដែលបានកំពុងបង្រៀន និងផ្តល់ការបណ្តុះបណ្តាលបំប៉នសមត្ថភាពជាប្រចាំដល់គ្រូបង្រៀនដែលបង្រៀនមុខវិជ្ជាឯកទេសដើម។
- ✓ ការលើកកម្ពស់សីលធម៌រស់នៅ វប្បធម៌សាមគ្គីភាព និងវប្បធម៌ចែករំលែក ចេះជួយគ្នាទៅវិញទៅមក បង្កើតបាននូវសុខដុមនីយកម្មនៅក្នុងវិទ្យាល័យ និងបង្កើតនូវទំនាក់ទំនងល្អ និងភាពស្និទ្ធស្នាលរវាងអាជ្ញាធរដែនដី សហគមន៍ និងវិទ្យាល័យក្រោមពាក្យស្លោក «សាលារៀនជារបស់សហគមន៍ សហគមន៍ដើម្បីសាលារៀន»
- ✓ ការដោះស្រាយបញ្ហាផ្តើមចេញពីតម្រូវការ និងស្ថានភាពជាក់ស្តែង ជាឧទាហរណ៍ការជួលរោងសម្រាប់រៀបចំកម្មវិធី និងព្រឹត្តិការណ៍នានានៅវិទ្យាល័យ តែងតែមានការលំបាករកមូលនិធិ ឬថវិកាសម្រាប់ការចំណាយថ្លៃជួល និងមានភាពយឺតយ៉ាវមិនទាន់ពេលវេលា។ ដោយសារតែបញ្ហាប្រឈមនេះ គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូ អ្នកគ្រូ បានប្រជុំគ្នារិះរកវិធីក្នុងការដោះស្រាយទៅតាមលទ្ធភាពជាក់ស្តែងនិងធនធានដែលខ្លួនមានស្រាប់។ ជាដំណោះស្រាយ ពួកគាត់បានសម្រេចបង្កើតក្រុមការងារទទួលខុសត្រូវ រៀបចំឱ្យមានឧបករណ៍ និងសម្ភារៈរៀបចំរោងពិធីដោយខ្លួនឯងមិនចាំបាច់ជួលពីខាងក្រៅទៀតឡើយ។

ជំពូកទី៤. សេចក្តីសន្និដ្ឋាន

ភាពជោគជ័យរបស់វិទ្យាល័យពេជ្រចិន្តា គឺដោយសារវិទ្យាល័យអនុវត្តតាមយុទ្ធសាស្ត្រកំណែទម្រង់របស់រាជរដ្ឋាភិបាលជាពិសេសការចូលរួមគាំទ្រពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**បានជួយឧបត្ថម្ភគាំទ្រ សម្ភារៈ និងថវិកាក្នុងការចូលរួមអភិវឌ្ឍវិទ្យាល័យពេជ្រចិន្តាចាប់តាំងពីការចាប់ផ្តើមកកើតរហូតមកដល់បច្ចុប្បន្ន។

គោលនយោបាយ និងកំណែទម្រង់ជាអាទិភាពផ្សេងៗទៀតនៃវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការជួយជំរុញអនុវត្តផ្ទាល់របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជាពិសេសគឺការអនុវត្តកម្មវិធីគ្រប់គ្រងតាមសាលារៀន តាមរយៈការផ្ទេរសិទ្ធិការអំណាច និងការសម្រេចចិត្ត ទៅដល់សហគមន៍ និងសាលារៀនដោយផ្ទាល់ក្នុងដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិទ្យាល័យ។ លើសពីនេះទៅទៀត គឺការជួយជ្រោមជ្រែងពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់នៅក្នុងខេត្ត ក៏ដូចជាការប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំ គ្រូបង្រៀន សហគមន៍ មាតាបិតា និងអ្នកអាណាព្យាបាល ដៃគូអភិវឌ្ឍ និងសិស្សានុសិស្ស។

តាមរយៈការសិក្សាស្រាវជ្រាវកន្លងមក ភាពជោគជ័យរបស់វិទ្យាល័យពេជ្រចិន្តាក្នុងការផ្តល់សេវាសាធារណៈគំរូ បានបង្ហាញឱ្យឃើញនូវធាតុចូលសំខាន់ និងសមិទ្ធផលសំខាន់ៗដូចខាងក្រោម÷

- ការជួយជ្រោមជ្រែងពីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការផ្តល់ស្វ័យភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ ផែនការប្រតិបត្តិ ការជួយឧបត្ថម្ភគាំទ្រសម្ភារៈ និងថវិកាក្នុងការចូលរួមអភិវឌ្ឍវិទ្យាល័យចាប់តាំងពីពេលកកើតរហូតមកដល់បច្ចុប្បន្ន
- ការជួយជំរុញពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្នុងការអនុវត្តគោលនយោបាយ

និងកំណែទម្រង់ជាអាទិភាពផ្សេងៗទៀតនៃវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា

- **ភាពជាអ្នកដឹកនាំ៖** គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន និងបុគ្គលិកអប់រំទាំងអស់នៃវិទ្យាល័យមានភាពជាអ្នកដឹកនាំ មានការរៀបចំរចនាសម្ព័ន្ធនៃការដឹកនាំ និងការគ្រប់គ្រង ព្រមទាំងមានការបែងចែកតួនាទីភារកិច្ចច្បាស់លាស់ ប្រកបដោយគំនិតផ្តួចផ្តើម ធ្វើការជាក្រុម មានការប្តេជ្ញាចិត្ត និងលះបង់ខ្ពស់ក្នុងការអភិវឌ្ឍវិទ្យាល័យ។ ក្រៅពីយន្តការដែលក្រសួងបានកំណត់ ថ្នាក់ដឹកនាំវិទ្យាល័យបានបង្កើតយន្តការផ្ទៃក្នុងថែមទៀត ដោយបានបង្កើតនូវគណៈកម្មការ និងក្រុមមួយចំនួនក្នុងវិទ្យាល័យក្នុងការអនុវត្តការងារអភិវឌ្ឍវិទ្យាល័យឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ វិទ្យាល័យមានការរៀបចំកិច្ចប្រជុំជាទៀងទាត់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅគ្រប់សកម្មភាពទាំងអស់នៅក្នុងការអភិវឌ្ឍវិទ្យាល័យ ចាប់តាំងពីដំណាក់កាលរៀបចំផែនការ ដំណាក់កាលអនុវត្ត និងដំណាក់កាលត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តការអភិវឌ្ឍវិទ្យាល័យ។
- **សាមគ្គីភាព៖** វិទ្យាល័យមានសាមគ្គីភាពផ្ទៃក្នុងល្អរវាងបុគ្គលិកអប់រំ និងគណៈគ្រប់គ្រងសាលារៀន ចេះស្រលាញ់រាប់អាន ជួយការងារគ្នា ចែករំលែកចំណេះដឹងគ្នាទៅវិញទៅមក មិនមើលបំណាំគ្នា និងចេះជួយកែលម្អគ្នាទៅវិញទៅមកដោយមិនប្រកាន់ឋានៈ និងតួនាទី។ បន្ថែមពីនេះ មានសាមគ្គីភាពល្អរវាងសហគមន៍ អាជ្ញាធរដែនដី អាជីវករ គណៈគ្រប់គ្រងសាលារៀន និងបុគ្គលិកអប់រំវិទ្យាល័យ ដោយបានចាត់ទុកសាលារៀនជារបស់សហគមន៍ សហគមន៍ដើម្បីសាលារៀន។
- **ការចូលរួមពីអាជ្ញាធរ៖** អាជ្ញាធរគ្រប់លំដាប់ថ្នាក់បានជួយសម្របសម្រួល និងគាំទ្រគ្រប់សកម្មភាពទាំងអស់របស់វិទ្យាល័យ ជាពិសេសការចូលរួមដល់ការអភិវឌ្ឍវិទ្យាល័យ។ អាជ្ញាធរមូលដ្ឋាន (ខេត្ត មន្ទីរ ស្រុក ការិយាល័យ ភូមិ ឃុំ មេក្រុម) តែងតែផ្តល់សហការ និងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសាលារៀនមានដូចជា៖

ការកៀរគរ និងផ្សព្វផ្សាយសិស្សឱ្យមកចុះឈ្មោះចូលរៀន ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការសិក្សា អាហារូបករណ៍ជាដើម។

- **ការចូលរួមពីសហគមន៍ និងអាជីវករ÷** វិទ្យាល័យមានការចូលរួមពីសហគមន៍ និងអាជីវករយ៉ាងផុសផុល ក្លៀវក្លា និងគ្រប់រូបភាពក្នុងការចូលរួមអភិវឌ្ឍវិទ្យាល័យ។
- **ការចូលរួមពីមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស÷** វិទ្យាល័យបានផ្តល់កិច្ចសហការ និងការគាំទ្រយ៉ាងជិតស្និទ្ធរវាងគណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំ និងមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស។
- **ការចូលរួមពីដៃគូអភិវឌ្ឍក្នុងវិស័យអប់រំ÷** ដោយសារមានទំនាក់ទំនងល្អជាមួយដៃគូអភិវឌ្ឍក្នុងវិស័យអប់រំ ដៃគូអភិវឌ្ឍក្នុងវិស័យអប់រំជាច្រើនបានចូលរួមឧបត្ថម្ភគាំទ្រ ទាំងថវិកា សម្ភារៈ និងបច្ចេកទេសដល់វិទ្យាល័យ។
- **ការចូលរួមរបស់សិស្សានុសិស្ស÷** សិស្សានុសិស្សនៃវិទ្យាល័យពេជ្រចិន្តាមានការចូលរួមយ៉ាងសកម្មនូវគ្រប់សកម្មភាពទាំងអស់ក្នុងអនុវត្តផែនការអភិវឌ្ឍន៍និងកែលម្អវិទ្យាល័យ។

សរុបមក ចំណុចលេចធ្លោមួយចំនួននៃវិទ្យាល័យពេជ្រចិន្តា ដែលធ្វើឱ្យវិទ្យាល័យទទួលបានជ័យលាភីលេខ១ ជាអង្គភាពផ្តល់សេវាសារណៈគំរូ ដោយវិទ្យាល័យបានអនុវត្តបានខ្ជាប់ខ្ជួនតាមគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗរបស់ក្រសួង ការជួយចង្អុលបង្ហាញរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ពិសេសការចូលរួមយ៉ាងសកម្មពីសិស្ស មាតាបិតា និងអាណាព្យាបាលសិស្ស ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធ។

គន្ថនិទ្ទេស

ល.រ	ឈ្មោះឯកសារ
១	ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
២	អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
៣	អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល
៤	អនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ស្តីពីការកម្រិតរបបម៉ោងកំណត់ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
៥	រាជរដ្ឋាភិបាលកម្ពុជា,ខែកញ្ញា ឆ្នាំ២០១៨ «យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤» របស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា
៦	ក្រសួងអប់រំ យុវជន និងកីឡា, សេចក្តីណែនាំលេខ២៥៦ អយក.សរណន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ ស្តីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សាមធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យ
៧	ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៧ ស្តង់ដានាយកសាលារៀន
៨	ក្រសួងអប់រំ យុវជន និងកីឡា,ខែមីនា ឆ្នាំ២០១៤ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨
៩	ក្រសួងអប់រំ យុវជន និងកីឡា, ខែមិថុនា ឆ្នាំ២០១៩ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣
១០	ក្រសួងអប់រំ យុវជន និងកីឡា, ខែវិច្ឆិកា ឆ្នាំ២០១៨ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣

១១	ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៨ សៀវភៅណែនាំប្រតិបត្តិស្ដីពីការគ្រប់គ្រងតាមសាលារៀន គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា
១២	ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៨ សៀវភៅណែនាំប្រតិបត្តិស្ដីពីការគ្រប់គ្រងតាមសាលារៀន
១៣	ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៨ គោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ
១៤	ក្រសួងអប់រំ យុវជន និងកីឡា, ខែមីនា ឆ្នាំ២០១៨ សមិទ្ធផលការអនុវត្តគោលនយោបាយស្ដីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)
១៥	ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៩ ផែនទីបង្ហាញផ្លូវការអប់រំនៅកម្ពុជាឆ្នាំ២០៣០
១៦	ក្រសួងមុខងារសាធារណៈ, សេចក្ដីសម្រេចលេខ ៣១៣៦មស.សសរ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ស្ដីពីការដាក់ឱ្យអនុវត្តតារាងលក្ខណនិច្ច័យសម្រាប់ការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល
១៧	ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លិខិតលេខ៨០១៥ សហវ.អថ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ស្ដីពីករណីសំណើសុំកែសម្រួលគោលការណ៍ចំណាយមួយចំនួនសម្រាប់អនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ សាលាគរុកោសល្យ និងវិក្រឹតការខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តចាប់ពីឆ្នាំ២០១៩ តទៅ
១៨	វិទ្យាល័យពេជ្រចិន្ដា, ឆ្នាំ២០១៩ បទបង្ហាញស្ដីពីសកម្មភាពរបស់គណៈកម្មការគ្រប់គ្រងសាលារៀនពេជ្រចិន្ដាប្រចាំឆមាសទី១ និងផែនការបន្តឆមាសទី២ ឆ្នាំ២០១៩-២០២០
១៩	វិទ្យាល័យពេជ្រចិន្ដា, ឆ្នាំ២០១៩ បទបង្ហាញស្ដីអំពីការចែករំលែកបទពិសោធន៍ នៃការគ្រប់គ្រង និងផ្ដល់សេវាសាធារណៈនៃអង្គភាពផ្ដល់សេវាសាធារណៈវិទ្យាល័យពេជ្រចិន្ដា
២០	វិទ្យាល័យពេជ្រចិន្ដា, ឆ្នាំ២០២០ បទបង្ហាញស្ដីពីនាយកសាលារៀនល្អ និងសាលារៀនស្អាត

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១៖ ស្តង់ដាសេវាសាធារណៈ

បទបញ្ជាផ្ទៃក្នុងសាលារៀន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាល័យពោធិ៍ចិន្តា

បទបញ្ជាផ្ទៃក្នុង
សម្រាប់គ្រឹះស្ថានមធ្យមសិក្សាទូទៅ

អនុលោមតាមព្រះរាជក្រឹត្យលេខ ទស.រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ១២ឆ្នាំ។

ដើម្បីធ្វើឱ្យសម្រេចតាមទិសដៅអប់រំនៅគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅរដ្ឋ សិស្សមធ្យមសិក្សាទាំងអស់ត្រូវអនុវត្តបទបញ្ជាផ្ទៃក្នុងដូចតទៅ៖

ប្រការ ១ : សិស្សដែលរៀននៅមធ្យមសិក្សាបឋមភូមិ និង ទុតិយភូមិត្រូវនៅលីវ។

ប្រការ ២ : អាចអនុញ្ញាតឱ្យចូលរៀនៈ

- នៅថ្នាក់ទី ៧ នៃមធ្យមសិក្សាបឋមភូមិ សិស្សថ្នាក់ទី៦ នៃបឋមសិក្សា ដែលមានមធ្យមភាគចាប់ពី មធ្យមភាគឡើងទៅ ហើយត្រូវមានអាយុយ៉ាងតិច ១២ឆ្នាំ។
- នៅថ្នាក់ទី១០ នៃមធ្យមសិក្សាទុតិយភូមិ សិស្សដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។

ប្រការ ៣ : សិស្សទាំងអស់ត្រូវស្អាតជានិច្ច មានសម្លៀកបំពាក់និងសក់សមរម្យ ក្រចកត្រូវកាត់ឱ្យខ្លី ។ សាលារៀនដែលពុំទាន់មានឯកសណ្ឋានសិស្សត្រូវ រៀបចំបណ្តើរៗ នូវឯកសណ្ឋានសិស្សគឺ៖

- អាវស ខោខៀវក្រមៅ សម្រាប់សិស្សប្រុស
- អាវស សំពតខៀវក្រមៅ សម្រាប់សិស្សស្រី
  ក្នុងសាលាសិស្សត្រូវពាក់អាវស ដាក់ក្នុងខោ ឬក្នុងសំពត់ ដោយមានប៉ាក់ឈ្មោះសាលា និង សាមីខ្លួនសិស្សនៅផ្ទៃអាវផ្នែកខាងឆ្វេងនិង ខាងលើ។
- ភាពឆើតឆាយនិងគ្រឿងអលង្កាផ្សេងៗ ត្រូវហាមឃាត់ក្នុងសាលារៀន
- ពាក់ស្បែកជើងប៉ែតតាពណ៌ស
- សិស្សមិនត្រូវធ្វើអ្វីដែលប៉ះពាល់ដល់ច្បាប់របស់រដ្ឋ និងប្រពៃណីទំនៀមទំលាប់ល្អរបស់ជាតិ ។

ប្រការ ៤ : ពេលម៉ោងសិក្សានៅមធ្យមសិក្សា ត្រូវបានកំណត់ដូចតទៅ៖

- ពេលព្រឹកចាប់ពីម៉ោង ៧.ម៉ ០០ ដល់ ១១.ម៉ ០០
- ពេលរសៀលចាប់ពីម៉ោង ១៤.ម៉ ០០ ដល់ ១៧.ម៉ ០០

ប្រការ ៥ : សិស្សទាំងអស់ត្រូវចូលរួមគោរពទង់ជាតិរាល់ថ្ងៃ តាមការកំណត់របស់សាលារៀន នៅម៉ោង ៧.ម៉ ០០ ។ សាលារៀនដែលមានសិស្សច្រើនអាចកំណត់វេនសិស្សតាមថ្នាក់អោយប្រារព្ធពិធីនៅជើងទង់ជាតិហើយសិស្សដទៃទៀតត្រូវឈរជាជួរគោរពទៅតាមទីតាំងដែលសាលាបានកំណត់។

ប្រការ ៦ : សិស្សត្រូវមករៀនឱ្យបានទៀងទាត់ និងទាន់ពេលវេលា។ សិស្សមិនត្រូវឈប់ឥតច្បាប់ដោយប្រការណាមួយទេ។ រាល់ការឈប់សម្រាក់ ត្រូវសុំច្បាប់ពីនាយកសាលា ដោយបញ្ជាក់មូលហេតុច្បាស់លាស់ និងមានការយល់ព្រមពីឪពុក

ម្តាយ ឬអាណាព្យាបាលផង។ នាយកសាលាជាអ្នកមានសមត្ថកិច្ចក្នុងការអនុញ្ញាតច្បាប់។ ក្នុងករណីពិសេស ឬបន្ទាន់ បើនាយកសាលាមិននៅ នាយករង ឬអនុរក្សប្រចាំថ្នាក់អាចអនុញ្ញាតច្បាប់បាន។ ក្នុងករណីនេះអនុរក្សមិនអានអនុញ្ញាតច្បាប់លើសពីមួយថ្ងៃឡើយ ហើយត្រូវផ្តល់ព័ត៌មានទៅទីចាត់ការសាលារៀន។

ប្រការ ៧ : សិស្សមានជំងឺត្រូវទៅឱ្យគ្រូពេទ្យពិនិត្យរោគ ដោយយកសៀវភៅពិនិត្យសុខភាពទៅជាមួយផង ។ ក្នុងករណីពិសេស ខ្យល់គរ ឬគ្រោះថ្នាក់ផ្សេងៗ នៅក្នុងសាលារៀន នាយក ឬនាយករង ឬអនុរក្សត្រូវនាំសិស្សនោះទៅមន្ទីរពេទ្យជាបន្ទាន់

ប្រការ ៨ : សិស្សដែលត្រលប់ពីការឈប់វិញ ត្រូវសុំលិខិតអនុញ្ញាតចូលរៀនពីនាយកសាលារៀន។

ប្រការ ៩ : ហាមឃាត់មិនឱ្យសិស្សយកអាវុធ គ្រឿងផ្ទុះ គ្រឿងញៀនចូលក្នុងសាលារៀន ។ សិស្សទាំងអស់មិនត្រូវយកម៉ូតូ កង់ ឡាន ក្នុងបរិវេណសាលារៀន មិនត្រូវប្រើ ពាក្យមិនសមរម្យ មិនត្រូវមើលសៀវភៅទស្សនាវដ្តីរូបភាពអាសអាភាស មិនត្រូវប្រព្រឹត្តអំពើដែលនាំឱ្យមានគ្រោះថ្នាក់ ឬអំពើដែលនាំឱ្យបាត់បង់សណ្តាប់ធ្នាប់ ក្នុងសាលារៀន។

ប្រការ ១០: ហាមជក់បារី ហាមលេងល្បែងស៊ីសងក្នុងបរិវេនសាលា។

ប្រការ ១១: សិស្សទាំងឡាយត្រូវដាក់កង់ម៉ូតូ ឱ្យមានរបៀបរៀបរយតាមការណែនាំរបស់សាលា និងមិនត្រូវគូសវាសសរសេរ ឬកោសលើបេងសាលា ជញ្ជាំងសាលា ឬ គ្រឿងសង្ហារិមឡើយ ។

ប្រការ ១២: សិស្សត្រូវប្រកាន់ខ្ជាប់នូវអនាម័យ មិនត្រូវខាកស្តោះតែពាស ទាំងក្នុងថ្នាក់រៀន ទាំងកាំជណ្តើរ និងបន្ទោរបង់ក្រៅបង្គន់។

ប្រការ ១៣: សិស្សទាំងឡាយត្រូវមានអាកប្បកិរិយាស្លូតបូត សុភាពរាបសា ចេះ ស្រលាញ់រាប់អានគ្នា ជួយយកអាសារមិត្តភក្តិ មានសុជីវធម៌ចេះគោរពចាស់ព្រឹទ្ធាចារ្យ គោរពលោកគ្រូ អ្នកគ្រូ និងជានិច្ចកាលអនុវត្តវិន័យសាលា ។

ប្រការ ១៤: នៅពេលម៉ោងសិក្សា សិស្សត្រូវរក្សាភាពស្ងៀមស្ងាត់ និងមានសណ្តាប់ធ្នាប់ជានិច្ច។ ក្នុងពេលកំពុងរៀនសិស្សមិនត្រូវចេញ ដោយគ្មានការអនុញ្ញាតពីលោកគ្រូអ្នកគ្រូឡើង។

ប្រការ១៥: កាលណាលោកគ្រូ អ្នកគ្រូ ឬភ្ញៀវចូលក្នុងថ្នាក់ ឬចេញពីថ្នាក់ សិស្សទាំងអស់ក្នុងថ្នាក់ត្រូវក្រោកឈរដោយស្ងៀមស្ងាត់

ប្រការ១៦: នៅពេលចេញលេង សិស្សត្រូវប្រកាន់អាកប្បកិរិយាសមរម្យ មិនត្រូវស្រែកឡូឡា ប្រលែងវាយទាត់ធាត់គ្នា ឬឈ្លោះប្រកែកគ្នាឡើយ។

ប្រការ១៧: នៅពេលអវត្តមានលោកគ្រូអ្នកគ្រូ ម៉ោងសិក្សាមុខវិជ្ជាណាមួយ សិស្សត្រូវរក្សាភាពស្ងៀមស្ងាត់ ក្រោមការគ្រប់គ្រងរបស់ប្រធានថ្នាក់ ជៀសវាងការរំខានដល់ថ្នាក់ជិតខាង និងថ្នាក់ដទៃទៀតកំពុងរៀន ។

ប្រការ១៨: សិស្សត្រូវចូលរួមរាល់សកម្មភាពរបស់សាលា ដែលចាត់ចែងដោយនាយកសាលា៖

- បោសសំអាត់ថ្នាក់រៀន សាលារៀន ធ្វើនិងថែទាំសួនច្បារ សួនបន្លែ យាមកាមសាលា និងចូលរួមពលកម្មសង្គម។

ប្រការ១៩: សិស្សទាំងឡាយត្រូវជារៀងទំនាស់ផ្សេងៗ ឱ្យបានជាដាច់ខាត ។ រាល់បាតុភាពដែលកើតមានឡើងនៅក្នុងសាលារៀន សិស្សត្រូវជំរាបលោកគ្រូ អ្នកគ្រូ ឬ នាយកសាលាជាបន្ទាន់។

ប្រការ២០: សិស្សទាំងឡាយត្រូវយកចិត្តទុកដាក់រៀនសូត្រ និងធ្វើកិច្ចការដែលគ្រូដាក់ឱ្យធ្វើ

ប្រការ២១: សិស្សឈប់ឥតច្បាប់ក្នុងពេលប្រឡង ឆមាសមុខវិជ្ជាណាមួយត្រូវបានពិន្ទុសូន្យ។

សិស្សឈប់ឥតច្បាប់ ឬមានច្បាប់ក្នុងពេលប្រឡងឆមាស ចាប់ពីបីមុខឡើងទៅ មិនត្រូវបានចំណាត់ថ្នាក់ ត្រូវរៀនត្រួតថ្នាក់ តែបើក្នុងករណីមានជំងឺ ឬមានគ្រោះថ្នាក់ជាក់ស្តែង និងមានវិញ្ញាបនបត្រពេទ្យបញ្ជាក់ ត្រឹមត្រូវនឹងអាចទទួលបានការអនុគ្រោះធ្វើចំណាត់ថ្នាក់បាន ។

ប្រការ២២: សិស្សនឹងអាចឡើងថ្នាក់បាន លុះត្រាតែមានមធ្យមភាគពិន្ទុប្រចាំឆ្នាំចាប់ពី ២៥,០០ លើ៥០ ឡើងទៅ និងមានសីលធម៌រស់នៅចាប់ពីមធ្យមឡើងទៅ ហើយមានការយល់ព្រមពីក្រុមប្រឹក្សាអប់រំ។ សិស្សដែលមានមធ្យមភាគប្រចាំឆ្នាំក្រោម ២៥,០០ លើ ៥០ នឹងត្រូវសម្រេចឱ្យត្រួតថ្នាក់ ឬឱ្យប្រឡងឡើងថ្នាក់ដោយក្រុមប្រឹក្សាអប់រំ។

ប្រការ២៣: ការឈប់ត្រូវកំណត់ដូចខាងក្រោម៖

- ការឈប់មួយម៉ោងត្រូវគិតថាឈប់មួយដង
- ការឈប់មួយព្រឹកឬមួយរសៀល ក៏ត្រូវគិតថាឈប់មួយដង
- សិស្សឈប់ដែលមានច្បាប់ចាប់ពី ៤៥ដងឡើងទៅ ត្រូវត្រួតថ្នាក់
- សិស្សឈប់ដោយមានច្បាប់ ចាប់ពី ៣០ ដល់ ៤៥ ត្រូវប្រឡងឡើងថ្នាក់ បើសាមីខ្លួនមានមធ្យមភាគពិន្ទុប្រចាំឆ្នាំ ចាប់ពី ២៥,០០ លើ ៥០ ឡើងទៅ តែត្រូវរៀនត្រួតថ្នាក់ចំពោះ សិស្សដែលមានមធ្យមភាគពិន្ទុប្រចាំឆ្នាំ ក្រោម ២៥,០០ លើ ៥០ ។
- សិស្សឈប់ឥតច្បាប់លើសពី ២០ដង ឡើងទៅត្រូវរៀនត្រួតថ្នាក់
- សិស្សឈប់ឥតច្បាប់ចំនួន១០ដង ត្រូវព្រមានសាមីខ្លួន និងជូនព័ត៌មានទៅឪពុកម្តាយ ឬអាណាព្យាបាលទទួលដឹងជាលើកទី១
- សិស្សឈប់ឥតច្បាប់ចំនួន១៥ដង ត្រូវព្រមានសាមីខ្លួន និងជូនព័ត៌មានទៅឪពុកម្តាយ ឬអាណាព្យាបាលទទួលដឹងជាលើកទី២
- សិស្សឈប់ឥតច្បាប់ចំនួន១៨ដង ត្រូវព្រមានសាមីខ្លួន និងជូនព័ត៌មានទៅឪពុកម្តាយ ឬអាណាព្យាបាលទទួលដឹងជាលើកចុងក្រោយ។
- រាល់ការព្រមានត្រូវផ្តល់ព័ត៌មានទៅ ឪពុកម្តាយឬអាណាព្យាបាល ដោយផ្ញើលិខិតផ្តល់ព័ត៌មានទៅជូនឪពុកម្តាយ អាណាព្យាបាល ដោយផ្ទាល់ដៃ

ប្រការ ២៤: សិស្សដែលមិនត្រូវបានចំណាត់ថ្នាក់ និងសិស្សដែលចូលក្នុងល័ក្ខខណ្ឌត្រូវរៀនត្រួតថ្នាក់តាមប្រការ ២៣ ខាងលើមិនអនុញ្ញាតឱ្យចុះឈ្មោះប្រឡងសញ្ញាបត្រឡើង។

ប្រការ២៥: សិស្សដែលប្រព្រឹត្តខុសឆ្គង ត្រូវដាក់ឱ្យក្រុមប្រឹក្សាវិន័យ ពិនិត្យ និងសម្រេច ។

វិន័យមានដូចតទៅ៖

- ណែនាំ
- ស្តីបន្ទោសផ្ទាល់មាត់
- ស្តីបន្ទោសដោយមានចុះក្នុងសៀវភៅសិក្ខាគារិត
- ផ្អាកការសិក្សាបណ្តោះអាសន្នមួយរយៈ
- ១ពេល ១ថ្ងៃ ១សប្តាហ៍ ១ខែ ១ឆមាស ១ឆ្នាំសិក្សា ។
- លុបឈ្មោះចេញពីបញ្ជីរបស់សាលារៀន។

ប្រការ២៦: បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអានពន្យល់សិស្ស និងបិទផ្សាយនៅក្នុងថ្នាក់ ហើយត្រូវផ្តល់ព័ត៌មានដល់ឪពុកម្តាយ ឬអាណាព្យាបាលសិស្សឱ្យបានយល់ដឹងអំពីគំនិត និងអត្ថន័យនៃបទបញ្ជានេះផង។

ប្រការ២៧: នាយកសាលារៀន និងលោកគ្រូអ្នកគ្រូ ទាំងអស់គ្រប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅរដ្ឋត្រូវមានភារកិច្ចអនុវត្តបទបញ្ជានេះឱ្យបានល្អប្រសើរ ។

ប្រការ២៨: បទបញ្ជាផ្ទៃក្នុងទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីបទបញ្ជានេះត្រូវទុកជានិរាករណ៍។

ថ្ងៃអង្គារ ១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ពេជ្រចិន្តា, ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០១៨

នាយក

មិន សុនី

ប្លង់អគារ



ឧបសម្ព័ន្ធ ១

ឧបសម្ព័ន្ធ ២៖ និយាមនៃការផ្តល់ការអប់រំវិទ្យាល័យពេជ្រចិន្តា

សៀវភៅការងារ គណៈកម្មការគ្រប់គ្រងវិទ្យាល័យពេជ្រចិន្តា ឆ្នាំសិក្សា ២០១៩-២០២០

សៀវភៅការងារ

គណៈកម្មការគ្រប់គ្រងសាលារៀន

វិទ្យាល័យ	ពេជ្រចិន្តា
ឆ្នាំសិក្សា	២០១៩-២០២០

មាតិកា

គណៈកម្មការគ្រប់គ្រងសាលារៀន (ក្រុមប្រឹក្សាភិបាល)

វិទ្យាល័យ ពេជ្រចិន្តា

ក សមាសភាព គណៈកម្មការគ្រប់គ្រងសាលារៀន
ខ រចនាសម្ព័ន្ធ គណៈកម្មការគ្រប់គ្រងសាលារៀន
គ តួនាទី និងភារកិច្ច គណៈកម្មការគ្រប់គ្រងសាលារៀន
ឃ កិច្ចការ គណៈកម្មការគ្រប់គ្រងសាលារៀន
ង ការជ្រើសរើស គណៈកម្មការគ្រប់គ្រងសាលារៀន
ច អាណត្តិ គណៈកម្មការគ្រប់គ្រងសាលារៀន

ក សមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន

វិទ្យាល័យ ពេជ្រចិន្តា

គណៈកម្មការគ្រប់គ្រងសាលារៀន **វិទ្យាល័យ ពេជ្រចិន្តា** មានសមាសភាព៣០រូប ដែលជាតំណាងឱ្យសាលារៀន និងសហគមន៍ទាំងមូល សម្រាប់ដឹកនាំ និងគ្រប់គ្រងរួម ក្នុងការអភិវឌ្ឍសាលារៀន ឱ្យក្លាយទៅជាសាលារៀនឆ្នើម និងលេចធ្លោ ក្នុងកម្រិតជាតិ និងកម្រិតតំបន់ តាមរយៈផលសម្រេច ផ្អែកលើស្តង់ដាប្រសិទ្ធភាពសាលារៀនទាំង៩ ដែលកំណត់ដោយនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ដែលផ្តោតជាពិសេសលើ៖ ការប្រមូលសិស្សចូលរៀនឱ្យបានអស់ សិស្សរៀនចេះទាំងអស់តាមស្តង់ដាកម្មវិធីសិក្សា ដែលកំណត់ដោយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងសិស្សរៀនចប់មានសមត្ថភាពពេញលេញ អំពីបំណិនជីវិតតាមមូលដ្ឋាន ដែលបានកំណត់ដោយនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ។

សមាសភាពទាំង៣១រូប នោះមាន៖

១ ឈ្មោះ. ភឿន ឡូត ភេទ ប្រុស អាយុៈ៥៧ ឆ្នាំ
ជាប្រធាន គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុកមើលការខុសត្រូវប្រតិបត្តិការរួម ដើម្បីអភិវឌ្ឍសាលារៀន តាមរយៈការអនុវត្តគោលនយោបាយ ការគ្រប់គ្រងតាមសាលារៀន របស់ក្រសួងអប់រំ យុវជន និងកីឡា។
មុខងារបច្ចុប្បន្នជា សមាជិកក្រុមប្រឹក្សាស្រុក

២ ឈ្មោះ. នាក់ ណេង ភេទ ប្រុស អាយុៈ៥៨ ឆ្នាំ
ជាអនុប្រធាន គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលការងារផែនការ និងការគ្រប់គ្រងថវិកាសាលារៀន ដើម្បីធានាបានការសម្រេចចិត្ត ការអនុវត្ត និងការតាមដាន ពីសំណាក់មាតាបិតា អាណាព្យាបាល មេក្រុម មេភូមិ ក្រុមប្រឹក្សាឃុំ និងស្ថាប័នពាក់ព័ន្ធទាំងអស់។
មុខងារបច្ចុប្បន្នជា មេភូមិភ្នំតូច

៣ ឈ្មោះ. ពាន ចាង ភេទប្រុស អាយុៈ ៥៣ឆ្នាំ
ជាអនុប្រធាន គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលការគ្រប់គ្រងមន្ត្រី និងបុគ្គលិកសាលារៀន ដើម្បីធានាបានការបំពេញការងារសាលារៀន ប្រកបដោយចំណេះដឹង និងមនសិការខ្ពស់ ដែលជាគម្រូដ៏ថ្លៃថ្នូរសម្រាប់សិស្ស ប្រជាជន និងសង្គម។
មុខងារបច្ចុប្បន្នជា មេជាងគ្រឿងចក្រ
៤ ឈ្មោះ លោកជំទាវ អាន គឹមអន ភេទស្រី អាយុៈ៤៦ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលការងារចូលរួមរបស់សហគមន៍ និងអភិបាលកិច្ចសាលារៀន ដើម្បីធានាបានការធ្វើការបំពេញឱ្យគ្នាទៅវិញទៅមក ប្រកបដោយសាមគ្គីភាព និងប្រសិទ្ធភាព រវាងសាលារៀន ជាមួយសហគមន៍ និងស្ថាប័នពាក់ព័ន្ធ។
មុខងារបច្ចុប្បន្នជា អាជីវករ

៥ ឈ្មោះ ម៉ៅ សារ៉ាយ ភេទប្រុស អាយុៈ៤៥ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងការអភិវឌ្ឍរបស់សាលារៀន ផ្ដែកលើស្តង់ដាប្រសិទ្ធភាពសាលារៀន ដើម្បីផ្សព្វផ្សាយផលសម្រេច ឱ្យបានទូលំទូលាយដល់សហគមន៍ និងស្ថាប័នក្នុងមូលដ្ឋាន និងក្រៅមូលដ្ឋាន។
មុខងារបច្ចុប្បន្នជា កសិករ

៦ ឈ្មោះ.ប្ដូ វង្ហា ភេទប្រុស អាយុ ៣៨ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក បេឡា គណនេយ្យភាពសាលារៀន ដើម្បីឱ្យសិស្ស មាតាបិតា មេក្រុម មេភូមិ ក្រុមប្រឹក្សាឃុំ និងស្ថាប័នពាក់ព័ន្ធទាំងក្នុងនិងក្រៅសាលារៀន មានជំនឿមានទំនុកចិត្ត និងឱ្យតម្លៃខ្ពស់ដល់សាលារៀន។
មុខងារបច្ចុប្បន្នជាអាជីវករ
៧ ឈ្មោះ.សុខ ច័ន្ទសេរី ភេទប្រុស អាយុ ៤៨ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក ប្រមូលថវិកា កសាងសាលារៀន ។
មុខងារបច្ចុប្បន្នជាកសិករ
៨ ឈ្មោះ.សំ សារ៉ែន ភេទប្រុស អាយុ ៣៨ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាអាជីវករ
៩ ឈ្មោះ.ណាត ស្រីល័ក្ខ ភេទស្រី អាយុ ៤២ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។
មុខងារបច្ចុប្បន្នជាអាជីវករ
១០ ឈ្មោះ.ផល គឹមហ៊ីន ភេទស្រី អាយុ ៤១ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។
មុខងារបច្ចុប្បន្នជាអាជីវករ
១១ ឈ្មោះ.ហេង ហេន ភេទស្រី អាយុ ៣៧ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។
មុខងារបច្ចុប្បន្នជាអាជីវករ
១២ ឈ្មោះ.គាត រ៉ា ភេទស្រី អាយុ ៤៨ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។
មុខងារបច្ចុប្បន្នជាអាជីវករ
១៣ ឈ្មោះ.ប៉ូវ ទីន ភេទប្រុស អាយុ ៥៥ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។
មុខងារបច្ចុប្បន្នជាសមាជិកក្រុមប្រឹក្សាស្រុក
១៤ ឈ្មោះ.អ៊ុំ ស៊ុនហាំង ភេទប្រុស អាយុ ៤០ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។
មុខងារបច្ចុប្បន្នជាអាជីវករ
១៥ ឈ្មោះ.ញ៉ែម ជឹម ភេទប្រុស អាយុ ៤៨ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។
មុខងារបច្ចុប្បន្នជាសមាជិកក្រុមប្រឹក្សាស្រុក
១៦ ឈ្មោះ.សេង លក្ខិណា ភេទស្រី អាយុ ៣៨ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។
មុខងារបច្ចុប្បន្នជាអាជីវករ
១៧ ឈ្មោះ.តែម ស៊ីនួន ភេទស្រី អាយុ ៣៧ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។
មុខងារបច្ចុប្បន្នជាក្រុមប្រឹក្សាឃុំ
១៨ ឈ្មោះ.តុប ងីវ ភេទស្រី អាយុ ៥៨ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។
មុខងារបច្ចុប្បន្នជាក្រុមប្រឹក្សាឃុំ
១៩ ឈ្មោះ.អឿន វ៉ៃ ភេទប្រុស អាយុ ៤០ ឆ្នាំ
ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។
មុខងារបច្ចុប្បន្នជាអាជីវករ
២០ ឈ្មោះ.អ៊ិក នៅ ភេទស្រី អាយុ ៤៨ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាអាជីវករ

២១ ឈ្មោះ.ឈុត ណាត ភេទប្រុស អាយុ ៤៩ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាអាជីវករ

២២ ឈ្មោះ.ឆាយ ម៉េង ភេទប្រុស អាយុ ៤៨ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាអាជីវករ

២៣ ឈ្មោះ.ប៉ាន់ សុខុម ភេទប្រុស អាយុ ៤០ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាគ្រូពេទ្យ

២៤ ឈ្មោះ ជេមស៍ ជូឡាយ ភេទប្រុស អាយុ ៤៨ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាអាជីវករ

២៥ ឈ្មោះ កុយ ស្រី ភេទស្រី អាយុ ៣០ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាអាជីវករ

២៦ ឈ្មោះ ពាន ម៉ានិត ភេទប្រុស អាយុ ៣៨ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាអធិការរងស្រុក

២៧ ឈ្មោះ.ម៉េង សៀវហួរ ភេទស្រី អាយុ ២៩ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាអាជីវករ

២៨ ឈ្មោះហ៊ុន សុភិន ភេទស្រី អាយុ ៣៨ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាអាជីវករ

២៩ ឈ្មោះស៊ិន ជុង ភេទប្រុស អាយុ ៥៨ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាអាជីវករ

៣០ ឈ្មោះ ពុជ ហួន ភេទប្រុស អាយុ ៦២ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

មុខងារបច្ចុប្បន្នជាមន្ត្រីចូលនិវត្តន៍

៣១ ឈ្មោះ ឃិន ឈុនលី ភេទប្រុស អាយុ៥០ ឆ្នាំ

ជាសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលបន្ទុក រកថវិកា ដើម្បីជួយដល់សាលារៀន។

ខ រចនាសម្ព័ន្ធ គណៈកម្មការគ្រប់គ្រងសាលារៀន

វិទ្យាល័យ ពេជ្រចិន្តា

គណៈកម្មការគ្រប់គ្រងសាលារៀន **វិទ្យាល័យ ពេជ្រចិន្តា** មានរចនាសម្ព័ន្ធប្រទាក់ក្រឡា ជាប្រព័ន្ធតែមួយ ដោយមានការតភ្ជាប់គ្នារវាង៖ គណៈកម្មការគ្រប់គ្រងសាលារៀន ដែលមានសមាសភាព៣០រូប ជាមួយនឹង (១)គណៈគ្រប់គ្រងសាលារៀន ដែលមានសមាសភាព ជានាយកសាលារៀន និងនាយករងសាលារៀន ដើម្បីដឹកនាំគ្រប់គ្រងសាលារៀន ឱ្យសម្រេចគោលដៅ និងបេសកកម្មរបស់សាលារៀន តាមរយៈការធ្វើការងារ (២)គណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដែលមានសមាសភាព ជាតំណាងឱ្យមាតាបិតា និងអាណាព្យាបាលរបស់សិស្សទាំងអស់នៅក្នុងថ្នាក់រៀននីមួយៗ ដើម្បីចូលរួមក្នុងសកម្មភាពអភិវឌ្ឍថ្នាក់រៀន ដោយផ្តោតលើការងាររៀននិងបង្រៀននិងរៀបចំកម្មវិធីជួយសិស្សរៀនយឺតនិងសិស្សរៀនលឿន
(៣)បណ្តាញអប់រំតាមភូមិចំណុះឱ្យសាលារៀន ដែលមានសមាសភាព ជាមេភូមិ ជាគ្រូបង្រៀន ជាក្រុមប្រឹក្សាយុវជន និងជាអ្នកពាក់ព័ន្ធ ដែលរស់នៅក្នុងភូមិចំណុះទាំងនោះ ដើម្បីចលនាអ្នកភូមិទាំងអស់ បានជួយដល់សិស្សរស់នៅក្នុងគ្រួសារ ជួបការលំបាកជាទីបំផុត ឱ្យបានចូលរៀន និងបានមករៀនទៀងទាត់។


គណៈកម្មការគ្រប់គ្រងសាលារៀន
គណៈកម្មការគ្រប់គ្រងថ្នាក់រៀន
(តំណាងអាណាព្យាបាលសិស្ស តាមថ្នាក់)
ភូមិពេជ្រចិន្តា

គណៈកម្មការគ្រប់គ្រងសាលារៀន



១ រចនាសម្ព័ន្ធគណៈគ្រប់គ្រងសាលារៀន



២ រចនាសម្ព័ន្ធបណ្ដាញអប់រំតាមភូមិចំណុះរបស់សាលារៀន

ភូមិ ភ្នំតូច	ភូមិ ពេជ្រចិន្ដា	ភូមិ ភូមិអូរ	ភូមិ អូរតាសុក
ប្រធាន: មេភូមិ	ប្រធាន: មេភូមិ	ប្រធាន: មេភូមិ	ប្រធាន: មេភូមិ
អនុប្រធាន: មេក្រុម	អនុប្រធាន: មេក្រុម	អនុប្រធាន: មេក្រុម	អនុប្រធាន: មេក្រុម
សមាជិក: សិស្ស	សមាជិក: សិស្ស	សមាជិក: សិស្ស	សមាជិក: សិស្ស
សមាជិក: គ្រូ	សមាជិក: គ្រូ	សមាជិក: គ្រូ	សមាជិក: គ្រូ
សមាជិក: មាតាបិតា	សមាជិក: មាតាបិតា	សមាជិក: មាតាបិតា	សមាជិក: មាតាបិតា

៣ រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងថ្នាក់រៀន

ថ្នាក់ទី 7A	ថ្នាក់ទី 7B	ថ្នាក់ទី 8A	ថ្នាក់ទី 8B
ប្រធានៈផែនការថ្នាក់ អនុប្រធានៈថវិកាថ្នាក់ សមាជិកៈតេស្ត សមាជិកៈហេដ្ឋារចនាសម្ព័ន្ធថ្នាក់រៀន	ប្រធានៈផែនការថ្នាក់ អនុប្រធានៈថវិកាថ្នាក់ សមាជិកៈតេស្ត សមាជិកៈហេដ្ឋារចនាសម្ព័ន្ធថ្នាក់រៀន	ប្រធានៈផែនការថ្នាក់ អនុប្រធានៈថវិកាថ្នាក់ សមាជិកៈតេស្ត សមាជិកៈហេដ្ឋារចនាសម្ព័ន្ធថ្នាក់រៀន	ប្រធានៈផែនការថ្នាក់ អនុប្រធានៈថវិកាថ្នាក់ សមាជិកៈតេស្ត សមាជិកៈហេដ្ឋារចនាសម្ព័ន្ធថ្នាក់រៀន

គ តួនាទី និងភារកិច្ច គណៈកម្មការគ្រប់គ្រងសាលារៀន

វិទ្យាល័យ ពេជ្រចិន្តា

គណៈកម្មការគ្រប់គ្រងសាលារៀន **វិទ្យាល័យ ពេជ្រចិន្តា** ជាតំណាងឱ្យសាលារៀន និងសហ គមន៍ទាំងមូល សម្រាប់ដឹកនាំ និងគ្រប់គ្រងរួម ក្នុងការអភិវឌ្ឍសាលារៀន ឱ្យក្លាយទៅជាសាលារៀនថ្មើម និងលេចធ្លោ ក្នុងកម្រិតជាតិ និងកម្រិតតំបន់ តាមរយៈផលសម្រេច ផ្អែកលើនៃស្តង់ដាប្រសិទ្ធភាពសាលារៀនទាំង៩ ដូច្នេះគណៈកម្មការគ្រប់គ្រងសាលារៀន មានតួនាទី និងភារកិច្ចដូចតទៅ៖

១ ការងារផែនការ និងថវិកាសាលារៀន

១.១ គណៈកម្មការគ្រប់គ្រងសាលារៀន ជួយគណៈគ្រប់គ្រងសាលារៀន ឱ្យមានចក្ខុវិស័យ គោលបំណង និងបេសកកម្មរបស់សាលារៀន ដើម្បីបានជាមូលដ្ឋានសម្រាប់ជួយ ឱ្យអ្នកពាក់ព័ន្ធទាំងអស់ មានការប្តេជ្ញាចិត្ត និងរួបរួមគ្នារៀបចំផែនការកែលម្អសាលារៀន សម្រាប់រយៈពេលខ្លី និងរយៈពេលវែង ដើម្បីអភិវឌ្ឍសាលារៀន ឱ្យក្លាយទៅជាសាលារៀនថ្មើម ផ្អែកលើលទ្ធផលសិក្សា។

១.២ គណៈកម្មការគ្រប់គ្រងសាលារៀន ជួយគណៈគ្រប់គ្រងសាលារៀន ដឹកនាំសកម្មភាពប្រជុំពិគ្រោះយោបល់ជាមួយសិស្សគ្រប់កម្រិតថ្នាក់ អាណាព្យាបាលសិស្ស មេក្រុម មេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ លោកគ្រូ អ្នកគ្រូ មណ្ឌលសុខភាព នគរបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត ទាំងក្នុងនិងក្រៅមូលដ្ឋាន ដើម្បីកំណត់បញ្ហាប្រឈម និងសរសេរសេចក្តីព្រាង សកម្មភាពអាទិភាព ផែនការកែលម្អសាលារៀន និងផែនការថវិកាសាលារៀន ដោយផ្តោតលើគុណភាពលទ្ធផលសិក្សារបស់សិស្ស ជាកត្តាចម្បងជាងគេជាទីបំផុត។

១.៣ គណៈគ្រប់គ្រងសាលារៀន ធ្វើការជាមួយគ្រូបង្រៀន ដើម្បីគ្រូបង្រៀនសហការណ៍ ជាមួយមេភូមិ ដែលជាមេបណ្តាញអប់រំតាមភូមិដែលគាត់រស់នៅ បានយកសេចក្តីព្រាងផែនការកែលម្អសាលារៀន ទៅឆ្លងជាមួយ អាណាព្យាបាលសិស្ស ដើម្បីអាចឱ្យគាត់បានដឹងពីសកម្មភាព និងសូចនាករផែនការកែលម្អសាលារៀន និងបាន លើកសំណូមពរបន្ថែមករណីចាំបាច់។

១.៤ គណៈគ្រប់គ្រងសាលារៀន ធ្វើការជាមួយគ្រូបង្រៀន ដើម្បីកែលម្អសម្រេចផែនការកែលម្អសាលា រៀន ដោយបញ្ចូលសំណូមពរ និងគំនិតដែលបានពីអាណាព្យាបាលសិស្ស។

១.៥ គណៈគ្រប់គ្រងសាលារៀន ស្នើសុំឱ្យគណៈកម្មការគ្រប់គ្រងសាលារៀន អនុម័តផែនការកែលម្អ សាលារៀន ដែលមានសូចនាករ និងសកម្មភាពអាទិភាព ផ្អែកលើស្តង់ដាប្រសិទ្ធភាពសាលារៀន តាមរយៈការអនុវត្ត គោលនយោបាយ ការគ្រប់គ្រងតាមសាលារៀន។

១.៦ គណៈគ្រប់គ្រងសាលារៀន ស្នើសុំឱ្យការិយាល័យអប់រំស្រុកខ័ណ្ឌ សម្រេចនិងឯកភាពផែនការកែ លម្អសាលារៀន និងបានជាមូលដ្ឋានសម្រាប់ រៀបចំសកម្មភាពចុះតាមដាន ជួយដឹកនាំធ្វើសកម្មភាព និងវាយតម្លៃ ផលសម្រេចពីការអនុវត្តផែនការកែលម្អសាលារៀន។

១.៧ គណៈគ្រប់គ្រងសាលារៀន ធ្វើការជាមួយក្រុមប្រឹក្សាយុវជន គ្រូបង្រៀន និងបណ្តាញអប់រំនៅ តាមភូមិគោលដៅ ដើម្បីផ្សព្វផ្សាយផែនការកែលម្អសាលារៀន ទៅអាណាព្យាបាលសិស្ស អាជ្ញាធរដែនដី និងស្ថាប័ន ពាក់ព័ន្ធក្នុងមូលដ្ឋាន និងតាំងបង្ហាញនៅសាលារៀន និងសហគមន៍។

២ ការគ្រប់គ្រងគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន

២.១ គណៈកម្មការគ្រប់គ្រងសាលារៀន ជួយគណៈគ្រប់គ្រងសាលារៀន រៀបចំគោលដៅបំពេញ ការងារប្រចាំត្រីមាសនិងប្រចាំឆ្នាំ (performance objective) ដោយពិភាក្សា និងឆ្លងជាមួយគ្រូបង្រៀន និងបុគ្គលិក របស់សាលារៀន នៅដើមឆ្នាំសិក្សា។

២.២ គណៈកម្មការគ្រប់គ្រងសាលារៀន អនុម័តគោលដៅបំពេញការងារ ប្រចាំត្រីមាសនិងប្រចាំឆ្នាំ របស់នាយកសាលារៀន និងនាយករង។

២.៣ គណៈកម្មការគ្រប់គ្រងសាលារៀន ឆ្លុះបញ្ចាំងផលសម្រេច ដែលនាយក និងនាយករងសម្រេច បានផ្អែកលើគោលដៅបំពេញការងារ ប្រចាំត្រីមាសនិងប្រចាំឆ្នាំ នៅចុងឆ្នាំសិក្សា។

២.៤ គណៈកម្មការគ្រប់គ្រងសាលារៀន រៀបចំកម្មវិធី និងសកម្មភាពលើកទឹកចិត្ត ដល់នាយកនិង នាយករងសាលារៀនណា ដែលបានបំពេញកិច្ចការ ទទួលបានផលសម្រេចខ្ពស់ ផ្អែកលើគោលដៅបំពេញការងារ ប្រចាំឆ្នាំ។ ឬមានវិធានការជួយចំពោះនាយក និងនាយករងសាលារៀន ដែលមិនអាចសម្រេចបាន លទ្ធផលដូចមាន កំណត់ក្នុងគោលដៅបំពេញការងារប្រចាំឆ្នាំ។

២.៥ គណៈគ្រប់គ្រងសាលារៀន ជួយគ្រូបង្រៀនម្នាក់ៗ ព្រាងគោលដៅបំពេញភារកិច្ចការងារ ប្រចាំត្រី មាសនិងប្រចាំឆ្នាំ នៅដើមឆ្នាំសិក្សានីមួយៗ ដោយឆ្លងជាមួយសិស្សរបស់គាត់ និងជាមួយគណៈកម្មការគ្រប់គ្រងថ្នាក់ រៀន ដើម្បីអាចឱ្យអ្នកទាំងនោះបានចូលរួមគំនិត និងបានប្តេជ្ញាចិត្តរួមសហការណ៍ជាមួយគ្រូបង្រៀន ក្នុងការអនុវត្ត ការកិច្ចបង្រៀនសិស្ស ឱ្យទទួលបានលទ្ធផល ទៅតាមតម្រូវការរបស់អាណាព្យាបាលសិស្ស។

២.៦ គណៈគ្រប់គ្រងថ្នាក់រៀន អនុម័តគោលដៅបំពេញការងារប្រចាំត្រីមាសនិងប្រចាំឆ្នាំ របស់គ្រូ បង្រៀន បន្ទាប់មកបញ្ជូនមកគណៈគ្រប់គ្រងសាលារៀន ដើម្បីទទួលដឹងឮ និងឯកភាព។

២.៧ គណៈគ្រប់គ្រងសាលារៀន ធ្វើការជាមួយគណៈកម្មការគ្រប់គ្រងថ្នាក់រៀន រួមជាមួយសិស្សទាំងអស់ក្នុងថ្នាក់ ឆ្លុះបញ្ចាំងផលសម្រេច ដែលគ្រូបង្រៀនសម្រេចបាន ផ្អែកលើគោលដៅបំពេញការងាររបស់គ្រូបង្រៀននៅចុងឆ្នាំសិក្សា។

២.៨ គណៈគ្រប់គ្រងសាលារៀន មានឧបករណ៍សម្រាប់កត់ត្រា និងបូកសរុបប្រចាំឆ្នាំ អំពីសកម្មភាព និងប្រធានបទ ដែលគ្រូបង្រៀនម្នាក់ៗ បានចូលរួមបង្កើនចំណេះដឹងមុខវិជ្ជា និងបំណិនបង្រៀន តាមរយៈសកម្មភាពបណ្តុះបណ្តាល នៅក្នុងសាលារៀន និងនៅក្រៅសាលារៀន។

២.៩ គណៈគ្រប់គ្រងសាលារៀន រៀបចំកម្មវិធី និងសកម្មភាពលើកទឹកចិត្ត ដល់គ្រូបង្រៀន និងបុគ្គលិកសាលារៀនណា ដែលបានបំពេញកិច្ចការ ទទួលបានផលសម្រេចខ្ពស់ ផ្អែកលើគោលដៅបំពេញការងារប្រចាំឆ្នាំ។ ឬមានវិធានការជួយចំពោះគ្រូបង្រៀន និងបុគ្គលិកសាលារៀនណា ដែលមិនអាចសម្រេចបាន លទ្ធផលដូចមានកំណត់ក្នុងគោលដៅបំពេញការងារប្រចាំឆ្នាំ។

៣ ការចូលរួមរបស់សហគមន៍ និងអភិបាលកិច្ចសាលារៀន

៣.១ គណៈកម្មការគ្រប់គ្រងសាលារៀន ជួយគណៈគ្រប់គ្រងសាលារៀន រៀបចំឱ្យមានបណ្តាញអប់រំតាមភូមិដើម្បីឱ្យគាត់មានការទទួលខុសត្រូវលើការងារអប់រំ មានដូចជាអាណាព្យាបាលសិស្ស មេក្រុម មេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ មន្ត្រីរាជការ សាសនិកជន និងអ្នកពាក់ពន្ធ័រស់នៅតាមភូមិចំណុះឱ្យសាលារៀននីមួយៗ សហការណ៍គ្នាចលនាធនធានពីអ្នកក្នុងភូមិ ជួយផ្ទាល់ដល់សិស្សមួយចំនួនតូច ដែលរស់ក្នុងគ្រួសារជួបការលំបាក ឱ្យបានចូលរៀន និងបានមករៀនទៀងទាត់។

៣.២ គណៈកម្មការគ្រប់គ្រងសាលារៀន ជួយគណៈគ្រប់គ្រងសាលារៀន រៀបចំគណៈកម្មការថ្នាក់រៀន ដើម្បីអាចឱ្យអាណាព្យាបាលសិស្ស ក្នុងថ្នាក់នីមួយៗបានជ្រើសរើសតំណាង សម្រាប់ចលនាធនធាន ពីអាណាព្យាបាលសិស្សក្នុងថ្នាក់ជាមួយគ្នា ជួយដល់គ្រូបង្រៀនក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងមធ្យោបាយបង្រៀន ដែលអាចឱ្យសិស្សរៀនបានលទ្ធផលប្រសើរ។

៣.៣ គណៈកម្មការគ្រប់គ្រងសាលារៀន ជួយគណៈគ្រប់គ្រងសាលារៀន រៀបចំកម្មវិធីសិក្សា និងប្រតិទិនសិក្សាសម្រាប់៣ខែម្តង ផ្អែកលើលទ្ធផលតេស្តប្រចាំខែ និងស្ថានភាពជីវភាពរស់នៅរបស់ប្រជាជន ដើម្បីធានាបានការជួយជាបន្ទាន់ដល់សិស្សរៀនលឿន រៀនបង្គួរ និងសិស្សរៀនយឺត។

៣.៤ គណៈកម្មការគ្រប់គ្រងសាលារៀន ជួយគណៈគ្រប់គ្រងសាលារៀន រៀបចំផែនការបង្រៀនមួយមេរៀនច្រើនម៉ោងសិក្សា និងកិច្ចតែងការបង្រៀនមួយម៉ោងសិក្សា ផ្អែកលើកម្មវិធីសិក្សា និងលទ្ធផលតេស្តដើម្បីអាចជួយជាបន្ទាន់ដល់សិស្សរៀនលឿន រៀនបង្គួរ និងសិស្សរៀនយឺត។

៣.៥ គណៈគ្រប់គ្រងសាលារៀន រៀបចំកម្មវិធីបដិសណ្ឋារកិច្ច នៅថ្ងៃចូលរៀនដំបូងសម្រាប់សិស្សថ្នាក់ទី៦ឡើងថ្នាក់ទី៧ រួមជាមួយអាណាព្យាបាលសិស្ស ដើម្បីអាចឱ្យសិស្សមានទំនុកចិត្ត និងអាណាព្យាបាលស្គាល់គ្រូបង្រៀនប្រចាំថ្នាក់ និងតាមមុខវិជ្ជា និងបានទស្សនកិច្ចសាលារៀនផងដែរ។

៣.៦ គណៈគ្រប់គ្រងសាលារៀន រៀបចំកម្មវិធីសម្រាប់ អាណាព្យាបាលសិស្ស និងគ្រូបង្រៀនបានពិភាក្សាគ្នា និងរកដំណោះស្រាយជួយកូនចៅ រៀនឱ្យកាន់តែប្រសើរថែមទៀត រៀងរាល់ត្រីមាស។

៣.៧ គណៈគ្រប់គ្រងសាលារៀន រៀបចំកម្មវិធីសម្រាប់ អាណាព្យាបាលសិស្ស និងគ្រូបង្រៀនបានធ្វើទំនាក់ទំនងគ្នាតាមទូរស័ព្ទ ឬតាមមធ្យោបាយផ្សេងទៀត ផ្តល់ព័ត៌មានគ្នាទៅវិញទៅមក អំពីវត្តមាន អវត្តមាន និងការមករៀនយឺតរបស់សិស្ស។

៣.៨ គណៈកម្មការគ្រប់គ្រងសាលារៀន ចូលរួមសម្រេចចិត្ត ក្នុងសកម្មភាពសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាលារៀន ដើម្បីអាចធានាបានតម្លាភាព និងគុណភាពលទ្ធផលការងារ និងអាចធានាបានបរិយាកាសនៃការសិក្សារបស់សិស្សប្រកបដោយមេត្រីភាព។

៣.៩ គណៈកម្មការគ្រប់គ្រងសាលារៀន ចូលរួមចលនាធនធាន និងសម្រេចចិត្តក្នុងសកម្មភាព សាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តថ្នាក់រៀន និងសាលារៀន ដើម្បីអាចធានាបានតម្លាភាព និងគុណភាពលទ្ធផលការងារ និងអាចធានាបានបរិយាកាស នៃការសិក្សារៀនសូត្ររបស់សិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព។

៤ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងសាលារៀន

៤.១ គណៈកម្មការគ្រប់គ្រងសាលារៀន ជួយគណៈគ្រប់គ្រងសាលារៀន រៀបចំផែនការ និងកម្មវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប្រចាំ ដោយអនុវត្តតាមកំណែទម្រង់ការប្រឡងសិស្សថ្នាក់ទី១២។

៤.២ គណៈគ្រប់គ្រងសាលារៀន ដឹកនាំនិងគ្រប់គ្រងការធ្វើតេស្តស្តង់ដាប្រចាំខែ ប្រចាំត្រីមាស និងតេស្តដើមឆ្នាំ និងចុងឆ្នាំ កម្រិតសាលារៀន ដោយអនុវត្តដូចការប្រឡងថ្នាក់ទី១២ ដែលអាចធានាបានគុណភាព លទ្ធផលសិក្សា។

៤.៣ គណៈគ្រប់គ្រងសាលារៀន ផ្តល់ព័ត៌មានត្រឡប់ទៅ និងផ្សព្វផ្សាយលទ្ធផលសិក្សារបស់សិស្សទៅអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធក្នុងមូលដ្ឋាន ដើម្បីអបអរសាទរ និងមានវិធានការរួមគ្នាពង្រឹងវិន័យ សណ្តាប់ធ្នាប់ និងវិធីសាស្ត្ររៀន និងបង្រៀនទាំងគ្រូបង្រៀនទាំងសិស្ស។

៤.៤ គ្រូបង្រៀនតាមមុខវិជ្ជា ផ្តល់ព័ត៌មានត្រឡប់ទៅសិស្សរៀនយឺតមួយចំនួនតូច ដែលអាចប្រឈមក្នុងការបាក់ស្មារតី អស់សង្ឃឹមក្នុងការរៀនសូត្រ ឱ្យមានការតាំងចិត្តខំរៀន ដោយគ្រូសន្យានឹងជួយសិស្សឱ្យរៀនបានប្រសើរ និងទទួលលទ្ធផលល្អ។

៤.៥ គ្រូបង្រៀនតាមមុខវិជ្ជា ផ្តល់ព័ត៌មានត្រឡប់ទៅអាណាព្យាបាលសិស្សរៀនយឺតមួយចំនួន ដើម្បីមានឱកាសពិភាក្សា និងរិះរកវិធានការជួយសិស្សរៀនយឺតជាមួយគ្នា តៅតាមមធ្យោបាយ និងជម្រើសផ្សេងៗដែលអាចធ្វើទៅបាន។

៤.៦ គ្រូបង្រៀនតាមមុខវិជ្ជា រៀបចំសកម្មភាពជួយសិស្សរៀនយឺត តាមរយៈសកម្មភាពប្រកួត ប្រចាំសប្តាហ៍នៅកម្រិតថ្នាក់រៀន។ រីឯការប្រកួតកម្រិតសាលារៀន និងកម្រិតភូមិ ដែលរៀបចំនិងដឹកនាំដោយគណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដែលប្រព្រឹត្តិទៅជារៀងរាល់ខែ និងសម្រាប់ប្រកួតផ្តាច់ព្រ័ត្រនៅក្នុងទិវាជាតិអំណានភាសាខ្មែរ។

៤.៧ គណកម្មការគ្រប់គ្រងសាលារៀន ជួយគណៈគ្រប់គ្រងសាលារៀន ដឹកនាំសកម្មភាពវាយតម្លៃផលសម្រេចប្រសិទ្ធភាពសាលារៀន មានស្តង់ដា៩ រៀងរាល់ត្រីមាស និងចុងឆ្នាំសិក្សា ដោយមានការចូលរួមពីសំណាក់សិស្សានុសិស្ស អាណាព្យាបាលសិស្ស មេក្រុម មេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ មណ្ឌលសុខភាព នគរបាល គ្រូបង្រៀន និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

៤.៨ គណៈគ្រង់គ្រងសាលារៀន ដឹកនាំសកម្មភាពវាយតម្លៃការប្រមូល ការប្រើប្រាស់ ការទុកដាក់ និងការផ្សព្វផ្សាយការគ្រប់គ្រងថវិកា និងធនធានសាលារៀន ដល់សិស្ស គ្រូបង្រៀន អាណាព្យាបាលសិស្ស មេក្រុម មេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ សាសនិកជន និងអ្នកពាក់ព័ន្ធផ្សេងទៀត។

៤.៩ គណៈគ្រប់គ្រងសាលារៀន ផ្សព្វផ្សាយរបាយការណ៍វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងសាលារៀនដល់សហគមន៍ និងអ្នកពាក់ព័ន្ធ។

៥ គណនេយ្យភាពសាលារៀន

៥.១ គណៈគ្រប់គ្រងសាលារៀន មានកត់ត្រានិងបូកសរុប ទិន្នន័យនិងព័ត៌មាន ដែលជាភស្តុតាងអំពីផលសម្រេចរបស់សាលារៀនមានប្រសិទ្ធភាព គ្រប់ស្តង់ដាទាំង៩ សម្រាប់ផ្សព្វផ្សាយដល់សិស្ស គ្រូបង្រៀន អាណាព្យាបាលសិស្ស មេក្រុម មេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ និងស្ថាប័នពាក់ពន្ធ័បានដឹង ពីការប្លែម និងការរីកចម្រើនរបស់សាលារៀន។

៥.២ គណៈគ្រប់គ្រងសាលារៀន មានកត់ត្រានិងបូកសរុប ទិន្នន័យនិងព័ត៌មាន ដែលជាភស្តុតាងអំពីលទ្ធផលសិក្សារបស់សិស្ស ដោយប្រៀបធៀបលទ្ធផលតេស្តដើមឆ្នាំ ជាមួយតេស្តចុងឆ្នាំ និងតេស្តប្រចាំខែ សម្រាប់ផ្សព្វផ្សាយដល់សិស្ស គ្រូបង្រៀន អាណាព្យាបាលសិស្ស មេក្រុម មេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ និងស្ថាប័នពាក់ពន្ធ័បានដឹង ពីការប្លែម និងការរីកចម្រើនរបស់សាលារៀន។

៥.៣ គណៈគ្រប់គ្រងសាលារៀន មានកត់ត្រានិងបូកសរុប ទិន្នន័យនិងព័ត៌មាន ដែលជាភស្តុតាងអំពីចំណូល ចំណាយ ការទុកដាក់ និងផលជះបានពីការចំណាយរបស់សាលារៀន ដោយប្រៀបធៀបតាមលំដាប់ឆ្នាំ និងលំដាប់ខែ សម្រាប់ផ្សព្វផ្សាយដល់សិស្ស គ្រូបង្រៀន អាណាព្យាបាលសិស្ស មេក្រុម មេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ និងស្ថាប័នពាក់ពន្ធ័បានដឹង ពីការប្លែម និងការរីកចម្រើនរបស់សាលារៀន។

ឃ កិច្ចការ គណៈកម្មការគ្រប់គ្រងសាលារៀន

វិទ្យាល័យ ពេជ្រចិន្តា

១ ការងារផែនការគណៈកម្មការគ្រប់គ្រងសាលារៀន

១.១ គណៈកម្មការគ្រប់គ្រងសាលារៀន រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ សម្រាប់ពិគ្រោះយោបល់ជាមួយគ្រូបង្រៀន គណៈកម្មការគ្រប់គ្រងថ្នាក់រៀន គណៈគ្រប់គ្រងសាលារៀន អាជ្ញាធរដែនដី និងអ្នកពាក់ពន្ធ័ ដើម្បីបានធាតុចូលសម្រាប់អនុវត្តរួមគ្នា។

១.២ គណៈគ្រប់គ្រងសាលារៀន ផ្សព្វផ្សាយផែនការសកម្មភាពប្រចាំឆ្នាំ របស់គណៈកម្មការគ្រប់គ្រងសាលារៀន ដល់សិស្ស អាណាព្យាបាល គ្រូបង្រៀន និងអ្នកពាក់ព័ន្ធក្នុង និងក្រៅសាលារៀន។

២ ការងារតាមដាន ការអនុវត្តការគ្រប់គ្រងតាមសាលារៀន

២.១ គណៈកម្មការគ្រប់គ្រងសាលារៀន ប្រជុំជាប្រចាំជាមួយគណៈគ្រប់គ្រងសាលារៀន និងប្រធានក្រុមបច្ចេកទេស និងអ្នកពាក់ព័ន្ធ ដើម្បីស្តាប់របាយការណ៍រីកចម្រើនរបស់សាលារៀន ផ្តោតលើលទ្ធផលសិក្សារបស់សិស្ស និងកម្មវិធីការគ្រប់គ្រងតាមសាលារៀន រួមមាន(១)ការគ្រប់គ្រងរដ្ឋបាលសាលារៀន (២)ការគ្រប់គ្រងការហារៀន និងបង្រៀន (៣)ការគ្រប់គ្រងហិរញ្ញវត្ថុ និង(៤)ការគ្រប់គ្រងបុគ្គលិកសិក្សា។

២.២ គណៈកម្មការគ្រប់គ្រងសាលារៀន រៀបចំរបាយការណ៍ប្រជុំ ផ្អែកលើលទ្ធផលប្រជុំ ជាអនុសាសន៍សម្រាប់គណៈគ្រប់គ្រងសាលារៀន អនុវត្ត អនុវត្តបន្ត និងដោះស្រាយកិច្ចការមួយចំនួនដែលរាំងស្ទះ ដល់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន។

៣ ការវាយតម្លៃ ការអនុវត្តការគ្រប់គ្រងតាមសាលារៀន

៣.១ គណៈកម្មការគ្រប់គ្រងសាលារៀន ជួយសាលារៀនធ្វើរបាយការណ៍រីកចម្រើន ប្រចាំត្រីមាសអំពីសាលារៀនមានប្រសិទ្ធភាព ជាពិសេសលទ្ធផលនៃការចូលរៀន និងការរៀនចេះរបស់សិស្ស។

៣.២ គណៈកម្មការគ្រប់គ្រងសាលារៀន ជួយសាលារៀនធ្វើរបាយការណ៍រីកចម្រើន ប្រចាំត្រីឆ្នាំអំពីសាលារៀនមានប្រសិទ្ធភាព ជាពិសេសលទ្ធផលនៃការចូលរៀន និងការរៀនចេះរបស់សិស្ស។

៣.៣ គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនផ្សព្វផ្សាយរបាយការណ៍រីកចម្រើនរបស់សាលារៀន ដល់សហគមន៍ និងស្ថាប័នពាក់ព័ន្ធ។

១ ការជ្រើសរើស គណៈកម្មការគ្រប់គ្រងសាលារៀន

វិទ្យាល័យពេជ្រចិន្តា

១ ផ្សព្វផ្សាយឯកសារស្តីពីការងារគណៈកម្មការគ្រប់គ្រងសាលារៀន
២ ការដាក់បេក្ខភាព និងការអញ្ជើញចូលរួមជាបេក្ខភាព គណៈកម្មការគ្រប់គ្រងសាលារៀន
៣ ការផ្សព្វផ្សាយសាវតា និងការប្តេជ្ញចិត្តរបស់បេក្ខភាព គណៈកម្មការគ្រប់គ្រងសាលារៀន
៤ ការបោះឆ្នោតជ្រើសរើស គណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកមានសិទ្ធបោះឆ្នោត
៥ ការប្រកាសគណៈកម្មការគ្រប់គ្រងសាលារៀន
៦ កសាងរចនាសម្ព័ន្ធ

២ អាណត្តិ គណៈកម្មការគ្រប់គ្រងសាលារៀន

វិទ្យាល័យ ពេជ្រចិន្តា

គណៈកម្មការគ្រប់គ្រងសាលារៀន មានអាណត្តិមួយឆ្នាំតែប៉ុណ្ណោះ។ ប្រសិនបើគណៈកម្មការគ្រប់គ្រងសាលារៀន មានដំណើរការល្អ ផែនការសាលារៀនបានអនុវត្ត បានតាមដាន និងបានវាយតម្លៃទទួលបានលទ្ធផលខ្ពស់ សាលារៀនមានការរីកចម្រើនជាងមុន សិស្សរៀនទទួលលទ្ធផលប្រសើរជាងមុន ខំរៀនជាងមុន សហគមន៍ស្រឡាញ់ចូលចិត្តបុគ្គលិកសាលារៀន ជួយសាលារៀនឱ្យសម្រេចបានតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាព គណៈកម្មការនេះអាចបន្ត ដោយមានការយល់ព្រមពីការិយាល័យអប់រំ។ ក្នុងករណីយ៍គណៈកម្មការមិនដំណើរការបានល្អទេ នោះត្រូវការជ្រើសរើសជាថ្មី នៅឆ្នាំបន្ទាប់។

រៀបចំដោយ
នាយកវិទ្យាល័យ
ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០១៩
ហត្ថលេខា

ម៉ិច ឈឿត

ហត្ថលេខាទទួលស្គាល់
គណៈកម្មការគ្រប់គ្រងវិទ្យាល័យពេជ្រចិន្តា
ថ្ងៃទី............ខែ............ឆ្នាំ..............
ប្រធានហត្ថលេខា

ឯកភាពបេក្ខភាព និងកិច្ចការ
គណៈកម្មការគ្រប់គ្រងវិទ្យាល័យពេជ្រចិន្តា
ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០១៩
ការិយាល័យអប់រំ យុវជន និងកីឡាស្រុកភ្នំព្រឹក
ហត្ថលេខា

ម៉ុត ពុំ

បានឃើញ និងឯកភាព
ប្រធានមន្ទីរអប់រំយុវជន និងកីឡា
ថ្ងៃទី ០១ ខែ [illegible] ឆ្នាំ ២០១៩
ហត្ថលេខា

យី សុខគី

ជីវប្រវត្តិសង្ខេប និងស្នាដៃសំខាន់ៗ

នាយកសាលារៀនវិទ្យាល័យពេជ្រចិន្តា

១. ជីវប្រវត្តិនាយកសាលារៀន

- ឈ្មោះ **ប៉ិច ឈឿត** ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត ០៣/០៣/៨៣
- ទីកន្លែងកំណើត ភូមិអូរតានប់ ឃុំក្តុរ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។
- ឪពុកឈ្មោះ ប៉ិច ឈិន មុខរបរ (ស្លាប់) ម្តាយឈ្មោះ នាក់ មុំ មុខរបរ កសិក
- ប្រពន្ធឈ្មោះចំរើន សេរីវ័ន្ត មុខរបរគ្រូបង្រៀន
- កូនឈ្មោះ ប៉ិច គហបតី មុខរបរ សិស្ស។
- ទីលំនៅបច្ចុប្បន្ន ភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

២. ស្នាដៃសំខាន់ៗរបស់នាយកសាលារៀន

- ប័ណ្ណសរសើររបស់ថ្នាក់ដឹកនាំមន្ទី
- ប័ណ្ណសរសើររបស់ថ្នាក់ដឹកនាំក្រសួង
- ប័ណ្ណសរសើររបស់ថ្នាក់ដឹកនាំខេត្ត
- ប្រកាសនីយបត្រពានរង្វាន់លេខ១សម្តេចតេជោសែន
- ប្រកាសនីយបត្រពានរង្វាន់លរខ៣ សាលាស្អាត
- ជ័យលាភីលេខ៣ សាលាមេត្រីបរិស្ថាន (ក្រសួងបរស្ថាន)
- ជ័យលាភីលេខ១ ការផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ

៣. វិធីសាស្ត្រគ្រប់គ្រង និង ដឹកនាំរបស់នាយកសាលារៀន

- ការស្រឡាញ់និងគោរពវិជ្ជាជីវៈជាអ្នកអប់រំ
- ការគោរពពេលវេលា
- ការរៀបចំផែនការច្បាស់លាស់
- មានចក្ខុវិស័យច្បាស់លាស់
- ការបែងចែងតួនាទីនិងភារៈកិច្ចច្បាស់លាស់
- គោរពថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់
- ធ្វើការជាមួយបេះដូងទន់ភ្លន់និងចេះបត់បែន
- ស្រឡាញ់មិត្តរួមការងារនិងសិស្សដូចបងប្អូនបង្កើត
- ដោយសារគ្រួសារជាគ្រូដូចគ្នាហើយយល់ការងារជាគ្រូជាទីប្រឹក្សានិងលើកទឹកចិត្តទុកពេលឲ្យនៅសាលារៀនបានច្រើន

- ជួយដោះស្រាយបញ្ហាសិស្ស គ្រូ មាតាបិតា ប្រជាពលរដ្ឋ ទាន់ពេលវេលានិងមិនប្រកាន់ពេលវេលា
- ទទួលស្តាប់គំនិតអ្នកដទៃឲ្យបានច្រើន
- មានយុត្តិធម៌តម្លាភាពគណនេយ្យភាព មិនប្រកាន់បក្សពួក មិនស្តាប់ពាក្យញោះញ៉ុងអុចអាល
- ពង្រឹងគុណវុឌ្ឍិគ្រូ
- ការប្រើប្រាស់ថវិកាប្រកបដោយតម្លាភាព
- ចុះឲ្យដល់ផ្ទះសិស្សឲ្យបានច្រើនតាមដែលអាចធ្វើបានពិសេសសិស្សមានបញ្ហាប្រឈមនានា
- កសប្បុរសជនជួយសិស្សក្រីក្រធ្វើឲ្យគាត់មិនបោះបង់ការសិក្សា
- ត្រូវតាមដាននិងដឹកឲ្យបានច្រើនពី នយោបាយរបស់អប់រំរបស់ក្រសួងសាមី និង នយោបាយអប់រំរបស់រដ្ឋាភិបាល
- ទាក់ទាញសហគមន៍ឲ្យជួយសាលាបានច្រើន ទាំងការអភិវឌ្ឍ ការជួយសិស្សរៀនយឺន សិស្សក្រីក្រ និងសិស្សបោះបង់
- ប្រតិភូកម្មទទួលបានជោគជ័យ
- ស្គាល់មិត្តរួមការងារឲ្យបានច្បាស់ទាំងចរិតនិងស្ថានភាពគ្រួសា
- ធ្វើខ្លួនជាមនុស្សល្ងង់សួរយោបល់គេឲ្យបានច្រើន
- ទោះមានរឿងអ្វីក៏ដោយមិនញាប់ញ័រ ភ្ញាក់ផ្អើលតក់ស្លុត បាក់ទឹកចិត្ត ភ័យខ្លាចឡើយ

៤. ទីតាំងភូមិសាស្ត្រ សាវតា ស្ថិតិ និង លទ្ធផលសិក្សារបស់សាលារៀន

វិទ្យាល័យពេជ្រចិន្តា មានទីតាំងស្ថិតនៅក្នុងភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង មានចម្ងាយ ១៣០ គីឡូម៉ែត្រ ពីទីរួមខេត្តបាត់ដំបង ជាប់ព្រំដែនថៃ។ បច្ចុប្បន្នសាលាមានផ្ទៃដីទំហំ (២២ ២០០) ម៉ែត្រក្រឡាដែលមាន (បណ្តោយ ១៥៨ម៉ែត្រ ទទឹង ១៤១ម៉ែត្រ)។ ទីតាំងវិទ្យាល័យពេជ្រចិន្តាបច្ចុប្បន្ន គឺជាអតីតសមរភូមិក្តៅជួរមុខរវាងកងទ័ពរដ្ឋាភិបាលកម្ពុជានិងក្រុមកម្ពុជាប្រជាធិបតេយ្យ និងជាតំបន់ចម្ការមីន។ ក្រោយសង្គ្រាមស៊ីវិលបានបញ្ចប់ និងបន្ទាប់ពីរដ្ឋាភិបាលបានធ្វើសមាហរណកម្មកងកម្លាំងយោធារួចមក ប្រជាពលរដ្ឋ សហគមន៍ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ បានមូលមតិគ្នាជាឯកច្ឆន្ទខិតខំប្រែក្លាយដីនេះ ឱ្យទៅជាថ្នាលបណ្តុះចំណេះដឹងសម្រាប់កូនចៅរបស់ពួកគាត់។ នៅឆ្នាំ២០០៣ សហគមន៍ និងអាជ្ញាធរ ដែនដី បានសម្រេចបង្កើតជា អនុវិទ្យាល័យភ្នំព្រឹក។ ដោយសារកំណើនសិស្សកាន់តែច្រើនឡើងៗ ក្រោយបញ្ចប់មធ្យមសិក្សាបឋមភូមិពិបាកធ្វើដំណើរ និង ទៅរកសាលារៀនដើម្បីបន្តការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ សហគមន៍ និងអាជ្ញាធរដែនដី បានសុំដំឡើង **អនុវិទ្យាល័យភ្នំព្រឹក** ទៅជា "**វិទ្យាល័យពេជ្រចិន្តា**"ឆ្នាំ២០០៧។ ក្នុងឆ្នាំសិក្សា ២០១៩-២០២០ នេះ វិទ្យាល័យពេជ្រចិន្តា មាន

សិស្សពីថ្នាក់ទី៧ ដល់ទី១២ សរុប ១២៥៩ នាក់ ស្រី ៦៥៦នាក់ មាន ២៤ថ្នាក់។ បុគ្គលិកអប់រំសរុប ៣៧ នាក់ ស្រី ១១ នាក់ ក្នុងនោះគ្រូទុតិយភូមិ ២០ នាក់ ស្រី ៥នាក់ និងគ្រូបឋមភូមិ ១៧នាក់ ស្រី ៦នាក់ ។ ស្ថិតិ៖ សិស្សសរុប ១២៦១នាក់ ស្រី ៦៥៨នាក់ ។

៥. ប្រព័ន្ធ និង រចនាសម្ព័ន្ធគ្រប់គ្រង ដឹកនាំរបស់សាលារៀន

១. សេចក្ដីប្រកាស សារាចរណែនាំ អនុក្រឹត្យ សេចក្ដីណែនាំផ្សេងៗ សេចក្ដីជូនដំណឹងផ្សេងៗ។

២. គោរពតាមសេចក្ដីណែនាំរបស់លិខិតបទដ្ឋាន។ពេលខ្លះក៏មានលក្ខណៈបត់បែនទៅតាមមជ្ឈដ្ឋាន។

៣. ជួបប្រទះឧបសគ្គមួយចំនួនដូចជា៖

- តឹងតែងពេក (ដំណោះស្រាយ បត់បែនទៅតាមភូមិសាស្រ្តសាលារៀន)

៤. បែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវ រៀបចំរចនាសម្ព័ន្ធទៅតាមគណកម្មការផ្សេងៗ ពណ៌នាអំពីតួនាទីផ្សេងៗ ប្រតិកូកម្ម

- ដើម្បីដឹងពីតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការអនុវត្ត
- មិនជ្រៀតជ្រែកតួនាទីភារកិច្ច
- ដំណើរការ ការងារមានភាពជឿទុកចិត្តគ្នា ហើយទាន់ពេលវេលា

៥. ជួបប្រទះឧបស្គ មិនទាន់យល់តួនាទីភារកិច្ចរៀងៗខ្លួ ជួបប្រទះឧបស្គ មិនទាន់យល់តួនាទី ភារកិច្ចរៀងៗខ្លួន មួយចំនួនថាមិនហ៊ានប្រើសិទ្ធរបស់ខ្លួន នៅមានភាពខ្មាស់អៀនខ្លាចគេមិនគោរព ដំណោះស្រាយ ជួយពន្យល់ណែនាំ និងលើកទឹកចិត្តទាំងអ្នកដឹកនាំ និងអ្នកដែលត្រូវគេដឹកនាំ

៦. យកលិទ្ធិប្រជាធិបតេយ្យជាធំ យកការប្រជុំដោះស្រាយជាធំ សហគមន៍មានសិទ្ធិសម្រេចការងារផ្សេងៗ បណ្ដុះក្រុមប្រឹក្សាយុវជនឲ្យមានភាពជាភាពជាអ្នកដឹកនាំ គ្រូបន្ទុកមានសិទ្ធិអំណាច។

៦. យុទ្ធសាស្រ្តអនុវត្តការងារ

១. ការចូលរួមរបស់សហគមន៍ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធ

២.ការធ្វើផែនការផ្ដេកទៅលើលទ្ធផលការសិក្សារបស់សិស្ស ផ្ដែកលើតំរូវការចាំបាច់

៣. រៀបចំកិច្ចតែងការបង្រៀន កម្មវិធីសិក្សា សៀវភៅសេវា ប្រជុះបច្ចេកទេស ជួយសិស្សរៀនយឺត បង្កើតក្លិបសិក្សា បង្កើតសម្ភារៈឧបទ្ទេស តាមដានការសិក្សាសិស្ស។

- រៀបរចនាសម្ព័ន្ធ តួនាទី ភារកិច្ច
- ការបែងចែភារកិច្ចរបស់បុគ្គលិក
- ក្នុងការអនុវត្តន៍ផែនការអេភិវឌ្ឍសាលា
- អនុវត្តផែនការសាលារៀន - ស្របតាមកិច្ចព្រមព្រៀង
- សាលារៀនស្អាត-បរិស្ថានសាលាល្អ មានអនាម័យ

- មិនលាក់បញ្ហា មិនបង្កើតបញ្ហា មិនពង្រីកបញ្ហាតែ
- ឆ្លើយតបព័ត៌មានទាន់ពេលវេលា និងដោះស្រាយ
- ជានាតម្លាភាពនៃការប្រើប្រាស់-ចាយបានផល
- វិភាគចំណុចខ្លាំង និង ចំណុចខ្សោយរបស់សាលារៀន
- អ្វីត្រូវធ្វើគឺថ្ងៃនេះ ដោះស្រាយថ្ងៃនេះ
- រៀបរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់បុគ្គលិក

៤. ក្នុងការអនុវត្តន៍ផែនការអភិវឌ្ឍសាលា

- អនុវត្តផែនការសាលារៀន - ស្របតាមកិច្ចព្រមព្រៀង
- សាលារៀនស្អាត-បរិស្ថានសាលាល្អ មានអនាម័យ
- មិនលាក់បញ្ហា មិនបង្កើតបញ្ហា មិនពង្រីកបញ្ហាតែ

៥. ឆ្លើយតបព័ត៌មានទាន់ពេលវេលា និងដោះស្រាយ

- ជានាតម្លាភាពនៃការប្រើប្រាស់-ចាយបានផល
- វិភាគចំណុចខ្លាំង និង ចំណុចខ្សោយរបស់សាលារៀន

៦. ជំរុញឲ្យទៅបន្តកាសិក្សា លើកទឹកចិត្ត ផ្ដល់ឱកាសឲ្យគ្រូបញ្ចេញសមត្ថភាពស្របតាមសញ្ញាបត្រ ដាក់ការងារឲ្យធ្វើស្របតាមឧបនិស្ស័យ

៧.ការរៀបចំផែនការថវិកា

- បានពិភាក្សាក្នុងអង្គភាព និងគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីរៀបចំផែនការថវិកាប្រចាំឆ្នាំ
- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា(៣ ឆ្នាំ២០២០-២០២៣)

៨. ការអនុវត្តផែនការថវិកា

- បានប្រជុំអនុម័តលើផែនការចំណូលចំណាយ ថវិកា
- មានសំណើសុំថវិកាពីលោកគ្រូ អ្នកគ្រូ
- ឯកសារទូទាត់
- ការប្រើប្រាស់ថវិកា ប្រកបដោយគណនេយ្យភាព តម្លាភាព យុត្តិធម៌
- បិទផ្សាយចំណូលចំណាយ
- ការរៀបចំបញ្ជីសារពើភ័ណ្ឌកត់ត្រាចំណូលចំណាយ និងរបាយការណ៍ហិរញ្ញវត្ថុ
- មានរបាយការណ៍ហិរញ្ញវត្ថុ
- បានកត់ត្រាចំណូល និងចំណាយ

៧. សាលាបានប្រជុំជាមួយ ភាគីពាក់ព័ន្ធ ប្រជុំបង្កើតផែនការ ៣ ឆ្នាំ ១ឆ្នាំ និង១ ត្រីមាស

- បានការបែងចែកភារកិច្ចរបស់បុគ្គលិក អនុវត្តន៍ផែនការអភិវឌ្ឍសាលា
- បានរៀបចំរចនាសម្ព័ន្ធតួនាទី និងភារកិច្ចថ្នាក់ដឹកនាំត្រឹមត្រូវ ក្រុមប្រឹក្សាយុវជន និងគណៈគ្រប់គ្រងសាលារៀន
- ការអនុវត្តវិន័យក្នុងសាលា ក្រោយពីប្រជុំពិភាក្សាជាមួយគណៈគ្រប់គ្រងសាលាលោកគ្រូអ្នកគ្រូនិងសហគមន៍) ការគោរពពេលធ្វើការ ទៀងទាត់ ជាងមុន សិស្សគោរពវិន័យបានល្អ
- បានបង្កើតគណៈគ្រប់គ្រងសាលា ដែលមានសមាសភាព៣១រូប ជួយអភិវឌ្ឍន៍សាលា
- រៀបចំក្រុមប្រឹក្សាយុវជន វិទ្យាល័យពេជ្រចិន្តា

៨. សាលាមានផែនការរៀបចំបរិស្ថានច្បាស់លាស់

- កំណត់ដាំកូនឈើ ឱ្យបាន១០០ដើមក្នុង១ឆ្នាំ
- រៀបចំអនាម័យ ឱ្យមានផាសុកភាព
- ក្នុងបរិវេនសាលាគ្មានធុងសំរាម
- រៀបចំកន្លែងលក់ចំណីអាហារ ប្រកបដោយអនាម័យ
- តាមបន្ទប់រៀននីមួយៗ រៀបចំប្រកបដោយភាពទាក់ទាញ មានរចនាសម្ព័ន្ធថ្នាក់រៀន និងមាន LCD Projector ចាប់ពីថ្នាក់ទី ១១ ដល់ ទី១២
- គ្រប់តុរបស់សិស្សមានបិទលេខទូរស័ព្ទអាណាព្យាបាលសម្រាប់ទាក់ទង
- អន្តេវាសិកដ្ឋានមានច្បាប់ និងរចនាសម្ព័ន្ធគ្រប់គ្រងត្រឹមត្រូវ

៩. មានគណកម្មការទទួលខុសត្រូវ មានបញ្ជីសារពើភណ្ឌ

១០. ប្រជុំវាយតម្លៃ មានសូចនាករវាយតម្លៃ មានផែនការវាយតម្លៃតាមការកំណត់

១១. ការទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ

១. សមាសភាពពីអាជ្ញាធរមូលដ្ឋាន សហគមន៍ មិត្តព្រះធម៌ សមាគមន៍អ្នកជិះកង់ សហគមន៍ជួយសិស្ស អតីតសិស្ស...

- ផ្តល់ទំនុកចិត្ត ពង្រឹងទំនាក់ទំនងល្អ សាមគ្គីភាព ជាមួយគណៈគ្រប់គ្រងសាលា មាតាបិតា សហគមន៍ អាជ្ញាធរ និងស្វែងរកអង្គការដៃគូ ដើម្បីអភិវឌ្ឍន៍
- មូលនិធិ របស់សហគមន៍ជួយសិស្សក្រីក្រ (២៣នាក់) រៀងរាល់ខែ
- អង្គការសម្រេចសុបិន្តកុមារកម្ពុជា ផ្តល់អាហារូបករណ៍ ដល់សិស្សក្រីក្រ ៩៧នាក់ និង ៣ នាក់នៅកម្រិតឧត្តមសិក្សា កសាងអន្តេវ ២ខ្នង ជួសជុល១ខ្នង ព្រមទាំងកុំព្យូទ័រ ៣១ គ្រឿង អតីតសិស្សបានជួយកុំព្យូទ័រ ចំនួន ១០គ្រឿង
- សហគមន៍បានកសាងបង្គន់ អនាម័យ ១ខ្នង ១០បន្ទប់ តបណ្តាញអគ្គិសនី៦០ វ៉ាត់
- ការជួយបង់សម្រាប់អង្គុយ ចំនួន ១២ឈុត

- មាតាបិតាសិស្ស ព្រះសង្ឃ ព្រមទាំង អាជ្ញាធរ ចូលរួមដាំដើមឈើ ក្នុងបរិវេនសាលា
- មាតាបិតាសិស្ស សហគមន៍ លោកគ្រូ អ្នកគ្រូ ជួយអំពូល សូឡា ៤៥គ្រឿង

១២. ឧបសគ្គ និង ដំណោះស្រាយ

- ការប្រជុំមិនឯកភាពគ្នានៅពេលធ្វើអ្វីមួយ
- ដំណោះស្រាយ បោះឆ្នោតសម្រេចយកសម្លេងភាគច្រើន

១៣. បញ្ហាប្រឈម ដំណោះស្រាយ និង គំនិតថ្មីៗ

១. ខ្វះគ្រូបង្រៀនទាំងពីរភូមិសិក្សា

- គ្រូមធ្យមសិក្សាបឋមភូមិ ៧នាក់ ភូមិ, ប្រវត្តិ ,រូប, គីមី ,គណិត ,ICT, សីលធម៌
- គ្រូទុតិយភូមិ ៥ នាក់ រូប ,ជីវៈ, ភូមិ ,ប្រវត្តិ, សីលធម៌
- បំពាក់ LCD មិនទាន់គ្រប់បន្ទប់
- អស់ថ្លៃភ្លើងច្រើន

២. ដំណោះស្រាយ

- យកគ្រូជួយបង្រៀន
- ទិញLCDបន្ថែមបណ្តើរៗ
- សុំថ្លៃភ្លើងខ្លះពីអាណាព្យាបាលសិស្ស

៣. គ្រូ និងសហគមន៍ ចុះជួបសិស្សនិង គ្រូ នៅតាមអនុវិទ្យាល័យចំណុះ

- បំពាក់ស្លាយ និង កាមេរ៉ា នៅគ្រប់បន្ទប់រៀន
- បង្កើតកន្លែងលក់ដូរ ចំណីអាហារប្រកបដោយផាសុកភាព
- បង្រៀនកុំព្យូទ័រសិស្សគ្រប់កម្រិតថ្នាក់
- លោកគ្រូ អ្នកគ្រូ និងសិស្សវិទ្យាល័យពេជ្រចិន្តា ជាគ្រូនិងសិស្សប្រកបដោយបច្ចេកវិទ្យា
- សហគមន៍បន្តគាំទ្រជួយដល់សិស្សក្រីក្រក្នុងវិទ្យាល័យ
- សិស្សដែលចេញពីសាលាវិទ្យាល័យពេជ្រចិន្តាត្រូវមានវិន័យ គុណធម៌ គុណភាព និងការច្នៃប្រឌិត។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប្រវត្តិរូបសង្ខេប

១. ព័ត៌មានផ្ទាល់ខ្លួន

- នាមត្រកូល និងនាមខ្លួន ៖ មិន សុនី ជាអក្សរឡាតាំង MIN SONY
- ភេទ ៖ ប្រុស
- ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៨០
- ទីកន្លែងកំណើត ៖ ភូមិ តាកោ ឃុំ តាកោ ស្រុក កំពង់លាវ ខេត្ត ព្រៃវែង
- តួនាទី ៖ នាយករង
- ក្របខ ណ្ឌ ៖ គ្រូកម្រិតឧត្ដម
- អង្គភាព ៖ វិទ្យាល័យពេជ្រចិន្តា
- ទីលំនៅបច្ចុប្បន្ន ៖ ទីលំនៅបច្ចុប្បន្ន ភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង
- ឪពុកឈ្មោះ ៖ ឃឹម សាង មុខរបរ កសិករ
- ម្ដាយឈ្មោះ ៖ សុខ លី មុខរបរ កសិករ
- លេខទូរស័ព្ទ ៖ ០៩២ ២៨៦ ២៧៦ ០៩០៥៥ ៦៦ ២២

២. ស្ថានភាពគ្រួសារ ៖ រៀបការហើយ

- ប្រពន្ធឈ្មោះ ៖ មឿង ចន្ធី មុខរបរ មន្ត្រីសាលាស្រុកភ្នំព្រឹក
- កូនទី១ ឈ្មោះ ៖ សាង សៀវថុង ភេទស្រី មុខរបរ សិស្ស
- កូនទី២ ឈ្មោះ ៖ សុនី សក្ខណា ភេទស្រី មុខរបរ សិស្ស

៣. ប្រវត្តិការសិក្សា

សាលាបឋមសិក្សាតាកោ	បឋមសិក្សា	១៩៨៨-១៩៩៤
អនុវិទ្យាល័យរោងដំរី	មធ្យមសិក្សាបឋមភូមិ	១៩៩៤-១៩៩៧
វិទ្យាល័យព្រះអង្គឌួង	មធ្យមសិក្សាទុតិយភូមិ	១៩៩៧-២០០០
គរុកោសល្យភូមិភាគហ៊ុនសែនព្រៃវែង	មធ្យមសិក្សាគរុកោសល្យ	២០០០-២០០២
សាកលវិទ្យាល័យឯកទេសនៃកម្ពុជា	បរិញ្ញាបត្រគណិតវិទ្យា	២០១០-២០១២
វិទ្យាស្ថានជាតិអប់រំ	គ្រូកម្រិតឧត្ដម(បរិញ្ញាបត្រ+១)	២០១៣-២០១៤
សាកលវិទ្យាល័យខេមរៈ	បរិញ្ញាបត្រជាន់ខ្ពស់គណិតវិទ្យា	២០១៦-២០១៨

៤. ប្រវត្តិការងារ

- ឆ្នាំ២០០២ដល់២០០៧ជាគ្រូបង្រៀនគណិត-រូប(ប្រធានក្រុមបច្ចេកទេស)នៅអនុវិទ្យាល័យពានរោង
- ឆ្នាំ២០០៧-២០១៦ជាគ្រូបង្រៀនគណិត-រូប-គីមី(អនុប្រក្រុមបច្ចេកទេស)វិទ្យាល័យពេជ្រចិន្តា

៥.ស្នាដៃដែលទទួលបានក្នុងការអប់រំ

- ប័ណ្ណសរសើររបស់ថ្នាក់ដឹកនាំមន្ទីរ
- ប័ណ្ណសរសើររបស់ថ្នាក់ដឹកនាំក្រសួង
- ប័ណ្ណសរសើររបស់ថ្នាក់ដឹកនាំខេត្ត
- ប្រកាសនីយបត្រពានរង្វាន់លេខ១ សម្តេចតេជោសែន
- ប្រកាសនីយបត្រពានរង្វាន់លេខ៣ សាលាស្អាត
- ជ័យលាភីលេខ៣ សាលាមេត្រីបរិស្ថាន(ក្រសួងបរិស្ថាន)
- ជ័យលាភីលេខ១ ការផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ

៦. បទពិសោធន៍ក្នុងការគ្រប់គ្រង និងដឹកនាំ

- បទពិសោធនៃការដឹកនាំគ្រប់គ្រងសាលារៀន
  - ឆ្នាំ២០០៧ ៖ ប្រកាសនាយករងវិទ្យាល័យពេជ្រចិន្តា
- បទពិសោធដែលជោជ័យ
  - ការស្រឡាញ់និងគោរពវិជ្ជាជីវៈជាអ្នកអប់រំ
  - ការគោរពពេលវេលា
  - ការរៀបចំផែនការច្បាស់លាស់
  - មានចក្ខុវិស័យច្បាស់លាស់
  - ការបែងចែងតួនាទីនិងភារៈកិច្ចច្បាស់លាស់
  - គោរពថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់
  - ធ្វើការជាមួយបេះដូងទន់ភ្លន់និងចេះបត់បែន
  - ស្រឡាញ់មិត្តរួមការងារនិងសិស្សដូចបងប្អូនបង្កើត
  - ដោយសារគ្រួសារជាគ្រូដូចគ្នាហើយយល់ការងារជាគ្រូជាទីប្រឹក្សានិងលើកទឹកចិត្តទុកពេលឲ្យនៅលាសាបានច្រើន
  - ជួយដោះស្រាយបញ្ហាសិស្ស គ្រូ មាតាបិតា ប្រជាពលរដ្ឋ ទាន់ពេលវេលានិងមិនប្រកាន់ពេលវេលា
  - ទទួលស្តាប់គំនិតអ្នកដទៃឲ្យបានច្រើន
  - មានយុត្តិធម៌ តម្លាភាព គណនេយ្យភាព មិនប្រកាន់បក្សពួក មិនស្តាប់ពាក្យញោះញ៉ុងអុចអាល
  - មានយុត្តិធម៌ តម្លាភាព គណនេយ្យភាព មិនប្រកាន់បក្សពួក មិនស្តាប់ពាក្យញោះញ៉ុងអុចអាល

- ពង្រឹងគុណវុឌ្ឍិគ្រូ
- ការប្រើប្រាស់ថវិកាប្រកបដោយតម្លាភាព

• បទពិសោធដែលលេចធ្លោ

- ទទួលបន្ទុករដ្ឋបាលចេះទុកឯកសាចេញចូល ចេះធ្វើផែនការ ចេះសរសេររបាយការណ៍
- ចុះឲ្យដល់ផ្ទះសិស្សឲ្យបានច្រើនតាមដែលអាចធ្វើបានពិសេសសិស្សមានបញ្ហាប្រឈមនានា
- រកសប្បុរសជនជួយសិស្សក្រីក្រធ្វើឲ្យគាត់មិនបោះបង់ការសិក្សា
- ត្រូវតាមដាននិងដឹកឲ្យបានច្រើនពី នយោបាយរបស់អប់រំរបស់ក្រសួងសាមី និង នយោបាយអប់រំរបស់រដ្ឋាភិបាល
- ទាក់ទាញសហគមន៍ឲ្យជួយសាលាបានច្រើន ទាំងការអភិវឌ្ឍ ការជួយសិស្សរៀនយឺន សិស្សក្រីក្រ និងសិស្សបោះបង់
- ស្គាល់មិត្តរួមការងារឲ្យបានច្បាស់ទាំងចរិតនិងស្ថានភាពគ្រួសារ
- ធ្វើខ្លួនជាមនុស្សល្ងង់សួរយោបល់គេឲ្យបានច្រើន

៧. លក្ខណៈសម្បត្តិ ឬ គុណសម្បត្តិ

• គុណវុឌ្ឍិ
  - បរិញ្ញាបត្រជាន់ខ្ពស់(គណិតវិទ្យា)២០១៨
  - បរិញ្ញាបត្រ(ណិតវិទ្យា)២០១១
  - គ្រូកម្រិតឧត្តមបរិញ្ញាបត្រ+១(គណិត-រូប)២០១៤
  - សញ្ញាបត្រមធ្យមសិក្សាគរុកោសល្យ១២+២(គណិត-រូប)២០០២
  - សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ២០០០
  - សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ១៩៩៧
• ចំណេះដឹងភាសាបរទេសITនិងផ្សេងៗទៀត
  - ភាសាបរទេសមធ្យម
  - ICTប្រើបាន
• អត្តចរិតអាកប្បកិរិយា
  - សុភាពរាបសា
  - ទន់ភ្លន់បត់បែន
  - រឹងមាំម៉ឺងម៉ាត់
  - មានសីធម៌ សុជីវធម៌(ខ្លួនឯង គ្រួសារ សង្គម)
  - រួសរាយរាក់ទាក់
• គោលដៅឬមហិច្ឆតា
  - ចង់ប្រែក្លាយសាលាក្លាយជាសាលាជំនាន់ថ្មី
  - សិស្សដែលចេញពីវិទ្យាល័យចេះភាសា ចេះICT

- សិស្ស និងគ្រូត្រូវមានជំនាញទន់ និងជំនាញរឹង
- ក្លាយជាសាលាគំរូរហូត
- ក្លាយជាសាលារបស់សហគមន៍

• រកប្រាក់ឧបត្ថម្ភគ្រូបន្ថែម

- ការទំនាក់ទំនង
  - ✓ មានទំនាក់ទល្អ ជាមួយសិស្ស គ្រូ សហគមន៍ មាតាបិតាសិស្ស អាជ្ញាធរ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់
  - ✓ ទាក់ទងអង្គការដៃគូឲ្យបានរលូន
- ការទទួលខុសត្រូវ
  - ✓ ហ៊ានទទួលខុសនិងត្រូវ
  - ✓ ស្តាប់មតិរិះគន់ស្ថាបនា
  - ✓ ការពារគ្នា
  - ✓ ហ៊ានប្រឈមមុខរាល់ទង្វើដែលខ្លួនបានធ្វើ

៨. **ទិសដៅទៅថ្ងៃអនាគត់**

- ➢ គ្រូ និងសហគមន៍ ចុះជួបសិស្សនិង គ្រូ នៅតាមបឋមសិក្សាចំណុះ
- ➢ គ្រូ និងសហគមន៍ ចុះជួបសិស្សនិង គ្រូ នៅតាមអនុវិទ្យាល័យចំណុះ
- ➢ កាត់បន្ថយអត្រាសិស្សបោះបង់ការសិក្សា ការត្រួតថ្នាក់នៅក្រោម ចំណុចដៅ
- ➢ បំពាក់ស្លាយ និង កាមេរ៉ា នៅគ្រប់បន្ទប់រៀន
- ➢ បង្កើតកន្លែងលក់ដូរ ចំណីអាហារប្រកបដោយផាសុកភាព
- ➢ បង្រៀនកុំព្យូទ័រសិស្សគ្រប់កម្រិតថ្នាក់
- ➢ លោកគ្រូ អ្នកគ្រូ និងសិស្សវិទ្យាល័យពេជ្រចិន្តា ជាគ្រូនិងសិស្សប្រកបដោយបច្ចេកវិទ្យា
- ➢ ប្តេជ្ញាជួយសិស្សឲ្យប្រឡងជាប់១០០%គ្រប់កម្រិតថ្នាក់
- ➢ សហគមន៍បន្តគាំទ្រជួយដល់សិស្សកីក្រក្នុងវិទ្យាល័យ
- ➢ សិស្សដែលចេញពីសាលាវិទ្យាល័យពេជ្រចិន្តាត្រូវមានវិន័យ គុណធម៌ គុណភាព និងការច្នៃប្រឌិត។
- ➢ បណ្តុះជំនាញមួយដល់សិស្ស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរ អប់រំ យុវជន និងកីឡា

បាត់ដំបង

វិទ្យាល័យ នេតយ៉ង់

បទពិសោធន៍ ការគ្រប់គ្រង និងដឹកនាំ វិទ្យាល័យ ពេជ្រចិន្តា

របស់ លោក អឿម ឃឿម

១. ជីវប្រវត្តិ និង ប្រវត្តិការងារ

ជីវប្រវត្តិ

- ខ្ញុំបាទ ឈ្មោះ **អឿម ឃឿម** (OEURM KHOEURM) ភេទ ប្រុស ថ្ងៃខែឆ្នាំ កំណើត ១៨ តុលា ១៩៨០
- ទីកន្លែងកំណើត ភូមិ ស្តី ឃុំ ព្រែកនរិន្ទ ស្រុក បាត់ដំបង ខេត្ត បាត់ដំបង ។
- ឪពុកឈ្មោះ សេង ឃី មុខរបរ ធ្វើស្រែ ម្តាយឈ្មោះ ព្រំ ហៀម មុខរបរ ស្លាប់
- បងប្អូនបង្កើត ចំនួន ៩នាក់ ស្រី ៤នាក់ ជាកូនទី ៥ ។
- ទីលំនៅបច្ចុប្បន្ន ភូមិស្តី ឃុំ ព្រែកនរិន្ទ ស្រុក ឯកភ្នំ ខេត្តបាត់ដំបង ។

ប្រវត្តិសិក្សា

- ១៩៨៦ ដល់ ១៩៩២ រៀននៅ សាលាបឋមសិក្សា ភូមិស្តី
- ១៩៩៣ ដល់ ១៩៩៦ រៀននៅ អនុវិទ្យាល័យ ព្រែកនរិន្ទ
- ១៩៩៧ ដល់ ២០០០ រៀននៅ វិទ្យាល័យស្រុកឯកភ្នំ
- ២០០៥ ដល់ ២០០៨ រៀននៅសាកលវិទ្យាល័យ ខេមរៈ បាត់ដំបង (បរិញ្ញាបត្រ គណិតវិទ្យា)
- ២០០៩ រៀននៅ វិទ្យាស្ថានជាតិអប់រំ (NIE) ឯកទេស គណិតវិទ្យា
- ២០១២ ដល់២០១៦ រៀននៅសាកលវិទ្យាល័យបៀលប្រាយ បាត់ដំបង(បរិញ្ញាបត្រអង់គ្លេស)
- ២០១៦ ដល់២០១៨ រៀននៅសាកលវិទ្យាល័យ ខេមរ បាតើដំបង (អនុបណ្ឌិត គណិតវិទ្យា)
- ២០១៨ ដល់បច្ចុប្បន្ន កំពុងបន្តការសិក្សា នៅភូមិន្ទភ្នំពេញ (ភាពជាអ្នកដឹកនាំ)

ប្រវត្តិការងារ

- ថ្ងៃខែឆ្នាំចូលបំរើការងារ ០១ ១០ ២០០២
- ២០០២ ដល់ ២០០៨ ជាគ្រូកម្រិតមូលដ្ឋាន បង្រៀននៅ អនុ ភ្នំព្រឹក ឯកទេស គណិតវិទ្យា រូបវិទ្យា

- ២០០៩ ដល់ ២០១៦ជាគ្រូកម្រិតឧត្តម ឯកទេសគណិត នៅវិទ្យាល័យពេជ្រចិន្តា ប្រធានក្រុមបច្ចេកទេស
- ២០១៧ ដល់២០១៩ ជានាយករងនៅវិទ្យាល័យ ពេជ្រចិន្តា បានធ្វើឲ្យវិទ្យាល័យពេជ្រចិន្តា ទទួលបានជ័យជំនះលេខ១ទូទាំងប្រទេស ផ្នែកសេវាសាធារណៈគំរូ លើវិស័យអប់រំ
- ២០១៩ ដល់បច្ចុប្បន្ន ជានាយកវិទ្យាល័យ នេតយ៉ង់

ស្នាដៃសំខាន់ៗក្នុងការដឹកនាំ និងគ្រប់គ្រង

ក្រោយពីបញ្ចប់ការសិក្សានៅវិទ្យាល័យ ស្រុកឯកភ្នំ ខេត្តបាត់ដំបង ខ្ញុំបាទប្រឡងជាប់គ្រូកម្រិតមូលដ្ឋាន ឯកទេសគណិតវិទ្យា។ នៅឆ្នាំ២០០២ ខ្ញុំបាទបានធ្វើជាគ្រូបង្រៀន នៅអនុវិទ្យាល័យភ្នំព្រឹក។ ក្រោមការដឹកនាំដ៏ឆ្លាតវៃរបស់សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន ប្រទេសកម្ពុជាមានការរីកចំរើន គ្រប់វិស័យ ជាពិសេស ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដើម្បីបម្រើភាពងាយស្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ ដែលជាហេតុធ្វើឲ្យរូបខ្ញុំបាទសម្រេចចិត្តបន្តការសិក្សា ថ្នាក់បរិញ្ញាបត្រ រហូតដល់ឆ្នាំ២០០៩ ខ្ញុំបានក្លាយជាគ្រូកម្រិតឧត្តម បរិញ្ញាបត្រ +១ ឯកទេសគណិតវិទ្យា។ នៅឆ្នាំសិក្សា២០១៣ ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកំណែទម្រង់លើការប្រឡងមធ្យមសិក្សាទុតិយភូមិ ខ្ញុំបាទបានធ្វើជា**គ្រូ ស្ម័គ្រចិត្ត** បង្រៀនត្រៀមប្រឡងសញ្ញាបត្រ ទុតិយភូមិ លើកទី២ នៅឆ្នាំសិក្សា ២០១៣ ២០១៤ របស់ **សសយក ខេត្តបាត់ដំបង** និងជាគ្រូបង្គោល លើមុខវិជ្ជាគណិតវិទ្យា ដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាល រយៈពេល ២ថ្ងៃ នៅ NIE នៅឆ្នាំ២០១៤ ។

នៅឆ្នាំសិក្សា ២០១៨ ២០១៩ ខ្ញុំបាទ និងលោកគ្រូអ្នកគ្រូ វិទ្យាល័យពេជ្រចិន្តា បានកៀរគមាតាបិតាសិស្សឲ្យចូលរួមតាមដាន និងលើកទឹកចិត្ត លើការសិក្សារបស់កូនៗរបស់ពួកគាត់ (អាណាព្យាបាលសិស្សមានការចូលរួមយ៉ាងច្រើន មិនគួរឲ្យនឹកស្មាន ខ្ញុំ និងលោកគ្រូអ្នកគ្រូ សប្បាយ និងរំភើបចិត្តណាស់) ។

- បង្កើតគណៈកម្មការគ្រប់គ្រងសាលា បានជោគជ័យ ដោយមានការចូលរួម រហូតដល់ ពួកគាត់ស្វែងរកថវិកាជាង១ម៉ឺន កសាង បន្ទប់ទឹក ។
- បង្កើតបរិស្ថានសាលាគ្មានផុងសម្រាម
- បណ្តុះឥរិយាបថសិស្ស (សីលធម៌)
- សាហការណ៍ជាមួយ សហគមន៍ លោកគ្រូ អ្នកគ្រូ នាយករង មិន សុនី និង អាជ្ញាធរ ធ្វើឲ្យវិទ្យាល័យពេជ្រចិន្តា ទទួលបានមេដាយមាស លើសេវាសាធារណៈគំរូ លើវិស័យអប់រំ នៅឆ្នាំ២០១៩។

វិធីសាស្ត្រគ្រប់គ្រង និងដឹកនាំ

- បែងចែកតួនាទី និងភារកិច្ច ឲ្យបានច្បាស់
- បង្កើតរចនាសម្ព័ន្ធ ការគ្រប់គ្រងនិងដឹកនាំ ក្រោយពីបែងចែកតួនាទី និងភារកិច្ចរួច

- បង្កើតចក្ខុវិស័យសាលារៀនរួមគ្នាជាមួយ គណៈគ្រប់គ្រងសាលា នាយក និងអ្នកពាក់ព័ន្ធ ដោយផ្អែកលើធនធានដែលមានស្រាប់ និងគោលនយោបាយរបស់ក្រសួងអប់រំ
- បណ្ដុះធនធានមនុស្ស ដោយលើកទឹកចិត្តដល់បុគ្គលិក និងសិស្សានុសិស្ស
- ធ្វើផែនការសកម្មភាព បង្រៀននិងរៀនជាមួយ អ្នកពាក់ព័ន្ធ
- ត្រូវយល់ច្បាស់ពីគោលនយោបាយអប់រំ និងរាជរដ្ឋាភិបាល
- ត្រូវធ្វើផែនការត្រួតពិនិត្យ និងវាយតម្លៃ ដោយផ្អែកលើ លទ្ធផល
- ប្រកាន់ភ្ជាប់ នៅតម្លាភាព និងគណនេយ្យភាពក្នុងការដឹកនាំ និងគ្រប់គ្រង
- មានគំនិតច្នៃប្រឌិត ក្នុងដោះស្រាយបញ្ហាប្រឈម
- មានទឹកចិត្តព្រហ្មវិហារធរ ជាមួយបុគ្គលិក
- ត្រូវចេះប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា
- ត្រូវចេះដឹកនាំបុគ្គលិកឲ្យចេះសិក្សាស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍សមត្ថភាព ឲ្យទាន់បច្ចេកវិទ្យា
- មានសមត្ថភាពលើកការគ្រោងថវិកា អភិវឌ្ឍន៍សាលា

ទីតាំងភូមិសាស្ត្រ និងសាវតារ វិទ្យាល័យ ពេជ្រចិន្តា

វិទ្យាល័យ ពេជ្រចិន្តា មានទីតាំង ស្ថិត នៅក្នុងភូមិ ភ្នំតូច ឃុំ ពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្ត បាត់ដំបង ខាងកើតជាប់ នឹង ស្រុកបវេល ខាងជើង ជាប់នឹងស្រុកសំពៅ ខាងត្បូងជាប់នឹង ស្រុកកំរៀង និងខាងលិចជាប់នឹងប្រទេសថៃ ។ វិទ្យាល័យពេជ្រចិន្តា មានផ្ទៃដី ២២៥៣០ ម៉ែត្រការេ នៅឆ្នាំ២០០៣ វិទ្យាល័យនេះ គឺជាអនុវិទ្យាល័យភ្នំព្រឹក ដែលមានសិស្ស ចំនួន ១៧៥នាក់ និងគ្រូចំនួន ៩នាក់ ស្រី ៤ នាក់ ដែលគ្រប់គ្រងដោយលោកនាយក ឯក ប៉ន ។ នៅឆ្នាំ២០០៧ កំនើនសិស្សកាន់តែកើនឡើង និងដើម្បីទប់ស្កាត់ការបោះបង់ការសិក្សាមន្ទីរអប់រំ យុវជន និងកីឡា បានសម្រេចប្តូរពី អនុវិទ្យាល័យ ភ្នំព្រឹក ទៅជាវិទ្យាល័យ ពេជ្រចិន្តា ។

២. ការរៀបចំប្រព័ន្ធ និង រចនាសម្ព័ន្ធគ្រប់គ្រងដឹកនាំរបស់សាលារៀន វិទ្យាល័យ ពេជ្រចិន្តា

ក្រសួងអប់រំ យុវជន និងកីឡាបានកែទម្រង់ ជាចន្រើនចំនុចដើម្បីអភិវឌ្ឍន៍សាលារៀន ស្របតាមគោលនិយោបាយ របស់រដ្ឋាភិបាល សាលាវិទ្យាល័យ ពេជ្រចិន្តា បានអនុវត្តន៍តាមលិខិតគិយុត្ត ជាច្រើនក្នុងដំណើរការអភិវឌ្ឍសាលារៀន ៖

- លិខិតលេខ ២៧ អយក សណន ស្តីអំពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល
- ការគ្រប់គ្រងតាមសាលារៀន នៅមធ្យមសិក្សា ដែលមាន ៩ ស្តង់ដា
- លិខិតស្តីអំពីសាលាកុមារមេត្រី

ការអនុវត្តតាមលិខិតបទដ្ឋាន

គ្រប់លិខិតបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញតាម គ្រឹះស្ថានអប់រំ ក្នុងគោលបំណង អភិវឌ្ឍន៍ធនធានមនុស្ស ឲ្យមានប្រសិទ្ធភាព ស្របពេលដែលមានការរីកចម្រើននៃបច្ចេកវិទ្យា ។

ដូចនេះតាមគ្រឹះស្ថានមធ្យមសិក្សាត្រូវរៀនធ្វើការផ្សព្វផ្សាយ និងអនុវត្តន៍តាមភាព ជាក់ស្តែងតាមអង្គភាព ក្នុងន័យបម្រើ ការរៀន និងបង្រៀន ដើម្បីទទួលគុណភាពខ្ពស់ ប្រកបដោយ អនុត្តរភាព នៃការអប់រំ ។

បញ្ហាប្រឈមនៃការអនុវត្តន៍លិខិតបទដ្ឋានគតិយុត្តិ

- របៀបគ្រប់គ្រងបុគ្គលិក និងសិស្ស
- ការមិនចូលរួមរវាង គ្រូ និងគ្រូ គ្រូ និងគណៈគ្រប់គ្រង នាយក និងសហគមន៍
- បង្កើនការគ្រប់គ្រង និងដឹកនាំ ច្រើន

ដំណោះស្រាយពេលអនុវត្តន៍លិខិតបទដ្ឋាន ស្តីអំពីការគ្រប់គ្រងតាមសាលារៀន (SBM)

- ការបង្កើតសហគមន៍ ឬ គណៈកម្មគ្រប់គ្រងទទួលបានជោគជ័យ
- ពង្រឹងគុណភាពអប់រំ (ប្រឡងតេស្ត)
- បង្កើតក្លឹមសិស្សជួយសិស្ស និងជួយសិស្សរៀនយឺត
- ពង្រឹការងាររដ្ឋបាលនិងគុណគ្រប់គ្រងធនធានមនុស្ស
- បរិស្ថាន និងអនាម័យ (សុខភាពសិស្ស)
- បណ្តុះជំនាញទន់ ដល់សិស្ស
- ការគ្រប់គ្រងសាលាតាមបែបបច្ចេកវិទ្យា
- ពង្រឹងទំនាកទំនងរវាងសាលានិងអ្នកពាក់ព័ន្ធ

ដើម្បីគ្រប់គ្រងសាលាបានល្អ គណៈគ្រប់គ្រងបានរៀបចំប្រព័ន្ធគ្រប់គ្រងដឹកនាំ តួនាទី និងភារកិច្ច ដូចជា:

- បានរៀបចំប្រពន្ធ័គ្រប់គ្រងដោយផ្អែកលើលទ្ធផល (ការរៀន និង បង្រៀន)
- បានរៀបចំហេដ្ឋារចនាសម្ព័ន្ធ គ្រប់គ្រងនិងដឹកនាំ
- បង្កើតចក្ខុវិស័យ សាលារៀន ដោយពឹងផ្អែកលើធនធាន ដែលមាន ស្រាប់ ផ្អែកលើទីតាំងភូមិសាស្រ្ត និង ការរីកចម្រើនបច្ចេកវិទ្យានាពេលបច្ចុប្បន្ន
- រៀបចំអ្នកដែលត្រូវធ្វើបេសសក្ករបស់សាលា
- បង្កើតគណៈកម្មការទទួលបន្ទប់តាមជំនាញ និងសមត្ថភាព (គណៈកម្មការ បរិស្ថាន ក្រុមប្រឹក្សាវិន័យ បដិសណ្ឋារកិច្ច)
- បង្កើតគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃ

- ការលើកទឹកចិត្ត

ការច្នៃប្រឌិតកម្រិតសាលារៀន ដើម្បីឲ្យបានល្អក្នុងការគ្រប់គ្រង ដឹកនាំ តួនាទី និងភារកិច្ច មាន ដូចជា:

- បាររៀបចំការត្រួតពិនិត្យវាយតម្លៃ លើការសិក្សា ការបង្រៀន និងអភិវឌ្ឍន៍សាលា ពី សហគមន៍ អង្គាធរ
- បង្កើតគណៈកម្មការគ្រប់គ្រងសំរាម (សាលារៀនគ្មានធុងសម្រាម)
- បង្កើតគណៈកម្មការ បដិសណ្ឋារកិច្ច
- បង្កើនទំនាក់ទំនង សាលារៀន ជាមួយ មាតាបិតាសិស្សក្នុងមួយខែម្តង និងអង្គការ នានា ដើម្បីងាយស្រួលក្នុងការអភិវឌ្ឍន៍សាលារៀន
- បណ្តុះ ជំនាញទន់ដល់សិស្ស
- បង្កើតកម្មវិធីការអប់រំសិស្សផ្សារភ្ជាប់និងសាសនា
- បានរៀបចំវាទិការ សាធារណៈ ដែលមានការចូលរួម ពី មាតាបិតាសិស្ស និងលោកគ្រូអ្នកគ្រូ និងសិស្សតាមកម្រិតថ្នាក់

៣. យុទ្ធសាស្ត្រអនុវត្តការងារនៅ វិទ្យាល័យ ពេជ្រចិន្តា

ចាប់តាំងពីវិទ្យាល័យពេជ្រចិន្តាមានទីតាំងពិតប្រាកដមក គណៈគ្រប់គ្រងសាលានិងលោកគ្រូអ្នកគ្រូ មាននាំកៀរគរសហគមន៍ និងមានតាបិតាសិស្ស ពង្រីកដី និងសាងសងសាលា ពីរជាន់ ១២បន្ទប់ (បាន៥០% ត្រូវបានសម្តេចតេជោ ហ៊ុន សែន ជួយសាងសងបង្ហើយ)។ បន្ទាប់មក មន្ទីរអប់រំ សហការជាមួយ ការិយាល័យអប់រំ នាយកសាលា បានទំនាក់ទំនាក់ជាមួយអង្គការសម្រេចសុបិន្តកុមារ បានសាងសង កន្លែងស្នាក់នៅ របស់សិស្សចំនួន ២ខ្នង ដោយសាលានិងអង្គការនេះមានការជាមួយគ្នាមានទំនាកទំនងល្អ អង្គការនេះបានផ្តល់ កុំព្យូទ័រ ជាច្រើនគ្រឿង ដើម្បីពង្រឹងគុណភាពសិក្សា។ លើកពីនេះទៅទៀត ដោយអង្គការមើលពីគុណភាពការអប់រំនៅទីនេះ ពួកគាត់បានផ្តល់អាហារូបករណ៍ដល់សិស្សនៅមធ្យសិក្សាក្នុងមួយនាក់ ៦០ដុល្លាក្នុងមួយខែ ១៦នាក់ក្នុងឆ្នាំសិក្សាដល់សិស្សដែលមានជីវភាពខ្សត់ខ្សោយ។ ដោយមើលឃើញទុក្ខលំបាករបស់សិស្ស គណៈគ្របគ្រងសាលាបានសហការជាមួយគណៈកម្មការគ្រប់គ្រង់សាលា បានសម្រេចកសាងបន្ទប់ទឹក ដែលចំណាយ ថវិកាជាងមួយម៉ឺនដុល្លា ថវិកាទាំងនេះបានពីការកៀរគរ ពីអង្គាធរ មានតាបិតាសិស្ស ។

២-ចូលរួមកសាងចក្ខុវិស័យ បេសកកម្ម និងផែនការសកម្មភាពដើម្បីអភិវឌ្ឍអង្គភាព

៣-សហការចូលរួមចលនាផ្សព្វផ្សាយដល់ឪពុកម្តាយ កុមារ យុវជនអោយនាំកូនចូលសាលារៀន

៤-សហការរៀនចំបង្កើតក្រុមបច្ចេកទេសបង្រៀនសម្រាប់អង្គភាព

៥-ពិនិត្យរៀបចំសិស្សតាមថ្នាក់នីមួយៗ

៦-រៀបចំសេចក្តីព្រាងកម្មវិធីសិក្សាតាមមុខវិជ្ជា និងកាលវិភាគជូននាយកដើម្បី ពិនិត្យនិង សម្រេច

៧-រៀបចំកាលវិភាគនិងគ្រប់គ្រងសកម្មភាពសម្រាប់ការងារបណ្ណាល័យ វិជ្ជាមេផ្ទះ រោងជាង កីឡា

៨-សហការរៀបចំបញ្ជីឈ្មោះសិស្សតាមកម្រិតថ្នាក់ និង ភេទ

៩-សហការប្រមូលសិស្សអោយចូលរៀននៅដើមឆ្នាំសិក្សាចែកពាក្យ ទទួលពាក្យ និងចុះឈ្មោះសិស្ស

១០-រៀបចំកម្មវិធីប្រជុំក្រុមបច្ចេកទេស និងពិនិត្យកិច្ចតែងការបង្រៀនរបស់គ្រូ

១១-ពិនិត្យនិងរៀបចំកសាងសម្ភារះឧបទេសតាមមុខវិជ្ជា និងការអភិវឌ្ឍបណ្ណាល័យ

១២-ចូលរួមរៀបចំវិញ្ញាសារប្រលងផ្សេងៗ និងចូលរួមពិនិត្យការប្រលងឆមាសរបស់សាលា

១៣-បូកសរុបរបាយការណ៍បច្ចេកទេស តាមខែ ត្រីមាស ឆមាសនិង ប្រចាំឆ្នាំ

១៤-អធិការកិច្ចវាយតម្លៃការងារបង្រៀន និងរៀនរបស់សិស្ស

១៥-ពិគ្រោះយោបល់ការងារជាមួយនាយក និងគណៈកម្មការផ្សេងៗនិងប្រជុំស្តាប់ការណែនាំការងារ

១៦-ចូលរួមដោះស្រាយបញ្ហារផ្សេងៗដែលកើតមានចំពោះអង្គភាព

១៧-បំពេញភារកិច្ចចាំបាច់តាមការចាប់តាំងរបស់ថ្នាក់លើ

១៨-ទំនាក់ទំនង និងចូលរួមការងារជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់

១៩-ចូលរួមបុណ្យជាតិផ្សេងៗនិងទស្សនៈកិច្ចឆ្លងខេត្តជាមួយក្រុមគម្រោងនានានិងកម្មវិធីសុខុមាលភាពសង្គមនិងមនុស្សធម៌

ថ្ងៃ៣កើត ខែចេត្រ ឆ្នាំកុរឯកស័ក ព.ស២៥៦៣

ព្រៃជ្រូចិន្តាថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩

នាយក

ប៊ិច ឈឿត

ភារកិច្ចគណនេយ្យ

- រៀបចំផែនការថវិកា
- រៀបចំលិខិតស្នាមទាក់ទងចំណូលចំណាយរបស់សាលារៀន
- ធ្វើតុល្យភាពចំណូលនិងចំណាយ
- រៀបចំបញ្ជិកាគណនេយ្យ
- ធ្វើបញ្ជីបញ្ចូលនិង បញ្ចេញ សម្ភារ
- ធ្វើរបាយការតុល្យភាពចំណូលចំណាយ
- បើកសាច់ប្រាក់ពីធនាគារនិងដល់អ្នកស្នើសុំក្រោយពីនាយកសម្រេចរួច
-

ថ្ងៃ៣កើតខែចេត្រ ឆ្នាំកុរឯកស័ក ព.ស២៥៦៣

ពេជ្រចិន្តា ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩

នាយក

ម៉ិច ឈឿត

ភារកិច្ចនាយករងទទួលបន្ទុកការងារកុមារ យុវជន កីឡានិងសិល្បៈ

ជាជំនួយការលើការងារកុមារ យុវជនកីឡានិងសិល្បៈរបស់នាយកសាលាហើយមានភារកិច្ចនិងទទួលខុសត្រូវដូចខាងក្រោម៖

១-ទទួលខុសត្រូវលើការងារកុមារ យុវជន កីឡានិងសិល្បៈរបស់អង្គភាព

២-ចូលរួមចក្ខុវិស័យ បេសកកម្ម និងផែនការសកម្មភាពដើម្បីអភិវឌ្ឍអង្គភាព

៣-សហការចូលរួមចលនាផ្សព្វផ្សាយដល់ឪពុកម្តាយ កុមារ យុវជនអោយនាំកូនមកចូលរៀន

៤-រៀបចំរចនាសម្ព័ន្ធក្រុមប្រឹក្សាកុមារ យុវជន ប្រចាំអង្គភាព

៥-បង្កើតសាខាកុមារ យុវជនតាមថ្នាក់រៀននិង អនុសាខា

៦-រៀបចំជ្រើសរើសតំណាង កុមារ យុវជន ប្រចាំឆ្នាំ

៧-គ្រប់គ្រងស្ថិតិកុមារ យុវជន

៨-ពិនិត្យតាមដាន និងជំរុញអោយលោកគ្រូ អ្នកគ្រូណែនាំកុមារ យុវជនអោយយកចិត្តទុកដាក់លើការងារយុវជនកុមារ យុវជន និងកាយសម្ព័ន

៩-រៀបចំកម្មវិធីអប់រំ មិត្តជួយមិត្ត ចលនាបីល្អ ជួយដល់កុមារ យុវជន

១០-ណែនាំកុមារ យុវជនអោយចេះដាំដំណាំ ចេះសម្អាតបរិស្ថានក្នុង និងក្រៅបរិវេណអង្គភាព

១១-ណែនាំកុមារ យុវជនអោយស្គាល់ការងារនិងចូលរួមការងារកាកបាទក្រហម កាយរិទ្ធ

១២-បង្ហាត់ រឺបណ្តុះបណ្តាលកុមារ យុវជនអោយចេះជួយសង្គ្រោះអ្នកដែលរងគ្រោះថ្នាក់ផ្សេងៗ

១៣-ណែនាំកុមារ យុវជនអោយជួយការពារទ្រព្យសម្បត្តិអង្គភាព

១៤-រៀបចំទីលានហ្វឹកហាត់និង ទីលានប្រគួតកីឡា

១៥-រៀនចំកម្មវិធីប្រគួតកីឡាថ្នាក់សាលា កម្រង ដើម្បីជ្រើសរើសជើងឯក

១៦-ដឹកនាំសកម្មភាពកីឡា សិល្បៈ រោងជាង កសិកម្ម ក្នុងនិងក្រៅអង្គភាព

១៧-ចូលរួមដោះស្រាយបញ្ហាផ្សេងៗដែលកើតមានចំពោះអង្គភាព

១៨-រៀបចំរបាយកាណ៍ការងារកុមារ យុវជននិងកីឡា សិល្ប:តាមខែត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយក

១៩ -ចូលរួមប្រជុំទទួលផែនការការងារ រឺស្តាប់ការណែនាំការងារពីនាយក រឺគណៈកម្មការការងារ

២០-ចូលរួមរៀបចំវិញ្ញាសា និងការប្រលងនានា

២១-ពិគ្រោះយោបល់ការងារជាមួយនាយក និងគណៈកម្មការរបស់អង្គភាព

២២-ចូលរួមការងារផ្សេងៗរបស់សហគម៍

២៣-បំពេញភារកិច្ចចាំបាច់តាមការចាត់តាំងរបស់ថ្នាក់លើ

២៤-ទំនាក់ទំនងង និងចូលរួមការងារជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់

២៥-ចូលរួមបុណ្យជាតិ ផ្សេងៗនិងទស្សនះកិច្ចឆ្លងខេត្តជាមួយក្រុមគម្រោងនានានិងកម្មវិធី សុខុមាលភាពសង្គម និងមនុស្សធម៌។

ថ្ងៃ៣កើត ខែចេត្រឆ្នាំកុរឯកស័ក ព.ស២៥៦៣

ពេជ្រចិន្តា ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩

នាយក

ប៊ិច ឈឿត

ភារកិច្ចបណ្ណារក្ស

១.រៀបចំនិងគ្រប់គ្រងបណ្ណាល័យទូដាក់សៀវភៅ

២.បង្កលក្ខណាងាយស្រួលដល់គ្រូសិស្សក្នុងការអានឯកសារផ្សេងៗ

៣.ថ្មើសៀវភៅសារពើភ័ណ្ឌ

៤.ធ្វើគម្រោងចំណាយលើការទិញសៀវភៅ ជួសជុល និងសម្ភារៈកនុងបណ្ណាល័យ

៥.ទទួលខុសត្រូវលើការទុកដាក់សៀវភៅនិងសម្ភារៈឧបទេស

៦.រៀបចំកាលវិភាគឲ្យសិស្សចូលអានសៀវភៅនិងសហការជាមួយគ្រូបន្ទប់ឲ្យសិស្សស្រាវជ្រាវ

៧.ចាត់តាំងការសុំសៀភៅនិងការអនុវត្តបទបញ្ជាបណ្ណាល័យ

៨.ការផ្សព្វផ្សាយការអានសៀវភៅដល់សិស្សិគ្រប់កម្រិតអាយុដើម្បីទទួលបានទិដ្ឋភាពបី

  ១.ការសិក្សាអស់មួយជីវិត

  ២.សកម្មភាពទំនាក់ទំនងក្នុងសហគមន៍

  ៣.ភាពជោគជ័យនៃវប្បធម៌ប្រពៃណី

៩.ធ្វើឲ្យសិស្សទទួលបានសេវានៃការអានពេញចិត្តសប្បាយរីករាយស្រឡាញ់ការអាន

ថ្ងៃ៣កើតខែចេត្រ ឆ្នាំកុរឯកស័ក ព.ស២៥៦៣

ពេញព្រះចិន្តា ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩

នាយក

ប៊ិច ឈឿត

ភារកិច្ចលេខា

១ ជាសេនាធិការឲ្យនាយក

២ នៅប្រចាំការសាលារៀនពេលម៉ោងធ្វើការ

៣ ចូលរួមរៀបចំសកម្មភាពអភិវឌ្ឍសាលា

៤ ចែកពាក្យ ទទួលពាក្យសិស្ស

៥ រៀបចំទុកដាក់ឯកសារនិង បញ្ជីផ្សេងៗ

៦ ទទួលខុសត្រូវលើការងារលិខិតស្នាម

៧ ទំនាក់ទំនងជាមួយមន្ត្រីអប់រំ គ្រូបង្រៀនក្នុងសាលារៀន

៨ រៀបចំរបាយណ៍ការផ្សេងៗ

៩ ទទួលខុសត្រូវលើការទុកដាក់លិខិតបទដ្ឋានគតិយុត្ត ឯកសាររដ្ឋបាលផ្សេងៗ

១០ រៀបចំទីចាត់ការឲ្យមានសោភណ្ឌភាព

១១ តាមដានវត្តមានគ្រូសិស្សជាប្រចាំ

១២ មើលការថែទាំទ្រព្យសម្បត្តិសាលា

១៣ ពិគ្រោះការងារចាំបាច់ជាមួយនាយក នាយករងសាលា

១៤ ប្រមូលស្ថិតិ និងពិន្ទុសិស្សពីគ្រូបន្ទុក

១៥ ទទួលខុសត្រូវកត់ត្រាលិខិតចេញ ចូលគ្រប់ប្រភេទ

១៦ កត់ត្រាកំណត់ហេតុ រៀបចំរបាយការណ៍ផ្សេងៗ

១៧ បញ្ជូនលិខិតទៅឲ្យពាក់ព័ន្ធ

១៨ រៀបចាំឯកសារផ្សេងៗ និងទីកន្លែងពេលប្រជុំ

២០ ទទួលខុសត្រូវលើការងារពិធីការ

២១ សរសេរនិងបិទផ្សាយសេចក្តីជូនដំណឹងផ្សេងៗ

២២ ជាអ្នកផ្តល់ព័ត៌មានដល់ថ្នាកើដឹកនាំ និងភ្ញៀវ

២៣ ទំនាក់ទំនងជាមួយមាតាបិតា អាណាពញ្ញាបាលសិស្សអំពីការសិក្សារបស់កូន

២៤ បំពេញភារកិច្ចចាំបាច់តាមការចាត់តាំងថ្នាក់លើ

២៥ ចូលរួមគ្រប់សកម្មភាពសង្គម

ថ្ងៃ៣កើតខែចេត្រ ឆ្នាំកុរឯកស័ក ព.ស២៥៦៣

ពេជ្រចិន្តា ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩

នាយក

ប៊ិច ឈឿត

ភារកិច្ចរបស់គ្រូបន្ទប់ថ្នាក់

១ ជាអ្នកស្គាល់សុខទុក្ខគ្រប់បែបយ៉ាងរបស់សិស្ស
២ តួនាទីជាអ្នកបង្រៀនផងនិងទទួលបន្ទុកថ្នាក់ផង
៣ គ្រប់គ្រងរៀបចំថ្នាក់ រៀបចំរចនាសម្ព័ន្ធថ្នាក់ តារាងទាំង៩
៤ ផ្តល់ព័ត៌មានដល់មាបិតាអណាព្យាបាលសិស្ស
៥ គ្រប់គ្រងសិស្សក្នុងការចូលរួមសកម្មភាពសង្គម
៦ ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ
៧ ជួយសិស្សរៀនយឺត
៨ ស្រង់ បូកពិន្ទុ សរសេរ សៀវភៅតាមដាន និងសិក្ខាគារិត

ថ្ងៃ៣កើតខែចេត្រ ឆ្នាំកុរឯកស័ក ព.ស២៥៦៣
ពេជ្រចិន្ដា ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩
នាយក

ម៉ិច ឈឿត

ឧបសម្ព័ន្ធ ៥៖ ការកែលម្អបរិស្ថានអង្គភាព

លិខិតបង្គាប់ការស្តីពីការបែងចែកតួនាទី ភារកិច្ចក្រុមប្រឹក្សាយុវជន និងកុមារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំយុវជន និងកីឡា

ខេត្តបាត់ដំបង

វិទ្យាល័យពេជ្រចិន្តា

លេខ: ០២ វ.ព.ច

លិខិតបង្គាប់ការ

ស្តីពី

ការបែងចែកតួនាទីភារកិច្ចជូនក្រុមប្រឹក្សាយុវជន និងកុមារនៃវិទ្យាល័យពេជ្រចិន្តា

នាយកវិទ្យាល័យពេជ្រចិន្តា

យោង ៖ - ស្មារតីកិច្ចកិច្ចប្រជុំបោះឆ្នោតថ្ងៃទី២ ខែមករាឆ្នាំ២០១៨ ស្តីពីការបែងចែកតួនាទីភារកិច្ចជូនក្រុមប្រឹក្សាយុវជន និងកុមារនៃវិទ្យាល័យពេជ្រចិន្តា

បង្គាប់

លរ	ឈ្មោះ	ភេទ	ថ្នាក់	តួនាទី
១	វៃ សៀវឡាង	ស្រី	សិស្សថ្នាក់ទី១២ A	ជាប្រធានក្រុមប្រឹក្សាវិន័យ
២	សាន ពុទ្ធា	ប្រុស	សិស្សថ្នាក់ទី១១ B	ជាអនុប្រធានទទួលបន្ទុកផ្នែកពលកម្ម
៣	ឡម សម្ផស្ស	ប្រុស	សិស្សថ្នាក់ទី១០ A	ជាអនុប្រធានទទួលបន្ទុកផ្នែកគណនេយ្យ
៤	សំ រ៉េត	ប្រុស	សិស្សថ្នាក់ទី១២ A	ជាអនុប្រធានទទួលបន្ទុកផ្នែកបរិស្ថាន
៥	ម៉ុក រ៉ុង	ប្រុស	សិស្សថ្នាក់ទី១១ D	ជាអនុប្រធានទទួលបន្ទុកផ្នែកអនាម័យ
៦	ដន ស៊ីណាត	ប្រុស	សិស្សថ្នាក់ទី១១ D	ជាសមាជិកអចិន្ត្រៃយ៍
៧	ណាន់ លីន	ប្រុស	សិស្សថ្នាក់ទី១១ C	ជាសមាជិកអចិន្ត្រៃយ៍
៨	សឿង គន្ធា	ស្រី	សិស្សថ្នាក់ទី១១ D	ជាសមាជិកអចិន្ត្រៃយ៍
៩	ប៉ូវ វីយ៉ា	ស្រី	សិស្សថ្នាក់ទី១១ D	ជាសមាជិកអចិន្ត្រៃយ៍
១០	ស៊ីម លីហួយ	ស្រី	សិស្សថ្នាក់ទី១១ A	ជាសមាជិកអចិន្ត្រៃយ៍

ថ្ងៃច័ន្ទ ៧ កើត ខែបុស្ស ឆ្នាំរកា សំរឹទ្ធិស័ក ព.ស.២៥៦២

ពេជ្រចិន្តា ថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៨

នាយក

ម៉ិច ឈឿត

ឧបសម្ព័ន្ធ ៥

ការបែងចែកសម្អាតបន្ទប់ទឹក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាល័យពេជ្រចិន្តា

ការបែងចែកសម្អាតបន្ទប់ទឹករបស់សិស្សវិទ្យាល័យពេជ្រចិន្តា

១.បន្ទប់ទឹកសហគមន៍

ចន្ទ	អង្គារ៍	ពុធ	ព្រហស្បត្តិ៍	សុក្រ	សៅរ៍
ថ្នាក់ទី១២ B	ថ្នាក់ទី១២ C	ថ្នាក់ទី១១ A	ថ្នាក់ទី១១ B	ថ្នាក់ទី១១ C	ថ្នាក់ទី១១ D

❖ ថ្នាក់១២ A ត្រូវត្រួតពិនិត្យឡដុតសំរាមពីថ្ងៃចន្ទ-សៅរ៍

២.បន្ទប់ទឹកអគារបីជាន់

បន្ទប់ទឹក	ចន្ទ	អង្គារ៍	ពុធ	ព្រហស្បត្តិ៍	សុក្រ	សៅរ៍
ជាន់ទី១	ថ្នាក់ទី៧ A	ថ្នាក់ទី៧ B	ថ្នាក់ទី៧ C	ថ្នាក់ទី៨ B	ថ្នាក់ទី៧ E	ថ្នាក់ទី៨ D
ជាន់ទី២	ថ្នាក់ទី៩ A	ថ្នាក់ទី៨ A	ថ្នាក់ទី៩ B	ថ្នាក់ទី៩ C	ថ្នាក់ទី៨ C	ថ្នាក់ទី៧ D
ជាន់ទី៣	ថ្នាក់ទី១០ A	ថ្នាក់ទី១០ B	ថ្នាក់ទី១០ C	ថ្នាក់ទី១០ D	ថ្នាក់ទី១០ E	ថ្នាក់ទី១០ A
ជាន់ទី១	ថ្នាក់ទី៧ A	ថ្នាក់ទី៧ B	ថ្នាក់ទី៧ C	ថ្នាក់ទី៨ B	ថ្នាក់ទី៧ E	ថ្នាក់ទី៨ D
ជាន់ទី២	ថ្នាក់ទី៩ A	ថ្នាក់ទី៨ A	ថ្នាក់ទី៩ B	ថ្នាក់ទី៩ C	ថ្នាក់ទី៨ C	ថ្នាក់ទី៧ D
ជាន់ទី៣	ថ្នាក់ទី១០ A	ថ្នាក់ទី១០ B	ថ្នាក់ទី១០ C	ថ្នាក់ទី១០ D	ថ្នាក់ទី១០ E	ថ្នាក់ទី១០ B

❖ **ថ្នាក់នីមួយៗត្រូវអនុវត្ត៖**

- លាងសម្អាតបន្ទប់ទឹក
- មានការត្រួតពិនិត្យរាល់ពេលម៉ោងចេញលេង
- ពិន័យចំពោះសិស្សណាដែលគ្មានអនាម័យពេលចូលបន្ទប់ទឹក។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ពេជ្រចិន្តា ថ្ងៃទី 5 ខែមករា ឆ្នាំ ២០១៨

ហត្ថលេខា

ថៃ សៀវឡាង

ថ្ងៃ[illegible] [illegible] ខែបុស្ស ឆ្នាំ[illegible] សំរឹទ្ធិស័ក ព.ស. ២៥៦២
ពេជ្រចិន្តា ថ្ងៃទី[illegible] ខែមករា ឆ្នាំ ២០១៨

បានឃើញ និងឯកភាព

នាយក

ម៉ិច ឈឿត

កិច្ចសន្យាជួលតូប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំយុវជន និងកីឡា
ខេត្ត បាត់ដំបង
វិទ្យាល័យពេជ្រចិន្តា

កិច្ចសន្យាជួលតូប

នាងខ្ញុំ/ខ្ញុំបាទឈ្មោះ...លុ..សារ៉ុង.... .ភេទ ប្រុស☑ / ស្រី☐ ជាអាជីវករលក់ដូរនៅក្នុងវិទ្យាល័យពេជ្រចិន្តា តូបលេខ..៤..។

នាងខ្ញុំ/ខ្ញុំបាទ សូមសន្យាជាមួយគណៈកម្មការគ្រប់គ្រងសាលា គណៈគ្រប់គ្រងសាលា និងបុគ្គលិកអប់រំវិទ្យាល័យពេជ្រចិន្តាទាំងអស់ថា នាងខ្ញុំ/ខ្ញុំបាទនឹងប្រកបអាជីវកម្មលក់ដូរនៅក្នុងវិទ្យាល័យដោយគោរពតាមលក្ខខណ្ឌដែលសាលាបានកំណត់។ ក្នុងករណីដែលសាលាទាមទារ ឬត្រូវការការផ្លាស់ប្ដូរទីតាំងដើម្បីសាងសង់អ្វីមួយ នាងខ្ញុំ/ខ្ញុំបាទនឹងយល់ព្រមធ្វើការរុះរើចេញដោយឥតលក្ខខណ្ឌ។

ស្នាមមេដៃអ្នកជួលតូប	**ស្នាមមេដៃអ្នកធានា**
លុ សារ៉ុង	សោង យ៉ា

ថ្ងៃអង្គារ ៧រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ពេជ្រចិន្តា ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៨
បានឃើញ និងឯកភាព
នាយក

មុិន សុខនី

ថ្ងៃអង្គារ ៧រោច ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ពេជ្រចិន្តា ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៨
បានឃើញ និងឯកភាព
ប្រធានគណៈកម្មការគ្រប់គ្រង

គឿន ឡុត

ផែនការសកម្មភាពរបស់ក្រុមប្រឹក្សាយុវជន និងកុមារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាល័យពេជ្រចិន្តា

ផែនការសកម្មភាពរបស់ក្រុមប្រឹក្សាយុវជន និងកុមារវិទ្យាល័យពេជ្រចិន្តា

ខែ	សកម្មភាព	អ្នកទទួលខុសត្រូវ
វិច្ឆិកា	· រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាយុវជន និងកុមារ · រៀបចំបទបញ្ជាផ្សេងៗ	· នាយករងទទួលបន្ទុកយុវជន · ប្រធានក្រុមប្រឹក្សានិន័យ
ធ្នូ	· ចូលរួមរើសសំរាមតាមដងផ្លូវ	· លោកគ្រូទទួលបន្ទុកផ្នែកបរិស្ថាន · ក្រុមប្រឹក្សាយុវជន · ប្រធានថ្នាក់គ្រប់កម្រិត
មករា	· ប្រជុំពិភាក្សាអំពីដំណើរការនៃការអនុវត្ត · លើកបញ្ហាប្រឈម និងដំណោះស្រាយ · ស្វែងរកមូលហេតុនៃការបោះបង់ការសិក្សារបស់សិស្ស	· លោកគ្រូទទួលបន្ទុកវិន័យ · អនាម័យ និងបរិស្ថាន · ក្រុមប្រឹក្សាយុវជន · ប្រធានថ្នាក់គ្រប់កម្រិត · លោកគ្រូ អ្នកគ្រូទទួលបន្ទុកថ្នាក់ · ក្រុមប្រឹក្សាយុវជន
កុម្ភៈ	· ប្រជុំជាមួយលោកគ្រូអ្នកគ្រូ · ចុះទៅតាមផ្ទះសិស្សបោះបង់ដើម្បីទាក់ទាញសិស្សមកចូលរៀនវិញ	
មិនា-សីហា	· ចុះទៅតាមផ្ទះសិស្ស(ក្រីក្រ,ប្រឈមនឹងការបោះបង់) ដើម្បីសាកសួរក៏ដូចជាប្រាប់ពួកគាត់អំពីរបៀបរៀនពីចម្ងាយ	· ក្រុមប្រឹក្សាយុវជន

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំ [illegible] សំរឹទ្ធិស័ក ព.ស. ២៥៦២
ពេជ្រចិន្តា ថ្ងៃទី 5 ខែ[illegible]ឆ្នាំ ២០១៨
ហត្ថលេខា

ទៃ សៀវឡាង

បានឃើញ និងឯកភាព
នាយក

ម៉ិច ឈឿត

លិខិតបង្គាប់ការស្ដីពីការបែងចែកតួនាទី ភារកិច្ចក្រុមកែលម្អបរិស្ថាន និងអនាម័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំយុវជន និងកីឡា
ខេត្តបាត់ដំបង
វិទ្យាល័យពេជ្រចិន្តា
លេខៈ ០១៩ វ.ព.ច

លិខិតបង្គាប់ការ
ស្ដីពី
ការបែងចែកតួនាទីភារកិច្ចជូនក្រុមកែលម្អបរិស្ថាន និងអនាម័យវិទ្យាល័យពេជ្រចិន្តា

នាយកវិទ្យាល័យពេជ្រចិន្តា

យោង ៖ -ស្មារតីកិច្ចប្រជុំថ្ងៃទី០១ខែមករា ឆ្នាំ២០១៨ ស្ដីពីការបែងចែកតួនាទីភារកិច្ចជូនក្រុមកែលម្អបរិស្ថាន និងអនាម័យវិទ្យាល័យពេជ្រចិន្តា

បង្គាប់

1. **លោក សួស សៀងឌី**	គ្រូកម្រិតឧត្ដមជាប្រធានក្រុមទទួលបន្ទុករួម
2. **លោក ឃុន សុភឿន**	គ្រូកម្រិតមូលដ្ឋានជាសមាជិកទទួលបន្ទុកសម្របសម្រួលដាក់ពិន័យ និងបង្កើតថ្មី
3. **លោក ឡឹក សុធាណា**	គ្រូកម្រិតមធ្យមជាសមាជិកទទួលបន្ទុកសម្របសម្រួល ដាក់ពិន័យ និងបង្កើតថ្មី
4. **លោក សុខ គិមសាន្ដ**	គ្រូកម្រិតឧត្ដមជាសមាជិកទទួលបន្ទុកគ្រប់គ្រងសួនជីវៈចម្រុះ និងសួនច្បារ
5. **លោក សាន ពុទ្ធា**	ប្រធានថ្នាក់ទាំង២៤ថ្នាក់ជាសមាជិកទទួលបន្ទុកបែងចែកសិស្សតាមថ្នាក់ ធ្វើពលកម្ម សម្អាតបរិស្ថានក្នុង និងជុំវិញសាលារៀន

ថ្ងៃ អង្គារ ១ កើត ខែ បុស្ស ឆ្នាំ ចារ សំរឹទ្ធិស័ក ព.ស. ២៥៦២
ពេជ្រចិន្តា ថ្ងៃទី ២ ខែ មករា ឆ្នាំ ២០១៨
នាយក

ប៊ុច ឈឿត

ឧបសម្ព័ន្ធ ៩

កាលវិភាគត្រួតពិនិត្យអនាម័យរបស់ក្រុមប្រឹក្សាយុវជន និងកុមារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាល័យពេជ្រចិន្តា

កាលវិភាគ
ត្រួតពិនិត្យអនាម័យ និងបរិស្ថានរបស់ក្រុមប្រឹក្សាយុវជន និងកុមារ
ព្រឹកម៉ោង ១០: ៤៥ ល្ងាចម៉ោង ១៥ : ៤៥

ចន្ទ	អង្គារ	ពុធ	ព្រហស្បតិ៍	សុក្រ	សៅរ៍
ថ្នាក់ទី៧ A B C D E	ថ្នាក់ទី៨ A B C D	ថ្នាក់ទី៩ A B C	ថ្នាក់ទី១០ A B C D E	ថ្នាក់ទី១១ A B C D	ថ្នាក់ទី១២ A B C

១. **ការត្រួតពិនិត្យអនាម័យ**
- អនាម័យក្រៅថ្នាក់
- អនាម័យក្នុងថ្នាក់
- សំរាមខាងក្នុង និងខាងក្រៅវិទ្យាល័យ
- សំរាមតាមថតតុ

២. **ការដាក់ពិន័យ**
លើកទី១៖ ធ្វើការណែនាំ
លើកទី២៖ បោសសំរាម ស្រោចផ្កា ឬលាងបន្ទប់ទឹក
លើកទី៣៖ រាយការណ៍ទៅក្រុមប្រឹក្សាវិន័យ និងអញ្ជើញមាតាបិតាមកជួប

៣. **ពាក្យស្លោកសម្រាប់ក្រុមប្រឹក្សាយុវជន និងកុមារ**
- ស្វ័យគ្រប់គ្រងសំរាម គឺជាសីលធម៌ល្អសម្រាប់គ្រប់គ្នា។
- ខ្ញុំស្រលាញ់សំរាម ដូចនេះខ្ញុំត្រូវទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។
- សាលាមានបរិស្ថានល្អ ថ្នាក់រៀនមានសោភ័ណភាពល្អ បន្ទប់ទឹកមានអនាម័យ សិស្សរៀនប្រកបដោយសីលធម៌ មានវិន័យ មានគុណភាព មានសុខភាពល្អនោះប្រទេសនឹងរីកចម្រើន។

ថ្ងៃ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ថ្ងៃ [illegible] ឆ្នាំចសំរឹទ្ធិស័ក ព.ស. ២៥៦២ ថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៨

ពេជ្រចិន្តា ថ្ងៃទី [illegible] ខែមករា ឆ្នាំ ២០១៨ — ហត្ថលេខា

បានឃើញ និងឯកភាព

នាយក

ម៉ិច ឈឿត — **ថៃ សៀវឡាង**

លិខិតស្នើសុំការត្រួតពិនិត្យចំណីអាហារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំយុវជន និងកីឡា
ខេត្តបាត់ដំបង
វិទ្យាល័យពេជ្រចិន្តា
លេខៈ ០៣០ វ.ព.ច

សូមគោរពជម្រាបជូន
លោកអភិបាលនៃគណៈអភិបាលស្រុកភ្នំព្រឹក

កម្មវត្ថុ៖ ស្នើសុំចាត់បុគ្គលិកមណ្ឌលសុខភាពចុះត្រួតពិនិត្យចំណីអាហារក្នុង និងក្រៅវិទ្យាល័យពេជ្រចិន្តា។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **លោកអភិបាលនៃគណៈអភិបាល** មេត្តាជ្រាបថា ដើម្បីលើកកម្ពស់សុខភាពសិស្ស ព្រមទាំងបុគ្គលិកអប់រំ ខ្ញុំបាទ សូម **លោកអភិបាលនៃគណៈអភិបាល** មេត្តាជួយសម្រួលក្នុងការចាត់បញ្ជូនមន្ត្រីជំនាញនៃមណ្ឌលសុខភាពមកចុះជួយត្រួតពិនិត្យចំណីអាហារខាងក្នុង និងក្រៅវិទ្យាល័យពេជ្រចិន្តាដោយសេចក្ដីអនុគ្រោះ។

សូម **លោកអភិបាលនៃគណៈអភិបាល** មេត្តាទទួលនូវសេចក្ដីគោរពពីខ្ញុំបាទ។

ថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំរកា សំរឹទ្ធិស័ក ព.ស.២៥៦២
ពេជ្រចិន្តា ថ្ងៃទី ៥ ខែកុម្ភៈឆ្នាំ២០១៨
នាយក

ម៉ិច ឈឿត

ឧបសម្ព័ន្ធ ៦៖ គំនិតនវានុវត្តន៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាល័យ ពេជ្រចិន្តា

ប្រធានបទ

ការច្នៃប្រឌិត

ណែនាំដោយ

លោកគ្រូ: ចន ចណ្ណារិទ្ធ

រៀបរៀងដោយ

១. សិស្ស វៃ ដាលីន   ២. សិស្ស ...ពៅសុវ៉ាន

កិច្ចការស្រាវជ្រាវថ្នាក់ទី ១០ B
មុខវិជ្ជា: សីលធម៌-ពលរដ្ឋវិជ្ជា

ឆ្នាំសិក្សា: ព.ស. ២៥៦១ គ.ស. ២០១៧

ការច្នៃប្រឌិត វិ.ពេជ្រចិន្តា

អារម្ភកថា

សៀវភៅ "ការច្នៃប្រឌិត"គឺជាសៀវភៅមួយដែលបង្កើតឡើងសម្រាប់អោយអ្នកអានទាំងអស់គ្នាងាយស្រួលក្នុងការស្រាវជ្រាវគំនិតថ្មីៗនិងស្វែងយល់នៅចំណេះដឹង។ សៀវភៅនេះប្រៀបដូចជាឧបករណ៍យ៉ាងសំខាន់ដែលផ្តល់អោយយើងនៅវិធីសាស្ត្រផ្សេងៗ ពីរបៀបធ្វើដែលជាមូលដ្ឋានគ្រឹះនៃការសិក្សា។

សៀវភៅដែលបានចងក្រងឡើងដោយក្រុមយើងខ្ញុំនេះ គឺដើម្បីអោយសិស្សានុសិស្ស និង មិត្តអ្នកអានទាំងអស់គ្នាសិក្សាស្វែងយល់ និង អាចជំនួយដល់ចំណេះមួយកម្រិតថែមទៀត។ សៀវភៅនេះក៏ចាត់ទុកមូលដ្ឋានគ្រឹះ ចំណេះដឹងអញ្ចឹងដែរដែលជួយដល់ ការសិក្សានិងការយល់ដឹងពីអ្វីផ្សេងៗទៀតដែលមាននៅក្នុងសៀវភៅ។វិស័យអប់រំក្នុងផ្នែកចំណេះដឹងទូទៅត្រូវបានគេចាប់ទុកជាវិស័យអាទិភាពមួយដើម្បីជំរុញការអភិវឌ្ឍប្រទេសជាតិ ជាពិសេស ក្នុងយុគសម័យបច្ចុប្បន្នដែលការអភិវឌ្ឍត្រូវផ្អែកទៅលើធនធានបញ្ញា។ មួយវិញទៀត ក៏អាចជួយបង្កើតធនធានមនុស្សដែលមានចំណេះដឹងបង្កើតសមត្ថភាពជំនាញ ច្បាស់លាស់ដល់ខ្លួនឯងនិងសង្គម។ ម៉្យាងវិញទៀតជួយអោយប្រទេសមានការជឿនលឿនទៅលើ ផ្នែកវិទ្យាសាស្ត្រ និងល្បីល្បាញទូទាំងពិភពលោក។ ម៉្យាងវិញទៀតផ្នែកវិទ្យាសាស្ត្រនេះ ក៏អាចជួយដល់សង្គមជាតិទាំងមូលអោយរួចផុតពីសង្គ្រាមផងដែរ។

សៀវភៅនេះខ្ញុំបានបង្ហាញអ្នកទាំងអស់គ្នាពីការច្នៃប្រឌិតជាច្រើនដូចជា ការកែច្នៃម៉ាស៊ីនបាញ់ថ្នាំ ទៅជាមាស៊ីនបូមទឹក ការបង្ហាញពីរបៀបចិញ្ចឹមកង្កែប ការធ្វើទរត្រងទឹករបៀបដេរប្រដាប់ចាប់ឆ្មាំង និង ការធ្វើម៉ាស៊ីនបូមធូលី។

ការច្នៃប្រឌិតគឺជាប្រធានបទសំខាន់នៅក្នុងការសិក្សាអំពី សេដ្ឋកិច្ច អាជីវកម្ម បច្ចេកវិទ្យា សង្គមវិទ្យា និង វិស្វកម្ម។ ខ្លឹមសារនៃសៀវភៅនេះ យើងខ្ញុំសង្ឃឹមថាអ្នកទាំងអស់គ្នានឹងទទួលបានចំណេះដឹងបន្ថែមទៀតព្រមទាំងយល់កាន់តែច្បាស់ពីការច្នៃប្រឌិត។

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ១

ការច្នៃប្រឌិត វិ.ពេជ្រចិន្តា

សេចក្តីថ្លែងអំណរគុណ

ការស្គាល់គុណ ដឹងគុណ តបគុណ ជាភាពមិនចេះសាបសូន្យនៃជីវិតលោកកីយ៍។ ក្នុងនាមនាងខ្ញុំទាំងពីរនាក់ដែលជាអ្នកបង្កើតសៀវភៅនេះឡើង យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណចំពោះបុព្វជនខ្មែរទាំងឡាយ ដែលលោកបានកសាងនិងបន្សល់ទុកនូវស្នាដៃការច្នៃប្រឌិតទាំងអម្បាលម៉ានសម្រាប់ពួកយើងខ្ញុំទាំងអស់ដើម្បីសិក្សារៀនសូត្រនូវគំរូ និងបទពិសោធន៍ផ្សេងៗ

កូនសៀវភៅតូចនេះអាចកើតឡើងបានគឺដោយសារតែមានការណែនាំពី ឪពុកម្តាយ និងលោកគ្រូអ្នកគ្រូរបស់ខ្ញុំ ដែលជាដំបូងខ្ញុំសូមអរគុណដល់ឪពុកម្តាយរបស់ពួកខ្ញុំទាំងពីរនាក់ ដែលលោកតែងតែផ្តល់កម្លាំងចិត្ត ថែរក្សានិងឧបត្ថមអោយពួកខ្ញុំរៀនតាំងពីរតូចរហូតមកដល់ពេលនេះ បើសិនជាគ្មានការលើកទឹកចិត្តពីលោកទាំងពីរទេសៀវភៅនេះក៏មិនអាចចេញមកល្អបែបនេះដែរ។

ក្រុមយើងខ្ញុំសូមថ្លែងអំណរគុណដល់លោកគ្រូ វិន វណ្ណារិទ្ធ ដែលបានដាក់ការងារស្រាវជ្រាវនេះដល់ពួកខ្ញុំទាំងអស់គ្នាធ្វើដើម្បីជាបទពិសោធន៍ ហើយធ្វើអោយពួកខ្ញុំកើនចំណេះដឹងមួយកម្រិតទៀត។ ម៉្យាងវិញទៀតយើងខ្ញុំទាំងអស់គ្នាសូមអរគុណដល់លោកគ្រូ ហិន សុភាព លោកគ្រូ យ៉េន វណ្ណា លោកគ្រូ ឡឹក សុខធាណា អ្នកគ្រូ សុខ ស្រីមិច និងលោកគ្រូអ្នកគ្រូដែលបង្រៀននៅសាលា WISDOM ជាពិសេសលោកគ្រូ ទូន សុហេង និង លោកគ្រូ អេង ដារ៉ូ ដែលបានផ្តល់ជាគំណិតនិងបានផ្តល់ជាសម្ភារៈសម្រាប់យើងខ្ញុំក្នុងការចងក្រងសៀវភៅនេះឡើង។ ពួកយើងទាំងពីរក៏សូមអំណរគុណទៅដល់លោកពូអ្នកមីងដែលរស់នៅស្រុកភ្នំព្រឹកដែលបានចូលរួមផ្តល់មតិយោបល់ដល់ការស្រាវជ្រាវរបស់ពួកខ្ញុំ។ហើយជាចុងក្រោយខ្ញុំសូមអរគុណដល់មិត្តភក្តិរបស់ខ្ញុំដូចជា ម៉េង ធារី ជិន លីនដា យ៉ុន សំណាន លឹម គឹមហួត ម៉ាប់ សៀវប៉ៃ ហឹមស្រីនុត និង ជី ស្រីណៃដែលបានផ្តល់ជាមតិយោបល់ គំនិត និងជួយ លើកទឹកចិត្តចំពោះស្នាដៃរបស់យើងខ្ញុំ។

ខ្ញុំសូមបួងសួងអោយអ្នកទាំងអស់គ្នានិងក្រុមគ្រួសារជួបតែសេចក្តីសុខ រកស៊ីមានបាន មានសុភមង្គលក្នុងគ្រួសារ។

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ២

ការច្នៃប្រឌិត វិ.ពេជ្រចិន្តា

ឧទ្ទិកថា

ខ្ញុំសូមក្រាបប្រណិប័តន៍ ឧទ្ទិសជូនចំពោះឧបការៈជនដល់អ្នកមានគុណចំពោះរូបខ្ញុំគឺ លោកឪពុករបស់ខ្ញុំ លោក គុល ប៉ុន ដែលបានចែកឋានទៅ សម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលលោកបានទុកនូវស្នាដៃ ដូចជា វចនានុក្រម ដែលទុកសម្រាប់ក្រុមយើងខ្ញុំក៏ដូចជាប្រជាជនខ្មែរពាសពេញប្រទេសសម្រាប់ស្រាវជ្រាវ ហើយមួយទៀតខ្ញុំសូមឧទ្ទិសទៅដល់ លោកគ្រូតា ឈ្មោះ ប្រាជ្ញ ធឿន ដែលលោកបានបង្រៀនខ្ញុំតាំងពីតូចមក សូមវិញ្ញាណក្ខន្ធរបស់លោកបានទៅកាន់សុគតិភពកុំបីអាក់ខានឡើយ។

សូមឧទ្ទិសសៀវភៅ ការច្នៃប្រឌិត នេះទៅដល់ជនដែលមានស្នាដៃរ នៃការបង្កើតថ្មី ដែលបានចែកឋានទៅ ដែលមានទឹកចិត្តស្នេហា ចំពោះការបង្កើតសៀវភៅ សូមវិញ្ញានក្ខន្ធរបស់អ្នករាល់គ្នាទៅកាន់សុគតិភពផងចុះ។

ជាចុងក្រោយក្រុមយើងខ្ញុំសូមឧទ្ទិសចំពោះលោកអ្នកដែលមានគុណនៃយើងខ្ញុំមាន លោកតា លោកយាយ បងប្អូនពូមីង និង ញាតិកាទាំងប្រាំពីរសណ្ដាន ដែលបានចែកឋានទៅ អស់រយៈពេលយ៉ាងយូរមកនោះ សូមឱ្យវត្ថុសក្ដសទ្ធិ ជួយនាំវិញ្ញានក្ខន្ធរបស់អ្នកទាំងអស់គ្នាទៅកាន់ ទីឋានបរមសុខ កុំបីឃ្លៀងឃ្លាតឡើយ។

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ៣

ការច្នៃប្រឌិត វិ.ពេជ្រចិន្តា

មាតិកា

អារម្ភកថា ១

សេចក្តីថ្លែងអំណរគុណ ២

ឧទ្ទិសកថា ៣

មាតិកា ៤

I, បុព្វហេតុ ៦

១.ការកំណត់អត្ថន័យ ៦

២.និយមន័យ ៦

៣.Definition of Innovation(Business dictionary) ៧

4.ការច្នៃប្រឌិត (Fresh consulting) ៨

II. លទ្ធផលស្រាវជ្រាវ ៨

១.ការប្រមូលទិន្នន័យ ៨

២.លទ្ធផលស្រាវជ្រាវ ៨

២.១ របៀបធ្វើម៉ាស៊ីនបាញ់ថ្នាំទៅជាម៉ាស៊ីបូមទឹក ៩

២.២ របៀបធ្វើទត្រេងទឹក ៩

២.២ការធ្វើប្រដាប់ចាប់ផ្តាំង ១០

២.៣ ការធ្វើម៉ាស៊ីនបូមធូលី ១១

២.៤ ការឆ្នៃប្រឌិតល្បីៗទូទាំងពិភពលោក ១២

២.៥ របៀបចិញ្ចឹមកង្កែប ១៣

២.៥ កត្តាទាំងឡាយនៃការបង្កើតថ្មី ១៦

III. សេចក្តីសន្និដ្ឋាននិងអនុសាសន៍ ១៨

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ៥

ការច្នៃប្រឌិត វី.ពេជ្រចិន្តា

១. សេចក្តីសន្និដ្ឋាន ១៨

១.១ គុណសម្បត្តិ ១៨

១.២ គុណវិបត្តិ ២០

២. អនុសាសន៍ ២១

ឧបសម្ព័ន្ធ ២២

ឯកសារយោង ២៥

ការច្នៃប្រឌិត វិ.ពេជ្រចិន្តា

I. **មុខហេតុ**

ការស្រាវជ្រាវជាការសិក្សាមួយដ៏មានសារៈសំខាន់សម្រាប់សិស្សានុសិស្ស ដែលកំពុងតែសិក្សា ពីព្រោះថាសិស្សានុសិស្ស គឺជាទំពាំងស្នងឬស្សីក៏ដូចជាធនធានមនុស្សដ៏សំខាន់សម្រាប់អភិវឌ្ឍប្រទេសជាតិនៅថ្ងៃអនាគតទើបលោកគ្រូអ្នកគ្រូបានដាក់ការងារស្រាវជ្រាវដល់ពួកយើងទាំងអស់គ្នាដែលកំពុងតែសិក្សាក៏ដូចជាសិស្សរៀនថ្នាក់ទី ១០"B" នៅវិទ្យាល័យពេជ្រចិន្តាដោយដាក់អោយពួកយើងធ្វើការស្រាវជ្រាវដើម្បីចងក្រងជាសៀវភៅមួយនេះឡើង គឺដើម្បីពង្រឹងនូវសមត្ថភាព និងចេះចងក្រងរាល់ការច្នៃប្រឌិតឬវិធីសាស្ត្រសំខាន់ៗរបស់បុគ្គលល្បីៗនៅលើពិភពលោក ក៏ដូចជាការច្នៃ ប្រឌិតដែលយើងបានជួបប្រទះកន្លងមកដើម្បីធ្វើអោយសមត្ថភាពរបស់ពួកយើងកាន់តែមានភាពលេចធ្លោផងដែរ។

១.ការកំណត់អត្ថន័យ

- ច្នៃ (កិ) : ក្រឡឹង, ធ្វើអោយមានពន្លឺដោយគ្រឿនប្រដាប់សម្រាប់ប្រកបការនោះ។
- ប្រឌិត (កិ) : មកពីរពាក្យប្រតិដ្ឋ(កិ) : ខ្មែរប្រើពាក្យនេះសំដៅសេចក្តីថាបង្កើតឡើងតាមយោបល់របស់ខ្លួន
- ពាណិជកម្ម(ន): ការ រឺ អំពីលក់ដូរ,របរលក់ដូរ
- ប្រយោជន៍(ន): ដំណើរដែរគួប្រកប, អ្វីៗដែលគេត្រូវការ, ដែលគេប្រកបទៅកើតការ , ផលដែលសម្រេចពីការប្រកប ។

២. និយមន័យ

- **ការច្នៃប្រឌិត** (ន): គឺជាការសម្រេចចិត្តចាត់ចែងធ្វើអ្វីអោយលេចចេញជារូបរាងហើយសម្រេចបានជោគជ័យ។[១]
- **ការច្នៃប្រឌិត**: គំនិតថ្មី ឧបករណ៍ថ្មី វិធីសាស្ត្រថ្មី រឺ ដំណើរការគំណិតថ្មីឧបករណ៍ រឺ វិធីសាស្ត្រថ្មី។[២]

---

[១] Definition of Innovation →Oxford living dictionaries

[២] Definition of Innovation by Merriam-Webster

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ៦

ការច្នៃប្រឌិត វី.ពេជ្រចិន្តា

-ការច្នៃប្រឌិតៈ គឺជារបៀបមួយក្នុងការប្រើគំនិតបញ្ញាសម្រាប់ឆ្លើយតបទៅនឹងបញ្ហាធំៗដែលកំពុងវិវត្តយ៉ាងលឿននៅក្នុងពិភពលោកដែលយើងទាំងអស់គ្នាកំពុងរស់នៅ។[៣]

១.៣ Definition of innovation (Business dictionary)

បើតាមទ្រឹស្តីអ្នកជំនួញការច្នៃប្រឌិតមានន័យថា ដំណើរការនៃការប្រែគំនិត រឺ ការកង្កើតអោយទៅជាផលិតផល ឬ សេវាកម្មដែលបង្កើតតម្លៃ ឬ សម្រាប់អតិថិជនត្រូវចំណាយ។ ដើម្បីអោយការច្នៃប្រឌិតលេចចេញជារូបរាងយើងត្រូវតែមានការស្រមើលស្រមៃ មានព័ត៌មានច្បាស់លាស់ មានវត្ថុធាតុដើមនិងបច្ចេកទេស។ ដើម្បីហៅថាការច្នៃប្រឌិតមួយគំនិតមួយត្រូវមានការថតចម្លងក្នុងការចំណាយសន្សំសំចៃ និងត្រូវបំពេញតម្រូវការជាក់លាក់មួយ។ ការច្នៃប្រឌិតជាប់ពាក់ព័ន្ធនិងកម្មវិធីចេតនានៃការពង្រើក,ការស្រមើលស្រមៃនិងការផកដួចផ្តើមក្នុងអត្ថប្រយោជន៍ទាក់ទងនឹងតម្លៃខុសគ្នាពីឋានៈធំឬធនធាន និងរួមបញ្ចូលនឹងដំណើរការទាំងអស់ ដែលត្រូវបង្កើតគំនិតថ្មី និងបានក្លាចទៅជាផលិតផលមានប្រយោជន៍។ ការធ្វើអាជីវកម្មកជាញឹកញាប់លទ្ធផលនៅពេលគំនិតនេះត្រូបានអនុវត្តន៍នៅក្នុងក្រុមហ៊ុនក្នុងគោលបំណងក្នុងការបំពេញតម្រូវការ និងការរំពឹងទុករបស់អតិថិជន។ ក្នុងបរិយាកាសសង្គម ការច្នៃប្រឌិតជួយបង្កើតវិធីសាស្ត្រថ្មីសម្រាប់ការបង្កើតសម្ព័ន្ធភាពអាជីវកម្មរួមគ្នា, ម៉ោងការងារអាចបំបែកបាននឹងបង្កើតនៃអំណាចទិញរបស់អ្នកទិញ។ ការបង្កើតបានបែកចែកជាពីរប្រភេទធំទូលាយៈ

ការបង្កើតថ្មីដែលវិត្តន៍ដែលត្រូវបានយកមកដោយបុកបន្ថែមជាច្រើននៅក្នុងដំណើរការនិងបច្ចេកវិទ្យាឬការបង្កើតការបដិវត្តន៍(ហៅផងដែរថាការបង្កើតថ្មីដែលមិនបន្តគ្នាដែលមានជាញឹកញាប់ចាស់និងថ្មី។ ការច្នៃប្រឌិតគឺមានន័យដូចជាការទទួលយកហានិភ័យដែលកើតឡើងនឹងបត្តិវង្ស បច្ចេកវិទ្យាផលិតផលគឺជាហានិភ័យដ៏ធំបំផុតពីព្រោះគេបានបង្កើតទីផ្សារថ្មី វាមានហានិភ័យតិចតួចគឺដោយសារតែពួកគេនឹងចាប់ផ្តើមជាមួយនឹងការច្នៃ ប្រឌិតមួយហើយយកវិធីសាស្ត្រដែលមានប្រសិតភាពបន្ថែមទៀត។

[៣] សៀវភៅសិក្សាសង្គមថ្នាក់ទី១០ ពលរដ្ឋវិទ្យា មេរៀនទីមួយ ជំពូកទីមួយ ទំព័រទី១៩៦

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ៧

៤.ការច្នៃប្រឌិត(Fresh consulting)

ការច្នៃប្រឌិតគឺជាការបង្កើតគំនិតថ្មីសំដៅលើការដែលបានទាញយកឬផលិតផលរបស់បុគ្គលពីគំនិតស្រាវជ្រាវវិទ្យាសាស្ត្រឬគំនិតច្នៃប្រឌិតថ្មីនៅលើដៃផ្សេងទៀតនោះគឺជារធ្វើពាណិជ្ជកម្មនៃការបង្កើតដោយខ្លួនឯង។

- ការច្នៃប្រឌិត: ការច្នៃប្រឌិតនេះសំដៅទៅលើការផ្លាស់ប្តូរទាំងរ៉ាឌីកាល់និងបន្ថែមទៅនឹងផលិតផលដែលដំណើរការសេវាកម្ម។

II. លទ្ធផលស្រាវជ្រាវ

១. ការប្រមូលទិន្នន័យ

ក្រុមយើងខ្ញុំធ្វើការស្រាវជ្រាវតាមរយះ

-សៀវភៅសិក្សាសង្គមថ្នាក់ទី ១០ ឆ្នាំ ២០១៣(ឯកសារគោល)

- ការចុះសួរផ្ទាល់
- ការស្រាវជ្រាវក្នុងក្រុម
- សៀវភៅសក្សាសង្គមថ្នាក់ទី៨ ឆ្នាំ ២០១២
- សៀវភៅ សិល្ប: រៀបចំគោលដៅ
- តាមរយ:បទពិសោធន៍ផ្ទាល់ខ្លួន
- Internet

២. លទ្ធផលស្រាវជ្រាវ

ដោយសារតែការច្នៃប្រឌិតបានផ្តោតសំខាន់ទៅលើការអភិវឌ្ឍគំនិត របស់មនុស្សហេតុនេះហើយ ទើបការច្នៃប្រឌិតជួយយើងរកអោយឃើញដំណោះស្រាយមួយ ដ៏ប្រសើរបំផុតសម្រាប់ទប់ទល់បញ្ហាដែលយើងកំពុងជួបប្រទះ ដូចជា ការច្នៃប្រឌិតផលិតផល គឺមានភាពប្រសើរយ៉ាងខ្លាំងហើយនេះរួមបញ្ចូលទាំងការដែលម្អយ៉ាងសំខាន់ក្នុងការប្រើបច្ចេកទេស សមាសភាគ និងសម្ភារ: កម្មវិធីនៅក្នុងផលិតផលនេះងាយស្រួលប្រើ ។ ហើយការច្នៃប្រឌិតធ្វើទីផ្សារជាវិធីសាស្ត្រក្នុងការធ្វើទី

ការច្នៃប្រឌិត វិ.ពេជ្រចិន្តា

ផ្សារមួយទាក់ទងនឹងការផ្លាស់ប្តូរថ្មីយ៉ាងសំខាន់នៅក្នុងការរចនាផលិតផល ឬវិចខ្ចប់ការដាក់ផលិតផលការផ្សព្វផ្សាយផលិតផលរឺតម្លៃ។ ហើយក្រុមយើងខ្ញុំនឹងបង្ហាញពីដំណោះស្រាយខ្លះៗពីការច្នៃប្រឌិតរបស់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ផ្សេងៗក៏ដូចជាប្រជាពលរដ្ឋដែលរស់ក្នុងស្រុកភ្នំពេញផងដែរ ។ យ៉ាងណាវិញពួកខ្ញុំបង្ហាញអ្នកទាំងអស់គ្នាពីរការច្នៃប្រឌិតរបស់ប្រជាពលរដ្ឋនៅស្រុកភ្នំពេញដូចជាការកែច្នៃម៉ាស៊ីនបាញ់ថ្នាំទៅជាម៉ាស៊ីនបូមទឹក ការបង្ហាញពីរបៀបចិញ្ចឹមកង្កែប ការធ្វើទរត្រងទឹក ប្រដាប់ចាប់ឆ្មាំង និង ម៉ស៊ីនបូមធូលី។

២.១ របៀបធ្វើម៉ាស៊ីបាញ់ថ្នាំទៅជាម៉ាស៊ីនបូមទឹក

ក. សម្ភារ:

- ម៉ាស៊ីនបាញ់ថ្នាំម
- ក្បាលបូមគូទខ្យង
- ទុយយ

ខ. របៀបធ្វើ

របៀបធ្វើម៉ាស៊ីនបូមទឹកដែលកែនេះពីម៉ាស៊ីនបាញ់ថ្នាំប្រមោយដំរី(រឺបាញ់ទាប)។ ដំបូងយើងត្រូវយកម៉ាស៊ីនបាញ់ថ្នាំនៅប្រើកើតតែគេលេងនិយមប្រើ យកវាមកដោះធុងទឹករួចដោះផ្នែកខាងក្រោយរបស់ម៉ាស៊ីនត្រង់កន្លែងផ្លិតខ្យល់រួចយើងចាប់ក្បាលបូមគូទខ្យងចូលផ្ទាប់ជាមួយផ្លិតខ្យល់និងទុយយហើយដាក់វាផ្ទាប់ជាមួយផ្នែកខាងក្រោយជាការស្រាច។

២.២របៀបធ្វើទរត្រងទឹក

ក.សម្ភារ:

- ល្វែតូច
- ល្វែធំ
- ថ្មល់រទេះភ្លើង
- កន្ត្រៃ

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ៩

ការច្នៃប្រឌិត   រ៉ិ.ពេជ្រចិន្តា

- ញញួរ
- ម៉ែត្រ
- បំពង់ទុយយទឹក
- ដែកចុះ
- ដែកដាប់
- ដែកដន្រែកប់
- ស្រទែន
- ដែកសង្កសី
- ដែកសរសៃ
- លួស

ខ. របៀបធ្វើ

កាត់ស័ង្កសីទទឹង ៣,៤,៥តឹក បណ្តោយ ៤,៥,៦,អា ស្រ័យលើតម្រូវការរបស់អតិថជន បន្ទាប់មកយកស្រទាស់ស័ង្កសីមកវៃ ពត់វាអោយចេញជាទម្រង់ទ្រវែង បន្ទាប់មកយកស្រទាស់ដាក់ត្រង់ផ្នែកខាងលើ និងខាងក្រោមរបស់ស្រទាប់ស័ង្កសីជាការស្រាច់។

២.៣ របៀបដេរប្រដាប់ចាប់ឆ្នាំង

- កម្ទេចកំណាតឬក្រណាត់សំឡីមួយបន្ទះរាងបួនជ្រុងស្មើដែលមានប្រវែង១១cm សម្រាប់ធ្វើស្នូល
- កំណាត់សាច់បញ្ឆិតដែលមានទទឹងប្រវែង ៣.៥cmនិងបណ្តោយប្រវែង៥៦cm សម្រាប់ធ្វើទ្រនាប់ដៃ
- អំបោះដេរម្ជុលដេរ
- កន្ត្រៃ

ខ. របៀបដេរ

- ដាក់កំណាត់ទាំងបីផ្ទាំងត្រួតលើគ្នាដោយដាក់កំណាត់ស្នូលនៅកណ្តាល
- ដេរដានរង្វើលពីចំណុច "ក" ទៅចំណុច "ខ"

វាយអត្ថបទដោយ វៃ ដាលីន   ទំព័រ ១០

ការច្នៃប្រឌិត វី.ពេជ្រចិន្ដា

- បន្ទាប់មកដេរជាបន្ទាត់ស្របអោយទាល់តែចេញផ្ទាំងកំណាត់ដោយត្រូវដេរអោយឃ្លាតពីគ្នាប្រហែល២cm

-ដេរជានរង្វើលម្តងទៀតពីចំណុច "គ" ទៅចំណុច"ឃ" អោយដូចចំណុច"ក"ទៅចំណុច"ខ"ដែរ។ ក្នុងករណីនៅផ្ទះមានម៉ាស៊ីនដេរយើងអាចដេរនឹងម៉ាស៊ីនដេរក៏បានដែរ

-ក្រោយពីដេរត្រូវចៀរជ្រុងទាំងមូលដើម្បីងាយស្រួលដេរចំសាច់កំណាត់បញ្ចិតព័ទ្ធជុំវិញជាយ។

-យកសាច់កំណាត់បញ្ចិតមកបត់ជាពីរជាន់ខាងត្រូវរួចដេរព័ទ្ធជុំវិញតូចៗនាប់ ដៃឬប្រដាប់ចាប់ឆ្នាំងដោយទុកអោយនៅសល់កន្ទុយកំណាត់៨cmសម្រាប់ធ្វើតម្លក់

-ត្រូវដេរមុខសាច់បញ្ចិតអោយជិតល្អជាការស្រាច់

មន្ថែមៈ ចំពោះស្នូលរបស់ប្រដាប់ចាប់ឆ្នាំងយើងអាចយកកម្ទេចកំណាត់តូចៗទៅតម្រៀបគ្នាធ្វើស្នូលអោយក្រាស់ក៏បានដែរ

២.៤ របៀបធ្វើម៉ាសីនបូមធូលី

ក. សម្ភារៈ

- ដីលេម្ង

-លួស

-គំរប់ទឹកសុទ

-ដបទឹកក្រូច

-កាវ502

-កំណាត់

-បន្ទាស់ដែក

-កន្ត្រៃ

-ខ្សែរភ្លើង

-កុងតាក់

-អាគុយ

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ១១

ការច្នៃប្រឌិត វិ.ពេជ្រចិន្តា

-ទុយយោ

ខ. របៀបធ្វើ

មុនដំបូងយើងត្រូវយកដបទឹកក្រូចទំហំប្រហែល១.៥លីត្រ មកកាត់ជាពីយកផ្នែកខាងក្រោមមកចុះវាជារន្ធតូចៗនៅខាងក្រោមដបនឹងនៅគៀនៗហើយបន្ទាប់មកយើងយកឌីលីម្ធមកតរខ្សែភ្លើងវែងល្មមអាចតជាប់អាគុយបាន ហើយយើងយកបន្ទះដែកមកកាត់ជារង្វង់ហើយកាត់វាអោយដូចជាស្លាបកង្ហារ(បន្ទះដែកកាត់រង្វង់ល្មមអាចដាក់ចូលមាត់ដបបាន) យកបន្ទះដែកដែលយើងកាត់មកភ្ជាប់ជាមួយក្បាល់ឌីលេម្ធហើងយើងសាក់តវាជាមួយអាគុយថាតើវាវិលបានល្អរឺអត់ បន្ទាប់មកយកឌីលេម្ធដែលយើងតរួចនោះមកដាក់ក្នុងដប(ដាក់អោយវាជាប់ល្អទើបវាមិនរបូត) យកលួសមកព័ទ្ធជារង្វង់ហើយយកដំណាត់មកស្រោបពីលើវាបិទអោយជិតល្អ ហើយយកវាមកយកវាដាក់ចូលក្នុងមាត់ដប(តែកុំដាក់ជ្រៅពេក)ចំណែកផ្នែកខាងលើវិញយកយកទុយយោមកតជាប់មាត់ដប(យល់ល្អយកស្កុតមុខពីរមកមកបិទជុំវិញមាត់ទុយយោហើយដាក់វាចូលទុយយោដាក់ប្រហែលប្រវែង៣តឹកយកផ្នែកខាងលើដាក់បញ្ចូលជាមួយផ្នែកខាងក្រោម (បិទស្កុតមុខពីជុំវិញមាត់ដប់ផ្នែកខាងលើ) ហើយដាក់ខ្សែភ្លើងជាមួយនឹងអាគុយជាការស្រាច់។

៣.ការច្នៃប្រឌិតល្បីៗទូទាំងពិភពលោក[4]

ប្រទេសដែលជាប់ចំណាត់ថ្នាក់ទូទាំងពិភពលោកមាន៖

ឈ្មោះប្រទេស	ចំណាត់ថ្នាក់
- ស្វីតសាឡែន	ចំណាត់ថ្នាក់លេខ១
- អង់គ្លេស	ចំណាត់ថ្នាក់លេខ២
- ស៊ុយអែត(Sweden)	ចំណាត់ថ្នាក់លេខ៣
- ហូឡង់ (Netherlands)	ចំណាត់ថ្នាក់លេខ៤
- សហរដ្ឋអាមេរិច(United States of America)	ចំណាត់ថ្នាក់លេខ៥

[4] www.wipo.int/pressroom/en/articles/2016/article_0008.html

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ១២

ការច្នៃប្រឌិត	វិ.ពេជ្រចិន្តា
- ហ្វាំងឡង់ (Finland)	ចំណាត់ថ្នាក់លេខ៦
- សឹង្ហបុរីSingapore	ចំណាត់ថ្នាក់លេខ៧
- អៀរឡង់ (Ireland)	ចំណាត់ថ្នាក់លេខ៨
- លុចសំបួរ(Luxembourg)	ចំណាត់ថ្នាក់លេខ៩
- ដែនម៉ាក់(Denmark)	ចំណាក់ថ្នាក់លេខ១០
- ហុង កុង(ចិន) Hong Kong(China)	ចំណាត់ថ្នាក់លេខ១១
- អាឡឺម៉ង់(Germany)	ចំណាត់ថ្នាក់លេខ១២
- អ៊ីស្លង់(Ice land)	ចំណាត់ថ្នាក់លេខ១៣
- សាធារណរដ្ឋកូរ៉េ(Republic of Korea)	ចំណាត់ថ្នាក់លេខ១៤
- នូវែលហ្សេឡង់(New Zealand)	ចំណាត់ថ្នាក់លេខ១៥
- កាណាដា(Canada)	ចំណាត់ថ្នាក់លេខ១៦
- អូស្ត្រាលី(Australia)	ចំណាត់ថ្នាក់លេខ១៧
- អូទ្រីស(Austria)	ចំណាត់ថ្នាក់លេខ១៨
- ជប៉ុន(Japan)	ចំណាត់ថ្នាក់លេខ១៩
- ន័រវេស(Norway)	ចំណាត់ថ្នាក់លេខ២០
- បារាំង(France)	ចំណាត់ថ្នាក់លេខ២១
- អីស្រាអែល(Israel)	ចំណាត់ថ្នាក់លេខ២២
- អេស្តូនី(Estonai)	ចំណាត់ថ្នាក់លេខ២៣
- ចិន(China)	ចំណាត់ថ្នាក់លេខ២៤
- បែលហ្សិក(Belgium)	ចំណាត់ថ្នាក់លេខ២៥

៤.របៀបចិញ្ចឹមកង្កែប

ការចិញ្ចឹមកង្កែបពីមុនគ្មានអ្នកចិញ្ចឹមទេ គឺប្រជាពលរដ្ឋរកបរិភោគតាម បឹងត្រពាំង វាលស្រែដែលរស់នៅបែបធម្មជាតិប៉ុន្តែក្រោយក៏មានការកែប្រែនិងការឆ្នៃប្រឌិតដើម្បី

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ១៣

ចិញ្ចឹមកង្កែប។ហេតុធ្វើអោយប្រជាកសិករចិញ្ចឹមកង្កែបដោយសារតែកំណើនមនុស្សចេះតែកើនឡើងហើយអ្នកប្រកបរបរចាប់កង្កែបគឺចាប់យកទាំងតូចទាំងធំធ្វើអោយកង្កែបបាត់បង់ស្ទើរតែផុតពូជ។ មួយវិញទៀតវិស័យកសិកម្មបានរៀបចំឲ្យមានឯកសារបង្រៀនពីបច្ចេកទេសក្នុងការចិញ្ចឹម និងផ្សព្វផ្សាយកង្កែបនេះដល់ប្រជាពលរដ្ឋឲ្យបានយល់ដើម្បីលើកស្ទួយក្នុងការចិញ្ចឹមកង្កែបនេះធ្វើឲ្យទទួលបានជោគជ័យនិងឧបត្ថម្ភទៅដល់ទីផ្សារប្រចាំថ្ងៃឲ្យបានគ្រប់គ្រាន់។

*ការជ្រើសរើសទីកន្លែងចិញ្ចឹមកង្កែប

-ជាកន្លែងស្រឡះមានដើមឈើបន្តិចបន្តួច

-ជិតប្រភពទឹក (រដូវប្រាំង)

-ជាមិនលិចទឹកនៅរដូវវស្សា

-ដីនៅឆ្ងាយពីផ្លូវដើរ

-គ្មានដើមឈើដែលមានជាតិពុល (ស្លែង គីនីន ប្រេងខ្យល់...)

-ជាកន្លែងស្ងៀមស្ងាត់ហើយមានសុវត្ថិភាព

*ការជីករណ្តៅចិញ្ចឹមកង្កែប

-ជីករណ្តៅឲ្យគ្រប់ចំនួនម៉ែត្រ កាលណាជីករាក់ពេក ឬមិនគ្រប់ប្រវែងកំណាត់កៅស៊ូនៅសល់ច្រើនបណ្តាលឲ្យទឹកក្តៅពេក មិនសមស្របការរស់នៅរបស់កង្កែប។

-យើងត្រូវជីករណ្តៅគឺបណ្តោយមាត់លើ ២.៥០ ម៉ែត្រនិងបាតក្រោម១.៥០ម៉ែត្រ ទទឹងមាត់លើ១.៥០ម៉ែត្រ និងបាតក្រោម១.៥០ម៉ែត្រនិងជម្រៅ គឺ០.៥០ម៉ែត្រ។

-ដាក់អាចម៍ដីចម្ងាយពីមាត់រណ្តៅឲ្យបាន០.៥ម៉ែត្រ ជៀសវាងអាចម៍ដីធ្លាក់ចូលក្នុងរណ្តៅវិញ។

-ត្រូវពង្រាបដីឲ្យបានរាបស្មើ នៅជុំវិញរណ្តៅងាយស្រួលយើងដាំស្មៅដើម្បីជួយរាំង កុំឲ្យហូរចូលក្នុងរណ្តៅវិញ។

- របៀបដាក់ប្លាស្ទិចនិងដាក់ទឹក

របៀបដាក់ប្លាស្ទិច

-កៅស៊ូប្លាស្ទិចមានច្នេញឈើឌុបគឺទទឹង២ម៉ែត្រ

-កៅស៊ូបណ្តោយមាន ៥ម៉ែត្រត្រូវបត់វាជា ២ត្រួតពីលើទាញឲ្យស្មើគ្នាប្រវែងនៅត្រឹមតែ ២.៥ម៉ែត្រ

-បន្ទាប់មកយកកៅស៊ូដែលបត់រួចហើយនោះទៅដាក់លើមាត់រណ្តៅរួចសង្កត់កៅស៊ូឲ្យធ្លាក់ដល់បាតរណ្តៅ ពិនិត្យនៅលើជ្រុងតាមមាត់រណ្តៅកៅស៊ូដែលសល់នោះឲ្យស្មើគ្នា

-បន្ទាប់មកទៀតយករអាចម៍ដីលប់ពីលើកៅស៊ូដែលនៅសល់ពីលើមាត់រណ្តៅដោយមានឈើរាំងផ្ទប់ដើម្បីចៀសវាងអាចម៍ដីធ្លាក់ចូលទៅក្នុងរណ្តៅ

*ការដាក់ទឹក

-បើបានស្រះទឹកឬទឹកទន្លេមកដាក់ប្រសើរជាងដាក់ទឹកអណ្តូងពីព្រោះទឹកអណ្តូងភាគច្រើនមានជាតិកំបោរច្រើន ដែលធ្វើឲ្យកង្កែបពិបាករស់នៅ

-ក្រោយពីបានដាក់ទឹករួចហើយត្រូវយកត្រកួនស្រែទៅដាក់ក្នុងរណ្តៅប្រហែល១០ទងដើម្បីឲ្យកង្កែបវាតោងអណ្តែតខ្លួនលេងនៅក្នុងទឹក បើមានពាសពេញរណ្តៅត្រូវយកចេញ។

-ក្រោយពីបានដាក់ទឹករួចហើយត្រូវដាំជីនាងវង ម្រះព្រៅ និងស្លឹកគ្រៃ នៅជុំវិញមាត់រណ្តៅដើម្បីឲ្យកង្កែបឡើងមកជ្រកនិងរង់ចាំទុំដើម្បីឲ្យវា បានហាលស្បែក។

យកស្បៃធ្វើរបងត្រូវដាក់ពីមាត់រណ្តៅចម្ងាយ១ម៉ែត្រព័ទ្ធជុំវិញរួចកប់ដីជើងក្រោមផង។នៅខាងក្រៅស្បៃរបងនោះត្រូវធ្វើស្មៅឲ្យស្អាតដើម្បីងាយស្រួលពិនិត្យតាមដានពីសត្វពស់កណ្តុរដែលមករកស៊ីកង្កែប។

*របៀបលែងកូនកង្កែប

-យកកូនកង្កែបទៅដល់កន្លែងចិញ្ចឹមត្រូវទុកឲ្យស្ងៀមយ៉ាងហោចណាស់ឲ្យបាន៣នាទី

ដងទឹកពីក្នុងរណ្តៅមកស្រោចលើកូនកង្កែបឲ្យសើមខ្លួនថាទុករយៈពេល២ឬ៣នាទីទៀតទើបលែងវា ចូលទៅក្នុងរណ្តៅ

-បន្ទាប់មកត្រូវដាក់ចំណីឲ្យវាស៊ីបន្តិចបន្តួចសិនបានហើយ ចៀសវាងកុំឲ្យវាស៊ីឆ្អែត ពេកខ្លាចវាហាល់ងាប់។

-ជ្រើសរើសតែកូនកង្កែបណាដែលវាដាច់កន្ទុយ

-ត្រូវយកមកចិញ្ចឹមតែទំហំប្រហាក់ប្រហែលគ្នា

ការច្នៃប្រឌិត វី.ពេជ្រចិន្តា

• របៀបចិញ្ចឹមកង្កែប

*ប្រភេទចំណី

ចំណីទិញទីផ្សារ នៅតាមទីផ្សារពុំមានចំណីសម្រាប់ចិញ្ចឹមកង្កែបទេប៉ុន្តែយើងអាចទិញចំណីត្រីអណ្តែងសម្រាប់ដាក់ឲ្យកង្កែបស៊ីបានដែរ ចំណីនេះមានបីប្រភេទគឺប្រភេទទី១ ជាចំណីគ្រាប់តូចៗ សម្រាប់ផ្តល់ឲ្យកូនកង្កែបតូចៗស៊ីចាប់ពីអាយុ ២ឬ៣ថ្ងៃទៅ៤៥ថ្ងៃ ចំណីប្រភេទទី២ ជាចំណីដែលមានគ្រាប់ធំជាងចំណីប្រភេទទី១ សម្រាប់ផ្តល់ឲ្យកង្កែបដែលមានទំហំប៉ុនកដៃកូនក្មេងឲ្យចាប់ពីអាយុ ៤៥ទៅ៧៥ថ្ងៃ។ចំណីប្រភេទទី៣ជាចំណីដែលមានគ្រាប់ធំៗសម្រាប់ផ្តល់ឲ្យកង្កែបដែលមានអាយុចាប់ពី៧៥ថ្ងៃរហូតដល់លក់(អាយុ៤០ខែ)។

ចំណីធម្មជាតិ ចំណីធម្មជាតិរួមមាន កណ្តៀរ ជន្លេន កន្ធក់បាយ ត្រី កំពឹស សត្វល្អិត...។ ចំពោះជន្លេនត្រីកំពឹសយើងត្រូវហាន់ពួកវាឲ្យតូចៗមុនដាក់ឲ្យកង្កែបតូចៗស៊ី។ យើងអាចដាក់ភ្លើងនៅពេលយប់សម្រាប់ទាក់ទាញសត្វល្អិតឲ្យកង្កែបស៊ីជាចំណីបាន។ ការផ្តល់ចំណីធម្មជាតិនេះអាចពី២ទៅ៣ដងក្នុង១ថ្ងៃហើយត្រូវផ្តល់ចំណីនៅពេលល្ងាចនិងយប់ច្រើនជាងពេលថ្ងៃ។

*បញ្ជាក់ ចំពោះការចិញ្ចឹមកង្កែបមាន ២របៀបគឺ

-ចំពោះកង្កែបនៅតូច យើងអាចដាក់បានពី៥០ទៅ៦០ក្បាលក្នុង១m² ប៉ុន្តែលុះដល់ធំយើងត្រូវចាប់បំបែកនៅត្រឹមតែ៣០ទៅ៤០ក្បាលប៉ុណ្ណោះក្នុង១m²។

-ចំពោះកូនកង្កែបយើងដាក់ចិញ្ចឹមត្រឹមតែ៣០ទៅ៤០ក្បាលលុះដល់ធំយើងមិនចាំបាច់ចាប់បំបែកចេញទេ។ ប៉ុន្តែបើកង្កែបធំៗនោះវាតូចឬធំខុសគ្នាខ្លាំងពេក ក៏ត្រូវចាប់ធំៗចេញដែរដើម្បីកុំឲ្យកង្កែបធំស៊ីកង្កែបតូច។

• ការវិភាគប្រព័ន្ធបរិស្ថានលើកង្កែប

និយមន័យគឺការវិភាគរាល់សមធាតុទាំងឡាយដែលមានទំនាក់ទំនងគ្នា(កត្តាមានជីវិត និងកត្តាគ្មានជីវិត) នៅជុំវិញរណ្តៅចិញ្ចឹមកង្កែប។

• ការថែទាំកង្កែប

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ១៦

ឧបសម្ព័ន្ធ ៦

កាការពារជម្ងឺ ថ្នាំការពាររលាកស្បែកឈ្មោះ ដែលមានលក់នៅកន្លែងលក់ថ្នាំ ចំណីសត្វ ដោយយើងគ្រាន់តែយកវាទៅបាចក្នុងអាងចិញ្ចឹមរបស់យើងនោះវានិងជាសះស្បើយ។ម្យ៉ាងវិញទៀតយើងត្រូវសំអាតអាងឲ្យបានស្អាត។ចំពោះជម្ងឺពួនយើងអាចទិញថ្នាំពួនពីកន្លែងលក់ចំណីសត្វយកមកលាយជាមួយចំណីឲ្យវាស៊ីដើម្បីព្យាបាលវា។ហើយចំពោះជម្ងឺស្រែង ជម្ងឺនេះច្រើនកើតនៅលើពោះកង្កែបដែលមានសញ្ញាពណ៌ក្រហមអុចៗដូចជាស្រែងមនុស្សដែរ។

• ការប្រមូលផលកង្កែប

ក្រោយពីចិញ្ចឹមវាបានរយៈពេលប្រហែល៤ខែកង្កែបមានទម្ងន់ជាមធ្យមក្នុង១kgប្រហែលពី៧ទៅ១០ក្បាលនៅពេលនោះអាចចាប់លក់បានហើយ។ ប៉ុន្តែនៅពេលនោះបើកង្កែបមានតម្លៃថោកយើងអាចពន្យាពេលរង់ចាំកង្កែបឡើងថ្លៃវិញក៏បានដែរ។

• ការវិភាគសេដ្ឋកិច្ច

គឺដើម្បីឲ្យដឹងចំណេញឬខាតនិងដើម្បីជាការដកពិសោធន៍ពេលវេលាដែលត្រូវចិញ្ចឹមឲ្យបានសមស្រប។

៥.កត្តាទាំងឡាយនៃការបង្កើតថ្មី

កត្តាដែលនាំអោយមានការបង្កើតថ្មី

-កត្តាចៃដន្យ ជាកត្តាដែលមិនអាចទាយទុកឬដឹងមុនបាន។ឧទាហរណ៍ ដំណើរអាក់សីមៃត្រ

-កត្តាភាគនៃទេពកោសល្យ ជានិស័យពីកំណើតរបស់មនុស្ស

-ចំណេះដឹងរបកគំហើញចុងក្រោយនៃវិទ្យាសាស្ត្រជាការប្រើប្រាស់ឧបករណ៍ទំនើបដើម្បីច្នៃប្រឌិតរឺបង្កើតអ្វីមួយ

-ទំនោរផ្នែកជីវវិទ្យា ជាការខិតខំបង្កើតថ្មីដើម្បីសម្របខ្លួននឹងមជ្ឈដ្ឋាន។

ការច្នៃប្រឌិត វិ.ពេជ្រចិន្តា

III. សេចក្តីសន្និដ្ឋាន

តាមរយៈការស្រាវជ្រាវនូវប្រធានបទ ការច្នៃប្រឌិត នេះក្រុមយើងខ្ញុំមានទទួលនូវគំនិតជានៃ ការច្នៃប្រឌិតដូចជា យើងអាចសន្និដ្ឋានបានថា ការច្នៃប្រឌិត គឺជាការធ្វើរបស់របបផ្សេងដែលមិនទាន់មានរូបរាង ឬការរបស់ផ្សេងៗមិនមានប្រយោជន៍សម្រាប់ប្រើប្រាស់ទៅជារបស់មួយដែលមានប្រយោជន៍សម្រាប់យើងធ្វើការ ហើយអាចឲ្យយើងទទួលបានជោគជ័យទៀតផង។ តាមការស្រាវជ្រាវរបស់ក្រុមយើង យើងទទួលបានការច្នៃប្រឌិតជាច្រើនពីរបស់មួយឲ្យក្លាយទៅជារបស់មួយផ្សេងទៀត ជាក់ស្តែងដូចជា ការធ្វើម៉ាស៊ីនបាញ់ថ្នាំដែលសម្រាប់បាញ់ជីដាក់ដំណាំ ឲ្យទៅជាម៉ាស៊ីនបូមទឹកជាដើម។ ពិសេសការច្នៃប្រឌិតក្នុងការចិញ្ចឹមកង្កែបដែលប្រើប្រាស់ទីធ្លីអស់តិច តែផ្ទុយទៅវិញ យើងនឹងទទួលបានលិទ្ធផលក្នុងការចិញ្ចឹមវាបានច្រើន។ ក្រៅពីនេះការច្នៃប្រឌិតក៏បានផ្តល់នូវគុណសម្បត្តិជាច្រើនដល់យើងគ្រប់គ្នាដូចខាងក្រោមនេះ៖

១. គុណសម្បត្តិ

ការច្នៃប្រឌិតដែលយើងបង្កើតថ្មីមានគុណសម្បត្តិដូចតទៅ៖

ការធ្វើម៉ាស៊ីនបាញ់ថ្នាំទៅជាម៉ាស៊ីនបូមទឹកមានផលប្រយោជន៍ដល់យើងគឺយើងយកម៉ាស៊ីនដែលគេបោះបង់យកមកកែប្រែជាម៉ាស៊ីនបូមទឹកប្រើតាមតម្រូវការប្រើប្រាស់របស់យើង។ជាពិសេសក៏ធ្វើឲ្យយើងមិនខាតបង់របស់ដែលទុលចោលឥតប្រយោជន៍ផងដែរ។

-ការធ្វើទ្រុងទឹកបានផ្តល់ផលប្រយោជន៍ជាច្រើនដូចជា៖

-អាចធ្វើអាជីវកម្មបាន

-ត្រងទឹកទុកសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ

-រកប្រាក់ចំណូលបានដើម្បីផ្គត់ផ្គង់គ្រួសារ

-ងាយស្រួលក្នុងការធ្វើនិងបត់បែនបានតូចធំ វែងខ្លីដើម្បីតម្រូវការអតិថិជន។

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ១៨

ឧបសម្ព័ន្ធ ៦

* គុណសម្បត្តិពីការចិញ្ចឹមកង្កែបមានដូចជា៖

-ជួយរកប្រាក់ចំណូលប្រចាំថ្ងៃក្នុងគ្រួសារ

-អាចធ្វើជាមុខងារឬអាជីវកម្មសម្រាប់គ្រួសារ

-ជួយកាត់បន្ថយភាពក្រីក្របានមួយចំណែកដែរព្រោះពេលទំនេរពីការងារស្រែចំការ យើងអាចចិញ្ចឹមវាបានព្រោះអីវាមិនពិបាកក្នុងការចិញ្ចឹមវាទេ។

-ជួយអ្នករៀនឲ្យទទួលបាននូវចំណេះដឹង បំណិននិងបទពិសោធន៍ក្នុងផ្នែកបំណិនជីវិតងាយៗដែលទាក់ទងទៅនឹងមុខងារប្រចាំគ្រួសារ

-ចេះជ្រើសរើសពូជកង្កែបឲ្យបានសមស្រប

-ចេះរៀបចំកន្លែងចិញ្ចឹមកង្កែប

* គុណសម្បត្តិក្នុងការធ្វើប្រដាប់ចាប់ឆ្នាំងមាន៖

-ជួយកាត់បន្ថយប្រាក់កាក់ក្នុងគ្រួសារ ពីការទិញរបស់ខាងក្រៅ

-ចេះកែច្នៃរបស់នៅក្នុងផ្ទះដែលគ្មានប្រយោជន៍ឲ្យទៅជាមានប្រយោជន៍

-ងាយស្រួលក្នុងការទំនាក់ទំនងគ្នាទៅវិញទៅមក(ទូរស័ព្ទ)

-ងាយស្រួលក្នុងការធ្វើដំណើរទៅវិញទៅមក (ឡាន ម៉ូតូ)

-អគ្គិសនីអាចប្រើប្រាស់នៅក្នុងរោងចក្រ និងគេហដ្ឋាន

-ឱសថព្យាបាលជម្ងឺ អាចព្យាបាលជម្ងឺដែលបង្កដោយមេរោគផ្សេងៗ

-មានកេរ្តិ៍ឈ្មោះល្បីល្បាញ មានគេទទួលស្គាល់ស្នាដៃ

-ធ្វើឲ្យប្រទេសជាតិមានភាពរុងរឿង និងជឿនលឿន

-ក្នុងវិស័យពាណិជ្ជករ បញ្ជាទំនិញផ្សេងៗតាមប្រព័ន្ធសារអេឡិចត្រូនិច ដោយពុំចាំបាច់ទៅដល់កន្លែងផលិតទេ។

-ជួយកាត់បន្ថយភាពក្រីក្រព្រោះធ្វើឲ្យប្រជាជនមានការងារធ្វើដែរ

-ក្នុងវិស័យអាកាសចរវិញគេអាចប្រើសំបុត្រអេឡិចត្រូនិចធ្វើដំណើរពាសពេញពិភពលោក

-ចំពោះសេវាធនាគារគេប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចទំនើបដែលអតិថិជនពាណិជ្ជករ ភ្ញៀវទេសចរណ៍អាចដកលុយតាមម៉ាស៊ីនអេធីអឹម គ្រប់ទីកន្លែងដែលមានសេវារបស់វា

ការច្នៃប្រឌិត   វិ.ពេជ្រចិន្តា

វិស័យកសិកម្មគេអាចបង្កាត់ពូជរុក្ខជាតិថ្មីដែលអាចផ្តល់ទិន្នផលខ្ពស់ហើយ ប្រើរយៈពេលខ្លីក្នុងការដាំដុះផងដែរ។ បច្ចុប្បន្ននេះនៅក្នុងប្រទេសជឿនលឿនការផលិតស្រូវអាចទទួលទិន្នផលពី៥ទៅ៧តោនក្នុងមួយហិចតានិងអាចធ្វើបានពីរដងក្នុងមួយឆ្នាំ។

-វិស័យសុខាភិបាល ការវះកាត់ដោយផ្ទាល់ដៃត្រូវបានកាត់បន្ថយដោយប្រើម៉ាស៊ីនឡាស៊ែជំនួសវិញ ដូចជាការបាញ់គ្រួស ក្នុងតម្រងនោម ព្យាបាលជម្ងឺមហារីក...។

-ជួយការពារកម្តៅពីឆ្អាំងបាយ ឬឆ្អាំងសម្ល។

វាយអត្ថបទដោយ វៃ ដាលីន   ទំព័រ ២០

ការច្នៃប្រឌិត វិ.ពេជ្រចិន្តា

២. គុណវិបត្តិ

របកគំហើញដែលយើងបង្កើតថ្មីមានគុណវិបត្តិដល់សង្គមនិងខ្លួនឯងដូចជា៖

-ការធ្វើម៉ាស៊ីនបាញ់ថ្នាំទៅជាម៉ាស៊ីនបូមទឹកក៏មានផលប៉ះពាល់ដល់យើងខ្លះដែរគឺមានរបួសពេលដែលកំពុងធ្វើ។ ពិបាកក្នុងការធ្វើវាផងដែរ។

-ការធ្វើទ្រុងទឹកក៏បានធ្វើឲ្យយើងមានផលវិបាកខ្លះដែរគឺអាចមានរបួសពេលកំពុងធ្វើវាពេលទុកយូរទៅក៏ធ្វើឲ្យវាច្រេះ ធ្វើឲ្យទឹកមិនស្អាត។

*ការចិញ្ចឹមកង្កែបមានផលវិបាកដូចជា៖

-ពិបាកក្នុងការចិញ្ចឹម នៅពេលយើងមិនបានរៀនពីការចិញ្ចឹមវា

-ពិបាកក្នុងការថែទាំ

-បើយើងមិនចេះជ្រើសរើសពូជកង្កែបទេនិងធ្វើឲ្យប៉ះពាល់ដល់កង្កែបយើងមានលក្ខណៈមិនល្អ។

*គុណវិបត្តិក្នុងការដេរប្រដាប់ចាប់ឆ្នាំងមាន៖

-អាចមានរបួសពេលកំពុងដេរវា

-ពិបាកក្នុងការដេរ។

*គុណវិបត្តិនៃការច្នៃប្រឌិតរបស់ផ្សេងៗ

-ទូរស័ព្ទធ្វើឲ្យប៉ះពាល់ដល់ភ្នែកនិងខួរក្បាលហើយមានផ្ទុកវិទ្យុសកម្មអាចប៉ះពាល់ដល់ផ្នែកផ្សេងៗទៀតនៃរាងកាយហើយអាចបណ្តាលឲ្យកើតមហារីកទៀតផង

-ឡានបញ្ចេញឧស្ម័នពុលទៅក្នុងបរិយាកាសនិងបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍ផ្សេងៗ

-ឪសថមួយចំនួនអាចធ្វើឲ្យប៉ះពាល់ដល់សុខភាពនិងអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់ជីវិតនៅពេលដែលយើងប្រើប្រាស់វាហួសប្រមាណ

-អគ្គិសនីអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់ជីវិត(ឆក់) និងបង្កឲ្យមានអគ្គិភ័យ

-ការប្រើប្រាស់ដោយគ្មានក្រមសីលធម៌ធ្វើឲ្យមានគ្រោះថ្នាក់ដល់ខ្លួននិងសង្គមជាតិ

-ការទិញទំនិញផ្សេងៗតាមប្រព័ន្ធសារអេឡិចត្រូនិចជួនកាលយើងត្រូវគេបោកប្រាស់ឬរបស់ក្លែងបន្លំជារបស់មិនពិតប្រាកដ។

វាយអត្ថបទដោយ វៃ ដាលីន . ទំព័រ ២១

ការច្នៃប្រឌិត វ.ពេជ្រចិន្តា

-ការប្រើប្រាស់សេវាតាមម៉ាស៊ីនអេធីអឹម គឺវាប្រើប្រាស់បានតែនៅក្នុងទីក្រុងទេ ចំណែកឯជនបទវិញវាពិបាកក្នុងការប្រើណាស់

-ការប្រើប្រាស់ជីគីមី នៅស្រែដំណាំដើម្បីទទួលបានទិន្នផលខ្ពស់គឺវាធ្វើឲ្យប៉ះពាល់ដល់សុខភាពប្រជាជនដែលបរិភោគ។

៣. អនុសាសន៍

ជាចុងក្រោយក្នុងនាមខ្ញុំជាសិស្សនឹងខិតខំសិក្សារៀនសូត្រស្រូបយកចំណេះដឹងបន្ថែមពីការស្រាវជ្រាវនេះឲ្យមានប្រយោជន៍។ជាពិសេសខ្ញុំនឹងយកចំណេះនេះទៅអភិវឌ្ឍដល់សង្គមជាតិឲ្យមានភាពរុងរឿងល្បីល្បាញនិងមានប្រទេសជិតខាងទទួលស្គាល់នូវស្នាដៃរបស់ប្រទេសយើងហើយនិងធ្វើឲ្យគ្រួសារមានមោទនភាពចំពោះខ្លួន មានកេរ្តិ៍ឈ្មោះមានគេទទួលស្គាល់ស្នាដៃ ធ្វើឲ្យគ្រួសារមានភាពរុងរឿង។

ម្យ៉ាងវិញទៀតក្រុមរបស់យើងខ្ញុំក៏សូមសំណូមពរដល់សិស្សានុសិស្សនិងអ្នកជំនាន់ក្រោយថា

-គួរតែខិតខំសិក្សាស្រាវជ្រាវបន្ថែម មិនគួរសិក្សាតែក្នុងសៀវភៅនោះទេ

-គួរតែទុកពេលទំនេរពីការលេងទូរស័ព្ទ ដើរលេងមកសិក្សាបន្ថែមនៅផ្ទះ

-គួរតែកុំសេពគ្រឿងញៀនព្រោះវាធ្វើឲ្យយើងខាតបង់ពេលវេលានិងខូចអនាគត

-គួរតែខិតខំបង្កើតគំនិតថ្មីដើម្បីសម្របខ្លួននឹងមជ្ឈដ្ឋាន

-គួរតែខំប្រឹងបន្ថែមដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនបានមួយកម្រិតទៀត។

គំនិតច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហា ក៏ជួយយើងពេលយើងប្រឈមមុខនឹងឧបសគ្គជាច្រើន ហើយមើលទៅហាក់ដូចជាគ្មានមធ្យោបាយដោះស្រាយចូរគិតពិចារណាឲ្យបានច្បាស់លាស់និងសាកល្បងរកដំណោះស្រាយគ្រប់យ៉ាង ដែលអាចទៅរួចទោះបីជាយើងមានធនធានឬវត្ថុធាតុដើមតិចតួចយ៉ាងណាក្តីឲ្យតែយើងចេះយកមកប្រើប្រាស់ ប្រកបដោយគំនិតច្នៃប្រឌិតរមែងធ្វើឲ្យយើងមានឱកាសទទួលជោគជ័យកាន់តែច្រើនឡើង។ ការតាំងចិត្តពុះពា និងយកចិត្តទុកដាក់ពិតប្រាកដរមែងតែងតែជួយជម្រុញគំនិតច្នៃប្រឌិតក្នុងខ្លួនរបស់យើងឲ្យចេញមកបាន។ បើយើងប្រើគំនិតច្នៃប្រឌិតយើងនឹងរកឃើញអ្វីផ្សេងៗមកជំនួសចំណុចខ្សោយទាំងអស់របស់យើងបាន។

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ២២

ការច្នៃប្រឌិត វិ.ពេជ្រចិន្តា

3.ឧបសម្ព័ន

ទរត្រងទឹក

សម្ភារៈ

ពេលចុះសួរព័ត៌មានពីការធ្វើទរ

វាយអត្ថបទដោយ វៃ ដាលីន ទំព័រ ២៣

ការច្នៃប្រឌិត

វិ.ពេជ្រចិន្តា

សៀវភៅការចិញ្ចឹមកង្កែប

ការស្រាវជ្រាវតាមរយៈសៀវភៅ

តាមពិភាក្សា និងស្រាវជ្រាវក្នុងក្រុម

វាយអត្ថបទដោយ វៃ ដាលីន

ទំព័រ ២៥

ការច្នៃប្រឌិត វិ.ពេជ្រចិន្តា

ការចុះសួរពីរបៀបក្នុងការធ្វើម៉ាស៊ីនបូមទឹក

ឯកសារយោង

- សៀវភៅសិក្សាសង្គម ថ្នាក់ទី១០ មេរៀនទី១ ជំពូកទី១ ទំព័រទី១៩៦ បោះពុំឆ្នាំ២០១៥
- សៀវភៅការចិញ្ចឹមកង្កែប បោះពុំដោយ ក្រសួងអប់រំ យុវជន និង កីឡា
- សៀវភៅសក្សាសង្គមថ្នាក់ទី៨ ឆ្នាំ ២០១២
- សៀវភៅ សិល្បៈ រៀបចំគោលដៅ
- www.wipo.int/pressroom/en/articles/2016/article_0008.html
- Definition of Innovation innovation-definition of innovation in English I Oxford Dictionary (http://en.oxfordictionary.com/definition/innovation)

-Definition of Innovation innovation I Definition of Innovation by Merriam-Webster(https://www.merriam-webster.com/dictionary/Innovation

មាតិកានុក្រមពិស្តារ

បុព្វកថា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ I

អារម្ភកថា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន គណៈកម្មការវាយតម្លៃអនុភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ III

អារម្ភកថា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ V

អារម្ភកថា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា.................................VII

សេចក្តីថ្លែងអំណរគុណ.. IX

បញ្ជីតារាង XIII

បញ្ជីរូបភាព XIV

បញ្ជីឧបសម្ព័ន្ធ... XV

ជំពូកទី១. សេចក្តីផ្តើម ១

១.១. លំនាំបញ្ហានៃការសិក្សាចងក្រង.. ១

១.២. គោលបំណងនៃការរៀបចំចងក្រងករណីសិក្សា.................................... ៦

ជំពូកទី២. វិធីសាស្ត្រសិក្សាចងក្រងករណីសិក្សា...................................... ៧

២.១. វិធីសាស្ត្រនៃការសិក្សាចងក្រងករណីសិក្សា ៧

២.២. ដែនកំណត់ និងវិសាលភាពនៃការសិក្សាចងក្រង ៧

២.៣. វិធីសាស្ត្រប្រមូលទិន្នន័យ ៩

២.៤. វិធីសាស្ត្រវិភាគទិន្នន័យ...១២

២.៥. ក្រមសីលធម៌នៃការសម្ភាសន៍ និងការចងក្រងករណីសិក្សា.....................១៣

ជំពូកទី៣. ស្ថានភាពទូទៅ ស្នាដៃ និងភាពជោគជ័យរបស់វិទ្យាល័យពេជ្រចិន្តា ... ១៥

៣.១. ស្ថានភាពទូទៅ និងស្នាដៃរបស់វិទ្យាល័យពេជ្រចិន្តា.............................. ១៥

៣.១.១. សារៈតារនៃអង្គភាព.. ១៥

៣.១.២. ចក្ខុវិស័យ បេសកកម្ម និងគោលបំណង ២១
៣.១.៣. រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងវិទ្យាល័យពេជ្រចិន្តា ២២
៣.១.៤. ក្រុមគោលដៅ និងភាគីពាក់ព័ន្ធ ២៣
៣.១.៥. សេវាសាធារណៈសំខាន់ៗរបស់វិទ្យាល័យ.......................... ២៣
៣.១.៦. ការប្រកាសទទួលស្គាល់ជាអង្គភាពសេវាសាធារណៈគំរូ............. ២៤
៣.១.៧. ពានរង្វាន់ រង្វាន់ និងជ័យលាភីដែលវិទ្យាល័យទទួលបាន.......... ២៤
៣.២. បទពិសោធន៍ជោគជ័យរបស់វិទ្យាល័យពេជ្រចិន្តា ២៥
៣.២.១. ស្តង់ដាសេវាសាធារណៈ... ២៥
៣.២.១.១. គុណភាពព័ត៌មាន.. ២៥
៣.២.១.២. ភាពងាយស្រួលក្នុងការទទួលយកសេវា ២៩
៣.២.១.៣. ការយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា....... ៣១
៣.២.១.៤. ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ... ៣៧
៣.២.១.៥. យន្តការព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា... ៤០
៣.២.២. ស្តង់ដានៃការផ្តល់សេវាអប់រំវិទ្យាល័យពេជ្រចិន្តា.................... ៤២
៣.២.២.១. ការដឹកនាំ និងការគ្រប់គ្រងសាលារៀន ៤៣
៣.២.២.២. ការដឹកនាំការបង្រៀន និងរៀន................................ ៥៦
៣.២.២.៣. គណនេយ្យភាពសាលារៀន..................................... ៦៣
៣.២.២.៤. ហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពធានាដល់ការបង្រៀន និងរៀនប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន..... ៦៤
៣.២.៣. ការគ្រប់គ្រងហិរញ្ញវត្ថុ... ៦៥
៣.២.៣.១. ការរៀបចំគម្រោងថវិកា... ៦៥
៣.២.៣.២. ការអនុវត្តថវិកា.. ៦៦
៣.២.៣.៣. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ........................ ៧១

៣.២.៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព........៧២

៣.២.៤.១. ការគ្រប់គ្រងធនធានមនុស្ស.................................... ៧៤

៣.២.៤.២. ការអភិវឌ្ឍធនធានមនុស្ស...................................... ៨៧

៣.២.៥. ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព............................ ៩៦

៣.២.៥.១. ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ភាពស្អាត និងសុខភាព... ៩៦

៣.២.៥.២. ការរៀបចំរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងកែលម្អបរិស្ថានអង្គភាព... ៩៨

៣.២.៥.៣. ការអនុវត្តដើម្បីភាពស្អាត អនាម័យ និងភាពបៃតង.......១០២

៣.២.៥.៤. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិស្ថានសាលារៀន...១០៧

៣.២.៥.៥. អនាម័យចំណីអាហារដែលលក់ដូរក្នុងបរិវេណសាលារៀន... ១១១

៣.២.៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និង ដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ.... ១១៤

៣.២.៦.១. ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ... ១១៤

៣.២.៦.២. ការកៀរគរធនធាន និងសហការជាមួយដៃគូអភិវឌ្ឍ.......១២០

៣.២.៦.៣. ការងារអភិវឌ្ឍន៍យុវជន.................................... ១២២

៣.២.៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍...១២៦

៣.២.៧.១. យន្តការទទួលព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ា...............១២៦

៣.២.៧.២. ការអនុវត្តវិធានការណ៍ឆ្លើយតបទៅនឹងបញ្ហាប្រឈម ស្របតាមស្ថានភាពជាក់ស្ដែង ១២៧

៣.២.៨. ការផ្ដួចផ្ដើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអង្គភាពមាន ដំណើរការកាន់តែប្រសើរ..១២៩

៣.២.៨.១. ការបញ្ជ្រាបអំពីប្រធានបទពាក់ព័ន្ធនឹងនវានុវត្តន៍ និង ការច្នៃប្រឌិតធ្វើឱ្យអង្គភាពដំណើរការកាន់តែប្រសើរ......១៣០

៣.២.៨.២. ការដឹកនាំអនុវត្ត ការជំរុញ និងការគាំទ្រការអនុវត្តគំនិតច្នៃប្រឌិត និងនវានុវត្តន៍ក្នុងអង្គភាព ១៣១

ជំពូកទី៤. សេចក្តីសន្និដ្ឋាន..១៣៥

គន្ថនិទ្ទេស ១៣៩

ឧបសម្ព័ន្ធ... ១៤១

គម្រោងរៀបចំករណីសិក្សាស្តីពី "**ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ច័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩**" សម្រាប់ "**វិទ្យាល័យពេជ្រចិន្តា ខេត្តបាត់ដំបង**" ស្ថិតក្រោមការដឹកនាំនិងគ្រប់គ្រងផ្ទាល់របស់សាលាភូមិន្ទរដ្ឋបាល ដែលមានសមាសភាពក្រុមការងារ ដូចខាងក្រោម÷

ក. សមាសភាពថ្នាក់ដឹកនាំគ្រប់គ្រងគម្រោង÷

១. ឯកឧត្តម **យក់ ប៊ុនណា**	រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល
២. ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន**	រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
៣. ឯកឧត្តម **ឆាយ ឆត្រាវុធ**	អនុរដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ
៤. ឯកឧត្តម **ឈុន សុជាតិ**	អគ្គនាយកនៃក្រសួងមុខងារសាធារណៈ
៥. ឯកឧត្តម **ប្រាក់ ម៉ូវ**	អគ្គនាយករងនៃក្រសួងមុខងារសាធារណៈ
៦. លោក **សៀត វិចិត្រ**	ប្រធាននាយកដ្ឋានសេវាសាធារណៈនៃក្រសួងមុខងារសាធារណៈ
៧. លោក **ផុន សុជាតិ**	មន្ត្រីនៃសាលាភូមិន្ទរដ្ឋបាល

ខ. សមាសភាពក្រុមការងារដឹកនាំនិងប្រតិបត្តិគម្រោង÷

១. ឯកឧត្តម **ថោង ប៊ុរ៉ាន់**	ប្រធាន
២. ឯកឧត្តមបណ្ឌិត **ជ័យ សារិន**	អនុប្រធាន
៣. លោកជំទាវ **នាង លីណា**	សមាជិក
៤. លោក **ព្រឹង មរកត**	សមាជិក
៥. លោក **តាំង ស៊ុនលាង**	សមាជិក
៦. លោក **ជ័យ រតនា**	សមាជិក
៧. លោក **លី វ៉ុង**	សមាជិក
៨. លោកស្រី **យឹម សុនី**	សមាជិក

៩. លោក **ជា ម៉េង** សមាជិក

១០. លោក **ហ៊ើល ប៊ុនថាន** សមាជិក

១១. លោក **យ៉ើម មករា** សមាជិក

១២. លោក **ទេព ទុទ្ធី** សមាជិក

១៣. លោក **ហួត វ៉េងហួ** សមាជិក

១៤. លោក **ឆយ ផានិត** សមាជិក

១៥. លោក **ប៊ុន ហៃ** សមាជិក

១៦. លោក **ប៉ុល អម្រិតកិត្យា** សមាជិក

១៧. លោក **រោ ចិត្រា** សមាជិក

១៨. លោក **ស៊ូ សុភា** សមាជិក

១៩. លោក **អ៊ុក មិថុនា** សមាជិក

២០. លោក **យឹម សុបញ្ញា** សមាជិក។

MINISTRY OF ECONOMY AND FINANCE

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ:
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

ISBN-13: 978-9924-554-08-0

ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ: giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

ISBN-13: 978-9924-554-08-0

9 789924 554080